ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



អៀង សារី

- មេដឹកនាំខ្មែរក្រហមបាញយកផលប្រយោជន៍ពីជីវិតមនុស្ស
- យុត្តិធម៌គឺពុំមែនជាការសងសឹកទេ

លេខ១០៦ ខែតុលា ឆ្នាំ២០០៨

ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៩ ខែកក្កដា ឆ្នាំ២០០១

## មាតិកា

◆សំបុត្រៈ មេដឹកនាំខ្មែរក្រហម ....................................១

**ផ្នែកឯកសារ**

◆អ៊ីស៊ូប គន្ធីៈ សកម្មភាពមុនពេលចាប់ខ្លួន ....................................២

◆គ្រោះថ្នាក់នៃការធ្វើបដិវត្តន៍ដោយគ្មានខត្តមគតិ....................................៦

◆រណ្តៅសាកសពប្រល័យពូជសាសន៍នៅខេត្តកំពង់ឆ្នាំង....................................៩

◆កៅលី ថុង់ហួត សមាជិកក្រុមគួរដៃនទី.................................... ១១

◆វៀតណាមនិងក្រសួងការបរទេសខ្មែរក្រហម....................................១៥

◆សេចក្តីថ្លែងការណ៍របស់បក្សកុម្មុយនិស្តកម្ពុជា....................................១៧

◆បញ្ជីឈ្មោះអ្នកទោសជនជាតិភាគតិច.................................... ២៥

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆យល់សប្តិគឺជាទោស.................................... ២៧

◆ការស្រាវជ្រាវតាមរយៈរូបថតជនរងគ្រោះ ព្រុំ គី.................................... ២៩

◆សម្លេងពីមន្ទីរស-២១.................................... ៣២

◆គុកជ្រៃអូរញ៉ោ.................................... ៣៦

**ផ្នែកច្បាប់**

◆តម្លៃនៃភ័ស្តុតាង.................................... ៤១

**វេទិកាពិភាក្សាជាសាធារណៈ**

◆សេចក្តីថ្លែងការណ៍របស់សហគមន៍អឺរ៉ុប ....................................៤៥

◆តុលាការខ្មែរក្រហមនឹងផ្សះរបួសសង្គមកម្ពុជា....................................៤៧

◆ជនកុម្មុយនិស្តខ្មែរក្រហមនិងវៀតណាម.................................... ៤៨

◆រឿងរ៉ាវនៃការនាំយកមេដឹកនាំខ្មែរក្រហម....................................៥២

◆ការពិភាក្សារវាងរាជរដ្ឋាភិបាលកម្ពុជា.................................... ៥៦

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆យុត្តិធម៌គឺពុំមែនជាការសងសឹកទេ ....................................៦០

**សិល្បៈខ្មែរក្រហម**

◆កំណាព្យៈ ភោគផលសម្បត្តិធម្មជាតិខ្មែរ ....................................ក្របក្រោយ



អ្នកទោសនៅពីមុខតុសួរចម្លើយ

## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងពត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងពត៌មាន
លេខ ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**(រូបថត អៀង សារី ក្របមុខថតដោយ ឆាំង យុ)**

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**វាគ្មិនលេខនេះ៖** ដេវីត ឆេនដល័រ, ចន ឆរឆីអាវី, មិទ្រី មូសយ៉ាកូវ, ប៉ែន យៀវនិន, ថូម៉ាស់ ហាម៉ាប៊ឹក, អ៊ូច សំអឿន, ផេង ពង្សរ៉ាស៊ី, អ៊ីសា ឧស្មាន, កែវ សំអាន, យិន នាន **អ្នកនិពន្ធនិងស្រាវជ្រាវៈ** សាន់ កល្យាណ, លី សុផល, ដួង សុភារិទ្ធ **ជំនួយការនិពន្ធនាយកៈ** អែម សុខឃឹម **និពន្ធនាយករងទី១ៈ** ផាត កុសល **និពន្ធនាយករងទី២ៈ** សឹម សុរិយ៉ា **អ្នកបកប្រែៈ** សួ ប៊ុនស៊ូ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** ទ្រី សុភក្តិ

*សំបុត្រ:*

# មេដឹកនាំខ្មែរក្រហម ទាញយកផលប្រយោជន៍ពីជីវិតមនុស្ស

មេដឹកនាំខ្មែរក្រហមកំពុងតែទាញយកផលប្រយោជន៍ពីជីវិតមនុស្សក្រោមភាពមិនចុះសម្រុងគ្នារវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ក្នុងការបង្កើតឲ្យមានតុលាការមួយដើម្បីធ្វើការវិនិច្ឆ័យទោសមេដឹកនាំខ្មែរក្រហមទាំងឡាយណាដែលកំពុងនៅរស់រានមានជីវិត ។ ការចាកចេញពីព្រៃចូលមកទីក្រុងភ្នំពេញជាលើកដំបូងក្នុងរយៈពេល២១ឆ្នាំ បានបង្ហាញថាមេដឹកនាំខ្មែរក្រហមមានជំនឿទុកចិត្តលើសមត្ថភាពខ្លួនឯង ក្នុងការទាញផលប្រយោជន៍ពីបទឧក្រិដ្ឋដែលខ្លួនបានប្រព្រឹត្ត ។ ក្នុងនោះមាន អៀង សារី ដែលមិនត្រឹមតែត្រូវបានទទួលការប្រទានការលើកលែងទោសពីព្រះមហាក្សត្រតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានទទួលនូវតំបន់ស្វយ័តប្រកបដោយសម្បត្តិស្តុកស្តម្ភពោលគឺទីក្រុងប៉ៃលិនដែលគ្រប់គ្រងដោយអ្នកដែលមានភក្តីភាព រួមទាំងកូនប្រុសរបស់ខ្លួនទៀតផង ។

មេដឹកនាំខ្មែរក្រហមគឺជាអ្នកទាញយកផលប្រយោជន៍ពីជីវិតមនុស្សពិតៗហើយដែលដឹងច្បាស់ថា ពេលណាត្រូវធ្វើឆ្លាត ពេលណាត្រូវធ្វើល្ងង់ ហើយនិងពេលណាត្រូវប្រើប្រាស់អង្គការសហប្រជាជាតិ និងពេលណាត្រូវប្រើប្រាស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីធ្វើជាខែលបិទបាំងនូវការទទួលខុសត្រូវរបស់ខ្លួនចំពោះមុខជនរងគ្រោះ ។

មេដឹកនាំខ្មែរក្រហមដែលស្ថិតនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនិស្តកម្ពុជានៃរបបកម្ពុជាប្រជាធិបតេយ្យគឺជាអ្នកទទួលខុសត្រូវចំពោះគោលនយោបាយនៃគណៈកម្មការនេះដែលបានធ្វើឲ្យប្រជាជនខ្មែររាប់លាននាក់បាត់បង់ជីវិត ។

អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាគួរតែបញ្ឈប់រាល់ការព្យាយាមរបស់មេដឹកនាំខ្មែរក្រហមក្នុងការទាញយកផលប្រយោជន៍ពីជីវិតមនុស្សនិងការឈឺចាប់របស់ប្រជាជនកម្ពុជា ដោយរួមដៃគ្នាធ្វើយ៉ាងណាដាក់ឲ្យមេដឹកនាំខ្មែរក្រហមទាំងអស់ទទួលខុសត្រូវចំពោះមុខច្បាប់ ។ **ឆាំង យុ**



# អ៊ីស៊ូប គន្ធីៈ សកម្មភាពមុនពេលចាប់ខ្លួន



អ៊ីស៊ូប គន្ធី

**(តចប់)** បន្ទាប់ពីបានទទួលការណែនាំ ពី ដួន ប្រាសិទ្ធ មក អ៊ីស៊ូប គន្ធី បានចូលគាល់សម្តេច សីហនុ ដើម្បីសុំការអនុញ្ញាត បើកការិយាល័យមួយនៅទីក្រុងប្រាក ប៉ុន្តែទ្រង់បានបដិសេធ ថាព្រះអង្គគ្មានអំណាចណាមួយដើម្បីប្រកាន់យកការសម្រេចចិត្ត នេះទេ ។ មានតែការិយាល័យនយោបាយនៃគណៈកម្មាធិការ កណ្តាលរបស់រណសិរ្សរួបរួមជាតិប៉ុណ្ណោះ ដែលអាចផ្តល់អំណាច ឲ្យប្រកាន់យកការសម្រេចចិត្តនេះ ។

ការស្នាក់អាស្រ័យប្រមាណជា២០ថ្ងៃនៅទីក្រុងប៉េកាំង រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាបានចាត់តាំង អ៊ីស៊ូប គន្ធី ធ្វើជា ភារធារីនៅស្ថានទូតប្រទេសកម្ពុជាប្រចាំទីក្រុងទីរ៉ាណា(ប្រទេស អាល់បានី) ។ ពីឆ្នាំ១៩៧១ដល់ឆ្នាំ១៩៧៣ អ៊ីស៊ូប គន្ធី ត្រូវ បានចាត់តាំងឲ្យទៅធ្វើការនៅប្រទេសអាល្លឺម៉ង់ជាប្រទេសដែល គ្មានស្ថានទូតអាមេរិកាំងនៅទីនោះ ។ ប៉ុន្តែ ពួកអាមេរិកាំង ក៏អាចទទួលបានពត៌មានផ្សេងៗស្តីពីរណសិរ្សរួបរួមជាតិកម្ពុជា ដដែល ។ នុត ឈឿម (អ្នកស៊ើបការណ៍សម្រាប់ក្រុម សេ.អ៊ី.អា នៅស្និទ្ធនឹងសម្តេច សីហនុ) ជាអ្នកផ្តល់ពត៌មានទៅឲ្យតំណាង សហរដ្ឋអាមេរិក ។

នៅខែកញ្ញា ឆ្នាំ១៩៧៤ សកម្មភាពរបស់ពួកសេ.អ៊ី.អា កាន់តែផុសផុលខ្លាំងជាងមុនៗ ហ្សូនសុន ដែលជាភ្នាក់ងារ សេ.អ៊ី.អា របស់ទីក្រុងស្តុកខូម បានសំណូមពរ អ៊ីស៊ូប គន្ធី កុំឲ្យធ្វើសកម្មភាពខ្លាំងពេកនៅពេលបោះឆ្នោតនៅអង្គការសហ ប្រជាជាតិ ។ អ៊ីស៊ូប គន្ធី បានបដិសេធថា គាត់មិនអាចនៅ ស្ងៀមបានទេ គាត់ត្រូវតែបំពេញមុខងារជាធម្មតាតាមការបង្គាប់ បញ្ជាពីរដ្ឋមន្ត្រីរបស់គាត់ ហើយធ្វើអន្តរាគមន៍ទៅអ្នកទទួលខុស ត្រូវនៅក្រសួងការបរទេសនៃប្រទេសស៊ុយអែដ បន្ទាប់មក រាយការណ៍ទៅក្រសួងការបរទេស ។

ង៉ួន ឆាយគ្រី អគ្គលេខាធិការក្រសួងការបទេស បាន ចាត់តាំង យ៉ែម សារ៉ុង ឯកអគ្គរដ្ឋទូតរបស់ លន់ ណុល ប្រចាំនៅ ប្រទេសស្វ៊ីស ឲ្យមកជួប អ៊ីស៊ូប គន្ធី នៅទីក្រុងហាំបួរក៍(អាល្លឺម៉ង់) នៅសណ្ឋាគារជីឡាហ្គារ ដើម្បីសុំឲ្យមានការបំភ្លឺស្តីពីលទ្ធភាពមួយ នៃការចរចាគ្នា ។ អ៊ីស៊ូប គន្ធី បកស្រាយថា គ្មានការសម្រប សម្រួលណាមួយជាមួយពួកក្បត់ដែលត្រូវបានគ្រោងគិតដោយ រណសិរ្សរួបរួមជាតិកម្ពុជាទេ ។ ដំណោះស្រាយមានតែមួយគត់ គឺត្រូវប្រគល់អំណាចទាំងអស់មកឲ្យរាជរដ្ឋាភិបាលនិងរណសិរ្ស រួបរួមជាតិកម្ពុជាវិញ ។ ស៊ុម វឌ្ឍនយ៉ា (ទន្តពេទ្យនិងជាមិត្តរបស់ លន់ ណុល) បានជួបសន្ទនាតាមទូរស័ព្ទជាមួយ អ៊ីស៊ូប គន្ធី ជា ច្រើនអំពីរឿងចរចាគ្នានេះដែរ ។ អ៊ីស៊ូប គន្ធី ក៏បានប្រាប់ឲ្យដឹងពី ជំហររបស់រណសិរ្សរួមជាតិកម្ពុជាថាចង់បានជ័យជម្នះ១០០ ភាគរយ ហើយ លន់ ណុល និងជនក្បត់ទាំង៧រូប ត្រូវចាកចេញ ឲ្យរហ័សពីទីក្រុងភ្នំពេញ ពីព្រោះកងទ័ពរំដោះជាតិនឹងវាយ ដណ្តើមយកក្រុងភ្នំពេញនាពេលខាងមុខនេះ ។

នៅដើមខែ១០ ឆ្នាំ១៩៧០ អ៊ីស៊ូប គន្ធី បានត្រឡប់មក

ពីប៉េកាំងវិញ ដោយឆៀងចូលទៅទីក្រុងប្រាគ រាយការណ៍ប្រាប់ ហ្សាកូវ ថាគាត់ត្រូវបានចាត់តាំងឲ្យធ្វើការនៅប្រទេសអាល់បានី ។ ហ្សាកូវ ក៏បានបញ្ជូនភ្នាក់ងារម្នាក់ឈ្មោះ ហ្សាកូឡូស សម្រាប់ទាក់ទងមួយខែម្តងនៅឯសណ្ឋាគារទីតូក្រាដប្រទេសយូហ្គោស្លាវី ។ អ៊ីស៊ូប គន្ធី តែងបានទទួលប្រាក់៥០០ដុល្លាររាល់ខែពី ហ្សាកូឡូស ជាមួយនឹងពត៌មានដែលខ្លួនផ្តល់ឲ្យ ។

នៅឯទីក្រុងស្តុកខុម អ៊ីស៊ូប គន្ធី បានជួបទាក់ទង ឌីមីទ្រី ជាលេខាធិការទី១របស់សូវៀត ប្រចាំប្រទេស (ស៊ុយអែដ) ដោយជម្រាបឯកអគ្គរដ្ឋទូតអំពីការងារចំពោះមុខរដ្ឋាភិបាលសូវៀត ដើម្បីភ្ជាប់ការងារបន្តទៅទៀត ។ ឌីមីទ្រី មានតួនាទីជាអ្នកទទួលពត៌មានពី អ៊ីស៊ូប គន្ធី ក្នុងមួយខែម្តង ។

ខែ៨ ឆ្នាំ១៩៧៤ ឌីមីទ្រី បានអញ្ជើញ អ៊ីស៊ូប គន្ធី ពិសាអាហារថ្ងៃត្រង់មួយពេល ដោយលើកយកបញ្ហាសម្រុះសម្រួលរវាងរណសិរ្សជាមួយពួកក្បត់នៅភ្នំពេញមកពិភាក្សា ។ អ៊ីស៊ូប គន្ធី ផ្តល់យោបល់ថា “បញ្ហានេះជដែកមិនកើតទេ ព្រោះទាំងរណសិរ្សខាងក្នុងប្រទេសនិងនៅប៉េកាំងមានជំហរច្បាស់ណាស់ គឺថាឯកភាពគ្នាមិនសម្រុះសម្រួលជាមួយពួកក្បត់នៅភ្នំពេញជាដាច់ខាត” ។ នៅខែសីហា ឌីមីទ្រី បានមកថ្លែងអំណរគុណដល់ អ៊ីស៊ូប គន្ធី ដែលបានជួយសរសេរកែតម្រូវ “នូវការចោទប្រកាន់របស់ពួកក្រុម អេហ្.អិន.អិល ស៊ុយអែដ អំពីជំហរសហភាពសូវៀតចំពោះកម្ពុជា” នៅលើទំព័រកាសែតអាហ្វតុងប្លាដែត ។ អ៊ីស៊ូប គន្ធី ដឹងថាការកែតម្រូវនេះជាកំហុសមួយយ៉ាងធ្ងន់ ដែលបានការពារនិងបម្រើផលប្រយោជន៍ឲ្យសហភាពសូវៀតដើម្បីបន្តស្ថានទូតនៅទីក្រុងភ្នំពេញ ។ ក្រោយមក ដោយមានការជ្រោមជ្រែងពីលោក ថេក ម៉ាន ដែលជាសមាជិកសភាសមាជិកគណបក្សកុម្មុយនិស្ត និងជាលេខាធិការគណៈកម្មការស៊ុយអែដ ដើម្បីប្រទេសវៀតណាម លាវ និងកម្ពុជានោះ អ៊ីស៊ូប គន្ធី បានទទួលមូលប្បទានប័ត្រពីរសន្លឹកដែលមានទឹកប្រាក់ចំនួន ២៥០០គួរ៉ោន ពីគណៈកម្មការស៊ុយអែដ ជារង្វាន់លើកទឹកចិត្តដែលបានខំការពារសហភាពសូវៀត ។

នៅខែកុម្ភៈ ឆ្នាំ១៩៧៥ សាស្ត្រាចារ្យ ស៊ី (ជនជាតិចិន) ជានាយកមជ្ឈមណ្ឌលស្រាវជ្រាវផ្នែកនយោបាយបរទេស ដែលឧបត្ថម្ភដោយក្រសួងការបរទេស(ស៊ុយអែដ) បានអញ្ជើញ អ៊ីស៊ូប គន្ធី ទៅទទួលទានបាយល្ងាច ។ នៅក្នុងឱកាសនោះ សាស្ត្រាចារ្យ ស៊ី បានប្រាប់ឲ្យដឹងថា ពួកអាមេរិកាំងកំពុងតែព្រួយបារម្ភអំពីការធ្លាក់ចុះនៃស្ថានការណ៍របស់ លន់ ណុល ។ អ៊ីស៊ូប គន្ធី បានប្រាប់នូវចម្លើយដដែលថា លន់ ណុល និងពួកក្បត់ផ្សេងទៀត ត្រូវតែចាកចេញពីកម្ពុជា ហើយទុកឲ្យរាជរដ្ឋាភិបាលរណសិរ្សរួបរួមជាតិដឹកនាំប្រទេសម្តង ។ នៅក្នុងស្ថានការណ៍យោធាដ៏អាក្រក់ខ្លាំងសម្រាប់ពួកក្បត់បែបនេះ សាស្ត្រាចារ្យ ស៊ី បានសុំឲ្យមានការស្វែងរកការសម្របសម្រួលមួយ ។ អ៊ីស៊ូប គន្ធី បានឆ្លើយតបថា គាត់ពុំមានអំណាចណាមួយដើម្បីសម្រេចឬសម្របសម្រួលក្នុងការចរចាគ្នានេះឡើយ ។

នៅពេលត្រឡប់មកពីក្រុងស្តុកខូមនៃប្រទេសស៊ុយអែដវិញ អ៊ីស៊ូប គន្ធី ត្រូវប្រឈមមុខនឹងយុទ្ធនាការមួលបង្កាច់ដែលដឹកនាំធ្វើដោយសត្រូវរបស់ខ្លួន ។ បន្ទាប់មក អ៊ីស៊ូប គន្ធី បានទៅក្រសួងការបរទេសដើម្បីប្រគល់ជូនសារលិខិតរបស់ ខៀវ សំផន និង ហ៊ូ នឹម ស្តីពីស្ថានការណ៍នៅប្រទេសកម្ពុជា រឿងនាវាម៉ាយ៉ាហ្គេ និងការវិវត្តនៃស្ថានការណ៍នៅក្នុង“ស្ថានទូតប្រទេសបារាំង” ។

នៅពេលដែលដឹងថា អ៊ីស៊ូប គន្ធី ត្រឡប់មកក្រុងភ្នំពេញវិញ ហ្សនសុន បានសុំឲ្យ អ៊ីស៊ូប គន្ធី ផ្តល់នូវពត៌មានផ្សេងៗស្តីពីប្រទេសកម្ពុជានៅពេលវិលត្រឡប់មកទីក្រុងស្តុកខូមវិញ ។

ថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៥ អ៊ីស៊ូប គន្ធី បានរៀបចំពិធីបដិសណ្ឋារកិច្ចមួយក្នុងឱកាសបុណ្យខួបរណសិរ្សរួបរួមជាតិកម្ពុជា ។ ឌីមីទ្រី និងទីប្រឹក្សាទី១ស្ថានទូតសូវៀតក៏បានចូលរួមដែរ ។ ក្នុងឱកាសនោះ ឌីមីទ្រី បានប្រគល់សារទូរលេខមួយច្បាប់ឲ្យ អ៊ីស៊ូប គន្ធី ដែលសារទូរលេខនេះជារបស់ កូស៊ីគីន ផ្ញើជូនប្រមុខរដ្ឋកម្ពុជានិងប្រធានរណសិរ្ស ។ នៅខែតុលា អ៊ីស៊ូប គន្ធី ត្រូវបានឯកអគ្គរដ្ឋទូតសូវៀតអញ្ជើញពិសាស្រានិងពិភាក្សាបញ្ហាមួយចំនួន ។ ឯកអគ្គរដ្ឋទូតបាននិយាយនាពេលនោះថា “រដ្ឋាភិបាលរបស់ខ្លួនចង់បានពត៌មានអំពីស្ថានការណ៍នៅកម្ពុជាខ្លះតើវិវត្តទៅយ៉ាងណា តើសហភាពសូវៀតមានលទ្ធភាពបែបណាខ្លះ...សហភាពសូវៀតយកចិត្តទុកដាក់បំផុតលើការវិវត្តនៃ

ស្ថានការណ៍នៅកម្ពុជានិងចង់ដឹងនយោបាយរបស់អ្នកដឹកនាំថ្មីចំពោះសូវៀត ។» អ៊ីស៊ូប គន្ធី រៀបរាប់ថា «ស្ថានការណ៍នៅកម្ពុជាតាមវិទ្យុកម្ពុជា និងទីភ្នាក់ងារផ្សេងៗផ្សព្វផ្សាយ គឺវិវត្តល្អ ប្រជាជនធ្វើការងារ ប្រទេសទាំងមូលត្រូវបានប្រែទៅជាការដ្ឋានសំណង់ ។ ប្រទេសកម្ពុជាត្រូវការផលិតស្រូវដើម្បីចិញ្ចឹមប្រជាជនដែលត្រូវជម្លៀសពីទីក្រុង» ។ ចំណែកមាគ៌ានយោបាយវិញ តាមសេចក្តីសម្ភាសន៍របស់ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកខាងកិច្ចការបរទេសជាមួយសារពត៌មានញូវស៊ីតថា «នយោបាយកម្ពុជាថ្មី គឺឯករាជ្យ អព្យាក្រឹត មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងប្រទេសដទៃ គោរពគ្នាទៅវិញទៅមក» ។ អ៊ីស៊ូប គន្ធី បន្តទៀតថា «សហភាពសូវៀតមានកំហុសដោយទុកស្ថានទូតនៅភ្នំពេញ» ។ ឯកអគ្គរដ្ឋទូតសូវៀតរូបនោះបានតបវិញថា «រដ្ឋាភិបាលរបស់ខ្លួនព្រមទទួលកំហុស ហើយចង់កែកំហុសនេះ...រដ្ឋាភិបាលសូវៀតមានបំណងនឹងគោរពមាគ៌ានយោបាយកម្ពុជាថ្មី និងជួយប្រជាជនកម្ពុជាឲ្យកសាងប្រទេសវិញដូចប្រទេសវៀតណាម» ។ ទោះបីជា អ៊ីស៊ូប គន្ធី បានរៀបរាប់អំពីស្ថានការណ៍នៅកម្ពុជាយ៉ាងនេះក៏ដោយ ឯកអគ្គរដ្ឋទូតនៅតែទទូចថា «រដ្ឋាភិបាលរបស់ខ្លួនព្រួយបារម្ភចំពោះស្ថានការណ៍នៅកម្ពុជាដែលអាចនឹងក្លាយទៅជាអាល់បានីថ្មីមួយនៅអាស៊ី-អគ្នេយ៍ ហើយខ្លាចប្រទេសកម្ពុជាក្លាយទៅជាមូលដ្ឋានយោធារបស់ចិន» ។ អ៊ីស៊ូប គន្ធី តបវិញថា «កម្ពុជាថ្មីប្រកាន់មាគ៌ានយោបាយមិនដូចប្រទេសអាល់បានីទេ... កម្ពុជាថ្មីមិនអនុញ្ញាតឲ្យមហាអំណាចបរទេសណាមួយមកតាំងមូលដ្ឋានយោធារបស់ខ្លួនឡើយ ។ ហេតុនេះនៅកម្ពុជាគ្មានមូលដ្ឋានយោធាចិនទេ » ។

## ២) ផែនការរបស់សូវៀតក្នុងការផ្តួលរំលំកម្ពុជាប្រជាធិបតេយ្យ

មានការពិភាក្សាមួយរវាង អ៊ីស៊ូប គន្ធី និងឯកអគ្គរដ្ឋទូតសូវៀត ។ អ៊ីស៊ូប គន្ធី និយាយថា សូវៀតមានផែនការដណ្តើមយកប្រទេសកម្ពុជានៅខែធ្នូ ឆ្នាំ១៩៧៦ ព្រោះកម្ពុជាឋិតក្រោមការគ្រប់គ្រងរបស់ចិន ម្យ៉ាងទៀត សូវៀតចង់ជួយវៀតណាមដើម្បីសម្រេចនូវគោលបំណងកសាង «ឥណ្ឌូចិន» ។ ផែនការគឺធ្វើនយោបាយសម្រុះសម្រួលមុនពេលរំដោះកម្ពុជា ដោយប្រមូលខ្មែរមួយក្រុមទុកបម្រើផែនការរបស់ខ្លួន បន្ទាប់មករំដោះប្រទេសកម្ពុជា ។ សូវៀតនឹងមានផែនការថ្មីទៀតចូលមកឈ្លានពានប្រទេសកម្ពុជាតាមផ្លូវយោធា ។ សូវៀតក្តាប់បានប្រទេសពីរ គឺវៀតណាមនិងឡាវ ។

ឯកអគ្គរដ្ឋទូតសូវៀតបានលើកបញ្ហាមួយចំនួនបញ្ជាក់ប្រាប់ អ៊ីស៊ូប គន្ធី ថា គាត់បានឃើញស្ថានការណ៍កម្ពុជាថ្មីមិនអនុគ្រោះដល់សភាពសូវៀតសោះ ហើយលទ្ធភាពក្នុងការដាក់ទូតរវាងប្រទេសទាំងពីរក៏គ្មានដែរ ។ ហេតុនេះសហភាពសូវៀតមានតែប្រឆាំងនឹងរបបគ្រប់គ្រងថ្មីនេះ ដោយរង់ចាំមើលស្ថានការណ៍មួយឆ្នាំសិន ប្រសិនបើមិនអំណោយផលដល់សូវៀតទេ អន្តរាគមន៍មួយអាចនឹងកើតឡើងតាមពីរដំណាក់កាល÷

ដំបូងសូវៀតនឹងជួយចលនាប្រឆាំងនៅតាមព្រំដែនកម្ពុជាវៀតណាម ។ ប្រមូលជនភៀសខ្លួននៅតាមព្រំដែនកម្ពុជានិងកម្ពុជាក្រោម បង្កអសន្តិសុខ ធ្វើដូចជាប្រទេសកម្ពុជាមានបញ្ហាផ្ទៃក្នុង ឲ្យសកលលោកចាប់អារម្មណ៍ថា កម្ពុជាមានអសន្តិសុខ ។ ប្រើប្រាស់កម្លាំង ស៊ីង ង៉ុកថាញ់ ដែលធ្វើសកម្មភាពតាមបណ្តោយព្រំដែននិងប្រមូលកម្លាំងខ្មែរក្រោមយកទៅហ្វឹកហាត់ឲ្យបានរហ័ស ។ បន្ទាប់មកសូវៀតនឹងសហការជាមួយវៀតណាមនិងឡាវទៀត ។ ប៉ុន្តែសូវៀតមិនយកកងទ័ពវៀតណាមទាំងអស់ទេ គឺយកខ្មែរកម្ពុជាក្រោមមកវាយកម្ពុជា ចៀសវាងកុំឲ្យវៀតណាមមានវិបត្តិជាមួយកម្ពុជាក្នុងទំនាក់ទំនងរវាងគ្នានិងគ្នា ។ សូវៀតត្រូវតែឲ្យកម្ពុជាឯកោដោយចាត់ការចិនកុំឲ្យផ្តល់ជំនួយមកកម្ពុជាបាន ។ តាមផ្លូវអាកាស សូវៀតបានស្នើឲ្យរដ្ឋាភិបាលឡាវបិទផ្លូវអាកាស ហើយមិនឲ្យចិនឆ្លងកាត់តាមផ្លូវសមុទ្រ ។ សូវៀតក៏បានធ្វើប្លង់មិនឲ្យកប៉ាល់ចិនដឹកចូលបាន ។ យកកម្លាំងយោធាទៅវាយភាគខាងត្បូងនៃប្រទេសកម្ពុជា ។ នៅពេលវាយបានហើយទើបចាត់តាំងរដ្ឋាភិបាលក្បត់មួយ បន្ទាប់មកដឹករថពាសដែកទៅដាក់នៅពោធិចិនតុង និងយប់ស្អែកឡើងកាន់កាប់រដ្ឋធានីឲ្យបានតែម្តង ។ បន្ទាប់មកគឺដឹកជញ្ជូនសម្ភារយោធានិងកងទ័ពឡើងទន្លេមេគង្គដោយមានការអនុញ្ញាតពីវៀតណាម ។ មួយផ្នែកទៀត«ដឹកសម្ភារសឹកនិងកងទ័ពមកដាក់នៅកំពង់សោម» ។ ប្រសិនបើមានការទប់ទល់សូវៀតនឹងទម្លាក់គ្រាប់បែក ។ ពេលបានជ័យជម្នះហើយ បង្កើតកងទ័ពស្រុកឲ្យទៅវាយទិសខាងកើត

ទៀត ។ កងទ័ពដែលចូលធ្វើអន្តរាគមន៍ជាកងទ័ពអឺរ៉ុបខាងកើត និងសូវៀត បន្ទាប់មកបញ្ចូលទ័ពគុយបាដូចនៅប្រទេសអង់ហ្គោឡាដែរ ។ បើអាចក្តាប់ផ្តែក្នុងប្រទេសទាំងមូលបាន ឲ្យពួក ស៊ីង ង៉ុកថាញ់ និងខ្មែរកម្ពុជាក្រោម ធ្វើប្រតិបត្តិការទៅទិសខាងកើត ក្រោមការឧបត្ថម្ភគាំទ្រពីវៀតណាម ។ ប៉ុន្តែបើស្ថានការណ៍ប្រទេសថៃវិវត្ត (រដ្ឋាភិបាលថៃនឹងបើកការចរចាជាមួយប្រទេសឡាវនិងប្រទេសវៀតណាម ដើម្បីធ្វើឲ្យមានប្រក្រតីភាពនូវទំនាក់ទំនងរវាងប្រទេសទាំងពីរខាងនយោបាយនិងសេដ្ឋកិច្ច) ដល់ពេលនោះ អាចនឹងមានការប្រើប្រាស់កម្លាំងខ្មែរភៀសខ្លួននៅថៃធ្វើសកម្មភាពប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យ ជនភៀសខ្លួនទាំងនេះអាចបើកប្រតិបត្តិការវាយប្រហារដោយសុំជំនួយពីសូវៀត ។

នៅក្នុងចម្លើយសារភាព អ៊ីស៊ូប គន្ធី បានសារភាពថា ខ្លួនបានប្រព្រឹត្តខុស ព្រោះនៅពេលដែលប្រទេសជាតិកំពុងមានសង្គ្រាមប្រជាជនធ្វើពលិកម្មគ្រប់បែបយ៉ាងរស់ទាំងលំបាកលំបិនក្រោមការទម្លាក់គ្រាប់បែកយ៉ាងព្រៃផ្សៃរបស់ពួកចក្រពត្តិអាមេរិកនោះ ខ្លួនបែរជានាំក្រុមគ្រួសារដើរកំសាន្តនៅក្រៅប្រទេសខ្ជះខ្ជាយលុយដែលបានមកពីញើសឈាមរបស់ប្រជាជនក្នុងខណៈដែលប្រជាជន កងកម្លាំងបដិវត្តន៍ និងកម្មាភិបាល កំពុងតែស៊ីអត់ស៊ីឃ្លានទៅវិញ ហើយបានលាក់កំបាំងនូវឥរិយាបថប្រឆាំងបដិវត្តន៍មិនឲ្យប្រជាជនដឹងទាំងក្នុងនិងក្រៅប្រទេស ព្រមទាំងបានផ្តល់បទសម្ភាសន៍ភូតកុហកដល់អ្នកកាសែតស៊ុយអែដ ដោយការពារខ្លួនថាខ្លួនមិនមែនជនកុម្មុយនិស្តទេ ។ ក្រៅពីនោះបានប្រព្រឹត្តល្មើសលួចផ្តល់ពត៌មានឲ្យភ្នាក់ងារសូវៀត ហ្សាកូឡូវ ស្តីពីរណសិរ្សនិងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជានិងជួបសន្ទនាស្ងាត់ៗជាមួយភ្នាក់ងារសេ.អ៊ី.អានៅផ្ទះរបស់ខ្លួនប្រាប់អំពីស្ថានការណ៍នៅកម្ពុជាថែមទៀត ។ អ៊ីស៊ូប គន្ធី បន្តទៀតថា ខ្លួនបានបដិសេធរាល់អត្ថបទចែកចាយផ្សេងៗរបស់ អៀង សារី ដោយអូសបន្លាយការណាត់ជួបគ្នារវាងឯកអគ្គរដ្ឋទូតសាធារណរដ្ឋប្រជាមានិតប្រជា-ធិបតេយ្យវៀតណាមជាមួយ អៀង សារី ។ មិនតែប៉ុណ្ណោះបានចោទអ្នកនៅជុំវិញសម្តេច សីហនុ ថាជាអ្នកប្រឆាំងកុម្មុយនិស្តក្នុងនោះមានៈ វ៉ាន់ឌី, ពុង ប៉េងចេង, អ៊ុង មាង និង ទឹម ណាំង ។ អ៊ីស៊ូប គន្ធី សារភាពថា បានធ្វើឲ្យសម្តេច សីហនុ ខូចព្រះទ័យនិងនឿយណាយតាមរយៈលិខិតភូតកុហកថា ព្រះអង្គលែងមានអំណាចទៀតហើយ អំណាចប្រមុខរដ្ឋដែលរដ្ឋធម្មនុញ្ញបានទទួលស្គាល់ក៏ត្រូវរបូតផុតពីព្រះអង្គដែរ ហើយអំណាចនយោបាយត្រូវការិយាល័យនយោបាយនិង អៀង សារី ជាអ្នកកាន់កាប់ដើម្បីដឹកនាំរណសិរ្សរួបរួមជាតិ ។ អ៊ីស៊ូប គន្ធី បានរកមធ្យោបាយឲ្យសម្តេច សីហនុ កម្ចាត់ អៀង សារី ដោយបង្កើតបរិយាកាសមិនទុកចិត្ត រវាងសម្តេច សីហនុ និង ជួន មុម្ម រីតតែមានសភាពធ្ងន់ធ្ងរឡើងៗ ហើយបានទូលថ្វាយព្រះអង្គថា ជួន មុម្ម បានបដិសេធមិនព្រមផ្តល់ឥណទានឲ្យគណៈបេសកកម្មស្និទ្ធសម្តេចសីហនុ ។ មិនតែប៉ុណ្ណោះ អ៊ីស៊ូប គន្ធី សារភាពថាបានបង្កឲ្យមានភាពមិនទុកចិត្តគ្នារវាងសម្តេចសីហនុ ចំពោះ សារិន ឆាក ដោយទូលថ្វាយសម្តេច សីហនុ ថា សារិន ឆាក បានសហការយ៉ាងជិតស្និទ្ធជាមួយ អៀង សារី ។ ក្រោយមក អ៊ីស៊ូប គន្ធី ត្រូវអង្គការហៅចូលប្រទេសវិញ ហើយចាប់ខ្លួននៅថ្ងៃទី២៩-៩-៧៦ ។ កម្ទេចនៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៦ ។




**លី សុផល**



# គ្រោះថ្នាក់នៃការធ្វើបដិវត្តន៍ដោយគ្មានឧត្តមគតិ ឬគ្មានទិសដៅច្បាស់លាស់

ក្នុងចលនាតស៊ូបដិវត្តជាហូរហែកន្លងមក យុវជន-យុវនារីបដិវត្តយើងបានរួមចំណែកយ៉ាងសកម្មប្រយុទ្ធយ៉ាងអង់អាចក្លៀវក្លាបំផុត ។ តែក្នុងនេះក៏មានយុវជន-យុវនារី យើងមួយចំនួនធ្វើបដិវត្តដោយគ្មានឧត្តមគតិ គ្មានទិសដៅច្បាស់លាស់អ្វីមួយឡើយ ។ គេធ្វើបដិវត្តន៍ដោយរោយតាមគេតាមឯង បណ្តែតៗខ្លួនទៅតាមតែចលនា ។ ចំពោះអ្នកទាំងនេះពេលស្រួលគេឈ្នះគេក៏សកម្មប្រយុទ្ធ សប្បាយរីករាយនឹងបដិវត្ត តែពេលលំបាកស្មុគ្រស្មាញ ពេលជួបឧបសគ្គ គេស្មុកស្មើរវារែក អល់អែកហើយធ្លាក់ទៅក្នុងភាពអសកម្ម ។ មិនត្រឹមតែប៉ុណ្ណោះ អ្នកទាំងនេះប្រើនវិវត្តទៅទោមនស្ស ថ្នាំងថ្នាក់នឹងបក្សបដិវត្ត នឹងសមូហភាព នឹងអង្គការវិន័យចាត់តាំង ។ ដូច្នោះបើមានខ្មាំង ឬសមាសភាពមិនល្អមកទាក់ទងផ្គុំតែបន្តិច អ្នកទាំងនេះក៏ងាយវិវត្តទៅក្បត់បក្ស ក្បត់បដិវត្ត ក្បត់ប្រទេសជាតិនិងប្រជាជនឯងវិញដែរ ហើយរួមសកម្មភាពប្រឆាំងបក្ស ប្រឆាំងបដិវត្ត បំផ្លិចបំផ្លាញប្រទេសជាតិនិងប្រជាជនឯងវិញ យ៉ាងថោកទាបបំផុត ។ មនុស្សបែបនេះគ្រោះថ្នាក់ណាស់ចំពោះចលនាបដិវត្ត ក៏ដូចចំពោះប្រទេសជាតិនិងប្រជាជនយើង ។ ទិសវិវត្តរបស់អ្នកទាំងនេះគឺងងឹតសូន្យសុង គឺវិនាសសាបសូន្យយ៉ាងពិតប្រាកដ ។

ក្នុងចលនាបដិវត្តយើងជាបន្តបន្ទាប់មក មានយុវជន-យុវនារីបដិវត្តយើងខ្លះធ្លាប់បានរួមប្រឡូកក្នុងចលនាតស៊ូបដិវត្តដ៏តឹងតែងស្មុគ្រស្មាញជាបន្តបន្ទាប់ ហើយមានអ្នកខ្លះរហូតដល់ធ្លាប់ត្រូវបង្ហូរឈាមស្រស់នៅលើសមរភូមិប្រយុទ្ធ ឬធ្លាប់ត្រូវខ្មាំងចាប់ចងដាក់គុកច្រវាក់ និងធ្វើទារុណកម្មយ៉ាងឈឺចាប់ខ្លោចផ្សាបំផុត តែនៅពេលដែលខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង វាផ្គុំតែ

បន្ទិចក៏ដួលគោលជំហរបដិវត្ត ហើយបែរទៅយល់ស្របជាមួយខ្មាំងវិញ ។ ឧទាហរណ៍ដូចជាវាថា “អាណិតមិត្តណាស់ ធ្វើបដិវត្តនឹងគេយូរយារណាស់ដែរ តែពុំមាននាទីតំណែងអ្វីនឹងគេសោះ ឬពុំបានឡើងបុណ្យសក្តិអ្វីនឹងគេសោះ” ឬក៏វាថា “ធ្វើបដិវត្តន៍សង្គមនិយមតឹងតែងណាស់ លំបាកណាស់ បានឯករាជ្យហើយនៅតែពុំបានដើរលេង សប្បាយហ៊ឺហា ដើរលេងស៊ីផឹក ស្រីញី រាំវែកដូចកាលពីសង្គមចាស់ទៀត ។ ដូច្នេះពុំសប្បាយទេ ធ្វើបដិវត្តន៍សង្គមនិយម” ឬក៏វាថា “ធ្វើបដិវត្តន៍សង្គមនិយមពុំសប្បាយទេ ព្រោះគ្មានផ្សារ គ្មានចាយលុយ គ្មានប្រាក់ខែ...” ឬក៏វាថា “មិត្តឯងធ្វើបដិវត្តន៍យូរណាស់ហើយ តែគ្មានបានឃើញទៅជាអីនឹងគេសោះ បើនៅក្នុងសង្គមចាស់ ប៉ុនៗមិត្តឯងនេះ យ៉ាងហោចណាស់ក៏ពាក់សក្តិប៉ុណ្ណេះ បានប្រាក់ខែប៉ុណ្ណេះ ហើយមិត្តឯងអាចដើរលេងស៊ីផឹក ស្រីញី រាំវែកតាមចិត្ត...” ។ល ។ គ្រាន់តែខ្មាំងឆ្កឹះតែប៉ុណ្ណឹង យុវជន-យុវនារីយើងខ្លះក៏ដោយរោយតាមវាយ៉ាងងូរ ។ អ្នកខ្លះស្រណោះខ្លួនហើយអាក់អន់ស្រពន់ចិត្តនឹងបក្ស នឹងសមូហភាព ។ អ្នកខ្លះទៀតក៏ស្មុគស្មាញ អស់សង្ឃឹមមើលខ្មៅចំពោះជីវិតបដិវត្តរបស់ខ្លួន ។ ហើយអ្នកខ្លះទៀតឈានរហូតដល់ទៅរួមគំនិតក្បត់ជាមួយខ្មាំង ធ្វើសកម្មភាពប្រឆាំងបក្ស ប្រឆាំងបដិវត្ត បំផ្លិចបំផ្លាញប្រទេសជាតិនិងប្រជាជនឯងវិញ បំផ្លិចបំផ្លាញលទ្ធផលបដិវត្តដែលជាជ័យផលរួមរបស់ខ្លួនផងដែរ ដោយគ្មានស្តាយស្រណោះគ្មានគិតគូរពិចារណាវែងឆ្ងាយឡើយ ។

តើមូលហេតុមកពីអ្វីបានជាយុវជន-យុវនារីបដិវត្តយើងខ្លះដែលធ្លាប់រួមប្រយុទ្ធក្នុងចលនាតស៊ូបដិវត្តយ៉ាងតឹងតែងស្មុគស្មាញជាបន្តបន្ទាប់មកដែរ ត្រឡប់បែរទៅជាប្រឆាំងបក្ស ប្រឆាំងបដិវត្ត ក្បត់ប្រទេសជាតិ ក្បត់ប្រជាជនខ្លួនវិញយ៉ាងងាយដូច្នោះ? គ្មានអ្វីពិបាកយល់ទេ មូលហេតុសំខាន់គឺមកពីកម្មសិទ្ធិឯកជន ខាងមុខមាត់ បុណ្យសក្តិ តំណែងនាទី និងកម្មសិទ្ធិឯកជនខាងលោកទស្សនៈមិនបដិវត្ត ជីវទស្សនៈមិនបដិវត្ត និងសីលធម៌រស់នៅមិនស្អាតស្អំជាអ្នកបដិវត្ត ។ ដូច្នេះខ្មាំងឆ្កឹះចំចំណុចក៏លោតតាមខ្មាំង ។

តែបើនិយាយឲ្យចំម្យ៉ាងទៀត មូលហេតុដែលនាំឲ្យយុវជនយុវនារីបដិវត្តយើងខ្លះ(ចំនួនតិចទេ) ងាយលោតតាមខ្មាំង ងាយដោយរោយតាមខ្មាំងដូច្នេះ ក៏ព្រោះមកពីអ្នកទាំងនោះគ្មានឧត្តមគតិឬទិសដៅឲ្យច្បាស់លាស់ក្នុងការធ្វើបដិវត្តន៍គ្រប់កាលសម័យ ។

អ្នកទាំងនោះភ្លេចអស់ថា កាលពេលដែលយើងឈានជើងចេញពីផ្ទះ ពេលដែលយើងលះបង់គ្រួសារ ឪពុកម្តាយ បងប្អូន លះបង់សេចក្តីសុខស្រួលក្លែងក្លាយជាបណ្តោះអាសន្នផ្ទាល់ខ្លួន មកធ្វើបដិវត្ត គឺពិតជាពុំមែនដើម្បីស្វែងរកលាភសក្ការៈផ្ទាល់ខ្លួន ស្វែងរកមុខមាត់ បុណ្យសក្តិ ឬនាទីតំណែងអ្វីមួយនៅក្នុងបដិវត្តឡើយ ។ តែផ្ទុយទៅវិញ នៅពេលដែលយើងឈានជើងចេញពីផ្ទះមកធ្វើបដិវត្តន៍ យើងម្នាក់ៗប្រាកដជាមានកំហឹងឈឺចាប់ចំពោះអាចោរចក្រពត្តិអាមេរិកនិងបរិវារដែលរុករានទន្ទ្រានឈ្លានពានទឹកដីប្រទេសជាតិយើង មានកំហឹងឈឺចាប់នឹងស្អប់ខ្ពើមជាទីបំផុតចំពោះអំពើជិះជាន់សង្កត់សង្កិនមើលងាយមើលថោកប្រជាជនយើងអំពីសំណាក់ចក្រពត្តិអាណានិគមនិយមថ្មី-ចាស់ ពិសេសចក្រពត្តិអាមេរិកនិងបរិវារ និងពួកវណ្ណៈសក្តិភូមិម្ចាស់ដីនាយទុនប្រតិកិរិយា ហើយស្អប់ខ្ពើមបំផុតនិងប្រឆាំងយ៉ាងដាច់អហង្ការនឹងអំពើពុករលួយ ពាលាអាវ៉ាសែសព្វបែបយ៉ាងរបស់ពួកវា ។ ដូច្នេះយើងទាំងអស់គ្នាដែលបានលះបង់សព្វបែបយ៉ាងមកធ្វើបដិវត្តន៍នេះ គឺពិតជាដើម្បីរំដោះប្រទេសជាតិ រំដោះប្រជាជន និងវាយកម្ចាត់នូវអំពើពុករលួយពាលាអាវ៉ាសែសព្វបែបយ៉ាងទាំងអស់ ហើយគឺពិតជាពុំមានទិសដៅអ្វីផ្សេងៗពីនេះទៀតឡើយ ។ ចុះហេតុអ្វីបានជាក្រោយពេលដែលរំដោះប្រទេសជាតិនិងរំដោះប្រជាជនកម្ពុជាបានទាំងស្រុងនិងជាស្ថាពរ ហើយដណ្តើមរដ្ឋអំណាចទាំងមូលមកក្នុងកណ្តាប់ដៃយើងហើយ យើងមិនគិតខិតខំវាយសំរុកការពារប្រទេសជាតិ ការពារប្រជាជន ការពាររដ្ឋអំណាចបដិវត្ត កម្មករ-កសិករ ការពារជ័យផលបដិវត្តដែលបានមកពីពលិកម្មច្រើនឥតគណនារបស់យើងរាល់គ្នា ឲ្យបានឋិតថេរគង់វង្សតរៀងទៅ និងមិនខិតខំវាយសម្រុកកសាងប្រទេសជាតិ លើកស្ទួយជីវភាពប្រជាជនយើងឲ្យសំបូរសប្បាយឆាប់រហ័ស ។ ហើយបែរជាគិតតែស្មុគស្មាញ ទោមនស្ស ថ្នាំងថ្នាក់តែពីរឿងកម្មសិទ្ធិឯកជនជុំវិញបុគ្គលស្ងួនគួខ្លួនទៅវិញ ។ តើយើងចង់ឡើងសោយរាជ្យ

ជំនួសស្តេចចាស់ ឬធ្វើជាវណ្ណៈជិះជាន់ថ្មីជំនួសវណ្ណៈជិះជាន់ចាស់ដែលទើបត្រូវរលំរលាយផុតទៅនេះ ដើម្បីបន្តការជិះជាន់សង្កត់សង្កិនទៅលើប្រជាជន កម្មករ កសិករក្រីក្រយើងទៀតហើយបន្តប្រព្រឹត្តនូវអំពើអបាយមុខ ពុករលួយ ពាលាអាវ៉ាសែសព្វបែបយ៉ាងតទៅទៀតឬយ៉ាងណា? ដូច្នេះវាខុសនឹងទិសដៅបដិវត្តយើង ហើយវាខុសនឹងឧត្តមគតិដ៏ថ្លៃថ្លារុងរឿងរបស់យើងហើយ ។ ដូច្នេះសូមមិត្តយុវជន-យុវនារីបដិវត្តយើងទាំងអស់គិតគូរពិចារណាឲ្យបានជ្រៅជ្រះក្នុងការស្តាប់ឬពាក្យឃោសនាអសុទ្ធចិត្តផ្សេងៗ ឬពាក្យញុះញង់មួលបង្កាច់បង្ខូចបន្តុះបង្អាប់បក្សយើង ចលនាបដិវត្តយើង របស់ខ្មាំងសត្រូវគ្រប់ប្រភេទមកពីខាងក្រៅ ក៏ដូចរបស់ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងដែរ ។ បើមិត្តយុវជន-យុវនារីបដិវត្តយើងមានទិសដៅច្បាស់លាស់ក្នុងការធ្វើបដិវត្តន៍ ហើយឈរយ៉ាងរឹងមាំដាច់ខាតលើឧត្តមគតិបដិវត្តឧត្តមគតិកុម្មុយនិស្តខាងលើនេះគ្រប់ពេលវេលា នោះមិនត្រឹមតែមិនជឿពាក្យឃោសនាញុះញង់អូសទាញរបស់ខ្មាំង មិនដោយរោយតាមខ្មាំងប៉ុណ្ណោះទេ តែមិត្តអាចរកខ្មាំងឃើញ សូម្បីតែខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងរាប់សិបឆ្នាំមកហើយក៏រកឃើញដែរ ។ ដូច្នេះមិត្តមិនត្រឹមតែអាចទប់ទល់ការពារខ្លួនមិត្តមិនឲ្យមានគ្រោះថ្នាក់ប៉ុណ្ណោះទេ តែមិត្តនៅបានរួមចំណែកយ៉ាងសកម្មនិងស័ក្តិសិទ្ធិបំផុតក្នុងការបោសសម្អាតខ្មាំងពីក្នុងជួរបក្សនិងជួរបដិវត្តន៍យើងឲ្យស្អាតអស់រលីងគេង រួមចំណែកការពារប្រទេសជាតិ ការពារបក្ស ការពារផលបដិវត្ត ការពាររដ្ឋអំណាចបដិវត្ត កម្មករ កសិករនិងការពារប្រជាជនបានជាអតិបរមាផង ។

ដូច្នេះសរុបមក ក្នុងការធ្វើបដិវត្តន៍គ្រប់កាលសម័យយុវជន-យុវនារីបដិវត្តយើងត្រូវមានទិសដៅនិងមានឧត្តមគតិច្បាស់លាស់ ទើបធ្វើបដិវត្តន៍បានខ្លាំងក្លាជាប់ជានិច្ច ដណ្តើមជោគជ័យជាបន្តបន្ទាប់ រហូតដល់ដណ្តើមជ័យជម្នះទាំងស្រុងនិងស្ថាពរ ។ បើមិនដូច្នេះទេ ឬបើប្រសិនជាយុវជន-យុវនារីបដិវត្តយើងធ្វើបដិវត្តន៍ដោយរោយតែតាមគេតាមឯង ធ្វើការងារបដិវត្តតូចធំប្រចាំថ្ងៃដូចជាម៉ាស៊ីន ចាំតែអនុវត្តដោយគ្មានគិតគូរត្រិះរិះពិចារណារកហេតុរកផលឲ្យបានវែងឆ្ងាយ ឬដោយគ្មានកំណត់ទិសដៅឲ្យច្បាស់លាស់ តើយើងធ្វើបដិវត្តន៍ដើម្បីអ្វី ដើម្បីអ្នកណាឲ្យបានត្រឹមត្រូវច្បាស់លាស់ទេ នោះយើងធ្វើបដិវត្តន៍មិនខ្លាំងក្លាទេ មិនរីករាយជ្រះថ្លាទេ ។ មិនត្រឹមតែប៉ុណ្ណោះ យើងអាចផុងខ្លួនធ្លាក់ទៅក្នុងអន្ទាក់ខ្មាំង ឬដោយរោយតាមខ្មាំង ឈានទៅក្បត់បក្ស ក្បត់បដិវត្ត ក្បត់ប្រទេសជាតិនិងប្រជាជនឯងទៀតផង ។ ដូច្នេះជាគ្រោះថ្នាក់ធំណាស់ចំពោះប្រទេសជាតិ ចំពោះបដិវត្ត ចំពោះប្រជាជន ក៏ដូចជាចំពោះខ្លួនឯងផ្ទាល់ដែរ បើកាលណាយុវជន-យុវនារីបដិវត្តយើងមិនបានកំណត់ទិសដៅមួយឲ្យច្បាស់លាស់នៅក្នុងជីវិតបដិវត្តរបស់ខ្លួនទេ ។

មិត្តយុវជន-យុវនារីបដិវត្តយើងទាំងអស់ត្រូវគិតគូរវាសនាអនាគតនៃជីវិតបដិវត្តខ្លួន ក្នុងឋានៈខ្លួនមិត្តជាអ្នកបន្តវេនបដិវត្តតទៅថ្ងៃមុខទៀត ។ ប្រទេសជាតិ ប្រជាជនកម្ពុជា និងបក្សកុម្មុយនិស្តកម្ពុជា ដាក់ក្តីសង្ឃឹមទាំងស្រុងនិងជំនឿជឿជាក់ទៅលើមិត្តយុវជន-យុវនារីយើងជំនាន់នេះ ហើយប្រគល់វាសនាអនាគតនៃប្រទេសជាតិប្រជាជននិងបដិវត្តកម្ពុជាយើងទាំងស្រុងទៅជូនមិត្ត ។ ដូច្នេះជាកិត្តិយសខ្ពង់ខ្ពស់ណាស់ចំពោះយុវជន-យុវនារីបដិវត្តយើងជំនាន់នេះ ដែលគ្មានអ្នកណាអាចកាត់តម្លៃបាន គ្មានរបស់អ្វីដែលថ្លៃបំផុតនៅក្នុងលោកនេះអាចមកប្រៀបផ្ទឹមបានឡើយ ។ ហើយគ្មានកម្មសិទ្ធិឯកជនណាមួយអាចមកប្រៀបផ្ទឹមឬមកដោះដូរនឹងកិត្តិយសខាងលើនេះរបស់យុវជន-យុវនារីបដិវត្តយើងបានឡើយ ។ ដូច្នេះមិត្តយុវជន-យុវនារីបដិវត្តយើងត្រូវមានមោទនភាពសមរម្យចំពោះកិត្តិយសរបស់ខ្លួនហើយខិតខំវាយកម្ចាត់នូវរាល់កម្មសិទ្ធិឯកជន កម្មសិទ្ធិបុគ្គលសួនតួ ឲ្យស្អាតរលីងគេង ដើម្បីកសាងខ្លួនឲ្យចំរើនឆាប់រហ័ស បន្តវាយសំរុកធ្វើបដិវត្តន៍សង្គមនិយម និងបន្តកសាងសង្គមនិយមឲ្យខ្លាំងក្លាដាច់ខាត ដើម្បីបន្តវេនបដិវត្តតទៅអនាគតទៀតឲ្យបានជោគជ័យទាំងស្រុង សមស្របតាមទំនុកទុកចិត្តនិងក្តីសង្ឃឹមដែលប្រទេសជាតិ ប្រជាជនកម្ពុជា និងបក្សកុម្មុយនិស្តកម្ពុជាមានចំពោះមិត្តយុវជន-យុវនារីយើងជំនាន់នេះ ។

**ស៊ឹម សុភ័ក្រ្ត**

**(ដកស្រង់ចេញពីសៀវភៅយុវជននិងយុវនារីបដិវត្ត**

**លេខ៥ ខែឧសភា ឆ្នាំ១៩៧៧)**

# រណ្ដៅសាកសពប្រល័យពូជសាសន៍នៅខេត្តកំពង់ឆ្នាំង

ការចុះធ្វើបញ្ជីរណ្ដៅសាកសពប្រល័យពូជសាសន៍នៅខេត្តកំពង់ឆ្នាំង ឆ្នាំ១៩៩៧ ក្នុងស្រុកកំពង់ឆ្នាំង និងស្រុកទឹកផុស ។

## ស្រុកកំពង់ឆ្នាំង

### វត្តក្បាលរាមៈ

វត្តក្បាលរាមគឺជាទីតាំងតម្កល់អដ្ឋិធាតុជនរងគ្រោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ទីតាំងនេះស្ថិតនៅក្នុងវត្តក្បាលរាម ឃុំក្បាលរាម ស្រុកកំពង់ឆ្នាំង ចម្ងាយ៥០០ម៉ែត្រខាងលិចសាលាខេត្តកំពង់ឆ្នាំង ។ តាមប្រព័ន្ធកំណត់ទីតាំងពិភពលោកបង្ហាញថាទីតាំងនេះស្ថិតនៅក្នុងខ្សែស្រប ១២° ៤៦' ៥០:៥១" និងខ្សែបណ្ដោយ ១០៤° ៣៩' ៧៥:១៩" ។ ទិន្នន័យចំណុចទីតាំងភូមិសាស្ត្រនេះត្រូវបានថតទុកនៅក្នុងឧបករណ៍អេឡិចត្រូនិកដោយលេខកូដ ៤០៣០១ និងលេខឯកសារ R:០៣០៦០៩A ។ ទីតាំងនេះត្រូវបានចុះទៅនៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៩៧ វេលាម៉ោង៤:១០នាទីល្ងាច ។

លោក សួស សុផល អាយុ៥៥ឆ្នាំ បច្ចុប្បន្នរស់នៅភូមិដំណាក់ពពូល ឃុំកំពង់ឆ្នាំង ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង តួនាទីជាប្រធានធម្មការខេត្តបានឲ្យដឹងថា គាត់បានជញ្ជូនអដ្ឋិធាតុទាំងនេះយកមកតម្កល់ទុកនៅវត្តក្បាលរាមនេះក្នុងឆ្នាំ១៩៨២ សរុបទាំងអស់មានចំនួន១៥០០ ។ សព្វថ្ងៃអដ្ឋិធាតុទាំងនោះនៅសល់តែ១៣០ប៉ុណ្ណោះ ។ គោលបំណងនៃការប្រមូលអដ្ឋិធាតុមកតម្កល់នេះ គឺដើម្បីធ្វើបុណ្យថ្ងៃ២ ធ្នូ និងថ្ងៃ៧ មករា ដើម្បីរំឭកដល់វិញ្ញាណក្ខ័ន្ធបងប្អូនពុក ម៉ែ មាមីង ដែលបានស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

## ស្រុកទឹកផុស

### ក) បន្ទាយចាស់ៈ

បន្ទាយចាស់គឺជាទីតាំងសម្លាប់និងតម្កល់អដ្ឋិធាតុជនរងគ្រោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ទីតាំងនេះស្ថិតនៅក្នុងភូមិស្រែតាជ័យ ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង មានចម្ងាយប្រហែល៣០០ម៉ែត្រចំពីមុខសាលាស្រុកទឹកផុស ។ តាមប្រព័ន្ធកំណត់ទីតាំងពិភពលោកបង្ហាញថាទីតាំងនេះស្ថិតក្នុងខ្សែស្រប១២° ០៣' ០២:៦១" និងខ្សែបណ្ដោយ១០៤° ៣១' ២៦:៩២" ។ ទិន្នន័យចំណុចទីតាំងភូមិសាស្ត្រនេះត្រូវបានថតទុកក្នុងឧបករណ៍អេឡិចត្រូនិកដោយលេខកូដ៤០៨០១ និងលេខឯកសារ R:០៣០៧០២A ។ ទីតាំងនេះត្រូវបានចុះទៅនៅថ្ងៃទី៧ ខែមីនា ឆ្នាំ១៩៩៧ វេលាម៉ោង១០ព្រឹក ។

លោក អ៊ុង វង់ឌឿន មានតួនាទីជាអភិបាលរងទី២ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង បានមានប្រសាសន៍ថា ការកាប់សម្លាប់ក្នុងស្រុកទឹកផុសចាប់ផ្ដើមមានតាំងពីខែមេសា ឆ្នាំ១៩៧៥មកម្ល៉េះ គឺនៅពេលដែលបែកភ្នំពេញភ្លាម ពួកខ្មែរក្រហមចាប់ផ្ដើមកាប់សម្លាប់ប្រជាជនភ្លាមតែម្ដង ។ ជនរងគ្រោះដំបូងបង្អស់ដែលត្រូវស្លាប់នៅទីនេះគឺជាទាហាន លន់ ណុល ដែលត្រូវចាប់បញ្ជូនមកពីភូមិភាគបូព៌ា ។ ជនរងគ្រោះជាបន្តបន្ទាប់មកទៀតគឺប្រជាជនថ្មី និងប្រជាជនត្រៀម ។

នៅក្នុងរបបខ្មែរក្រហម ប្រជាជនត្រូវបែងចែកជា៣ប្រភេទៈ ប្រភេទទី១ ប្រជាជនពេញសិទ្ធិ គឺប្រជាជនមូលដ្ឋានសុទ្ធសាធ ដែលមិនមានជាប់ពាក់ព័ន្ធនិន្នាការនយោបាយ ។ ប្រភេទទី២ គឺប្រជាជនមូលដ្ឋានដែលមានជាប់ពាក់ព័ន្ធបងប្អូនមាននិន្នាការ និងប្រភេទទី៣ ប្រជាជនថ្មី (ប្រជាជន១៧មេសា) ។

លោក វង់ឌឿន បន្ថែមថា រូបលោកផ្ទាល់ស្ថិតនៅក្នុងកងប្រជាជនថ្មី ។ ប្រជាជននៅក្នុងកងរបស់លោក វង់ឌឿន ត្រូវរងនូវទារុណកម្មយ៉ាងធ្ងន់ធ្ងរពីពួកខ្មែរក្រហម មានតាំងពីការវាយបង្ខំឲ្យហូបស្បែកគោ ស្បែកឆ្មា យកត្រដោកដាក់ក្បូចធ្វើទារុណកម្ម ចងទម្លាក់ទឹក ហើយមានមនុស្សជាច្រើននាក់ទៀតត្រូវបាត់ខ្លួនដោយគ្មានមូលហេតុតែម្ដង ។ មានប្រជាជនមួយចំនួនទៀត ដោយទ្រាំទ្រនឹងសភាពលំបាកវេទនាមិនបាន ក៏សុខចិត្តចងកសម្លាប់ខ្លួន ។

លោក គី សុងឆាយ អាយុ៤៣ឆ្នាំ បច្ចុប្បន្នជាប្រធានមន្ទីរវប្បធម៌ស្រុកទឹកផុស រស់នៅភូមិស្រែតាជ័យ ឃុំអភិវឌ្ឍន៍



គុកវត្តចំប៉ា ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង

គុកសន្តិសុខនេះគឺស្ថិតនៅក្នុងខ្សែស្រប ១៣° ០៣' ១០:៨៧" និងខ្សែបណ្តោយ ១០៤° ៣១' ៧២:៩៧" ។ ទិន្នន័យចំណុចទីតាំងភូមិសាស្ត្រនេះត្រូវបានថតទុកនៅក្នុងឧបករណ៍អេឡិចត្រូនិកដោយលេខកូដ៤០៨០២ និងលេខឯកសារ R:០៣០៧០៣A ។ ទីតាំងនេះត្រូវបានចុះនៅថ្ងៃទី៧ ខែមីនា ឆ្នាំ១៩៩៧ វេលាម៉ោង១០:៤០នាទីព្រឹក ។

លោក ជា គីមលន់ អាយុ ៤៩ឆ្នាំ បច្ចុប្បន្នជាអនុប្រធានមន្ទីរវប្បធម៌ស្រុកទឹកផុស សព្វថ្ងៃរស់នៅភូមិតាជ័យ ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង បានមានប្រសាសន៍ថា សាកសពជនរងគ្រោះដែលបានស្លាប់នៅទីនេះគឺកុមារនិងស្ត្រី ហើយត្រូវសម្លាប់នៅក្បែរវត្តតែម្តង ។ ជនរងគ្រោះដែលស្លាប់នៅទីនេះមានចំនួនសរុបទាំងអស់គឺជាងមួយរយនាក់ ហើយមានរណ្តៅចំនួន២០រណ្តៅ ក្នុងរណ្តៅនីមួយៗមានសាកសពពី ៤ ទៅ ៥ នាក់ ។ **អ៊ុច សំអឿន**

ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ជាអ្នកដែលបានចូលរួមក្នុងការគាស់អដ្ឋិធាតុជនរងគ្រោះនៅទីតាំងសម្លាប់បន្ទាយចាស់នេះ បានឲ្យដឹងថា រណ្តៅសាកសពនៅបន្ទាយចាស់នេះមានចំនួន៤រណ្តៅ ។ រណ្តៅនីមួយៗមានបណ្តោយប្រហែល៣០ម៉ែត្រ ទទឹង៥ម៉ែត្រ និងជម្រៅ២ម៉ែត្រ អាចដាក់សាកសពប្រហែល១ពាន់នាក់ ។ សរុបទាំង៤រណ្តៅធំៗ មានចំនួនសាកសពប្រហែល៤ពាន់នាក់ ។ លោក សុងឆាយ ក៏បានចូលរួមគាស់រណ្តៅតូចៗ ផ្សេងទៀតនៅទូទាំងស្រុកទឹកផុស ដែលមានសាកសពប្រហែល២ពាន់នាក់ ។ លោក សុងឆាយ បានបញ្ជាក់ថា ការជីកគាស់នេះមិនទាន់អស់នៅឡើយទេ នៅមានរណ្តៅមួយចំនួនទៀតមិនទាន់បានគាស់នៅឡើយ ។ អដ្ឋិធាតុដែលគាស់ពីបន្ទាយចាស់ត្រូវបានដឹកយកទៅតម្កល់ទុកនៅវត្តសុវណ្ណសុនារាម ។ បច្ចុប្បន្នអដ្ឋិធាតុទាំងនោះត្រូវបាត់បង់ជាបណ្តើរៗ ហើយ ដោយខ្វះការថែរក្សាឲ្យបានដិតដល់ ។

### ២) វត្តសុវណ្ណសុនារាម

វត្តសុវណ្ណសុនារាមជាទីតាំងសម្លាប់និងគុកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ទីតាំងនេះស្ថិតនៅក្នុងភូមិតាជ័យ ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង មានចម្ងាយ៥០០ម៉ែត្រ ខាងកើតសាលាស្រុកទឹកផុស ។ តាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រពិភពលោកបានបង្ហាញថា ទីតាំងសម្លាប់និង

## ពន្យល់ពាក្យខ្មែរក្រហម

- សួនតួនិយមៈ និយមតែខ្លួនឯង ។
- សត្យានុម័តៈ សម្រេចនូវពាក្យសច្ចៈ ។
- សម្ព័ន្ធយុវកកៈ អង្គការយុវជន ។
- កម្មាជីវូបនីយកម្មៈ គឺរស់នៅក្នុងការងារ ។
- ស្វ័យឯកកោនិយមៈ សម្រេចនឹងអនុម័តដោយចិត្តឯង ។
- ហ្វាស៊ីសភាវូបនីយកម្មៈ យោរយោគាប់សម្លាប់ដាក់គុកច្រវ៉ាក់ ។
- បដិវត្តន៍ៈ បដិសន្ធិនឹងការវិវត្ត ប្តូរលំរំវណ្ណៈមួយ កសាងវណ្ណៈមួយ ។ (កំណត់ហេតុ TSL N-97, N-11 លេខៈ10)



# កៅលី ជុនហួត
# សមាជិកក្រុមគូរផែនទីកម្ពុជាប្រជាធិបតេយ្យ

**ឯកសារ** K-56 TSL

កៅលី ជុនហួត ហៅ ធឿន មានស្រុកកំណើតនៅភូមិ អង់ឃ្មាំ ឃុំប្រឡាយ ស្រុកស្ទោង ខេត្តកំពង់ធំ ។ ឪពុកឈ្មោះ កៅលី អាយុ៦៥ឆ្នាំ និងម្ដាយឈ្មោះ ហ៊ុន រឿន(ស្លាប់) ។ ធឿន ជាកូនច្បងក្នុងចំណោមបងប្អូនបីនាក់ (ប្រុសម្នាក់និងស្រីពីរនាក់) ។ មុនពេលប្រទេសកម្ពុជាធ្លាក់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ធឿន ជាសិស្សនៅវិទ្យាល័យកំពង់ធំ ហើយបានប្រឡងជាប់ចូលរៀននៅសាលាគ្រូកំពង់កន្ទួត ។ ចាប់ផ្ដើមនៅកណ្ដាលឆ្នាំ ១៩៦៨ ធឿន បានទទួលមនោគមវិជ្ជាឲ្យស្អប់ខ្ពើមរបបកុម្មុយនិស្ដ ដែលមានតែការលំបាក ស៊ីអង្ករកំប៉ុង ហើយតម្រូវឲ្យអួតសរសើររបបសេរី (បែបអាមេរិកាំង) វិញ ។ ការបណ្ដុះមនោគមវិជ្ជារបៀបនេះយូរៗទៅធ្វើឲ្យ ធឿន ក្លាយខ្លួនជាមនុស្សប្រឆាំងនឹងរបបកុម្មុយនិស្ដយ៉ាងពេញទំហឹង និងគ្មានអ្វីមករារាំងនូវជីវិតជាសេ.អ៊ី.អារបស់ ធឿន បានឡើយ ។ មុខងាររបស់ ធឿន មានការផ្លាស់ប្ដូរយ៉ាងឆាប់រហ័សទៅតាមស្ថានការណ៍ជាក់ស្ដែង ។ ធឿន ធ្លាប់ធ្វើជាអនុប្រធានសន្តិសុខស្រុកស្ទោងក្នុងឆ្នាំ១៩៧៣ ។ រហូតដល់ប្រទេសជាតិស្ថិតនៅក្រោមការត្រួតត្រានៃរបបកម្ពុជាប្រជាធិបតេយ្យ ធឿន នៅតែមិនអាចលះបង់គំនិតស្រឡាញ់របបសេរីដដែល ទោះជាខ្លួនមានមុខងារជាអនុប្រធានសន្តិសុខតំបន់៤៣ នៅក្នុងខែមីនា ឆ្នាំ១៩៧៦ យ៉ាងណាក៏ដោយ ។ ជីវិតជា សេ.អ៊ី.អា នេះបានបន្តរហូតដល់ដាច់ពាក់កណ្ដាលឆ្នាំ ១៩៧៧ ទើប ធឿន ត្រូវបានវែកមុខមាត់ដោយកម្មាភិបាលខ្មែរក្រហម ហើយបានបញ្ជូនមកកាន់មន្ទីរស-២១ នៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧៧ ដើម្បីអប់រំកែប្រែ ។ ក្នុងរយៈកាលនៃការកែប្រែនៅក្នុងមន្ទីរស-២១ ធឿន បានទទួលតួនាទីជាសមាជិកក្រុមគូរផែនទី ។ អស់រយៈពេលជិតមួយឆ្នាំនៅក្នុងមន្ទីរស-២១ ធឿន មិនអាចទាក់ទងនិងកសាងបានកម្លាំងសេ.អ៊ី.អា ថ្មីបានទេ ។ ផ្ទុយទៅវិញ ធឿន បានខិតខំធ្វើការតាមបញ្ជាដែលបក្សបានដាក់ឲ្យធ្វើ ។ ប៉ុន្តែអ្វីដែលជាបញ្ហាមិនអាចគេចរួចគឺ ធឿន បានព្យាយាមរកលេសដើម្បីរំលោភនារីម្នាក់ឈ្មោះ ហុង រហូតដល់មានរឿងបែកការណ៍ ។ ក្រោយមក ធឿន ក៏ត្រូវបានចាប់ខ្លួនម្ដងទៀតនៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៧៨ នៅក្នុងមន្ទីរស-២១តែម្ដង ។

ឯកសារចម្លើយសារភាពរបស់ កៅលី ជុនហួត ហៅ ធឿន ដែលមានចំនួន៤៦ទំព័រ បានបង្ហាញពីសកម្មភាពមួយចំនួនរបស់ ធឿន ដូចតទៅ÷

កាលនៅពីតូច ធឿន ជាសិស្សនៅសាលាតីមហួន នៅឯស្រុកកំណើត ។ លុះដល់ឆ្នាំ១៩៧២ ធឿន បានបន្តការសិក្សានៅអនុវិទ្យាល័យស្ទោង (ថ្នាក់ទី៦ដល់ថ្នាក់ទី៣) ។ នៅឆ្នាំ១៩៦៧ ធឿន បានផ្លាស់ទៅរៀននៅវិទ្យាល័យកំពង់ធំ (ថ្នាក់ទី២) ។ នៅចុងឆ្នាំដដែល ធឿន បានប្រឡងជាប់ចូលរៀននៅសាលាគរុកោសល្យកំពង់កន្ទួត ។ ក្នុងអំឡុងពេលនៃការសិក្សា ធឿន បានទទួលការណែនាំពីឈ្មោះ ណៃ ជៀក ឲ្យស្អប់របបកុម្មុយនិស្ដ ដែលមានតែការលំបាកស៊ីអង្ករកំប៉ុង ហើយបំផុសបញ្ចូលមនោគមវិជ្ជាឲ្យស្រឡាញ់របបសេរីបែបអាមេរិកាំងដែលអាច

ធ្វើអ្វីៗបានតាមចិត្ត ។ ណៃ ជៀក ចេះតែព្យាយាមបញ្ចុះបញ្ចូល ធឿន ហើយតែងតែបបួល ធឿន ឲ្យចូលធ្វើជា សេ.អ៊ី.អា ជាមួយខ្លួន រហូតដល់មានការយល់ព្រម ។ នៅខែមិថុនា ឆ្នាំ១៩៦៨ ធឿន ត្រូវបានប្រកាសឲ្យចូលធ្វើជាសេ.អ៊ី.អា ពេញសិទ្ធិដោយមាន ទី សុគន្ធ ជាអ្នកខទ្មេសនាម និង ណៃ ជៀក ជាអ្នកទទួលស្គាល់ផ្លូវការ ។ ក្រោយពេលប្រកាស ធឿន បានទទួលភារកិច្ចពី ណៃ ជៀក មកអនុវត្ត ។ ក្រុមសេ.អ៊ី.អា ចំនួន៦នាក់ត្រូវបានណែនាំឲ្យ ធឿន ខស្សរាប់ទាក់ទងជាមួយនៅក្នុងសាលាគរុកោសល្យកំពង់កន្ទួត ។ អ្នកទាំងអស់សុទ្ធតែមានភារកិច្ចរួមមួយគឺ "ការពាររបបសេរី ប្រឆាំងរបបកុម្មុយនិស្ត" ។ ដើមខែកញ្ញា ឆ្នាំ១៩៦៨ ធឿន ត្រូវបានតម្រូវឲ្យទៅបង្រៀនសាលាខេត្តកំពង់ធំ ជាមួយអ្នកគ្រូ ណូរី ដែលជាខ្មែរសេ.អ៊ី.អាជាមួយគ្នា ។ មុនពេលចេញដំណើរ ធឿន បានទទួលការណែនាំពី ណៃ ជៀក ឲ្យខស្សរាប់ទាក់ទងជាមួយលោកគ្រូ ចាន់ បូ ។ ចុងខែធ្នូ ឆ្នាំ១៩៦៨ ធឿន ខស្សរាប់ទាក់ទងជាមួយឈ្មោះ ចាន់ បូ តាមការណែនាំរបស់ ណៃ ជៀក ។ ចាន់ បូ ជាខ្មែរសេ.អ៊ី.អានៅកំពង់ចាម ។ ចំណែកអ្នកគ្រូ ណូរី បានផ្លាស់ទៅបង្រៀននៅខេត្តកំពត បន្ទាប់ពីបានរៀបការរួច ។ នៅឯស្រុកកំណើត ធឿន កសាងកម្លាំងបានខ្មែរសេ.អ៊ី.អា ដែលភាគច្រើនជាសិស្សថ្នាក់ទី៧នៃសាលារៀនគីមហួន ចំនួន៦នាក់ និង៨នាក់ផ្សេងទៀតជាប្រជាជន ។

ពាក់កណ្តាលឆ្នាំ ១៩៦៩ ធឿន ត្រូវបាន ចាន់ បូ ឲ្យយកគ្រួសារត្រកូលបដិវត្តមួយ (ដែលតាមការនិយាយរបស់ ចាន់ បូ ថា គ្រួសារនេះគឺក្រហមទាំងក្មេងទាំងចាស់) ក្នុងគោលបំណងជ្រៀតចូលឲ្យកៀកស្រួលយកការណ៍ និងដើម្បីបម្រើខ្មែរ សេ.អ៊ី.អា ឲ្យបានយូរអង្វែងផង ។ នៅខែកញ្ញា ឆ្នាំ១៩៦៩ ផែនការរៀបចំគ្រួសាររបស់ ធឿន ត្រូវបានសម្រេច ។ តាំងពីរៀបការហើយ ធឿន តែងតែរករឿងហេតុជាមួយគ្រួសារខាងប្រពន្ធជាញឹកញាប់ ។ ធឿន រកលេសស្តីបន្ទោសប្រពន្ធគ្មានលោះថ្ងៃឡើយ ព្រោះ ធឿន យល់ថាការរៀបការនេះជាផែនការមួយតែប៉ុណ្ណោះ មិនមែនដើម្បីសុភមង្គលគ្រួសារទេ ។

ខែមេសា ឆ្នាំ១៩៧០ រាល់សកម្មភាពរបស់ខ្មែរ សេ.អ៊ី.អា ត្រូវបានផ្អាកមួយរយៈ ពួកខ្មែរក្រហមតែងតែបានទទួលជោគជ័យជាបន្តបន្ទាប់ក្នុងការដណ្តើមយកស្រុកមួយចំនួនក្នុងខេត្តកំពង់ធំ ជាពិសេសប្រជាជនភាគច្រើនកំពុងតែមានការបះបោរហើយដើរតាមខ្មែរក្រហម ។ អ្នករដ្ឋការទាំងអស់មានការភិតភ័យយ៉ាងខ្លាំង ហើយតម្រូវឲ្យគ្រូបង្រៀនទាំងអស់កាន់កាំភ្លើងការពារស្រុកភូមិ ។ នៅខែតុលា ឆ្នាំ១៩៧០ ខ្មែរសេ.អ៊ី.អាមួយចំនួន បូករួមទាំង ចាន់ បូ ផង បាននាំគ្នារត់ចូលភ្នំពេញដោយខ្លាចការតាមចាប់ខ្លួន ។ ចំណែក ធឿន មិនបានផ្លាស់ទៅភ្នំពេញទេ នៅបន្តតាមដានសភាពការណ៍តទៅទៀត ។ លុះដល់ខែមករា ឆ្នាំ១៩៧១ ធឿន បានព្យាយាមស្កាត់ជួបលេខាស្រុកស្ទោងឈ្មោះ ស្រ៊ុន ក្នុងគោលបំណងសុំចូលធ្វើបដិវត្តន៍ ។ ចុងខែមករា ការស្នើសុំរបស់ ធឿន ហាក់មានប្រសិទ្ធភាព ។ ស្រ៊ុន ជាខ្មែរ សេ.អ៊ី.អា ម្នាក់ដែលមានរូបភាពខាងក្រៅជាអ្នកធ្វើបដិវត្តន៍ពិតៗ ប៉ុន្តែភារកិច្ចសំខាន់គឺសេ.អ៊ី.អា បង្កប់ខ្លួន កសាងកម្លាំងដើម្បីកម្ទេចក្បាលម៉ាស៊ីនដឹកនាំបដិវត្តន៍ ។ ពេលបន្ទាប់ ធឿន ត្រូវបានតែងតាំងដោយ ស្រ៊ុន ឲ្យធ្វើជាអ្នកគ្រប់គ្រងថ្មីនៅឃុំសាគ្រាម ។ កម្លាំងសេ.អ៊ី.អាចំនួន២៦នាក់ក្នុងស្រុកបានត្រូវខទ្មេសនាម ធឿន ឲ្យខស្សរាប់ទាក់ទងក្នុងការធ្វើសកម្មភាពកម្លាំងថ្មីនៅឃុំសាគ្រាម ។ ភារកិច្ចថ្មីរបស់ ធឿន គឺតម្រូវឲ្យយកមាគ៌ាបដិវត្តន៍ទៅច្នៃឲ្យខុសខ្លះក្នុងការដឹកនាំដើម្បីបំបែកប្រជាជនពីអង្គការបដិវត្តន៍ ។ ខែកុម្ភៈ ឆ្នាំ១៩៧១ ធឿន បានចូលរួមប្រជុំជាមួយសមាជិក សេ.អ៊ី.អា ចំនួន១៥នាក់ ដែលមានស្រ៊ុនជាប្រធានអង្គប្រជុំ ។ អត្ថន័យនៃអង្គប្រជុំត្រូវបាន ធឿន លើកយកមកនិយាយក្នុងឯកសារចម្លើយសារភាពរបស់គាត់ថា "ត្រូវបន្ថយកម្លាំងពីតំបន់រំដោះ ហើយទប់ស្កាត់ប្រជាជននៅភ្នំពេញកុំឲ្យចេញមក ។ ត្រូវនិយាយឃោសនាជាពាក្យចិត្តសាស្ត្រថា បន្តិចទៀតអ្នកមានទ្រព្យសម្បត្តិច្រើនត្រូវអង្គការប្រមូលដាក់រួមទាំងអស់ ឯអ្នករាជការទាំងអស់ត្រូវកម្ទេចចោល ព្រោះជាសក្តិភូមិ" ។ ក្នុងរយៈពេលជិតមួយឆ្នាំ ធឿន បានបំផ្លិចបំផ្លាញផលដំណាំអស់យ៉ាងច្រើន ហើយបានកសាងកម្លាំងសេ.អ៊ី.អាក៏បានច្រើនដែរ ។ ការបំផ្លាញទាំងនេះគឺពិតជាមានគោលបំណងចង់ឲ្យប្រជាជនបាត់ជំនឿទៅលើការដឹកនាំរបស់អង្គការ ហើយបែរមកប្រឆាំងនឹងអង្គការវិញ ។ ខែកុម្ភៈ ឆ្នាំ១៩៧២ ធឿន

បានប្តូរឲ្យមកនៅឃុំពពកវិញ មូលហេតុបានបង្កទំនាស់យ៉ាងច្រើននៅឃុំសាគ្រាម ។ ទៅដល់ឃុំពពក ធឿន បានចាប់ផ្តើមបង្កមហន្តរាយផ្សេងៗដែលខ្លួនអាចធ្វើបាន ។ ធឿន បានដាក់បញ្ជាឲ្យណាន ជន និង ភ្លៀវ ទៅលួចដុតជង្រុកស្រូវនៅភូមិពពកនិងភូមិអន្លង់ក្រាញ់ ។ ខែឧសភា ធឿន កសាងបានកម្លាំងសេ.អ៊ី.អា ៣នាក់ទៀត ។ ខែកញ្ញា ធឿន រួមជាមួយឈ្មោះ មៃ ត្រូវបានចាត់តាំងឲ្យទៅគ្រប់គ្រងនៅកងផលិតស្រែប្រាំង បំណងរៀបចំផែនការបញ្ចេញស្បៀងទៅភ្នំពេញ ។ ក្នុងរវាងពាក់កណ្តាលឆ្នាំរហូតដល់ចុងឆ្នាំ១៩៧២ ធឿន កាន់តែមានភាពរកិច្ចប្រឆាំងនឹងអង្គការបដិវត្តធំឡើងៗ រហូតដល់មានការរំលោះសេដ្ឋកិច្ចពីតំបន់រំដោះចូលភ្នំពេញ ពោធិសាត់ និង ខេត្តកំពង់ឆ្នាំង ហើយព្រមទាំងបានលួចទំនាក់ទំនងជាមួយឈ្មួញក្នុងការនាំទំនិញចេញដូចជា អង្ករ ត្រីសាច់...រាប់តោនទៅដោយស្ងាត់ៗបំផុត ។

ដើមឆ្នាំ១៩៧៣ ធឿន ត្រូវបានខទ្ទេសនាមឲ្យធ្វើជាអនុប្រធានសន្តិសុខ ស្រុកស្ទោង ដែលមានឈ្មោះ យិន ជាប្រធាន និង ហឿន ជាសមាជិក ។ ក្នុងមុខងារនេះ ធឿន បានទទួលបញ្ជាពីឈ្មោះ ឡើង (ខ្សែសេ.អ៊ី.អា ដែលតែងតែគាំទ្រនិងឲ្យយោបល់ដល់ ធឿន) បើកផ្លូវឲ្យផ្នែកទាហានកំពង់ធំចូលមកដឹកស្បៀង ដោយបញ្ឆោតឲ្យកម្លាំងយោធាស្រុកទៅត្រៀមនៅមាត់ទន្លេពាមបាងទាំងអស់ ដើម្បីចៀសវាងការប៉ះទង្គិចគ្នា ។ ខែកុម្ភៈ ឆ្នាំ១៩៧៣ ធឿន បានទៅទាក់ទងជាមួយឈ្មោះ សង, មល, ហ៊ិន និង ឆន ដើម្បីអនុវត្តផែនការជម្លៀសប្រជាជនចេញពីភូមិដោយមិនឲ្យយកស្រូវបុកអង្ករទៅជាមួយ ។ នៅខែមិថុនា ឆ្នាំ១៩៧៣ ធឿន បំផុសបានកម្លាំងសេ.អ៊ី.អា ចំនួន៧នាក់ទៀត ដោយមានឈ្មោះ ឡើង ជាអ្នកទទួលស្គាល់ ។ កម្លាំងទាំងនេះត្រូវបានដាក់ឲ្យនៅតាមខ្សែត្រៀមសម្រាប់ដើរចល័តចុះឡើងក្នុងបំណងបិទបាំងសកម្មភាពសេ.អ៊ី.អា ។ ចុងឆ្នាំ១៩៧៣ ធឿន បានចូលរួមប្រជុំជាមួយក្រុមសេ.អ៊ី.អាចំនួន២៣នាក់ ដែលមានឈ្មោះ ឡើង ជាប្រធានអង្គប្រជុំដដែល ។ កិច្ចប្រជុំត្រូវបានណែនាំឲ្យក្រុមសេ.អ៊ី.អា ទាំងអស់ត្រូវតែអនុវត្តតាមផែនការ «បំផ្លិចបំផ្លាញសហករណ៍សមូហភាព» ដើម្បីកុំឲ្យប្រជាជនមានជំនឿលើសហករណ៍សមូហភាព ត្រូវចាត់ចែងដឹកនាំធ្វើការងារសមូហភាពកុំឲ្យរីកលូតលាស់បាន ។ របស់របរសមូហភាពត្រូវបំផ្លាញឲ្យអន្តរាយដូចជា គោ រទេះ ចបជាដើម ។

នៅពាក់កណ្តាលឆ្នាំ១៩៧៤ គ្រួសារខាងឪពុកម្តាយក្មេករបស់ ធឿន ត្រូវបំបែកឲ្យទៅរស់នៅតំបន់ឆ្ងាយៗពីគ្នា ដែលកាលនោះរៀបចំដោយឈ្មោះ ឡើង បន្ទាប់ពីមានការរាយការណ៍យ៉ាងលម្អិតពី ធឿន ថាក្រុមគ្រួសារខាងប្រពន្ធគាត់នៅតែមិនចុះសម្រុងគ្នាជាមួយគាត់ក្នុងការរៀបចំផែនការបំផ្លាញអង្គការបដិវត្តន៍ ។ តាមសម្តីរបស់ ឡើង និយាយថា ធ្វើយ៉ាងនេះដើម្បីចៀសវាងភាពអុជអាលមាត់កវែងឆ្ងាយពីបញ្ហាអូសទាញកម្លាំងចូលសេ.អ៊ី.អាជាមួយនឹងប្រជាជនដទៃទៀតដែលនាំឲ្យបែកការណ៍ ។ ចុងឆ្នាំ១៩៧៤ ស៊្រុន បានកាន់តួនាទីជាលេខាស្រុកស្ទោង ។ ពេលនោះ ធឿន ហាក់មានសង្ឃឹមខ្លាំងក្នុងការកសាងកម្លាំងសេ.អ៊ី.អា និងទទួលឥទ្ធិពលខ្លាំងក្នុងការប្រឆាំងអង្គការបដិវត្តន៍ទៀតឡើង ។ ធឿន បានចូលរួមប្រជុំសម្ងាត់ជាមួយ ស៊្រុន និងក្រុមអេ.អ៊ី.អាចំនួន១២នាក់ទៀតនៅមន្ទីរភូមិកោះ ។ កិច្ចប្រជុំបានសម្រេចឲ្យសមាជិកទាំងអស់អនុវត្តឲ្យខុសពីពាក្យស្លោកមួយរបស់ខ្មែរក្រហមថា «ការពាររបបសមូហភាព» ដោយធ្វើយ៉ាងណាឲ្យមានការរឹតបន្តឹងថែមទៀតចំពោះរបបអាហាររបស់ប្រជាជន ។

ចុងខែធ្នូ ឆ្នាំ១៩៧៤ កិច្ចប្រជុំមួយបានកើតឡើងនៅផ្ទះរបស់ ស៊្រុន ឯភូមិកោះ ហើយ ធឿន ក៏បានចូលរួមប្រជុំសម្ងាត់នេះដែរ ដែលកាលណោះមាន ស៊្រុន ជាប្រធានអង្គប្រជុំនិងមាន ឡើង, ស៊ឹម ជាអ្នកចូលរួមប្រជុំផង ។ ផែនការទម្លាយទំនប់ពពកបង្ហូរទឹកចោលជាផែនការថ្មី ហើយត្រូវបានសម្រេចក្នុងអង្គប្រជុំលើកនេះ ។ សម្តីរបស់ ស៊្រុន ត្រូវបាន ធឿន រៀបរាប់នៅក្នុងឯកសារចម្លើយសារភាពរបស់គាត់ថា «ធ្វើយ៉ាងនេះដើម្បីឲ្យប្រជាជនកាន់តែក្តៅក្រហាយថែមមួយកម្រិតទៀតលើអង្គការ» ។ រំលងបានប្រហែលកន្លះខែ គឺនៅពាក់កណ្តាលខែមករា ឆ្នាំ១៩៧៥ កម្លាំងរបស់ ធឿន រួមជាមួយកម្លាំងរបស់ ឡើង និង ស៊ឹម ដែលមានចំនួន២៤នាក់ បានទៅទម្លាយទឹកទំនប់បង្ហូរទឹកដែលត្រៀមស្តុកទុកសម្រាប់ធ្វើស្រែ ចោលអស់ ។

ក្រោយរំដោះទូទាំងប្រទេសខែមេសា ឆ្នាំ១៩៧៥ កម្លាំង

សេ.អ៊ី.អា ទាំងអស់ត្រូវបែងចែកគ្នាទៅនៅតាមសហករណ៍ផ្សេងៗដើម្បីបង្កប់ឲ្យបានយូរអង្វែងក្នុងជួរបក្សកុម្មុយនិស្តកម្ពុជា ។ ចំណែកកម្លាំងរបស់ ធឿន ត្រូវបាន ស្រ៊ុន ណែនាំឲ្យដកប្រជាជនដែលជម្លៀសទាំងប៉ុន្មានពីឃុំដូង បន្ទាយស្រោងនិងពពក ឲ្យចុះមកភូមិឃុំកំណើតវិញ ។ បន្ទាប់មក នៅដើមខែ៧ ឆ្នាំ១៩៧៥ ធឿន ត្រូវបានដកឲ្យធ្វើការនៅសន្តិសុខតំបន់៤៣ ។ ហើយក្រុម សេ.អ៊ី.អា ផ្សេងទៀតក៏ត្រូវដកដូចគ្នាទៅកន្លែងផ្សេងគ្នា ដូចជាខ្លះទៅនៅភ្នំពេញ ខ្លះទៅគ្រប់គ្រងនៅក្នុងក្រសួងមន្ទីរក្នុងតំបន់៤៣ដើម្បីម្ចាស់ការ ។ រយៈពេលនៃការធ្វើការនៅមន្ទីរសន្តិសុខ ធឿន និងបក្ខពួក បានលួចដោះលែងអ្នកទោសអស់៥នាក់ ។ ដើមឆ្នាំ១៩៧៦ ឈ្មោះ ឡើង ត្រូវបានចាត់តាំងឲ្យមកធ្វើការជាអនុប្រធានមន្ទីរសន្តិសុខតំបន់៤៣ ។ នេះជាឱកាសមួយល្អសម្រាប់ខ្សែ សេ.អ៊ី.អារបស់ ធឿន ក្នុងការបង្ករឿងហេតុតទៅទៀត ។ ពាក់កណ្តាលខែមីនា ឆ្នាំ១៩៧៦ ធឿន បានក្លាយជាអនុប្រធានសន្តិសុខតំបន់៤៣ ។ ប៉ុន្តែនៅខែមេសា ធឿន ត្រូវចុះមកជាយុទ្ធជននៅក្រសួងខស្សរាហកម្មតំបន់៤៣វិញ ។ ឡើង បាននិយាយណែនាំ ធឿន ថាឲ្យទ្រាំធ្វើជាយុទ្ធជនសិន ទៅព្រោះនេះជាផែនការបង្កប់ខ្សែសេ.អ៊ី.អា នៅតាមបណ្តាក្រសួងមន្ទីរនិងការងារសំខាន់ៗក្នុងជួររដ្ឋអំណាចបដិវត្ត ។ ភារកិច្ចរបស់ ធឿន តាមដែល ឡើង បញ្ជា គឺធ្វើយ៉ាងណាដឹកជញ្ជូនកីតម្បាញពីរោងចក្រកំពង់ចាមដោយបំផ្លាញធ្វើឲ្យខូច បាក់បែក បាត់ខ្ទេចខ្ទី និងរួមចំណែកធ្វើឲ្យដំណើរការរោងចក្រតម្បាញនេះរាំងស្ទះ ។ ធឿន ត្រូវបានឡើងណែនាំឲ្យស្គាល់ខ្សែសេ.អ៊ី.អា ១១នាក់ទៀតដើម្បីងាយស្រួលធ្វើការ ។ ក្នុងរយៈពេលជិត៣ខែ ធឿន បានបំផ្លាញកីតម្បាញអស់ចំនួន២គ្រឿង និងប្រដាប់ប្រដាជាច្រើនទៀត ។ នៅខែមិថុនា ឆ្នាំ១៩៧៦ ធឿន បានប្តូរការងារទៅកាប់ឈើនៅប្រាសាទសំបូរព្រៃគុហ៍ ។ ភារកិច្ចជាអ្នកកាប់ឈើ ធឿន មិនបានកាប់ឈើល្អៗទេ ។ ខែតុលា ឆ្នាំដដែល ធឿន បានចាត់តាំងឲ្យមកអារឈើនៅស្រោង ។ នៅកន្លែងអារឈើ ធឿន កសាងបានកម្លាំង សេ.អ៊ី.អា ម្នាក់ឈ្មោះ ឃឹម ។ ខែឧសភា ឆ្នាំ១៩៧៧ ក្រសួងបានដក ធឿន មកគ្រប់គ្រងនៅរោងជាងដែកផ្នែកខាងរោងចក្រតម្បាញតំបន់៤៣ ។ ក្នុងខែនេះ ស្រ៊ុន ត្រូវអង្គការចាប់ខ្លួន ។ ឡើង ត្រូវអង្គការដកឲ្យទៅនៅកសិកម្មស្រុកសន្ទុក ។ ខ្សែសេ.អ៊ី.អា ចាប់ផ្តើមរង្គោះរង្គើខ្លាំងទៅៗ ធ្វើឲ្យ ធឿន ពិបាកក្នុងការធ្វើការងារនិងរស់នៅ ។ ក្រោយមក ធឿន បានទៅជួប ពៃ ហើយបើកអង្គប្រជុំសម្ងាត់មួយជាមួយ លឹម និង ពាត់ ដើម្បីចាត់វិធានការក្នុងការកសាងកម្លាំង សេ.អ៊ី.អា តទៅទៀត ។ កម្លាំង សេ.អ៊ី.អា ថ្មីចំនួន៤នាក់ទើបតែបានកសាងឡើងដោយ ធឿន នៅក្នុងរោងជាងដែក ។ ចំណែកឯខាង ពាត់ វិញ បំផុសបានបួននាក់ដែរ ។ ធឿន បានដាក់បញ្ជាដល់កម្លាំងថ្មីនេះធ្វើយ៉ាងណាឲ្យរោងជាងទាំងមូលលែងដំណើរការ ដោយធ្វើឲ្យឆេះឌីណាម៉ូ ដាច់ភ្លើង... ។ ថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៧៧ ធឿន ត្រូវអង្គការចាប់ខ្លួននៅមន្ទីរតំបន់៤៣ បន្ទាប់មក ត្រូវបានបញ្ជូនទៅទាំងគ្រួសារចូលមន្ទីរស-២១ ។ នៅមន្ទីរស-២១ ធឿន មានមុខងារថ្មីគឺជាអ្នកឈូសឈើធ្វើដែនទីនិងក្តារខៀន ។ លើកនេះ ធឿន មិនបានដើរហើរទៅទីណាបានសេរីដូចមុនឡើយ ។ បន្ទាប់មកនៅដើមឆ្នាំ១៩៧៨ ធឿន ត្រូវបានចាត់តាំងឲ្យមកគូរផែនទីវិញ ។ ដោយមានរឿងរ៉ាវអាស្រូវខាងសីលធម៌ជាមួយនារី ហុង ខ្លះៗនោះ ធឿន ត្រូវបានចាប់ខ្លួនម្តងទៀតនៅមន្ទីរស-២១ កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៧៨ ។

រំលងបានប្រហែលជិតមួយខែ ធឿន ត្រូវបានដដឹកសួរចម្លើយដោយក្រុមអ្នកសួរចម្លើយនៅមន្ទីរស-២១ ។ សរុបទៅ ឯកសារចម្លើយសារភាពរបស់ ធឿន បានព្យាយាមរៀបរាប់រហូតដល់ទៅ៤៦ទំព័រ នៃសកម្មភាពបំផ្លាញបដិវត្តន៍របស់ខ្លួនតាំងពីឆ្នាំ១៩៦៨មក រហូតដល់ថ្ងៃចាប់ខ្លួនលើកទី១ ថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៧៧ ។ ក្រោយពីសារភាពនូវទង្វើរបស់ខ្លួនហើយ ធឿន បានឆ្លើយដាក់មនុស្សចំនួន១៥០នាក់ផ្សេងទៀតដែលជាប់ពាក់ព័ន្ធខ្សែសេ.អ៊ី.អាជាមួយផង ។ នៅពីក្រោយឈ្មោះនីមួយៗក្នុងបញ្ជីសុទ្ធតែមានបញ្ជាក់ពីឋានៈនិងមុខងារបច្ចុប្បន្នយ៉ាងច្បាស់ ។ ជាមួយនឹងការចុះហត្ថលេខាសារភាពរបស់ ធឿន បូករួមនឹងស្នាមផ្តិតមេដៃនិងមានបញ្ជាក់កាលបរិច្ឆេទនៅថ្ងៃទី ១៤-៨-៧៨ ក៏មានស្នាមចុះហត្ថលេខាអ្នកសួរចម្លើយឈ្មោះ ណាន ចុះថ្ងៃទី១៤-៨-៧៨ ដែរ ។

**ផេង ពង្សរ៉ាស៊ី**

# វៀតណាមនិងក្រសួងការបរទេសខ្មែរក្រហម

## កំណត់ហេតុឯកសារលេខD ០១៩០២: បញ្ហាព្រំដែនវៀតណាមកម្ពុជា

ថ្ងៃ៣-១១-១៩៧៧ ពីម៉ោង៨ដល់៩ ភារធារីវៀតណាម ត្រឹន ស៊ីន ម៉ិន និងអ្នកបកប្រែ គាវ មិញ មកជួបធ្វើការជាមួយ សមមិត្ត ហុង នៅ ប-១ ។ ក្រោយពីការសាកសួរ សួរសមបន្តិច ក៏ចាប់ផ្តើមធ្វើការ ។

***ភារធារីវៀតណាម:*** យើងខ្ញុំមកនេះដើម្បីប្រគល់លិខិតរបស់ក្រសួងការបរទេសនៃសាធារណរដ្ឋសង្គមវៀតណាម ជូនដល់ក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ ។ (វានិយាយខ្លឹមសារលិខិតនេះ គឺមិនទទួលខ្សែប្រេវីយេជាព្រំដែនសមុទ្រ ហើយស្នើជួបចរចាគ្នា លិខិតនេះចុះថ្ងៃ ២៨-១០-១៩៧៧)

***សមមិត្ត ហុង:*** អរគុណសមមិត្តភារធារីដែលបានខំទ្មេសនាមខ្លឹមសារលិខិតនេះ យើងខ្ញុំនឹងជូនដល់ក្រសួងពិនិត្យ ។ តទៅនេះ យើងខ្ញុំសូមបញ្ជាក់អំពីគោលជំហរយើងខ្ញុំដែលបានបោះពុម្ពផ្សាយ ដែនទីនេះ ។ យើងខ្ញុំក៏បានទទួលដែនទីដែលសមមិត្តប្រគល់មកឲ្យយើងខ្ញុំវិញ ។ សមមិត្តមិនទទួលនេះជាសិទ្ធិរបស់សមមិត្ត ។ បើនិយាយពីមុនមកប្រទេសយើងខ្ញុំត្រូវបាត់បង់ទឹកដីជាច្រើនណាស់ ។ នេះជាលទ្ធផលរបស់អាណានិគមនិយមបារាំងវាបានបែកឲ្យ ។ អ្នកណាក៏ដោយ បើឈរមើលពីកែបទៅ ក៏សុទ្ធតែនិយាយថាកោះត្រល់ជាកោះរបស់កម្ពុជា ។ បើគិតជាប្រវត្តិសាស្ត្រនិងភូមិសាស្ត្រ កោះត្រល់ជាកោះរបស់កម្ពុជា តែយើងមិនគិតទេរឿងចាស់ ព្រោះចៀសវាងប៉ះពាល់ដល់មិត្តភាព យើងខ្ញុំគិតតែបច្ចុប្បន្នកាលនិងទៅអនាគតកាលទេ ។ ឯខ្សែប្រេវីយេធ្លាប់បានប្រើប្រាស់យូរណាស់មកហើយ ។ ពីឆ្នាំ១៩៦៦ ប្រតិភូរណសិរ្សជាតិរំដោះវៀតណាមខាងត្បូងក៏បាននិយាយជាឱឡារិកជាមួយរដ្ឋាភិបាល សីហនុថា ចាត់ទុកខ្សែប្រេវីយេជាព្រំដែនរដ្ឋរវាងប្រទេសទាំងពីរ ។ បញ្ហានេះវាច្បាស់លាស់ហើយ យើងខ្ញុំទទួលយកខ្សែប្រេវីយេនេះក៏ដើម្បីចង់បានមិត្តភាពសាមគ្គីភាពល្អជាមួយវៀតណាមដែរ ។ តែដល់ឥឡូវនេះ វៀតណាមបែរជាមិនទទួលយកខ្សែប្រេវីយេវិញ យើងខ្ញុំក៏លំបាកដែរមិនដឹងវៀតណាមចង់បានមិត្តភាពឬចង់បានអីទេ? ឯយើងមិនអាចថយពីខ្សែប្រេវីយេនេះបានទេ ។ បើវៀតណាមមិនទទួលខ្សែប្រេវីយេទេ យើងខ្ញុំក៏អាចពិនិត្យកោះនិងខេត្តនានានៅវៀតណាមខាងត្បូងវិញដែរ តែបញ្ហានេះយើងខ្ញុំមិនចង់ទេសំខាន់លើការយល់គ្នា ។ បើនិយាយតែខាងសីលធម៌ក៏ឃើញច្បាស់ថា បើវៀតណាមមិនទទួលយកខ្សែប្រេវីយេ ហើយដីចេះតែដុះឡើងៗទៅជិតជាប់កោះ តើយើងខ្ញុំមានផ្លូវឯណាចេញចូលបាន? បញ្ហានេះវៀតណាមគ្មានយោគយល់ដល់យើងខ្ញុំសោះ ។ ទាល់តែមានការយោគយល់គ្នាទើបចរចាគ្នាបានផល ។

អំពីបញ្ហាព្រំដែនៈ ជារៀងរាល់ថ្ងៃ ខាងវៀតណាមបានបាញ់កាំភ្លើងធំមកលើទឹកដីយើងខ្ញុំ ឲ្យកងទ័ពចូលឈ្លានពានរំលោភទឹកដីយើងខ្ញុំ ។ ប្រជាជនយើងខ្ញុំត្រូវរងគ្រោះ និងខូចខាតទ្រព្យសម្បត្តិជាច្រើន ។ ឯដំណឹងថាខាងសមមិត្តចាប់បាន ៤០នាក់ ហើយឆ្លើយថាយើងខ្ញុំចង់ទៅយកព្រៃនគរនោះ តើសមមិត្តអាចជឿបានដែរ? នេះជាដំណឹងញុះញង់គ្មានសមហេតុផល ។ ទាល់តែមានមូលដ្ឋានច្បាស់លាស់ទើបអាចជឿបាន មិនមែនចេះតែជឿៗទៅទេ ។ យើងខ្ញុំគ្មានបំណងអីទៅឈ្លានពានរំលោភទឹកដីវៀតណាមទេ ហើយផ្ទុយមកវិញ ក៏យើងខ្ញុំដាច់ខាតមិនឲ្យវៀតណាមមកឈ្លានពានរំលោភទឹកដីយើងខ្ញុំបានដែរ ។ បញ្ហានេះគួរខាងវៀតណាមពិនិត្យមើលថែមទៀត ឯខាងយើងខ្ញុំ យើងខ្ញុំមានបំណងចង់តែមានមិត្តភាពសាមគ្គីភាពល្អជាមួយវៀតណាមទេ ។ តែយើងខ្ញុំដាច់ខាតការពារទឹកដីយើងខ្ញុំ ។ នេះជាគោលជំហររបស់យើងខ្ញុំយ៉ាងដូច្នេះ ។

***ភារធារីវៀតណាម:*** យើងខ្ញុំសូមមានយោបល់ដូចតទៅៈ

អំពីខ្សែព្រំដែនគោករវាងប្រទេសយើងទាំងពីរមានហើយ ដោយប្រវត្តិសាស្ត្រទុកឲ្យ ។ អម្បាញ់មិញ សមមិត្ត ហុង និយាយដល់ការពិនិត្យកោះនិងខេត្តនានានៅវៀតណាមខាងត្បូង

នេះគឺជួយនឹងពាក្យសមមិត្តថាមិនគិតដល់រឿងចាស់ទេ ។ ឯខ្មែរប្រេវីយេមិនមែនជាខ្សែព្រំដែនទេ វាគ្រាន់តែជាខ្សែចែកការអភិបាលនិងប៉ូលិសនៅលើកោះ ។ ហេតុដូច្នេះបានជាពីខែ៥ ឆ្នាំ១៩៧៦ ប្រតិភូទាំងពីរបានជួបចរចាគ្នាដើម្បីដោះស្រាយបញ្ហានេះ តែកំពុងពិភាក្សាគ្នាមិនទាន់ចប់ផង មិនទាន់សម្រេចព្រំដែនសមុទ្រនេះទេ ។ ម្យ៉ាងទៀត បើខាងសមមិត្តមានការលំបាក ខាងយើងខ្ញុំក៏មានការលំបាកដែរ មើលក្នុងផែនទីគឺឃើញខ្សែប្រេវីយេរត់តួតជិតកោះយើងខ្ញុំណាស់ ។ ទាល់តែមានអ្នកមានឋានៈជួបចរចាគ្នាដោយមានផែនទីច្បាស់លាស់កំណត់សម្រេចជាមួយគ្នាទើបបាន ។ ឯយើងអង្គុយនៅទីនេះមិនអាចសម្រេចបានទេ ។ ហើយយើងខ្ញុំមកនេះគ្រាន់តែដើម្បីបញ្ជាក់អំពីគោលជំហរយើងខ្ញុំចំពោះព្រំដែនសមុទ្រ ព្រោះការប្រជុំគ្នាពីខែ៥ ឆ្នាំ១៩៧៦ មិនទាន់សម្រេចទេ ។ ចំណែកគោលជំហររបស់បក្ស យើងខ្ញុំច្បាស់លាស់ដូចបានចែងក្នុងសេចក្តីសម្រេចចិត្តនៃមហាសន្និបាតលើកទី៤ គឺរក្សាមិត្តភាពសាមគ្គីភាព...។ ចំពោះបញ្ហាព្រំដែន ទោះបីមានការលំបាកស្មុគស្មាញក៏យើងខ្ញុំឈរលើគោលជំហរខាងលើដើម្បីដោះស្រាយ ។ យើងខ្ញុំគ្មានបំណងចង់បានទឹកដីកម្ពុជាទេ ។ ឯសមមិត្តហុង ថាទាល់តែមានការយល់គ្នាទើបជួបគ្នាបានផល ។ យើងខ្ញុំយល់ថាបើមិនជួបគ្នា មិនអាចយល់គ្នាទេ ជួបគ្នាទើបយល់គ្នាបណ្តើរៗ ។

ឯបញ្ហាដែលសមមិត្ត ហុង ថា ខាងយើងខ្ញុំបាញ់កាំភ្លើងធំនិងមានការរំលោភទៅលើទឹកដីកម្ពុជានោះ គឺវាឃ្លាតឆ្ងាយពីគោលជំហរយើងខ្ញុំណាស់ តែមានករណីខ្វះបង្ខំឲ្យយើងខ្ញុំការពារខ្លួន ហើយយើងខ្ញុំយល់ថាការពារទឹកដីបាន ទើបការពារសាមគ្គីភាពមិត្តភាពបាន ។

សរុបមក យើងខ្ញុំចង់ដោះស្រាយជាក់ស្តែង ហើយមានជំនឿថាដោះស្រាយបាន ។

***សមមិត្ត ហុង៖*** យើងខ្ញុំក៏មានគោលជំហរចង់ដោះស្រាយបញ្ហាដែរ ។ យើងខ្ញុំយល់ថា ឲ្យតែគ្មានគំនិតរំលោភឈ្លានពានវាតទីលេបទឹកដីកម្ពុជា ហើយមានការយល់គ្នា គឺអាចដោះស្រាយបាន ។ ឯខ្សែប្រេវីយេធ្លាប់បានអនុវត្តជាយូរណាស់មកហើយជិត៤០ឆ្នាំហើយ ។ ហើយពីឆ្នាំ១៩៦៦ រណសិរ្សជាតិរំដោះវៀតណាមខាងត្បូងក៏បានចាត់ទុកជាខ្សែព្រំដែនរដ្ឋដែរ ។ បញ្ហានេះគួរណាស់តែវៀតណាមយល់ បើទទួលខ្សែប្រេវីយេនេះជាព្រំដែនរដ្ឋ អាចដោះស្រាយបញ្ហាឯទៀតក៏បាន ។ ជាភូមិសាស្រ្ត ជាប្រវត្តិសាស្រ្ត វាច្បាស់លាស់ណាស់ទៅហើយ ។ បើវៀតណាមមិនទទួលយើងខ្ញុំក៏លំបាកដែរ ។ យើងខ្ញុំដាច់ខាតមិនថយពីខ្សែនេះបានទេ ។

ឯបញ្ហាសិទ្ធិការពារ យើងខ្ញុំមិនថាអីទេ តែជាក់ស្តែងនៅលើសមរភូមិប្រជាជនយើងខ្ញុំត្រូវទទួលការខូចខាតច្រើនណាស់ ។ ការប្រចួតកាត់ក៏មានការលំបាក ដោយសារខាងវៀតណាមរំលោភវាតទីមកលើទឹកដីយើងខ្ញុំ ។ សភាពការណ៍ក្តៅណាស់មិនអាចចរចាគ្នាបានទេ ទាល់តែទុកឲ្យសភាពការណ៍ត្រជាក់សិនទើបជួបចរចាគ្នាបានផល ។ ម្យ៉ាងទៀត យើងខ្ញុំទទួលបានពត៌មានពីហាណូយថា មានការនិយាយអាក្រក់ពីកម្ពុជាច្រើនណាស់ ។ នៅប៉ារីសក៏យើងខ្ញុំបានដឹងអ្នកដើរអុជអាលឲ្យពួកបារាំងដើរនិយាយមួលបង្កាច់ពីសិទ្ធិមនុស្សនៅកម្ពុជា ។ អំពើទាំងនេះសុទ្ធតែមានបំណងចាក់រុកបង្ករឿងបំផ្លាញមិត្តភាពរវាងប្រទេសទាំងពីរ ។ ឯខាងយើងខ្ញុំវិញ មិនដែលដើរនិយាយអីអាក្រក់ពីវៀតណាមទេ និយាយតែពីការទាក់ទងល្អ ។

***ការធារី វៀតណាម៖*** អំពីការថាយើងខ្ញុំទៅវាតទីឈ្លានពាននោះ យើងខ្ញុំបានបដិសេធជាច្រើនលើកហើយ តែផ្ទុយទៅវិញទេ គឺខាងកម្ពុជាទៅរំលោភឈ្លានពាន...(វារំឭកពត៌មានវាពីលើកមុន) ។ ឯបញ្ហាចាក់រុកអុជអាល យើងខ្ញុំគ្មានទេ ។ ការនិយាយអាក្រក់ពីកម្ពុជាក៏យើងខ្ញុំគ្មានដែរ យើងខ្ញុំមិនអាចទទួលខុសត្រូវចំពោះពួកចក្រពត្តិវាដើរនិយាយអាក្រក់ពីកម្ពុជាទេ ។ ចំពោះយើងខ្ញុំ ក៏វានិយាយអាក្រក់ដែរ ។

***សមមិត្ត ហុង៖*** តែយោគយល់គ្នា មិនរំលោភឈ្លានពានលេបទឹកដីគ្នា អាចដោះស្រាយបាន ។

***ការធារី វៀតណាម៖*** យោគយល់គ្នា ហើយមានការជួបគ្នាអាចដោះស្រាយបាន ។

*(សម្គាល់៖ វាមិនហ៊ានរំឭកដល់ពាក្យរណសិរ្សខាងត្បូងទទួលស្គាល់ខ្សែប្រេវីយេជាព្រំដែនរដ្ឋទេ)* ។

# សេចក្តីថ្លែងការណ៍របស់បក្សកុម្មុយនិស្តកម្ពុជាចំពោះបក្សពលករដាណឺម៉ាក

## ខែកក្កដា ឆ្នាំ១៩៧៨

**(តពីលេខមុន)** យើងត្រូវតែកំណត់មាគ៌ារបស់យើងដោយឈរលើមូលដ្ឋាននៃទំនាស់របស់យើងផ្ទាល់ ។ សភាពការណ៍អំណោយផលដល់ការតស៊ូប្រដាប់អាវុធ ។ ពីព្រោះបក្សរបស់យើងបានរួបរួមតាមគោលការណ៍នេះនិងមាគ៌ានេះ ហើយប្រជាជនយើងគាំទ្របដិវត្តន៍អស់ពីចិត្តពីថ្លើម ។ ការបះបោរប្រឆាំងនឹងវណ្ណៈកាន់អំណាចចាប់ផ្តើមឡើងនៅក្នុងខេត្ត១៧ក្នុងចំណោមខេត្តទាំង១៩ ។ យើងគ្មានអាវុធអ្វីទាំងអស់ ហើយជំនួយមកពីក្រៅក៏គ្មានដែរ ។ យើងមានតែកាំភ្លើងដៃការ៉ាប៊ីនពីរបីដើមដែលរឹបអូសពីខ្មាំង ។ ជួនកាលនៅពេលយើងអស់គ្រាប់បាញ់ យើងចេះតែស្ពាយកាំភ្លើងនេះគ្រាន់តែកម្លាចខ្មាំងតែប៉ុណ្ណោះ ។ ជាបណ្តើរៗ យើងអាចពង្រីកកម្លាំងរបស់យើង ពីព្រោះយើងដើរតាមមាគ៌ាសង្គ្រាមប្រជាជនរបស់បក្ស ។

### II. ការតស៊ូប្រដាប់អាវុធឆ្នាំ១៩៦៨-៧៥

ប្រជាជនបានផ្តល់ការគាំទ្រចំពោះយើងដោយខំលាក់បាយទុកឲ្យ លាក់កម្លាំងឈ្លប និងកម្មាភិបាលរបស់យើង ។ ការណ៍នេះបានបង្រៀនកម្មាភិបាលរបស់យើងឲ្យមានការប្រុងប្រយ័ត្នដើរតាមមាគ៌ាបក្សក្នុងការរួបរួមជាមួយមហាជននិងផ្អែកលើមហាជន ។ កាលនោះកងទ័ពយើងមិនធំណាស់ណាទេ ។ កងទ័ពនេះបានប្រើព្រួញស្នាក្នុងការប្រយុទ្ធ ជាពិសេសនៅតាមមូលដ្ឋាននៅភាគឦសាន ។ យើងបានធ្វើឲ្យប្រជាជនទុកចិត្តជឿជាក់មកលើយើងដោយបង្ហាញប្រជាជនទាំងនោះថាអាវុធបុរាណទាំងនេះអាចសម្លាប់សត្រូវបាន ។ ប្រជាជនកាលនោះជឿលើមាគ៌ារបស់បក្សនិងបដិវត្តន៍ ។ ខ្មាំងបានប្រើប្រាស់អាវុធគ្រប់ធុនជាពិសេសនៅភូមិភាគឦសានដែលជាមូលដ្ឋានរបស់គណៈមជ្ឈិមរបស់យើង ។ ប៉ុន្តែតំបន់នេះរឹងមាំណាស់ ។ ខ្មាំងមិនអាចធ្វើអ្វីយើងបានឡើយ ។ ប៉ុន្តែកាលនោះ បដិវត្តន៍វៀតណាមកំពុងតែមានបញ្ហាដោយសារខ្មាំងបានកសាងភូមិយុទ្ធសាស្ត្រនានានៅវៀតណាមខាងត្បូង ។ ដោយគ្មានដីសម្រាប់គេចខ្លួន វៀតណាមក៏សុំដីយើងស្នាក់នៅយើងក៏ផ្តល់ឲ្យទៅ ។ ការនេះនាំដល់រដ្ឋប្រហារកាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ របស់សហរដ្ឋអាមេរិក ។

អាមេរិកខិតខំរកវិធីបំផ្លាញបដិវត្តន៍យើង ប៉ុន្តែដោយសារយើងខ្លាំង យើងក៏ចាប់ផ្តើមកសាងអំណាចក្នុងរដ្ឋរបស់យើងនៅក្នុងតំបន់រំដោះ ។ យើងបានទទួលជោគជ័យភ្លាមៗនៅលើផ្ទៃដី៧០ភាគរយនៃជនបទ ។ ប្រសិនបើអាមេរិកមិនបានឈ្លានពានទេនោះ ម៉្លេះយើងអាចរំដោះប្រទេសទាំងមូលបានចប់សព្វគ្រប់នៅត្រឹមខែមិថុនា ឆ្នាំ១៩៧០ ។ នៅឆ្នាំ១៩៦៧-៦៨ មានមនុស្សជាច្រើននិយាយថាយើងឆ្វេងនិយមជ្រុល ។ នៅក្នុងឆ្នាំ១៩៧០ ម្នាក់ៗយល់ស្របថាយើងមានជំហរត្រឹមត្រូវ ។ ម្នាក់ៗក៏ដើរតាមយើង ។ ប្រទេសសង្គមនិយមនិងប្រទេសផ្សេងទៀតនៅទូទាំងពិភពលោកបានគាំទ្រយើង ដោយជួយយើងឲ្យបន្តកិច្ចការសេដ្ឋកិច្ច យោធា និងកិច្ចការអន្តរជាតិ ល្អប្រសើរជាងមុន ។ ប៉ុន្តែខ្ញុំសូមបញ្ជាក់ថា ទោះបីជាមានលក្ខណៈអំណោយផលយ៉ាងនេះក្តី ក៏យើងនៅតែរក្សាការសម្ងាត់នៃអត្តិភាពរបស់បក្សយើង ហើយយើងបន្តកសាងដោយផ្អែកលើការតស៊ូសម្ងាត់ជាមូលដ្ឋានយុទ្ធសាស្ត្រ ។ យើងបានឈានដល់ម្ចាស់ការលើស្ថានការណ៍ ពីព្រោះយើងមានមូលដ្ឋានរបស់យើងនៅតាមជនបទ ហើយយើងមានកម្លាំងពីរណសិរ្សរួបរួមជាតិ ។


នួន ជា

ដំបូងយើងមិនបានសង្កេតទៅលើទំនាស់របស់យើងជាមួយវៀតណាមទេ ។ និយាយដោយត្រង់ទៅយើងគិតថាវៀតណាមគឺជាមិត្តរបស់យើង ។ ប៉ុន្តែដុយ

ទៅវិញ វៀតណាមមិនត្រឹមតែមិនបានជួយយើងទេ តែថែមទាំងមកឆក់យកកម្លាំង កសាងកម្លាំងខ្លួនឯង និងក្តាប់បក្សរបស់យើងទាំងមូលទៀតផង ។ មានការលំបាកច្រើនដំពូកណាស់ ។ យើងត្រូវតែវាយកងកម្លាំងធំរឹតរបស់អាមេរិកដែលត្រូវបានបញ្ជូនមកជួយ លន់ ណុល ហើយនៅពេលទន្ទឹមគ្នានេះ វៀតណាមបានព្យាយាមចាក់យើងពីក្រោយខ្នង ។ ពិតណាស់ បក្សរបស់យើងបានសម្រេចចិត្តដោះស្រាយទំនាស់ធំៗជាមុន ពោលគឺត្រូវយកជ័យជម្នះលើ លន់ ណុល ។

មកដល់ឆ្នាំ១៩៧៣ ទំនាស់រវាងយើងនិងវៀតណាមកាន់តែជ្រាលជ្រៅទៅៗ នៅពេលដែលវៀតណាមរួមគ្នាជាមួយអាមេរិកនៅលើតុចរចា ។ រំពេចនោះ អាមេរិកក៏ដាក់លក្ខខណ្ឌឲ្យវៀតណាមគាបសង្កត់កម្ពុជាឲ្យចូលរួមក្នុងតុចរចា ។ វៀតណាមបានព្យាយាមម្តងហើយម្តងទៀត តែយើងមិនព្រម ។ ពេលនោះវៀតណាមចាប់ផ្តើមបំផ្លាញបដិវត្តន៍យើងដោយរិះរកគ្រប់មធ្យោបាយដែលអាចធ្វើទៅបាន ។ នៅក្នុងខណៈនោះដែរ ដោយវៀតណាមនិងឡាវទម្លាក់អាវុធចុះចាញ់ អាមេរិកបានប្រមូលផ្តុំកម្លាំងរបស់វាទាំងអស់មកទម្លាក់គ្រាប់បែកមកលើទឹកដីកម្ពុជា ពោលគឺកម្លាំងរបស់វាទាំងអស់ដែលស្ថិតនៅភូមិភាគអាស៊ី-អគ្នេយ៍ ។ អាមេរិកទម្លាក់គ្រាប់បែកចំនួន២០០ថ្ងៃ និង២០០យប់ដើម្បីបង្ខំឲ្យយើងចូលតុចរចា ។ បក្សរបស់យើងប្រឆាំងដាច់ខាតមិនលុតជង្គង់ចុះចាញ់អាមេរិកឡើយ ។ បើយើងចុះចាញ់នោះ ម៉េះពួកក្បត់ លន់ ណុល នៅភ្នំពេញប្រហែលជាមានពេលកសាងកម្លាំងរបស់ខ្លួនបាត់ទៅហើយ ។ យើងក៏សម្រេចចិត្តតស៊ូលុះដល់ទីបញ្ចប់ ។ ទោះជាយើងនៅក្នុងករណីណាក៏ដោយ ក៏យើងអាចទប់ទល់នឹងសង្គ្រាមអាកាសរបស់អាមេរិក បានធ្វើឲ្យអាមេរិកបរាជ័យ ហើយការជឿទុកចិត្តក៏កាន់តែកើនឡើងនៅក្នុងជួរបក្ស ។ ប្រជាជនកាន់តែច្រើនឡើងៗមានការជឿជាក់ថាមាគ៌ាបក្សយើងគឺត្រឹមត្រូវ ។ ខ្ញុំហ៊ាននិយាយថាការភ្ញាក់រឭកចំពោះមាគ៌ាបក្សមិនមែនបានមកដោយភ្លាមៗ ឬតាមការសិក្សាផ្នែកទ្រឹស្តីនោះទេ ។ វារីកចម្រើនដោយសារបទពិសោធន៍និងការឈឺចាប់របស់ប្រជាជន និងកំហឹងវណ្ណៈ ។ គឺមានតែតាមរយៈការអនុវត្តជាក់ស្តែងទេ ទើបការយល់ដឹងលើមាគ៌ារបស់បក្សកាន់តែជ្រាលជ្រៅឡើងៗ ។

នៅឆ្នាំ១៩៧៤ ជាឆ្នាំក្រោយពីមានសង្គ្រាមអាកាស បក្សយើងបានសម្រេចចិត្តធ្វើការវាយលុកក្នុងទ្រង់ទ្រាយធំចុងក្រោយដើម្បីរំដោះទីក្រុងភ្នំពេញ និងប្រទេសទាំងមូលនៅក្នុងរដូវប្រាំងឆ្នាំ១៩៧៥ ។ វៀតណាមត្រូវបានជម្រាបអំពីបញ្ហានេះ ។ វៀតណាមជឿថាអាមេរិកនឹងមិនឲ្យយើងឈ្នះទេ ។ មិនតែប៉ុណ្ណោះគេមិនត្រៀមឲ្យយើងឈ្នះមុនទេ ។ ជាលទ្ធផល វៀតណាមបានបដិសេធមិនព្រមដឹកអាវុធគ្រាប់រំសេវផ្តើមកពីចិននិងមកពីប្រទេសផ្សេងៗទៀត ប៉ុន្តែពិសេសបំផុតគឺមកពីប្រទេសចិនតែម្តង ។ យើងត្រូវបង្ខំចិត្តប្រើប្រាស់គ្រាប់រំសេវចាប់បានពីខ្មាំង ។ យើងមិនបានទទួលអ្វីមកពីវៀតណាមទេ ។ វៀតណាមប្រឆាំងជោគជ័យរបស់យើង ពីព្រោះវៀតណាមចង់រំដោះទីក្រុងសៃហ្គុន ហើយបញ្ជូនទ័ពរបស់ខ្លួនមករំដោះទីក្រុងភ្នំពេញ ដើម្បីកសាងអង្គការចាត់តាំងនយោបាយនៅទីនេះ រួចហើយបង្កើតបក្សថ្មីមួយដោយកំចាត់ចោលនូវបក្សកុម្មុយនិស្តកម្ពុជា ព្រមទាំងបង្កើតសហព័ន្ធឥណ្ឌូចិន ។

ទោះបីជួបបញ្ហាលំបាកយ៉ាងនេះក៏ដោយ ក៏បក្សយើងខិតខំពុះពារនិងរំដោះភ្នំពេញទាល់តែបាននៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គឺពីរសប្តាហ៍មុនពេលរំដោះទីក្រុងសៃហ្គុន ។ នៅពេលដែលយើងបានរំដោះប្រទេសទាំងមូល និងធានាបាននូវឯករាជ្យភាពនិងអធិបតេយ្យភាពរួចរាល់ហើយ ពោលគឺនៅខែមិថុនា ឆ្នាំ១៩៧៥ វៀតណាមបានបញ្ជូនកងទ័ពរបស់ខ្លួនមកកាន់កាប់ទឹកដីយើង គឺកោះវៃ ។ យើងការពារបានហើយវាយរុញច្រានឲ្យវៀតណាមដកថយទៅវិញ ។ អ្វីដែលយើងចង់បញ្ជាក់លោកឲ្យបានច្បាស់គឺថា នៅក្នុងអំឡុងបដិវត្តប្រជាជាតិប្រជាធិបតេយ្យ មានការតស៊ូលំបាកស្មុគស្មាញណាស់ ដោយមានការលំបាកជាមួយនឹងសហភាពសូវៀតនិងវៀតណាម ប៉ុន្តែចុងក្រោយ យើងអាចពុះពារជម្នះបាន ហើយបានទទួលជោគជ័យ ។

***សំណួរ៖ តើនៅពេលបង្កើតបក្សកុម្មុយនិស្តមានការជជែកពិភាក្សាអំពីមាគ៌ានយោបាយសម្រាប់អំឡុងពេលឆ្ពោះទៅកុម្មុយនិស្តនិយមដែរឬទេ?***

នៅក្នុងកម្មវិធីរបស់បក្សយើងមានសរសេរថាយើងនឹងបន្តបដិវត្តសង្គមនិយម និងឈានទៅរកកុម្មុយនិស្តនិយមក្រោយពីបដិវត្តប្រជាជាតិប្រជាធិបតេយ្យ ប៉ុន្តែយើងមិនបាននិយាយលម្អិតទេ ។ យើងដោះស្រាយការងារកសាងសង្គមនិយមក្រោយពីរំដោះ ។

ការងារសំខាន់របស់យើងគឺការពារអំណាចរដ្ឋ និងបន្តបដិវត្តសង្គមនិយមនិងកសាងសង្គមនិយម ។ យើងបានការពារទឹកដីនិងអធិបតេយ្យភាពចាប់តាំងពីថ្ងៃរំដោះ ដោយតស៊ូស្រួចស្រាល់និងស្មុគស្មាញ ជាពិសេសប្រឆាំងនឹងវៀតណាម ។ យើងគិតថាការតស៊ូនេះនឹងមានទៅមុខទៀតដ៏យូរអង្វែង ពីព្រោះវៀតណាមមានមហិច្ឆតាធំណាស់ ។ វៀតណាមចង់បង្ខំឲ្យកម្ពុជាចូលក្នុងសហព័ន្ធឥណ្ឌូចិន ហើយបន្តមហិច្ឆតាវាតទីនិយមនៅក្នុងភូមិភាគអាស៊ី-អគ្នេយ៍ទាំងមូល ។

ចំពោះបញ្ហាជីវភាពរស់នៅវិញ យើងបានដោះស្រាយបានជាមូលដ្ឋានហើយចំពោះបញ្ហាការបញ្ចេញបញ្ចូលទឹកស្រែ ។ សព្វថ្ងៃនេះយើងកំពុងតែបង្កើនធនធានសម្រាប់ការអភិវឌ្ឍប្រទេសដោយផ្អែកលើមូលដ្ឋានឯករាជ្យស្វ័យម្ចាស់ការ ។

## III. អំពីការកសាងសតិអារម្មណ៍បក្ស

ការមានមាគ៌ានយោបាយត្រឹមត្រូវមិនទាន់ជាការគ្រប់គ្រាន់នៅឡើយទេក្នុងការទទួលជ័យជម្នះ ។ បក្សរបស់យើងត្រូវមានជំហរបដិវត្តន៍រឹងប៉ឹងជាច់ខាតទៀត ។ នេះមួយផ្នែកមកពីការតស៊ូរបស់យើងភាគច្រើនមិនមានលក្ខណៈស្របច្បាប់ ។ ដូចនេះជួនកាលប្រសិនបើកម្មាភិបាលរបស់យើងមានសតិអារម្មណ៍មិនត្រឹមត្រូវចុះចូលជាមួយខ្មាំងឬត្រូវចាប់ខ្លួន ពេលនោះគេនឹងនិយាយការសម្ងាត់អស់ ។ ដើម្បីចៀសវាងកុំឲ្យមានករណីនេះកើតឡើង យើងបានសង្កត់ធ្ងន់ទៅលើការអប់រំសតិអារម្មណ៍ ។

នៅអំឡុងពេលនៃការតស៊ូ យើងបានជួបប្រទះនូវការលំបាកជាច្រើន ។ ឧទាហរណ៍ដូចជា កម្មាភិបាលមួយចំនួនបានបែកពីគ្រួសារនិងមិនមានគោលជំហរសតិអារម្មណ៍រឹងប៉ឹង ជួនកាលក៏សម្រេចចិត្តរត់ទៅរស់ជាមួយគ្រួសារវិញ និងរត់ចេញពីជួរបដិវត្តន៍ ។ ហើយនៅពេលខ្លះទៀត កម្មាភិបាលធ្វើការងារជាលក្ខណៈបង្កប់ជាមួយនឹងក្បាលម៉ាស៊ីនដឹកនាំខ្មាំង និងទទួលបានប្រាក់ខែយ៉ាងច្រើនទៀតផង ។ ដោយខ្វះជំហរបដិវត្តន៍រឹងប៉ឹង ខ្មាំងអាចទិញខ្លួនបាន ។ ដូច្នេះបក្សយើងមើលឃើញថាសតិអារម្មណ៍ពិតជាកត្តាសំខាន់ក្នុងការអនុវត្តមាគ៌ានយោបាយក៏ដូចជាមាគ៌ាចាត់តាំង ។ ការកសាងបក្សផ្នែកសតិអារម្មណ៍មានពីរយ៉ាង គឺបំផ្លាញជំហរបក្សមិនត្រឹមត្រូវ និងកសាងជំហរបក្សត្រឹមត្រូវ ។

១) កសាងជំហរសតិអារម្មណ៍វណ្ណៈជាមូលដ្ឋាននៅក្នុងបក្សពោលគឺសតិអារម្មណ៍វណ្ណៈកម្មករ ។ ដើម្បីធ្វើរបៀបនេះ យើងត្រូវកំណត់ពីវណ្ណៈផ្សេងៗគ្នានៅក្នុងសង្គមរបស់យើងនិងទំនាស់រវាងវណ្ណៈទាំងនោះ ។ តាមរយៈមូលដ្ឋាននេះ យើងបានបំពាក់ផ្នែកសតិអារម្មណ៍លើកម្មាភិបាលយើងនូវជំហរវណ្ណៈកម្មករ ។ កិច្ចការនេះត្រូវបានធ្វើឡើងដោយការពន្យល់អំពីស្មារតីលះបង់ដើម្បីផលប្រយោជន៍រួម និងតម្រូវការចាំបាច់ក្នុងការបោះបង់ចោលនូវកម្មសិទ្ធឯកជន ហើយឈានចាប់យកកម្មសិទ្ធិសមូហភាពនិងការស្រលាញ់ចំពោះកិច្ចការរបស់បក្ស វិធីសាស្ត្រស្វ័យទិតៀននិងមធ្យោបាយនានាក្នុងការរួមយ៉ាងជិតស្និទ្ធជាមួយនឹងមហាជន ។

២) កសាងគោលជំហរសតិអារម្មណ៍បដិវត្តន៍ស្នេហាជាតិនិងអន្តរជាតិ ។ ជំហរទីមួយមានសារសំខាន់ណាស់ ។ យើងចង់និយាយថា ប្រយុទ្ធអស់កម្លាំងកាយដើម្បីធ្វើបដិវត្តន៍ យើងទទួលជោគជ័យលើចក្រពត្តិនិយមនិងពួកសើរើនិយមនៅក្នុងប្រទេសយើង ។ ការនេះនឹងធ្វើដំណើរឆ្ពោះទៅមុខនិងគាំទ្រការតស៊ូអន្តរជាតិ ។ បើចេះតែនិយាយអន្តរជាតិនិយមដោយមិនធ្វើបដិវត្តន៍នៅក្នុងប្រទេសខ្លួនទេនោះ វាគ្មានន័យអ្វីទាំងអស់ ។ យើងត្រូវតែច្បាស់លាស់អំពីរឿងនេះ ។ យើងព្យាយាមបង្រៀនប្រជាជនយើងអំពីគោលការណ៍ស្វ័យម្ចាស់ការ ដើម្បីកុំឲ្យខ្លួនយើងក្លាយជាបន្ទុកលំបាកដល់ប្រទេសជាមិត្ត ។ នៅពេលដែលគេចង់ជួយយើង គេត្រូវធ្វើបដិវត្តន៍របស់គេ ហើយដោះស្រាយបញ្ហាជីវភាពជូនប្រជាជនគេ ។ ដូចនេះយើងព្យាយាមតាមតែអាចធ្វើទៅបានក្នុងការចៀសវាងជំនួយមកពីខាងក្រៅ ពុះពារការលំបាកគ្រប់បែបយ៉ាងដោយគ្មានរកជំនួយ ទាល់តែចាំបាច់ខ្លាំងមែនទែនទើបរកជំនួយ ។ មួយផ្នែកយើងខំចៀសវាងកុំឲ្យជាតិនិយមជ្រុលពេក ហើយមួយផ្នែកទៀតចៀសវាងកុំឲ្យអន្តរជាតិនិយមជ្រុលពេក ។

៣) កសាងគោលជំហរសតិអារម្មណ៍ ថែរក្សាគោលជំហរ ក្នុងបដិវត្ត ជាពិសេសបំណងប្រាថ្នាចង់ធ្វើជាប្រជាជនសាមញ្ញ ពិសេសប្រជាកសិករក្រីក្រ ។ ហេតុនេះហើយទើបកម្មាភិបាលបក្សនិងយុវជន-យុវនារីរបស់យើងនៅក្នុងជួរកងទ័ពមិនទទួលប្រាក់បំណាច់ ។ អ្នកទាំងនេះត្រូវបានប្រាប់ឲ្យបម្រើបក្ស និងទទួលតែពីបក្សប៉ុណ្ណោះ ។ តាមវិធីនេះយើងចៀសវាងការបង្កើតវណ្ណៈដឹកនាំថ្មីមួយទៀតផ្សេងពីប្រជាជន ។

៤) កសាងទស្សនៈមហាជននិងមាគ៌ាមហាជន ពោលគឺមានជំនឿទាំងស្រុងទៅលើមហាជន និងរស់នៅជាមួយមហាជន ជាពិសេសប្រជាកសិករក្រីក្រ ។ មានតែធ្វើយ៉ាងនេះទេ ទើបបដិវត្តន៍យកជ័យជម្នះនិងកសាងកម្លាំងបាន ។ យើងសង្កត់ធ្ងន់ចំណុចនេះចំពោះកម្មាភិបាលពីព្រោះមានកម្មាភិបាលមួយចំនួនមានធាតុដើមជាវណ្ណៈអនុធន ជាពិសេសអ្នកចេះដឹងដែលខ្វះការជឿជាក់ចំពោះមហាជន ជាពិសេសប្រជាកសិករក្រីក្រ ។ យើងព្យាយាមធ្វើឲ្យគេជឿថាប្រជាជនក្រីក្រអាចធ្វើអ្វីៗបានគ្រប់យ៉ាងទាំងអស់ ។ ប្រជាជនក្រីក្របានធ្វើឲ្យខ្មាំងបរាជ័យ ធ្វើការផលិតបង្កបង្កើនផលនិងអ្វីៗផ្សេងៗទៀតគ្រប់យ៉ាង ។ ពីព្រោះតែប្រជាជនទាំងនេះធ្វើអ្វីៗគ្រប់យ៉ាងដូចនេះហើយបានជាយើងបម្រើគាត់ ។

៥) កម្មាភិបាលក៏ត្រូវបានពន្យល់អំពីការប្រុងប្រយ័ត្នបដិវត្តដែរ ពោលគឺយកចិត្តទុកដាក់ប្រុងប្រយ័ត្នចំពោះខ្មាំង ។

៦) យើងបំពាក់កម្មាភិបាលនូវការយល់ដឹងអំពីសម្ភារនិយមបដិច្ចសមុប្បាទដើម្បីឲ្យកម្មាភិបាលអាចវិភាគបញ្ហាផ្សេងៗជ្រាបអំពីគោលជំហរសតិអារម្មណ៍បក្ស ។

គោលជំហរសតិអារម្មណ៍ទាំងនេះត្រូវបានផ្សព្វផ្សាយឃោសនានៅតាមសាខានិងអង្គការបក្ស ។ ការងារនេះមិនមែនធ្វើឡើងដោយគ្រាន់តែអានឯកសារនោះទេ តែដោយការវិភាគសកម្មភាពប្រចាំថ្ងៃ កំណត់ថាអ្វីដែលធ្វើខុស និងអ្វីដែលជាចំណុចខ្វះខាតដែលត្រូវកែប្រែ ។

ចំពោះសៀវភៅរបស់យើងមានតែពីរបីទំព័រតែប៉ុណ្ណោះព្រោះឯកសារសង្ខេបមានលក្ខណៈសមស្របជាងសម្រាប់ប្រជាកសិករក្រីក្រ ។ យើងនៅមានវគ្គសិក្សាមួយចំនួនទៀតដែលភាគច្រើនជាវគ្គខ្លីៗសម្រាប់ក្រុមតូចៗ ។ ចំពោះកិច្ចការបង្កប់គឺមួយវគ្គមានតែមនុស្សពីរទៅបីនាក់តែប៉ុណ្ណោះដែលត្រូវបានរៀបចំឡើងមួយដង ឬពីរដងក្នុងមួយខែ ។ ហើយមានវគ្គមួយចំនួនទៀតរៀបចំឡើងពីរដងក្នុងមួយឆ្នាំ ។ នៅក្នុងវគ្គនោះសមាជិកបក្សត្រូវបានខទ្ទេសនាមជូនអំពីទស្សនៈបដិវត្តន៍និងអប់រំអំពីមាគ៌ានយោបាយ សតិអារម្មណ៍ និងចាត់តាំង ។

សូម្បីតែឥឡូវក្រោយពីថ្ងៃរំដោះយើងជឿថា កត្តាសតិអារម្មណ៍គឺជាកត្តាកំណត់សំខាន់ណាស់ ។ នៅក្នុងការអប់រំកម្មា-ភិបាលយើងសង្កត់ធ្ងន់ទៅលើការកម្ទេចគោលជំហររបបសង្គមចាស់ដែលនៅមានឥទ្ធិពលនៅឡើយ ។ នៅក្នុងចំណោមកម្មាភិបាលដឹកនាំយើងក៏សង្កត់ធ្ងន់ទៅលើការការពារនិងកសាងសតិអារម្មណ៍វណ្ណៈកម្មករ ។ ការណ៍នេះគឺធ្វើឡើងដើម្បីចៀសវាងសេរីនិយម ។ នៅពេលបក្សក្លាយទៅជាអ្នសេរីនិយម គឺមិនមែនដោយសារសមាជិកសាមញ្ញក្លាយជាអ្នកសេរីនិយមនោះទេ តែផ្ទុយទៅវិញថ្នាក់ដឹកនាំទេដែលនាំបក្សទៅកាន់សេរីនិយម ។ យើងមិនសូវនិយាយច្រើនពីបញ្ហាសេរីនិយមនៅក្រៅជួរបក្សមែន តែនៅក្នុងជួរបក្សយើងបានប្រយុទ្ធប្រឆាំងយ៉ាងខ្លាំងប្រឆាំងនឹងសេរីនិយមនេះ ។ មួយផ្នែកគឺដោយសារមូលហេតុនេះហើយ បានជាយើងចៀសវាងបានមិនប្រើឯកសារអ្នកផ្សេង ។ យើងផ្អែកមួយភាគធំទៅលើការវាយតម្លៃការតស៊ូវណ្ណៈ ។ នេះជាការច្បាស់លាស់ណាស់ ។ កម្មាភិបាលយើងមួយចំនួនដែលធ្លាប់បានរស់នៅក្រៅប្រទេស និងអ្នកដែលធ្វើការជាមួយនឹងបក្សកុម្មុយនិស្តបរទេស តែងតែស្នើឯកសារពីបរទេសដោយអះអាងថាយើងមិនយកចិត្តទុកដាក់ទៅលើការសិក្សាលទ្ធិម៉ាក្ស-លេនីន ។ ប៉ុន្តែយើងប្រាប់អ្នកទាំងនោះថា លទ្ធិម៉ាក្ស-លេនីនកើតឡើងពីការតស៊ូរបស់ប្រជាជន ។ បទពិសោធន៍របស់យើងគឺជាឯកសារម៉ាក្ស-លេនីនពិតៗ ។

## IV. មាគ៌ាចាត់តាំងរបស់បក្ស

យើងកសាងបក្សតាមសតិអារម្មណ៍និងចាត់តាំងដោយផ្អែកលើការវិភាគវណ្ណៈរបស់យើង យកប្រជាកសិករនិងវណ្ណៈកម្មករក្រីក្រជាមូលដ្ឋាន ។ អ្នកដែលចូលរួមចាប់តាំងពីវណ្ណៈអនុធនឬវណ្ណៈដទៃទៀត បានព្យាយាមអភិវឌ្ឍគោលជំហរនៃវណ្ណៈទាំងនោះ ប៉ុន្តែលះបង់វណ្ណៈចាស់របស់ខ្លួនចោល និងបង្កើត

សតិអារម្មណ៍វណ្ណៈកម្មករវិញ ។ កម្មាភិបាលត្រូវបានវាយតម្លៃតាមរយៈសកម្មភាពជាក់ស្តែងរបស់ខ្លួន ។ សតិអារម្មណ៍របស់កម្មាភិបាលត្រូវតែស្អាតស្អំ មិនពុករលួយ និងមិនជាប់ពាក់ព័ន្ធជាមួយនឹងខ្មាំង ។ យើងស៊ើបអង្កេតប្រវត្តិជីវិតនិងធាតុវណ្ណៈដើមមុននិងក្រោយពេលចូលបដិវត្តន៍ ។ យើងធ្វើនេះ គឺដើម្បីការពារកុំឲ្យពួកភ្នាក់ងារផ្សេងៗ ជ្រៀតចូលបានដូចជា សេ.អ៊ី.អា កា.ហ្សេ.បេ ឬភ្នាក់ងារវៀតណាម ។ ដោយអនុវត្តតាមនូវគោលការណ៍ចាត់តាំងនេះយើងបានរួបរួមគ្នាជាមួយនឹងបក្ស ហើយអាចបោសសម្អាតសមាសភាពមិនល្អចេញពីបក្ស ។ យើងមិនទាន់ធ្វើបានសម្រេចមួយរយភាគរយទេ ។ ខ្មាំងនៅតែមានការប៉ុនប៉ងបំផ្លាញបក្សដដែល ។ ជាលទ្ធផល យើងកំពុងតែវាយប្រយុទ្ធពង្រឹងការអប់រំផ្នែកនយោបាយសតិអារម្មណ៍និងចាត់តាំង និងដើម្បីធ្វើឲ្យបក្សស្អាត ។

ជាសរុបមកយើងអាចនិយាយថា បក្សយើងត្រូវបានបញ្ចូលរួបរួមគ្នាតាមរយៈការងារនយោបាយសតិអារម្មណ៍និងចាត់តាំង ។ បក្សកាន់តែខ្លាំងទៅៗ ។ យើងដឹងថានៅពេលដែលលោកមានបក្សខ្លាំងហើយស្អាតនោះ លោកនឹងមានចលនាបដិវត្តន៍ខ្លាំងក្លា ។ យើងនៅមានផ្លូវដែលត្រូវធ្វើដំណើរវែងឆ្ងាយទៀត ហើយខ្មាំងទាំងពួកចក្រពត្តិ និងពួកសេរីវី ក៏ដូចជាពួកវៀតណាមនៅតែបន្តវាយយើង ។ ដូចនេះ ការកសាងបក្សចេះតែបន្តរហូតពីជំនាន់មួយទៅជំនាន់មួយ ។ យើងសង្ឃឹមថានឹងចៀសវាងបាននូវលទ្ធភាពរបស់ជំនាន់ក្រោយមិនឲ្យក្លាយជាអ្នកសេរីវីឡើយ ។ ប្រសិនបើយើងអាចការពារដោយសុវត្ថិភាពនូវផលប្រយោជន៍របស់ប្រទេស នោះយើងក៏ចូលរួមវិភាគទានក្នុងការតស៊ូនៅក្នុងសកលលោកទាំងមូល ។ យើងដឹងអំពីការកើតឡើងនៃការសេរីវីនិយមនៅសហភាពសូវៀត ហើយយើងមានការសោកស្តាយណាស់ចំពោះរឿងនេះ និងវិនាសកម្មបន្តឡើងដោយខ្មាំងចំពោះបក្សឥណ្ឌូនេស៊ី ។ យើងបានរៀនសូត្រពីបទពិសោធន៍ទាំងនេះ ហើយបទពិសោធន៍នានាមកពីបក្សផ្សេងៗទៀត ។ យើងបានព្យាយាមមិនឲ្យដួលតាមចិញ្ចើមថ្នល់នោះទេ ។

**សំណួរៈ មានគ្រោះថ្នាក់ពីប្រទេសខាងក្រៅឬខាងក្នុងបក្សទេ ពេលគ្រោះថ្នាក់ដែលវណ្ណៈថ្មីកំពុងតែត្រូវបានបង្កើតឡើង?**

ដើម្បីបញ្ជាក់អំពីសារជាតិនៃការតស៊ូនៅក្នុងបក្សបានពិតជាមានគ្រោះថ្នាក់ទាំងពីរយ៉ាង ។ នៅក្នុងបក្សមានទំនាស់រវាងគោលជំហរកម្មសិទ្ធិឯកជននិយមនិងសមូហភាពនិយម ។ ប្រសិនបើយើងមិនយកចិត្តទុកដាក់ទេ វាអាចក្លាយជាទំនាស់បដិបក្ខ ។ ទំនាស់មួយទៀតគឺមកពីខាងក្រៅ ។ ជាពិសេស វៀតណាមកំពុងតែព្យាយាមបំផ្លាញបក្សរបស់យើងទាំងខាងយោធានយោបាយសេដ្ឋកិច្ច និងសតិអារម្មណ៍ ។ វៀតណាមក៏ព្យាយាមដែរក្នុងការជ្រៀតចូលក្នុងបក្សយើង ។ យើងមិនព្រួយបារម្ភអ្វីទេអំពីការឈ្លានពានផ្នែកយោធាមកពីខាងក្រៅ ។ យើងព្រួយបារម្ភបំផុតគឺខ្មាំងផ្ទៃក្នុង ។

**សំណួរៈ ហេតុអ្វីបានជាការងារខុសច្បាប់នៅតែជាការងារសំខាន់និងជាមូលដ្ឋាន?**

នៅក្នុងដំណាក់កាលក្រោយរំដោះនេះ ការងារសម្ងាត់គឺជាការងារសំខាន់ ។ យើងលែងប្រើពាក្យថា «ស្របច្បាប់» ឬ «ខុសច្បាប់» ទៀតហើយ ។ យើងប្រើពាក្យថា «សម្ងាត់» និង «ចំហ» ។ ការងារសម្ងាត់ដែលយើងធ្វើគឺសំខាន់ទាំងអស់ ។ ឧទាហរណ៍ការជ្រើសរើសកម្មាភិបាលឲ្យមកដឹកនាំការងារគឺធ្វើទៅដោយសម្ងាត់ ។ កន្លែងដែលថ្នាក់ដឹកនាំយើងរស់នៅគឺសម្ងាត់ ។ យើងលាក់ការណ៍សម្ងាត់ទាំងការប្រជុំ ទីកន្លែង និងកិច្ចការផ្សេងទៀត ។ ទីមួយគឺជាគោលការណ៍ទូទៅ ហើយទីពីរគឺជាវិធីការពារខ្លួនកុំឲ្យខ្មាំងជ្រៀតចូល ។ ដរាបណានៅមានការតស៊ូវណ្ណៈឬការតស៊ូប្រឆាំងនឹងចក្រពត្តិនិយម ការងារសម្ងាត់នៅតែសំខាន់រហូត ។ មានតែតាមរយៈការសម្ងាត់នេះទេដែលយើងអាចធ្វើម្ចាស់លើសភាពការណ៍ និងយកជ័យជម្នះលើខ្មាំងសត្រូវដែលមិនដឹងថាអ្នកណាជាអ្នកណា ។

ការងារការបរទេសក៏យ៉ាងដូច្នេះដែរ ។ ឧទាហរណ៍សហភាពសូវៀតបានសុំមកភ្នំពេញនៅពេលរំដោះ ។ គេបានរៀបចំបញ្ជូនមនុស្ស២០០នាក់មកស្ថានទូត ។ យើងនិយាយថា យើងមិនអាចមានលទ្ធភាពទទួលគេទេ ហើយសូវៀតខឹងខ្លាំងណាស់ ។ អ្វីៗគ្រប់បែបយ៉ាងគឺយើងផ្អែកលើការសម្ងាត់ទាំងអស់ ។ នេះគឺស្ថិតនៅក្នុងផលប្រយោជន៍វណ្ណៈកម្មករ ។

***សំណួរៈ ហេតុអ្វីបានជាលោកមិននិយាយអំពីសូវៀតនៅខាងក្រៅ?***

*នៅក្នុងបក្សយើងតស៊ូដាច់ខាតប្រឆាំងនឹងសហភាពសូវៀត ប៉ុន្តែឥឡូវនេះយើងមានសត្រូវច្រើនណាស់ មានដូចជាចក្រពត្តិអាមេរិក ថៃឡង់ វៀតណាម ហើយមូលហេតុយុទ្ធសាស្រ្តផ្សេងៗទៀតគឺយើងត្រូវកម្រិតខ្មាំងរបស់យើងតាមតែអាចធ្វើទៅបាន ។ គួរតែមានន័យច្បាស់ហើយថាយើងប្រឆាំងនឹងសហភាពសូវៀតនិងសេរីរើនិយម ប៉ុន្តែមាគ៌ារបស់យើងគឺត្រូវតែខុសពីមាគ៌ាដែលត្រូវបានប្រកាន់យកនៅក្នុងប្រទេសចិន ពីព្រោះយើងជាប្រទេសតូចតាច ។*

*សូមលើកឧទាហរណ៍មួយទៀតគឺឥរិយាបថរបស់យើងចំពោះ«លោកទាំងបី» ។ យើងមានគោលជំហរដូចគ្នាបេះបិទ ប៉ុន្តែចំពោះអ្វីដែលយើងធ្វើយើងត្រូវតែចាំក្នុងចិត្តអំពីផលប្រយោជន៍ជាក់ស្តែងរបស់ប្រទេសយើង ។*

***សំណួរៈ តើលោកមានកម្មវិធីបក្សដែរឬទេ?***

*បាទ! យើងមានមួយ ប៉ុន្តែមានតែនៅប្រទេសកម្ពុជាទេ ។ យើងនៅមានការងារច្រើនណាស់ ។ យើងមិនទាន់បានធ្វើការឃោសនាគ្រប់គ្រាន់នៅក្នុងឆាកអន្តរជាតិទេ ។ ខ្មាំងយួនមានលទ្ធភាពធ្វើការឃោសនាជាអន្តរជាតិច្រើនប្រឆាំងនឹងយើង ដោយសារតែការឃោសនារបស់យើងនៅលើឆាកអន្តរជាតិមានការខ្វះខាត ។*

## V. ***ការងារជាក់ស្តែងមុននិងក្រោយរំដោះ***

*នៅមុនរំដោះសកម្មភាពស្របច្បាប់ដែលពាក់ព័ន្ធនឹងការងារដែលធ្វើឡើងដោយអង្គការផ្សេងៗគ្នាដូចជាសហពន្ធ័ និស្សិត សមាគមកម្មករ សមាគមស្រ្តី និងអង្គការផ្សេងៗទៀត ។ យើងធ្វើការងារគ្រប់យ៉ាងនៅក្រោមច្បាប់របស់ខ្មាំង ឲ្យតែខ្មាំងឲ្យធ្វើ ។ មានផ្នែកតូចៗរបស់សកម្មភាពមិនស្របច្បាប់ឬមិនចំហ គឺពាក់កណ្តាលចំហនិងពាក់កណ្តាលសម្ងាត់ ឬពាក់កណ្តាលស្របច្បាប់និងពាក់កណ្តាលមិនស្របច្បាប់ ។ ទោះបីជាវណ្ណៈកាន់អំណាចអាចនឹងចាប់យើងបានក៏ដោយ តែយើងបានប្រារព្ធធ្វើបុណ្យ ១ឧសភា ។ យើងរក្សាប្រពៃណីនៅពេលដែលប្រពៃណីនេះកើតឡើង ។ ប្រហែលជាមានការខុសប្លែកគ្នានៅកន្លែងយើង ។ តាំងពីមុនមក បក្សកុម្មុយនិស្តកម្ពុជាមិនដែលធ្លាប់ស្របច្បាប់ម្តងណាសោះឡើយ ។ នេះជាការពិតចំពោះអង្គការចម្រើននានាដែលយើងបានបង្កើត ។ យើងអភិវឌ្ឍវិធីសាស្រ្តសម្ងាត់ ទី១គឺដើម្បីការពារខ្លួន ទី២ កៀងគរកម្លាំងថែមទៀត និងទី៣គឺបម្រើឲ្យការតស៊ូរបស់យើងដូចជាការកសាងកម្លាំងបញ្ញវ័ន្តជាដើម ។ យើងយល់ឃើញថា បញ្ញវ័ន្តទាំងនោះនឹងមិនចូលរួមជាមួយយើងទេបើយើងប្រើទម្រង់ពាក់កណ្តាលមិនស្របច្បាប់ ប៉ុន្តែដោយសារមានទម្រង់ស្របច្បាប់ដូចជាការប្រារព្ធពិធីផ្សេងៗ និងទៅធ្វើទស្សនកិច្ចដើរមើលប្រាសាទនានាបញ្ញវ័ន្តទាំងនោះចូលជាមួយយើង ។ ដូចនេះយើងធ្វើឲ្យបញ្ញវ័ន្តទាំងនេះចូលរួមជាមួយយើងមួយជំហានម្តងៗ ។ សកម្មភាពពាក់កណ្តាលសម្ងាត់ និងពាក់កណ្តាលមិនស្របច្បាប់និងសម្ងាត់ជាច្រើន ត្រូវបានរៀបចំឡើងដើម្បីការពារសកម្មភាពសម្ងាត់និងមិនស្របច្បាប់ទាំងអស់របស់មជ្ឈិមបក្ស ។ ដូច្នេះនៅពេលខ្មាំងវាយពីខាងក្រៅ គឺវាវាយសកម្មភាពពាក់កណ្តាលសម្ងាត់ និងពាក់កណ្តាលមិនស្របច្បាប់ ហើយយើងអាចការពារបក្សនិងថ្នាក់ដឹកនាំរបស់យើង ។ នៅក្នុងសង្គមពាក់កណ្តាលសក្តិភូមិ និងអាណានិគមបែបថ្មីយើងត្រូវតែធ្វើការឲ្យបានសម្ងាត់បំផុត ទាំងក្នុងបក្ស និងអង្គការផ្សេងៗទៀត ។*

*សមាជិកបក្សដែលធ្វើការនៅក្នុងជួរមហាជន ក៏ត្រូវអនុវត្តតាមរបៀបនេះដែរ ។ ចាប់តាំងពីពេលរំដោះមក យើងបានបន្តការងារសម្ងាត់ទៅមុខទៀត ពីព្រោះយើងចាត់ទុកមាគ៌ាយុទ្ធសាស្រ្តថាមានសារសំខាន់ជាងកលយុទ្ធ ។ យើងបានចេញផ្សាយឈ្មោះកម្មាភិបាលនិងសមាជិករបស់យើងតែពីរបីនាក់ប៉ុណ្ណោះ ។ មិនត្រូវផ្សព្វផ្សាយជាសាធារណៈច្រើនពេកទេ ។ នៅក្នុងអំឡុងពេលសង្រ្គាម អ្នកទាំងនោះសុទ្ធតែស្ថិតនៅក្នុងភាពសម្ងាត់ទាំងអស់ ។ ក្នុងផ្នែកនេះ យើងបានរៀនសូត្រពីបទពិសោធន៍ប្រឡាក់ឈាមរបស់បក្សកុម្មុយនិស្តឥណ្ឌូនេស៊ី ។*

*ដោយធ្វើប្រតិបត្តិការជាសម្ងាត់ អង្គការយើងដើរតាមក្រឹតក្រមដូចតទៅ÷ សមាជិក៣នាក់បង្កើតបានជាកងមួយ ឧទាហរណ៍ដូចជានៅក្នុងរោងចក្រ ។ ប្រសិនបើសមាជិកលើសពី៣នាក់ លេខាកងត្រូវដឹកនាំការងារបក្ស ។ ប្រសិនបើមានរហូត*

ដល់៦នាក់ យើងបង្កើតជាកងពីរដាច់ពីគ្នាដោយមិនមានការទាក់ទងគ្នាឡើយ ។ ទោះជាមានគ្នា៥នាក់ ក៏យើងអាចបង្កើតកងពីរបានដែរ ។ កងទាំងពីរនេះធ្វើការសម្ងាត់និងដាច់ដោយឡែកពីគ្នា ។ ប្រសិនបើខ្មាំងរកឃើញកងមួយ កងមួយទៀតអាចបន្តកិច្ចការរបស់ខ្លួនតទៅទៀត ។ កងនិងកងមិនអាចទាក់ទងគ្នាដោយផ្ទាល់បានទេ ។ នៅក្នុងរោងចក្រនីមួយៗមានកម្មាភិបាលដឹកនាំមួយនាក់ ។ មានតែកម្មាភិបាលដឹកនាំទេដែលដឹងកិច្ចការនេះ ។ កម្មាភិបាលដឹកនាំអាចដឹកនាំដោយផ្ទាល់ ។ ដំណើរការទាំងនេះក៏ត្រូវយកទៅអនុវត្តចំពោះផ្នែកផ្សេងៗទៀតបានដែរ ដូចជាសិស្សជាដើម ។ យើងបង្កើតកងដោយមិនស្គាល់គ្នា និងមិនអាចទាក់ទងគ្នា ។ ករណីនេះដូចគ្នាទៅនឹងទំនាក់ទំនងរវាងកម្មាភិបាលដឹកនាំនិងថ្នាក់ដឹកនាំដែរ ។ ការទាក់ទងគឺត្រូវបានរៀបចំដោយមនុស្សទីបី ។ ប្រសិនបើខ្មាំងចាប់បានកម្មាភិបាលដឹកនាំ ខ្មាំងមិនអាចរកមេដឹកនាំឃើញទេ ឃើញតែអ្នកនៅចន្លោះកណ្តាលតែប៉ុណ្ណោះ ។ នេះគឺជាអង្គការសម្ងាត់របស់យើង ។

តាមពិសោធន៍របស់យើងកន្លងមក ការសម្ងាត់គឺគ្រាន់តែជាផ្នែកមួយប៉ុណ្ណោះក្នុងការកសាងអង្គការ ។ ចំណុចដែលសំខាន់ជាងនេះទៅទៀត គឺកម្រិតនៃការយល់ដឹងផ្នែកសតិអារម្មណ៍របស់កម្មាភិបាលដែលត្រូវបានចាត់តាំងឲ្យដឹកនាំ ។ កម្មាភិបាលទាំងនេះត្រូវមានវិន័យត្រឹមត្រូវ ។ យើងត្រូវប្រយ័ត្នឲ្យមែនទែននៅពេលធ្វើការនៅក្រុងនានា ។ កម្មាភិបាលអាចត្រូវបានបង្ខំឲ្យចាកចេញឲ្យបានឆាប់ ។ កម្មាភិបាលមិនគួររស់នៅជាមួយគ្រួសារទេ ប្រសិនបើរស់នៅជាមួយគ្រួសារនឹងមានបញ្ហាស្មុគស្មាញមិនខាន ។ វានឹងចំណាយពេលយូរណាស់ដើម្បីឲ្យកម្មាភិបាលចេញផុតពីគ្រួសារ ។ យើងមានបទពិសោធន៍ជូរចត់ណាស់កន្លងមក ។ ក្រោយមក យើងក៏សម្រេចចិត្តតាមដានអង្កេតវិន័យនេះកាន់តែតឹងរ៉ឹង ។ អនុញ្ញាតឲ្យខ្ញុំនិយាយថា យើងកំពុងតែនិយាយអំពីបទពិសោធន៍ជាក់ស្តែងកន្លងមក និងលក្ខខណ្ឌជាក់ស្តែងនៅក្នុងប្រទេសយើងខ្ញុំ ។ ស្រេចតែខាងលោកទេក្នុងការសម្រេចចិត្តទទួលឬមិនទទួលយកនូវបទពិសោធន៍ទាំងនេះ ។ យើងផ្តល់ឧទាហរណ៍ទាំងអម្បាលម៉ាននេះចេញពីសតិអារម្មណ៍ភាតរបដិវត្តពិតៗ ។

សម្ងាត់មានន័យថាគេចចេញពីច្បាប់ ។ ឧទាហរណ៍យើងត្រូវធ្វើអត្តសញ្ញាណប័ណ្ណដើម្បីកុំឲ្យមានឈ្មោះយើងលេចឡើងនៅក្នុងបញ្ជី ។ ប្រសិនបើខ្មាំងចាប់បានអត្តសញ្ញាណប័ណ្ណ រូបថតនិងសំបុត្រធ្វើការងារពិតប្រាកដនោះ ម្ល៉េះខ្មាំងមិនដឹងជារកយើងឃើញស្រួលយ៉ាងណាទេ ។ ដូចគ្នានេះដែរ ប្រសិនបើអ្នកបដិវត្តមិនមានការងារអ្វីទេ ខ្មាំងប្រហែលជាសង្កេតយើងឃើញហើយ ។ យើងបើកហាងសៀវភៅសម្រាប់ប្រើប្រាស់ខ្លួនយើង ប៉ុន្តែដើម្បីកុំឲ្យចេញឈ្មោះរបស់យើង យើងលាក់នៅពីក្រោយខ្នងនិងឈ្មោះរបស់មនុស្សទីបី ។ នៅសម័យសង្គ្រាម កម្មាភិបាលជាច្រើនត្រូវឈប់ធ្វើការងារជាបណ្តោះអាសន្ន ហើយយើងត្រូវតែការពារអ្នកទាំងនោះ ។ ការទាក់ទងគ្នានិងកិច្ចប្រជុំគឺមាននៅពេលយប់ ចំណែកឯវគ្គសិក្សានយោបាយក៏ដូច្នេះដែរ ។ យើងចាក់សោរៀននៅក្នុងបន្ទប់ពីរបីថ្ងៃរហូតដល់ចប់សព្វគ្រប់ ។ ការទាក់ទងគ្នារវាងថ្នាក់ដឹកនាំដែលគេស្គាល់ជាទូទៅ ដូចជាអ្នកធ្វើការនៅក្នុងសភាជាមួយនឹងថ្នាក់ដឹកនាំសម្ងាត់ គឺធ្វើឡើងតាមរយៈមនុស្សពីរបីនាក់ផ្សេងទៀត ។ យើងបានប្រើល្បិចកលផ្សេងៗដើម្បីទប់ទល់ការគាបសង្កត់របស់ខ្មាំង ។ ចំពោះកិច្ចប្រជុំនៅក្នុងផ្ទះជាឧទាហរណ៍ស្រាប់ យើងបានប្រើសញ្ញាផ្សេងៗដូចជាដាក់ក្រមានៅមុខផ្ទះជាដើម ។ ប្រសិនបើមានក្រមានៅមុខផ្ទះ អាចចូលបានដោយសុវត្ថិភាព ។ ប្រសិនបើមិនមានទេ គឺខ្មាំងនៅទីនោះហើយ ។ ដំបូងយើងបាត់មនុស្សជាច្រើនដោយសារខ្មាំងដឹងសញ្ញាសម្ងាត់របស់យើង ។ ចាប់ពីនោះមកយើងលែងដើរចូលផ្ទះដោយផ្ទាល់ទៀតហើយ ប៉ុន្តែធ្វើជាដើរជុំវិញលេងជាមួយអ្នកជិតខាង ឬដើរចូលហាងរកអ្វីផឹក ហើយធ្វើជាសួរថា មានអ្វីកើតឡើងនៅក្នុងផ្ទះនោះ? ជួនកាលមនុស្សល្អក៏ប្រាប់យើងស្ងាត់ៗអំពីខ្មាំង ។ មានពេលខ្លះទៀត ប្រជាជនមិនមែនជាជនបដិវត្តទេ តែអាចរំពុកយើងថាមានគិញ ឬភ្នាក់ងារស៊ើបការណ៍នៅទីនោះ ។

យើងក៏បានប្រើនិរសាឲ្យរត់សំបុត្រ លីសែងគ្រាប់ជាដើម ។ល ។ យើងមិនឲ្យនិរសាដឹងពីកន្លែងពិតរបស់យើងទេ បើមិនអ៊ីចឹងទេ ពេលដែលនិរសាត្រូវចាប់ខ្លួន ខ្មាំងនឹងបង្ខំឲ្យឆ្លើយប្រាប់ពីកន្លែងសម្ងាត់របស់យើងអស់ ។ យើងត្រូវប្រើមនុស្សពីរទៅ

បីនាក់សម្រាប់ធ្វើជាស្ពានក្នុងការទាក់ទងជាមួយនិរសា ។ ប្រសិនបើមិនឃើញមុខនិរសាពីរបីថ្ងៃ យើងឈប់ធ្វើអ្វីទាំងអស់ពីរបីថ្ងៃ ។ ប៉ុន្តែក្រោយពីហេតុការណ៍នេះ យើងត្រូវផ្លាស់ប្តូរទីតាំងទៅកន្លែងផ្សេងទៀត ។ នៅពេលដឹងការណ៍នេះ ខ្មាំងបានវាយធ្វើបាបនិរសាដើម្បីរកចាប់យើង ។ តាមពិសោធន៍កន្លងមក យើងតែងតែបោះបង់ចោលផ្ទះមួយរំពេចប្រសិនបើនិរសាមកយឺតតែពីរឬបីម៉ោង ។ ខ្មាំងបានមកដល់រកមើលពីរបីដង ហើយយើងក៏ប្រើអាវុធដើម្បីឲ្យកម្មាភិបាលដឹកនាំរត់រួចខ្លួន ។ ការណ៍នេះនឹងផ្តល់ជាគំនិតមួយចំនួននៃបទពិសោធន៍របស់យើងកន្លងមក ។ កលយុទ្ធនិងវិធីសាស្ត្រផ្សេងៗគឺមានសារសំខាន់ទីពីរ ។ រឿងដែលសំខាន់បំផុតគឺជីហវណ្ណៈរបស់កម្មាភិបាល ។

ចាប់តាំងពីរំដោះមក បទពិសោធន៍របស់យើងមានទាក់ទងជាមួយនឹងសកម្មភាពប្រឆាំងបក្សដែលរៀបចំឡើងនៅផ្ទៃក្នុងបក្ស ។ សកម្មភាពទាំងអស់នេះមានដូចជា សកម្មភាពសេ.អ៊ី.អា វៀតណាម និងភ្នាក់ងារកា.ហ្សេ.បេរបស់សូវៀត ។ បទពិសោធន៍របស់យើងលើផ្នែកនេះគឺនៅថ្មីៗ ប៉ុន្តែបើតាមអ្វីដែលយើងដឹងមក ប្រហែលជាថា ភ្នាក់ងារសេ.អ៊ី.អា ភ្នាក់ងារវៀតណាម និងភ្នាក់ងារកា.ហ្សេ.បេ ធ្វើសកម្មភាពនៅក្នុងជួរបក្សយូរណាស់មកហើយ ។ នៅពេលយើងសង្កេតឃើញថាខុស យើងគិតថាវាជាទំនាស់ផ្ទៃក្នុង ហើយយើងបានព្យាយាមដោះស្រាយទំនាស់នេះតាមវិធីបញ្ចុះបញ្ចូលស៊ុយទិគៀន និងវិធីផ្សេងៗទៀត ។ ឧទាហរណ៍ បក្សត្រូវដាក់បញ្ហាដល់សាខាទាក់ទងនឹងជីវភាពរស់នៅរបស់ប្រជាជន ។ នៅពេលឃើញគ្មានការផ្លាស់ប្តូរ យើងដឹងថាច្បាស់ជាមានបញ្ហា ។ នៅពេលមានសមាសភាពដូចជាឆ្វេងឬក៏ស្តាំនិយម យើងពិនិត្យយ៉ាងហ្មត់ចត់ទៅលើធាតុដើមរបស់កម្មាភិបាល ។ យើងក៏ស្តាប់មតិរបស់មហាជនដែរ ។ ធ្វើដូចនេះយើងអាចវែកមុខរកឃើញភ្នាក់ងារខ្មាំងជាបន្តបន្ទាប់ ។ ជាទូទៅរកឃើញថាពួកវាពាក់ព័ន្ធសកម្មភាពខ្មាំងរយៈពេលយូរហើយ ។ ជួនកាលកម្មាភិបាលត្រូវបានចាប់ដាក់គុកនិងធ្វើទារុណកម្មហើយក្រោយមក កម្មាភិបាលរបស់យើងក៏ចុះចូលខាងខ្មាំង ។ ក្រោយពីដោះលែងហើយ កម្មាភិបាលទាំងនោះបានក្លាយជាភ្នាក់ងារ ។ យើងពេញចិត្តនឹងទទួលអ្នកទាំងនោះមកវិញដោយមិនចាំបាច់មើលអ្វីដែលកើតឡើងនៅក្នុងគុកនោះទេ ។ ឥឡូវនេះយើងដឹងថា កម្មាភិបាលទាំងនោះគឺជាភ្នាក់ងាររបស់ខ្មាំង ។

អ្នកណាៗក៏ដឹងដែរថា អាមេរិកមានផែនការរឹបអូសអំណាចពីយើង៦ខែក្រោយរំដោះ ។ ផែនការនេះមានការចូលរួមពីសំណាក់សហរដ្ឋអាមេរិក កា.ហ្សេ.បេ និងវៀតណាម ។ នឹងមានការវាយពីក្នុងនិងពីខាងក្រៅ ។ ប៉ុន្តែយើងបានវាយបំបាក់ផែនការនេះហើយ ។ គ្រាន់តែក្រោយពេលរំដោះភ្លាមយើងជម្លៀសទីក្រុងទាំងអស់ ។ ពេលនោះ ភ្នាក់ងារសេ.អ៊ី.អា កា.ហ្សេ.បេ និងភ្នាក់ងារវៀតណាម ត្រូវទៅនៅតាមជនបទ ហើយមិនអាចអនុវត្តផែនការដែលបានគ្រោងទុកនេះឡើយ ។ អ្នកដែលជ្រៀតចូលក្នុងបក្សមិនអាចបញ្ចេញប្រតិកម្មភ្លាមៗទេ ប៉ុន្តែយើងបានរកឃើញអ្នកទាំងនោះក្រោយមកទៀត ពេលគឺពេលដែលពួកវាមានផែនការរដ្ឋប្រហារ ។ សកម្មភាពរបស់ពួកវាគួបផ្សំជាមួយការឈ្លានពានមកពីខាងក្រៅ ។ ពួកវាមិនមែនជាអ្នកមានអំណាចទេ ។ បំណងរបស់ពួកវាគឺចង់ឆ្លៀតឱកាសវៀតណាមវាយលុកចូល ន្ទាលនឹងបានធ្វើឃាតថ្នាក់ដឹកនាំរបស់យើង រួចហើយប្រកាសឲ្យពិភពលោកដឹង ។ ក៏ប៉ុន្តែនៅពេលវៀតណាមធ្វើការវាយលុក កងទ័ពយើងក៏បានវាយធ្វើឲ្យវាបរាជ័យ និងថែមទាំងចាប់បានពួកក្បត់ជាតិនៅក្នុងជួរបក្សទៀតផង ។

ទោះបីជាយើងនិយាយថា ផែនការទាំងនេះត្រូវបានកម្ទេចអស់ក្តី ក៏យើងមិនអាចនិយាយថាខ្មាំងបានបោះបង់ចោលគំនិតវាដែរ ។ យើងបន្តកសាង និងការពារបក្សរបស់យើងនិងថ្នាក់ដឹកនាំយើង និងធ្វើឲ្យអ្នកដែលលួចជ្រៀតចូលបង្កប់ក្នុងបក្សដឹងខ្លួន ។ យើងដឹងថា ផែនការថ្មីនេះពាក់ព័ន្ធមិនត្រឹមតែជាមួយភ្នាក់ងារវៀតណាមទេ តែថែមទាំងទាក់ទងជាមួយចក្រពត្តិអាមេរិក និងកា.ហ្សេ.បេ ទៀតផង ។ គឺអាទាំងអស់ហ្នឹង! ករណីស្រដៀងគ្នានេះដែរកើតឡើងនៅប្រទេសយេម៉ែន ទាំងនៅខាងជើងនិងខាងត្បូង និងនៅប្រទេសអាហ្វកានីស្ថាន ។ ប៉ុន្តែនៅពេលមានរឿងកើតឡើង មុខមាត់របស់សូវៀតកាន់តែលេចច្បាស់ទៅៗ ។

**(នៅមានត)**

# បញ្ជីឈ្មោះអ្នកទោស "ជនជាតិភាគតិច"
## ដែលជាប់ឃុំឃាំងនៅមន្ទីរស-២១

រៀបរៀងដោយ យិន នាន

| ល.រ | ឈ្មោះអ្នកទោស | ភេទ | មុខងារ | ថ្ងៃចូល | ថ្ងៃកម្ទេច | ជនជាតិ |
|---|---|---|---|---|---|---|
| ១ | អ៊ី ម៉ូល | ប្រុស | ទាហានធីវគី | ៧-១០-៧៨ | (ឥតមាន) | ព្នង |
| ២ | ប៊ីស ផៀប | ស្រី | (ប្រពន្ធ អ៊ីម៉ូល) | ៧-១០-៧៨ | ៣១-១០-៧៨ | ព្នង |
| ៣ | ញ៉ារូង ម្រែវ | ប្រុស | កងឆ្នក់ | ១៩-៤-៧៨ | ១០-៦-៧៨ | ព្នង |
| ៤ | ខែក ស្រូល | ស្រី | (ប្រពន្ធ ញ៉ារូង ម្រែវ) | ១៧-៤-៧៨ | ២១-៤-៧៨ | ព្នង |
| ៥ | ញ៉ា វ៉ាយពឿ | ប្រុស | កងឆ្នក់ | ១៧-៤-៧៨ | ??-៥-៧៨ | ព្នង |
| ៦ | យ៉ាង បាវ៉ាញ់ | ស្រី | (ប្រពន្ធ ញ៉ា វ៉ាយពឿ) | ១៧-៤-៧៨ | ២១-៤-៧៨ | ព្នង |
| ៧ | ចាក ដើម | ប្រុស | កងឆ្នក់ | ១៧-៤-៧៨ | ២៧-៥-៧៨ | ព្នង |
| ៨ | ដាង នួយ | ស្រី | (ប្រពន្ធ ចាក ដើម) | ១៧-៤-៧៨ | ២១-៤-៧៨ | ព្នង |
| ៩ | អ៊ី ពើងណិល | ប្រុស | កងទ័ពហ៊ុលរ៉ូ | ២៤-១០-៧៨ | (ឥតមាន) | ព្នង |
| ១០ | អ៊ី ប្មេន | ប្រុស | កងទ័ពហ៊ុលរ៉ូ | ២៤-១០-៧៨ | (ឥតមាន) | ព្នង |
| ១១ | វិន ឡួយ | ប្រុស | យុទ្ធជនក-១៧ មន្ទីរតំបន់១០៥ | ២០-១០-៧៨ | ៣១-១២-៧៨ | ទំពួន |
| ១២ | ឆ ជ្រៃ | ប្រុស | ធ្វើស្រែ | ២៧-៥-៧៧ | (ឥតមាន) | ជ្រៃ |
| ១៣ | ឆ លក់ | ប្រុស | ធ្វើស្រែ | ២៧-៥-៧៧ | (ឥតមាន) | ជ្រៃ |
| ១៤ | ឆ ទ្រឿ | ប្រុស | ធ្វើស្រែ | ២៧-៥-៧៨ | (ឥតមាន) | ជ្រៃ |
| ១៥ | ភឿន ភុន | ប្រុស | យុទ្ធជននៅមន្ទីរក១៧ តំបន់១០៥ | ២០-១០-៧៨ | (ឥតមាន) | ទំពួន |
| ១៦ | ហង បើត | ប្រុស | កងឆ្នក់ | ១៧-៤-៧៨ | ១០-៦-៧៨ | ព្នង |
| ១៧ | ប៊ួ ប៊ុន | ប្រុស | មេក្រុមមន្ទីរក-១០ ស-៧១ | ៣០-៦-៧៨ | (ឥតមាន) | កួយ |
| ១៨ | សាង ខែប ហៅ ផា | ប្រុស | ជួសជុលគេអូ អង្គការយុទ្ធជន | ១-៥-១៩៧? | (ឥតមាន) | ទំពួន |
| ១៩ | ខល ផល | ប្រុស | អនុប្រធានមន្ទីរជ-៤៦ | ១៨-៣-៧៨ | (ឥតមាន) | ទំពួន |
| ២០ | មៀម ប្រ៉ប | ប្រុស | សមាជិកគណៈឃុំសណ្ដាយ ក្រចេះ | ៣-៥-៧៨ | (ឥតមាន) | ព្នង |
| ២១ | ឈី ហ៊ ហៅ ផាន | ប្រុស | យុទ្ធជនបង្កើនផល អង្គភាពប-៣ | ៣០-៣-៧៨ | ២៧-៥-៧៨ | កួយ |
| ២២ | យើយ ខុម ហៅ ខាន | ប្រុស | យុទ្ធជនបើកបរឡានក្រសួងដឹកជញ្ជូន | ៣០-៣-៧៨ | ២៩-៤-៧៨ | ព្នង |
| ២៣ | ឃ្លិប ភីន ហៅ ការ | ប្រុស | យុទ្ធជនផ្នែកចាក់ជ័រកៅស៊ូ | ៣០-៣-៧៨ | ២៩-៤-៧៨ | ព្នង |
| ២៤ | វិន សិន | ប្រុស | មេពួកមន្ទីរផ្គត់ផ្គង់ស្រុកស្នួល | ១២-៤-៧៨ | ២៩-៣-៧៨ | ព្នង |
| ២៥ | អំពញ បឿង ហៅ ម៉ៃ | ប្រុស | អនុក្រុមចម្ការកៅស៊ូស្រុកស្នួល | ១៥-៤-៧៨ | ២៩-៤-៧៨ | ព្នង |

| | | | | | | |
|---|---|---|---|---|---|---|
| ២៦ | ហន់ សុផ ហៅ គីន | ប្រុស | ប្រធានរោងចក្រ ជ.៦ | ៨-៤-៧៨ | (ឥតមាន) | ទំពួន |
| ២៧ | បឺញ អ៊ីបាន | ប្រុស | កងទ័ពហ៊ុលវ៉ូ | ២៦-៦-៧៨ | (ឥតមាន) | ជ្វែ |
| ២៨ | ក្លោង អ៊ី ហៅ ជន់ | ប្រុស | មេក្រុមយុទ្ធជនស្រុកច្បារ | ១២-១១-៧៧ | (ឥតមាន) | ព្នង |
| ២៩ | កាឌូ ហៅ បន | ប្រុស | អនុពាណិជ្ជកម្មភាគឧត្តរ | ២៧-៣-៧៧ | (ឥតមាន) | គ្រឹង |
| ៣០ | រុំ ខ្ជូន ហៅ ជន | ប្រុស | សមាជិកគណៈដឹកជញ្ជូនភាគឦសាន | ៣០-៧-៧៨ | (ឥតមាន) | ទំពួន |
| ៣១ | ស្រុន លី | ស្រី | យុទ្ធនារីកាត់ដេរ ក-១៦ តំបន់១០៥ | (ឥតមាន) | (ឥតមាន) | ព្នង |
| ៣២ | ស្រេវ ដ្លិស | ស្រី | យុទ្ធនារីមន្ទីរ ក-១៦ តំបន់១០៥ | ??-១០-៧៧ | (ឥតមាន) | ព្នង |
| ៣៣ | ហ្គ្រេះ ដូន | ស្រី | (ប្រពន្ធ ហង បើត) | ១៧-៤-៧៨ | ២១-៤-៧៨ | ព្នង |
| ៣៤ | ពូយ ត្វាង | ប្រុស | សមាជិកស្រុកបរកែវខាងជើង | ១២-១១-៧៨ | ១២-១១-៧៨ | ទំពួន |
| ៣៥ | រ៉ាស់ ឡាន់កុំ | ប្រុស | (?) | ១៤-៦-៧៧ | ២០-១០-៧៧ | ចារ៉ាយ |
| ៣៦ | រ៉ាស់ ឡាន់ម៉ាត់ | ប្រុស | (?) | ១៤-៦-៧៧ | ២០-១០-៧៧ | ចារ៉ាយ |
| ៣៧ | កុសល់ យើង | ប្រុស | (?) | ១៤-៦-៧៧ | ២០-១០-៧៧ | ចារ៉ាយ |
| ៣៨ | ប៊ូ កែវ (ប៊ូ ខាវ) | ប្រុស | លេខាស្រុកកុកឡាក់ តំបន់១០១ | ??-៣-៧៧ | (ឥតមាន) | កូវៃត |
| ៣៩ | ប៊ូ សាមុត | ស្រី | មេពួកនារី | ១-៧-៧៧ | (ឥតមាន) | ព្នងកាត់ខ្មែរ |
| ៤០ | កក់ ឃីម | ប្រុស | ប្រជាជនសហករណ៍ស្រែធំ | ១៤-៨-៧៧ | (ឥតមាន) | ព្នងកាត់ខ្មែរ |
| ៤១ | កែវ វេង | ប្រុស | យុទ្ធជន យោធាស្រុកកែវសីមា | ??-៣-៧៨ | (ឥតមាន) | លាវ |
| ៤២ | ក្រង់ ខ្លឹង (រី) | ស្រី | ពេទ្យមន្ទីរក-៨០ | (ឥតមាន) | (ឥតមាន) | ព្នង |
| ៤៣ | គ្រិស យ៉េន (យុន) | ប្រុស | មេក្រុមកុមារនៅមន្ទីរក-១៧ | ??-៨-៧៧ | (ឥតមាន) | ខ្មែរ ព្នង |
| ៤៤ | ខ្វេង ង៉ុក (ឡេង) | ប្រុស | លេខាវរសេនាតូច៥០២ | ??-១-៧៨ | (ឥតមាន) | ចារ៉ាយ |
| ៤៥ | ឡាយ ខ្លឹង (ដូស) | ស្រី | យុទ្ធនារីមន្ទីរក-១៦ តំបន់១០៥ | ១-៧-៧៧ | (ឥតមាន) | ព្នង |
| ៤៦ | លីត ចាន់ | ស្រី | ចារកិច្ចលាវ | ៥-១១-៧៨ | (ឥតមាន) | លាវ |
| ៤៧ | មស់ យេប (នឿន) | ប្រុស | មេក្រុមពេទ្យតំបន់១០៥ | ២៧-៤-៧៧ | (ឥតមាន) | ព្នង |
| ៤៨ | ណាង ដាវ | ស្រី | ប្រជាជន | ៧-៤-៧៦ | (ឥតមាន) | លាវ |
| ៤៩ | ណាង កេវ (ស៊ី) | ស្រី | ប្រជាជន | (ឥតមាន) | (ឥតមាន) | លាវ |
| ៥០ | ដាន យោន (ជន) | ប្រុស | អនុប្រធានពាណិជ្ជកម្ម តំបន់១០៥ | ២៣-១១-៧៧ | ??-៥-៧៨ | លាវ |
| ៥១ | សាទ ខែប (ខាន់) | ប្រុស | ជួសជុលគេអូអគ្គការ យុទ្ធជន | ១-៥-៧៦ | (ឥតមាន) | ទំពួន |
| ៥២ | សេង ព្រេន (ហ៊ិន) | ស្រី | យុទ្ធនារីមន្ទីរ ក-១៦ តំបន់១០៥ | ??-១១-៧៧ | (ឥតមាន) | ព្នង |
| ៥៣ | ស៊ី តង់ (ប៊ុល្លី) | ស្រី | សមាជិកពេទ្យ ក-៨ | ??-៧-៧៧ | (ឥតមាន) | លាវ |
| ៥៤ | សឹង ក្លើល (នីន) | (?) | ប្រធានយានដ្ឋានជួសជុលឡាន យ-១ | ១២-១១-៧៨ | (ឥតមាន) | ទំពួន |
| ៥៥ | អ៊ី ប៊ឹញ អេបាន | (?) | (?) | (ឥតមាន) | (ឥតមាន) | ចារ៉ាយ |
| ៥៦ | ប្រូ ប្រើក (ខាំវ៉ាត់) | ប្រុស | ប្រធានសហករណ៍សុខសាន្ត | ២៣-១១-៧៧ | ១៩-២-៧៨ | ទំពួន |
| ៥៧ | ប្រី ស្រើក (ខាំវ៉ាត) | (?) | ប្រធានសហករណ៍ | ??-៨-៧៧ | ១៩-៧-៧៨ | ព្នង |

# យល់សប្តិគឺជាទោស


លី ហាក់

ជនជាតិចាមជាច្រើននាក់នៅភូមិស្វាយឃ្លាំង (ភូមិទី៥) ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម បានរៀបរាប់ប្រាប់ខ្ញុំអំពីប្រវត្តិជូរចត់របស់គាត់នៅក្នុងរបបខ្មែរក្រហម ។ បងប្អូនខ្លះបានបង្ហាញខ្ញុំនូវស្នាមរបួសជិតដាមលើខ្លួនប្រាណរបស់គាត់ដែលខ្មែរក្រហមបានចាប់យកគាត់ទៅធ្វើទារុណកម្មនៅតាមទីកន្លែងផ្សេងៗ ។ តាំ ម៉ាន សព្វថ្ងៃអាយុ៥០ឆ្នាំ ជាអ្នកភូមិស្វាយឃ្លាំង ។ នៅចំពោះមុខខ្ញុំ តាំ ម៉ាន បានបង្ហាញឲ្យខ្ញុំឃើញនូវស្នាមរបួសលើក្បាលរបស់គាត់ដោយស្នាដៃខ្មែរក្រហមដែលបានវាយគាត់នឹងកំណាត់ឫស្សីពីងពង់ ។ ស្លាកស្នាមនេះនៅច្បាស់ក្រឡែត ។ គាត់និយាយថា “ខ្ញុំត្រូវស្លាប់ តែខ្ញុំបានរស់វិញ” ។ ខ្ញុំសួរគាត់ថា “ហេតុអ្វីបានជាត្រូវខ្មែរក្រហមវ៉ៃ?” គាត់ឆ្លើយយ៉ាងខ្លាំងថា “មកពីខ្ញុំដេកមមើ” ។

តាំ ម៉ាន បានរៀបរាប់ថា “*នៅពេលព្រឹកឡើង ខ្ញុំពួអ្នកជិតខាងប្រាប់ខ្ញុំថា ខ្ញុំដេកមមើស្រែកថា កាប់ៗៗ ។ តាមពិតយប់នោះ ខ្ញុំមិនបានដឹងខ្លួនអ្វីសោះ ។ ព្រោះតែខ្ញុំដេកមមើនេះហើយបានជាពួកវា (កម្មាភិបាលខ្មែរក្រហម) វ៉ៃខ្ញុំនឹងព្រនង់ឫស្សីពីងពង់ មានស្លាកស្នាមដល់ពេលនេះ*” ។ តាំ ម៉ាន បានរៀបរាប់ពីដំណើររឿងដែលបណ្តាលឲ្យមានទោសដោយការដេកមមើដែលកើតឡើងនៅមន្ទីរឃុំឃាំងឡចំហុយថ្នាំ នៅព្រៃកតាដួង ឃុំក្រូចឆ្មារ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម (ជាកន្លែងឃុំឃាំងអ្នកទោសប្រុស បន្ទាប់ពីចលនាបះបោរនៅភូមិស្វាយឃ្លាំងត្រូវបរាជ័យ) នាឆ្នាំ១៩៧៥ ។

យប់នោះ លី ហាក់ ដេកនៅជិត ម៉ាន ក៏បានឮ ម៉ាន មមើស្រែកថា កាប់ៗៗ ។ ដំបូង លី ហាក់ មិនចាប់អារម្មណ៍ថានឹងមានរឿងអ្វីមួយកើតឡើងចំពោះ ម៉ាន ឡើយ ហើយគាត់បានបញ្ជាក់ថា “ខ្ញុំគិតថាគ្មានអ្នកណាចាប់ទោសពៅអ្នកដេកមមើឡើយ” ។ ទីន សា អ្នកនៅក្នុងឡជាមួយគ្នា ក៏បានពោលដែរថា “ពេលខ្ញុំកំពុងតែដេកលក់ ខ្ញុំភ្ញាក់ព្រោះ ម៉ាន ដែលនៅក្បែរខ្ញុំមមើស្រែកខ្លាំងៗថា កាប់ៗៗ” ។ បងប្អូនដែលនៅសេសសល់ពីស្លាប់មួយចំនួនទៀតបានដឹងឮពីរឿងរបស់ ម៉ាន ដូចៗគ្នា ។

ក្រោយយប់ដែល ម៉ាន ដេកយល់សប្តិ ស្អែកឡើងរហូតដល់ថ្ងៃរសៀល ម៉ាន ត្រូវបានកម្មាភិបាលខ្មែរក្រហមហៅឈ្មោះឲ្យចេញទៅក្រៅ ដើម្បីយកទៅវាយសួរចម្លើយរឿងហេតុនៃការដេកមមើ ។ ម៉ាន រៀបរាប់ថា “*ពេលពួកកម្មាភិបាលខ្មែរក្រហមហៅឈ្មោះខ្ញុំឲ្យចេញក្រៅ ខ្ញុំអត់បានដឹងថាមានរឿងអ្វីទេ ខ្ញុំមិនចាប់អារម្មណ៍ថាមកពីខ្ញុំដេកមមើទេ ។ ពេលខ្ញុំដើរផុតពីឡប្រហែល៥០ម៉ែត្រ កម្មាភិបាលខ្មែរក្រហមវ៉ៃខ្ញុំមួយព្រនង់ចំកំភួនជើងពីក្រោយ ខ្ញុំដួលផ្កាប់មុខ ។ វាទាញខ្ញុំក្រោកហើយឲ្យដើរទៅមុខទៀត ។ ទៅប្រហែល១០០ម៉ែត្រទៀត វាវ៉ៃខ្ញុំនឹងព្រនង់ឫស្សីពីងពង់ត្រូវក្បាលខ្ញុំពីរដង វាវ៉ៃជាសញ្ញាលេខបូក ។ ពេលនោះខ្ញុំងងឹតមុខស្រ៊ុប ហើយវាបណ្តើរទៅមុខបាន៤-៥ជំហាន វាប្រាប់ឲ្យខ្ញុំអង្គុយចុះ ខ្ញុំបើកភ្នែកឡើងឃើញរណ្តៅនៅចំពីមុខខ្ញុំជ្រៅហើយធំ ។ ខ្ញុំអង្គុយនៅមាត់រណ្តៅ ។ ពេលនោះមានកម្មាភិបាលខ្មែរក្រហមម្នាក់ដើរតម្រង់មកខ្ញុំដោយមានកាន់ដាវមួយសស្ងាច ។ ម្នាក់ចាប់សក់ខ្ញុំភ្ញើយឡើងលើម្នាក់ដែលកាន់ដាវ បានដាក់ផ្លែដាវលើបំពង់កខ្ញុំ ខ្ញុំដឹងថា ខ្ញុំត្រូវពួកខ្មែរក្រហម*

អារ-កសម្លាប់ដាក់ក្នុងរណ្តៅនេះហើយ ។ វាមិនទាន់អារក្លាមទេ វាប្រាប់ខ្ញុំថា បើខ្ញុំឆ្លើយត្រូវវាឲ្យខ្ញុំត្រឡប់ទៅវិញ បើឆ្លើយមិនត្រូវវាឲ្យខ្ញុំនៅក្នុងរណ្តៅនេះ ។ ហើយវាសួរថា ហេតុអ្វីបានជាដេកមមើ? ពេលនោះហើយទើបខ្ញុំដឹងពីមូលហេតុដែលវាវៃខ្ញុំ ហើយយកខ្ញុំមកកន្លែងនេះ គឺដោយសារតែខ្ញុំដេកមមើកាលពីយប់ ។ ខ្ញុំឆ្លើយថា នៅយប់បះបោរមានមនុស្សមកវៃទ្វារផ្ទះខ្ញុំក្តុងក្តាំង ខ្ញុំចេញទៅក្រៅផ្ទះ ឃើញអ្នកភូមិកាន់កាំបិតផ្គាក់ខ្ញុំភ័យណាស់ស្មានតែគេមកកាប់ខ្ញុំ ។ អ៊ីចឹងបានជាខ្ញុំដេកមមើស្រែកថា កាប់ កាប់ កាប់ ។ ប្រហែលជាខ្ញុំឆ្លើយត្រូវ ទើបបានវាដកដាវពីកខ្ញុំហើយលែងសក់ក្បាលខ្ញុំវិញ ។ វាជូនខ្ញុំទៅឃុំឃាំងវិញ រួចផ្តាំថាកុំឲ្យខ្ញុំនិយាយប្រាប់អ្នកណាទាំងអស់ ។ ពេលទៅដល់កន្លែងវិញ ទោះជាឪពុកខ្ញុំលបសួរក៏ដោយ ក៏ខ្ញុំអត់ហ៊ានប្រាប់គាត់ដែរ» ។

ពេលត្រឡប់មកវិញ ទោះជា ម៉ាន មិនបាននិយាយប្រាប់អ្នកដែលនៅក្នុងឡជាមួយគ្នាក៏ដោយ ប៉ុន្តែគ្រប់ៗគ្នាបានសំឡឹងឃើញស្នាមរបួសនៅលើក្បាលរបស់ ម៉ាន មានឈាមហូរប្រឡាក់ដោតខោអាវ ។ ម្នាក់ៗគិតថា នេះមកពីដើមហេតុដែល ម៉ាន ដេកមមើយប់មិញនេះហើយ ។ អ្នកជាប់ឃុំឃាំងជាមួយ ម៉ាន ម្នាក់ទៀតឈ្មោះ ស្វាស់ សា បានឲ្យដឹងថា «នៅពេល ម៉ាន ត្រឡប់មកដល់កន្លែងឃុំឃាំងវិញ ខ្ញុំឃើញ ម៉ាន មានសភាពទ្រុឌទ្រោម ហើយបែកក្បាលហូរឈាម ។ ខ្ញុំគិតថាមកពីវាដេកមមើយប់នោះហើយបានជាពួកខ្មែរក្រហមវៃវា ។ ប៉ុន្តែទោះជាអ្នកណាសួរវាយ៉ាងម៉េច ក៏វាមិនឆ្លើយដែរ ខ្ញុំស្មានតែវាខូចសរសៃប្រសាទ ព្រោះចាប់តាំងពីនោះមក វាអត់ហ៊ាននិយាយរកអ្នកណាទេ» ។

បន្ទាប់ពីឃើញដូច្នោះមក អ្នកដែលជាប់ឃុំឃាំងទាំងអស់មានការប្រុងប្រយ័ត្នយ៉ាងខ្លាំងនៅក្នុងការដេករៀងរាល់យប់ ។ លី ហាក់ បាននិយាយថា «ខ្ញុំពុំសូវបានដេកនឹងគេទេ ព្រោះខ្ញុំឃ្លាំមើលក្មេងៗ ក្រែងមានស្រែកមមើទៀតទ្រលនឹងខ្ញុំទៅខ្ទប់មាត់» ។

**អ៊ីសា ឧស្មាន**

# សេចក្តីណែនាំអំពីការប្រើពាក្យ "អង្គការ" និងពាក្យ "បក្ស"

**ឯកសារលេខ D១២៦៦**

តាមការពិនិត្យកន្លងមកឃើញថា អ្នកខ្លះនិងអង្គការខ្លះ មានការភ័ន្តច្រឡំក្នុងការប្រើពាក្យ «**អង្គការ**» និងពាក្យ «**បក្ស**» ។ ហើយនៅកន្លែងខ្លះទៀតមានសមាសភាពអាក្រក់និងសមាសភាពខ្មាំងបង្កប់ផ្ទៃក្នុង បន្លំប្រើពាក្យ «អង្គការ» នេះដើម្បីបោកប្រាស់និងបំផ្លិចបំផ្លាញបក្សនិងបដិវត្តន៍ក៏មិនតិចដែរ ។

ម្យ៉ាងទៀត បក្សយើងសង្កេតឃើញថា ប្រើពាក្យ «អង្គការ» សម្រាប់ហៅបុគ្គលមិនចំណោញសោះដល់ការកសាងជំហរនយោបាយជំហរសតិអារម្មណ៍និងជំហរចាត់តាំងរបស់បក្ស វាផ្ទុយស្រឡះពីជំហរបដិវត្តសង្គមនិយមរបស់បក្សយើង ពីជំហរចាត់តាំងកម្មសិទ្ធិសួនតួរបស់យើង ។

អាស្រ័យហេតុនេះ គណៈមជ្ឈិមបក្សសុំធ្វើសេចក្តីណែនាំចំពោះគ្រប់មូលដ្ឋាន គ្រប់ក្រសួងមន្ទីរ និងគ្រប់អង្គភាពដូចតទៅ÷

១) ពាក្យ «អង្គការ» ឬពាក្យ «បក្ស» ប្រើតែចំពោះអង្គការចាត់តាំងមិនត្រូវប្រើសម្រាប់បុគ្គលឡើយ ។

២) ចំពោះបុគ្គលត្រូវប្រើពាក្យថា សមមិត្តឈ្មោះនេះ ឬសមមិត្តតំណែងនេះនោះ ឬសមមិត្តតំណាងអង្គការថ្នាក់នេះថ្នាក់នោះ ។ ឧទាហរណ៍ សមមិត្ត តេង សមមិត្តលេខា សមមិត្តតំណាងអង្គការភូមិភាគ.... ។

សូមអង្គការបក្សគ្រប់ថ្នាក់ណែនាំ និងអប់រំបញ្ហានេះដើម្បីឲ្យសមមិត្តនិងមិត្តយើងជ្រួតជ្រាបនិងអនុវត្តបានល្អ ។

<u>ចម្លងជូនៈ</u> គ្រប់កងពលនិងវរសេនាធំ ដោយភាតរភាពបដិវត្តកក់ក្តៅបំផុត

គ្រប់មន្ទីរ«ដើម្បីអនុវត្ត» ថ្ងៃ១១-៧-៧៧

ភាតរភាពបដិវត្តកក់ក្តៅបំផុត គណៈ៨៧០

ថ្ងៃទី២៨-៧-៧៧ ខៀវ (សុនសេន) (ការិយាល័យប៉ុលពត)

# ការស្រាវជ្រាវតាមរយៈរូបថតជនរងគ្រោះ ព្រុំ គី



ព្រុំ គី

ព្រុំ គី មានអាយុ៣៨ ឆ្នាំ ជនជាតិខ្មែរ កើតនៅភូមិប្រឡាយ ឃុំប្រឡាយ ស្រុកថ្មបាំង តំបន់១១ ភូមិភាគបស្ចិម ។ ព្រុំ គី ជាប្រធានយោធាវរសេនាធំ១១ តំបន់១១ ។ មុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ព្រុំ គី ធ្វើជាកងទ័ពប្រចាំតំបន់១៥ ក្រុងភ្នំពេញ ។ គាត់មានប្រពន្ធឈ្មោះ ចាន់ ទីលំនៅនៅភូមិប្រឡាយ ស្រុកថ្មបាំង តំបន់១១ ខេត្តកោះកុង ហើយមានកូនបីនាក់ (ស្រី២ ប្រុស១) ។ ម្តាយរបស់ ព្រុំ គី ឈ្មោះភឹម ឪពុកឈ្មោះ ព្រុំ។ ព្រុំ គី បានចូលធ្វើជាគិញនៅឆ្នាំ១៩៦៧ ដើម្បីយកការណ៍ពីខ្មែរក្រហមនៅព្រំប្រទល់ខេត្តពោធិ៍សាត់និងខេត្តបាត់ដំបង ហើយត្រូវអង្គការឃាត់ខ្លួននៅថ្ងៃទី៣០-១១-១៩៧៦ សួរចម្លើយថ្ងៃទី២៧-៦-៧៧ ។ ក្នុងចម្លើយសារភាពបានឲ្យដឹងថា ព្រុំ គី បានផ្លាស់មកនៅភូមិភាគពិសេសធ្វើសកម្មភាពនៅតំបន់១៥វិញ ។ ដល់ថ្ងៃរំដោះភ្នំពេញ ព្រុំ គី នៅតែបន្តសកម្មភាពរហូតដល់អង្គការចាប់ខ្លួននិងសួរចម្លើយ ។ ព្រុំ គី បានសារភាពថា÷

ចាប់តាំងពីដឹងក្តីមកដល់អាយុ១០ឆ្នាំ ឪពុកម្តាយបាននាំខ្លួនទៅបួសនៅវត្តទ័ពឃ្លៃ ស្រុកកោះកុង តំបន់១១ អស់រយៈពេលពីរឆ្នាំ ទើបសឹកមកជួយធ្វើស្រែឪពុកម្តាយ ។ នៅពេលអាយុ១៨ឆ្នាំ ព្រុំ គី បានមកបួសម្តងទៀតក្រោមការដឹកនាំពីចៅអធិការ ឆន ឈ្លាប ។

នៅឆ្នាំ១៩៦៧ សភាពការណ៍នៅខេត្តបាត់ដំបងកើតមានខ្មែរក្រហមច្រើន ព្រុំ គី ក៏ចូលធ្វើជាគិញតាមរយៈ យន សឿយ និង សុខុម វណ្ណា។ ព្រុំ គី និងគ្នីគ្នាមួយក្រុមទៀត មាននាទីដើររកខ្ទឹមចន្ទន៍ក្រស្នា និងយកការណ៍ពីខ្មែរក្រហម នៅភ្នំខ្មោច ភ្នំប្រវាប ព្រំប្រទល់ខេត្តពោធិ៍សាត់និងខេត្តបាត់ដំបង ម្តងបានប្រាក់៥០០រៀល តែមិនដែលបានយកការណ៍ពីខ្មែរក្រហមទេ ។

ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ ឈ្មោះទាំង៧នាក់ខាងលើបានចូលទៅបង្កប់ក្នុងជួរបដិវត្តន៍ដែល ម៊ុន ជាអ្នកខទ្វេសនាមឲ្យ (អង្គការកម្មុបឆ្នាំ១៩៧៤) ។ ព្រុំ គី និង ម៊ុន បានចូលបង្កប់ក្នុងជួរបដិវត្តន៍ តែមិនឲ្យធ្វើសកម្មភាពអ្វីទេ ខំតែធ្វើការឲ្យអង្គការទុកចិត្តទៅបានហើយ ។ ក្រោយមក ព្រុំ គី បានទទួលនាទីជាប្រធានភូមិនៅស្រុកថ្មស តំបន់១១ នាំទ័ពមកកាន់ភ្នំស្រួច តំបន់៣២ ។

ដើមឆ្នាំ១៩៧១ រឿន នាំ ព្រុំ គី ទៅជួបនឹងឈ្មោះ ឆាន់ លេខាឃុំចាន់តាសែនលើ និងឈ្មោះ រឿន អនុប្រធានឃុំចាន់តាសែនក្រោម ។ រឿន បានខទ្វេសនាម ម៊ុន មកធ្វើសកម្មភាពបំផ្លាញបដិវត្តន៍បន្ត ដើម្បីពង្រីកកម្លាំងក្នុងជួរកងទ័ពនិងនៅតាមមូលដ្ឋានឲ្យបានច្រើន ស៊ីរូងផ្ទៃក្នុងបដិវត្តន៍ឲ្យបានជ្រៅនិងយូរអង្វែង ។ កន្លះខែក្រោយទាហាននៅបន្ទាយបាត់ដឹងមកវាតត្បាតនៅភូមិត្រពាំងគូ ។ ព្រុំ គី ទៅត្រៀមវាយខ្មាំងគ្រាន់តែបំភ័ន្តភ្នែកអង្គការ ពេលមកដល់ទីតាំងសឹកក៏បញ្ជាកងទ័ពឲ្យរត់អស់ទុកឲ្យខ្មាំងចូលវាតត្បាតផ្ទះប្រជាជនអស់រាប់រយខ្នង ។

ពាក់កណ្តាលឆ្នាំ១៩៧៣ អង្គការបញ្ជូន ព្រុំ គី មករៀនសូត្រក្នុងស្រុកខដុង្គ ឆ្លៀតឱកាសនោះ ព្រុំ គី និងបក្សពួកក្តោបយកឱកាសពង្រីកកម្លាំងបង្កប់ថែមទៀត ។ មកដល់អង្គភាពវិញ អង្គការចាត់តាំង ព្រុំ គី ឲ្យនាំអង្គភាពទៅវាយឈ្លបនៅភ្នំអដ្ឋរស្សទៀត ។ ការធ្វើសកម្មភាពនៅអដ្ឋរស្សនេះ គឺគ្រាន់តែដឹកនាំកងទ័ពយកទៅត្រៀម តែមិនធ្វើសកម្មភាពទេ (ខ្មាំងកៀរប្រជាជនអស់៥០០គ្រួសារ) ។ នៅចុងឆ្នាំ១៩៧៣ ព្រុំ គី ចាត់តាំងកម្លាំង៥នាក់ឲ្យទៅកៀងគោអ្នកស្រុកតំបន់៣២ បានចំនួន៥០០ក្បាល ចាប់តាំងពីពេលនោះមក ការធ្វើសកម្មភាពត្រូវផ្អាកមួយរយៈ ។

ពាក់កណ្តាលឆ្នាំ១៩៧៤ នៅបញ្ជាការដ្ឋានកងវរសេនាតូច១១៣ ភូមិភាគពិសេស ព្រុំ គី នាំទ័ពទៅវាយខ្មាំងនៅផ្លូវជាតិលេខ៤ ហើយឆ្មៀតកសាងកម្លាំងបាន៣នាក់ទៀត ។ ចុងឆ្នាំ១៩៧៤ មុនទៅតំបន់១១វិញ ព្រុំ គី បានចូលរួមប្រជុំពីបញ្ហាលើកទិសទៅវាយយកក្រុងភ្នំពេញក្នុងឆ្នាំ១៩៧៥ ។

ព្រុំ គី បានទៅទំនាក់ទំនងជាមួយទាក់ទងសក្តិ២ នូ តាមរយៈមិត្ត ដូ (ដូ ពីមុនជាអ្នករត់ពន្ធទំនិញពីប្រទេសវៀតណាមមកកោះកុង) ។ ការជួបជាមួយសក្តិ២ នូ នេះ គឺរកវិធីរារាំងផែនការអង្គការបដិវត្តន៍ដែលមានគម្រោងវាយក្រុងភ្នំពេញឆ្នាំ១៩៧៥ ។

ក្នុងចម្លើយនោះបាននិយាយ ព្រុំ គី បានទៅខូចសីលធម៌ជាមួយពេទ្យនារី ខុម រួចអប់រំឲ្យធ្វើសកម្មភាពជាមួយ ។ បន្ទាប់មកអង្គការចាត់តាំងនាំទ័ពទៅវាយខ្មាំងនៅបន្ទាយពយជប៉ុនត្រៀមចម្ងាយជាង១,៥គម ។ ព្រុំ គី បានទាក់ទង នូ ឲ្យបាញ់កាំភ្លើងធំៗដាក់កងទ័ពនៅខ្សែត្រៀមស្លាប់អស់១០នាក់របួសជាង១០នាក់ រួចនៅបន្តសកម្មភាពជាដដែល ។ ទន្ទឹមនឹងនោះពេលកងទ័ពរបួសបញ្ជូនមកស្នាក់ការសរមភូមិ នារី ខុម ចាក់ថ្នាំឲ្យឈឺកាន់តែឈឺធ្ងន់ ។

រយៈពេលមួយខែក៏នៅតែវាយខ្មាំងមិនឈ្នះអង្គការបានបញ្ជូនអង្គភាពរបស់មិត្ត ជិន មកបន្ថែមទៀត ។ តែបីថ្ងៃសោះកងទ័ពក៏ស្លាប់អស់៤០នាក់ និងរបួស៩០នាក់ ។ ខែ៤ ឆ្នាំ១៩៧៥ មុនរំដោះភ្នំពេញបីថ្ងៃ ខ្មាំងនៅបន្ទាយពយជប៉ុនរត់ទៅកោះស្ទាប់អស់ ។ ព្រុំ គី និងឈ្មោះ នៅ បានបញ្ជាកងទ័ពឲ្យជញ្ជូនជយភណ្ឌដាក់តាមថ្នល់ ពេលនោះយន្តហោះទម្លាក់គ្រាប់បែកឆេះអស់គ្រាប់មួយចំនួនធំ ។ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងកម្លាំងខ្មែរក្រហមកាន់កាប់ក្រុងភ្នំពេញ ។ ព្រុំ គី និងឈ្មោះ នៅ មកកោះកុងនៅត្រឹមកោះស្ទាប់ ប្រជុំតែពីរនាក់នៅបន្ទាយសក្តិ៣ យ៉ន ។ ការប្រជុំរិះរកវិធានការបញ្ចេញប្រជាជនឲ្យរត់ទៅប្រទេសសៀមឲ្យអស់ ។ យប់ថ្ងៃទី២២ ហេង ផុន ក៏បាននាំប្រជាជននិងទាហាន១ពាន់គ្រួសារទៅស្រុកថៃ ។ ថ្ងៃទី២៣ អង្គការមានវិធានការប្រមូលពលទាហាននិងនាយទាហានសក្តិធំៗ ។ ព្រុំ គី បានប្រមូលពលទាហានដែលចេញមុខជាងគេបញ្ជូនមក រួចរាយការណ៍ទៅឈ្មោះ នៅ ។ នៅ ក៏បានឲ្យនាំកម្លាំងទាំងនោះដាក់តាមយានដ្ឋាននិងតាមម៉ាស៊ីនភ្លើង បើអង្គការសួរថា“ពួកកម្មករ” ។ ក្រោយមក ព្រុំ គី និង នៅ ចាត់តាំង ធី និង ជិន ដុតបំផ្លាញគ្រាប់ជយភណ្ឌនៅបន្ទាយតាម៉ាលាខាងកើតកោះកុងអស់មួយចំនួន ។ ប្រហែលជា១០ថ្ងៃ ធី បំផុសប្រជាជននៅភូមិនាងកុក ដើងគ្រក់ និងភូមិមណ្ឌល រត់ទៅសៀមអស់ ។ ក្រោយរំដោះកោះកុងបានមួយខែ អង្គការតំបន់បានហៅកម្មាភិបាលមករៀនសូត្រនៅវិទ្យាល័យកោះកុង ។ តាមចម្លើយសារភាពរបស់ ព្រុំ គី ឈ្មោះ នៅ បានណែនាំថា “សមមិត្តទាំងអស់បន្តសកម្មភាពឲ្យបានកាន់តែខ្លាំងក្លានៅតាមមូលដ្ឋាននិងតាមកងទ័ព ធ្វើម៉េចឲ្យតែប្រជាជនរត់ទៅស្រុកសៀមប្រឫកប្រូបល់ បង្អាក់ដំណើរការកសាងប្រទេសរបស់បដិវត្តន៍ ចែកអង្ករឲ្យប្រជាជន១កំប៉ុងសម្រាប់៧-៨នាក់ បើឈឺសមមិត្តមិនបាច់មើលទេ មិត្តត្រូវរកគ្រប់យុទ្ធវិធីទាំងអស់ដឹកនាំប្រជាជនឲ្យបាត់ជំនឿលើបដិវត្តន៍ ពង្រីកកម្លាំងឲ្យបានច្រើននៅតាមមូលដ្ឋានក៏ដូចជាតាមកងទ័ព ពិសេសប្រមូលទាហានដែលមានសក្តិធំៗទៅបង្កប់តាមមូលដ្ឋាន” ។

ដើមខែ៨ ឆ្នាំ១៩៧៥ អង្គការហៅ នៅ ឲ្យទៅរៀនសូត្រ ។ បន្ទាប់មក អង្គការតំបន់មានផែនការដកកម្មករចេញពីយានដ្ឋាននិងកន្លែងម៉ាស៊ីនក្រឡឹង ។ ព្រុំ គី ក៏យកអ្នកទាំងនោះលាក់បំពួននៅឃុំសូផាត ។ ឆ្លៀតឱកាសនោះ នៅ បានប្រជុំម្តងទៀត ដោយបានណែនាំបន្ថែមថា “សមមិត្តទាំងអស់កុំព្រួយពីរឿងអត់ស្បៀង ធ្វើសង្គ្រាមទាល់តែដាច់ខាតក្នុងការដឹកនាំទើបយកជ័យជម្នះពីបដិវត្តន៍បាន ។ បញ្ហាសំខាន់យើងនៅខ្វះកម្លាំង សមមិត្តត្រូវពង្រីកកម្លាំងឲ្យច្រើនអប់រំកងទ័ពនៅតាមអង្គភាពនីមួយៗឲ្យស្តាប់បញ្ជាយើង ។ ដូច្នេះផែនការរបស់យើងធ្វើនៅខែ៤-១៩៧៦នោះ ធ្វើម៉េចវាយយកកោះកុងធ្វើជាមូលដ្ឋានទើប សម្រេចបានគ្រប់កន្លែងទាំងអស់ ។ ពេលវាយបានហើយយើងនិងកងទ័ពសៀមរួមគ្នាវាយបុកផ្លូវជាតិលេខ៤មកភ្នំពេញ” ។

ដើមឆ្នាំ១៩៧៦ ព្រុំ គី បានអូសទាញកម្មាភិបាល៦នាក់នៅវរសេនាធំ១១តំបន់១១ ។ ឈ្មោះទាំង៦នាក់នោះបានចូលរួមបំផុសបន្តរឿងសីលធម៌ពុករលួយតាមអង្គភាពនិងប្រជាជននៅ

តាមមូលដ្ឋានរត់ទៅស្រុកសៀម ចាក់ថ្នាំបំផ្លាញកម្លាំងកម្មាភិបាលឲ្យស្លាប់មួយខែៗអស់ពី៥០-២០០នាក់ ។ ផែនការនេះត្រូវបែកការណ៍ដោយ កែម (ខ្សែចាត់តាំងរបស់ នៅ) ត្រូវអង្គការចាប់ខ្លួនបាន ។

នៅថ្ងៃទី១០-៧-១៩៧៦ ឈ្មោះ នៅ បានកំណត់ជួប ហេង ផុន ម្តងទៀតដើម្បីរៀបចំលើកផែនការធ្វើរដ្ឋប្រហារមកថ្ងៃទី២៥ ខែ៩ ឆ្នាំ១៩៧៦វិញ ។ ព្រុំ គី បានទៅបោះទ័ពនៅភូមិទួលពោធិ៍ ស្រុកថ្មស បានពីរថ្ងៃអង្គការដកមកកោះសាឡៅវិញ ។ ផាត ត្រូវអង្គការចាប់នៅពាក់កណ្តាលខែ៨ ។ ផែនការត្រូវផ្អាកមួយរយៈទៀត ប៉ុន្តែនៅតែរកវិធីបំផ្លាញអង្គការគ្រប់ពេលវេលា ។ នៅ ក៏បាននិយាយដែរថា «ទោះបីជាផែនការមិនសម្រេច យើងត្រូវរៀបផែនការផុតឃ្លាំងគ្រាប់ទៀត...បើទុកគ្រាប់នោះ អង្គការនឹងវាយយើងវិញមិនខាន» ។

ផែនការដុតឃ្លាំងនោះត្រូវបានទទួលជោគជ័យព្រោះមាន នារី ភា ជាស្នងការអនុសេនាតូច៣០៣ វរសេនាធំ១១និង នារី ឡូត ស្នងការអនុសេនាតូច៣០៣ តំបន់១១ ជាអ្នកដុត ។ ក្រោយពីការដុតបានមួយថ្ងៃ ព្រុំ គី ត្រូវអង្គការចាត់ឲ្យទៅប្រូតស្រូវនៅនាងកុក រហូតដល់ថ្ងៃ៣០-១១-១៩៧៦ ទើបអង្គការចាប់ខ្លួន ។

ចម្លើយសារភាពខាងលើនេះបានសង្ខេបពីឯកសារលេខ J៨៤ ដែលមាន៥១ទំព័រ ក្នុងនោះមានភ្ជាប់បញ្ជីឈ្មោះអ្នកចូលរួម៤ទំព័រដែរ ។ ចុងបញ្ចប់នៃចម្លើយក៏មានស្នាមមេដៃរបស់ ព្រុំ គី និងហត្ថលេខារបស់អ្នកសួរចម្លើយ ហើយនៅខាងមុខនៃចម្លើយនេះដែរមានចំណាររមួយមិនបញ្ជាក់ឈ្មោះបានសរសេរថា «***ជូនអង្គការពីរច្បាប់ហើយ ១៣-៧-៧៧***» និងចំណាររបស់ ឌុច សរសេរថា «***បងជាទីគោរពអត្ថបទ ព្រុំ គី ច្បាស់ប្រវត្តិដើមរបស់វា ដែលជាគិញរបស់អា សុខុម វណ្ណា (បាល័ដ្ឋស្រុកថ្មបាំង) និងដំណើរខ្លះមកក្រោយៗទៀត ។ វានិយាយសំខាន់ដំណើររឿង និងមនុស្សណាដែលបែកការណ៍ ហើយមាន អាកាត់, អាអ៊ី, អាឆាន់, ខាងតំបន់១៥ សូមជូនជាអត្ថបទមួយដោយឡែក អំពីសំណុំរឿងដែលស្តីអំពីមិត្តស៊ីវ ៗ ដោយគោរព! ១២-៧-៧៧***» ។ លី សុផល












**(តពីលេខមុន)** *"ខ្ញុំសូមឲ្យអង្គការសម្លាប់ខ្ញុំចោលចុះ ពីព្រោះខ្ញុំមិនដើរតាមបដិវត្តន៍...ខ្ញុំសមតែស្លាប់ ពីព្រោះអង្គការធ្លាប់តែទុកចិត្តមកលើខ្ញុំ ។ ខ្ញុំមិនចង់រស់ទៀតទេ មិនចង់តវ៉ាជាមួយនឹងអង្គការអ្វីទេ គឺធ្វើនេះដើម្បីរកយុត្តិធម៌ ។ ប៉ុន្តែខ្ញុំសូមប្រកាសថា នៅក្នុងចិត្តខ្ញុំ ខ្ញុំមិនដែលក្បត់អង្គការទាល់តែសោះ ។ ខ្ញុំសូមឆ្លើយថាខ្ញុំមានកំហុស...ដោយសារពេលនេះខ្ញុំជិតដល់ពេលស្លាប់ហើយ ។ ជយោ! បដិវត្តន៍ដ៏រុងរឿង! ជយោ! អង្គការបដិវត្តន៍"* ។

កិច្ចខិតខំប្រឹងប្រែងរបស់បក្សក្នុងការជម្រិតយកចម្លើយសារភាពថាមានកំហុស មិនមែនតែងតែទទួលបានផលជានិច្ចនោះទេ ។ ឈ្មោះ ស្បូវ ហិន (ហៅអឿន) ដែលជាលេខាកងពល៣១០ ត្រូវបានចាប់ខ្លួននៅក្នុងខែឧសភា ឆ្នាំ១៩៧៧ ។ ក្រោយពីសារភាពថាខ្លួនបានលាក់កន្ទុល់មិនបដិវត្តន៍ចំពោះបញ្ហាគ្រួសារ និងមិនស្មោះត្រង់ចំពោះអង្គភាពយោធាដោយលះបង់អាទិភាពរបស់ជាតិ ហិន ក៏ស្ថិតក្នុងសភាពគួរឲ្យគ្រោះថ្នាក់បំផុតៈ *"ខ្ញុំត្រូវរាយការណ៍ពីផែនការធ្វើរដ្ឋប្រហារផ្តួលរំលំបក្ស ។ នៅក្នុងជីវិតបដិវត្តន៍របស់ខ្ញុំអស់រយៈពេល១៩ឆ្នាំនេះ ខ្ញុំបានបំពេញភារកិច្ចចាត់តាំងក្នុងនាមជាជនកុម្មុយនិស្ត ។ ខ្ញុំរៀបចំខ្លួនជាស្រេចក្នុងការលះបង់...ជីវិតដើម្បីរំដោះវណ្ណៈនិងជាតិខ្ញុំ ។ នៅក្រោមការដឹកនាំរបស់បក្ស ខ្ញុំបានកែប្រែខ្លួនម្តងហើយម្តងទៀត...ខ្ញុំគ្មានអ្វីលាក់បាំងចំពោះបក្សទេ ។ ខ្ញុំមិនដែលមានគំនិតចង់ធ្វើរដ្ឋប្រហារប្រឆាំងនឹងបក្សឡើយ ។ ខ្ញុំយល់ថានេះជារឿងគ្មានសមហេតុផលអ្វីបន្តិចសោះ ពីព្រោះខ្ញុំមិនដែលមានគំនិតបែបនេះទាល់តែសោះ...ខ្ញុំមានការសោកស្តាយណាស់ដែលខ្ញុំមិនដឹងមុនថាខ្ញុំនឹងត្រូវបានចាប់ខ្លួនដូចពេលនេះ ។ បើខ្ញុំដឹងមុន ម៉្លេះខ្ញុំឆ្លើយពីភក្តីភាពរបស់ខ្ញុំចំពោះបក្សទៅហើយ ។ ប៉ុន្តែពេលនេះវាហួសពេលទៅហើយ ។ ខ្ញុំជាប់ខ្នោះនៅមន្ទីរស-២១ហើយ"* ។

ស្បូវ ហិន ត្រូវជាប់ខ្នោះគំនិតថា គ្មានការងើបប្រឆាំងនឹងរដ្ឋអំណាចបក្សបានឡើយ ទោះបីជា (ឬជាពិសេស) នៅពេលបក្សនេះបានទទួលពត៌មានសុទ្ធតែមិនពិតក៏ដោយ ហើយធ្វើឲ្យតែពិរោះស្តាប់ ។ នៅពេលបញ្ចប់ចម្លើយសារភាពរបស់ខ្លួនដោយប្រយោគមួយឃ្លាថា "មានតែបក្សទេដែលដឹងពីប្រវត្តិខ្ញុំ" ស្បូវ ហិន បាននិយាយថាខ្លួនគ្មានកំហុសទេ ហើយបានទទួលស្គាល់សិទ្ធិរបស់បក្សក្នុងការដាក់កំហុសមកលើខ្លួន ។




**សម្លេងពីមន្ទីរ ស-២១**
**ខគ្គទី៤: បង្កើតសំណួរសម្រាប់ទម្លាក់កំហុស**
**ដោយសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ**

អស់រយៈពេលជាច្រើនថ្ងៃខែក្រោយមក អ្នកសួរចម្លើយនៅមន្ទីរ ស-២១ បានវាយលុកទៅលើរាងកាយ ចិត្តគំនិត និងប្រវត្តិសាស្ត្រ ដោយថែមថយនិងប្រឌិតការចងចាំ ដើម្បីឲ្យស៊ីគ្នាជាមួយនឹងការចោទប្រកាន់ដែលរៀបចំទុកជាស្រេច និងធ្វើឲ្យចេញរូបរាងជាចម្លើយសារភាព ។ អ្នកទោសនិងអ្នកសួរចម្លើយធ្វើការដូចជាកីឡាករសកលហាត់វាយខ្យល់ដូច្នេះដែរ ដោយអ្នកសួរចម្លើយព្យាយាមទាញយក "ការពិត" (ទាំងគ្មានបញ្ជាក់ថាវាជាអ្វីឡើយ) ហើយអ្នកទោសព្យាយាមចាក់ខ្សែស្របតាម ឬក្នុងករណីជាច្រើន (ប៉ុន្តែមិនដឹងករណីមួយណា) ដើម្បីបង្វែងដានអ្នកសួរចម្លើយដោយលាក់កំបាំងឬផ្លាស់ប្តូររឿងរ៉ាវរបស់ខ្លួន ។

អ្នកសួរចម្លើយត្រូវបានឲ្យធ្វើការបញ្ចុះបញ្ចូលនិងគំរាមបំភ័យអ្នកទោសលុះត្រាតែអ្នកទោសបញ្ចេញនូវឯកសារមួយដែលស៊ីគ្នាជាមួយនឹងការដឹងឮរបស់បក្ស ចំពោះ "បទល្មើស" របស់ខ្លួន និងការអានរបស់បក្សលើប្រវត្តិរបស់ខ្លួនដែលម្តងអីចេះម្តងអីចុះ ។

តាមរបៀបស្រមើស្រមៃដែលពិបាកយល់ នៅក្នុងស្នាដៃរបស់ មីឡែន យូនដេវ៉ា "ការដាក់ទណ្ឌកម្មតែងតែត្រូវបាន







ធ្វើឡើងដើម្បីជម្រិតយកចម្លើយសារភាពថាខ្លួនពិតជាមានកំហុស» ។ ដូចនេះអ្នកទោសត្រូវតែលាយឡំបញ្ចេញបញ្ចូលឬទប់នូវអ្វីដែលខ្លួននៅចាំបានច្បាស់លាស់ដើម្បីផ្សំផ្គុំឲ្យចេញជាចម្លើយសារភាពមួយដែលជាតម្រូវការរបស់អ្នកសួរចម្លើយ ។ ចំពោះអ្នកសួរចម្លើយនិងអ្នកទោសក៏ដូច្នេះដែរ អាឡិចសាន់ឌ័រ សូលហ្សិននីតស៊ីន បានសរសេរថា ដំណើរការរបៀបនេះបង្កើតបានជា «ការលេងសូលីទែរដ៏អស្ចារ្យមួយដែលមានក្បួនលេងមិនងាយយល់សម្រាប់អ្នកលេងល្បែងនេះ» ។ បើយើងបកស្រាយន័យធៀបនេះមកវិញគឺថា មជ្ឈិមបក្សបានលាក់កំបាំងក្បួនច្បាប់ផ្សេងៗ ហើយអ្នកសួរចម្លើយត្រូវបានជំរុញឲ្យធ្វើសំណួរសម្រាប់ទម្លាក់កំហុសនៅក្នុងផ្លូវមួយដែលថា «ខ្មាំងមិនអាចក្តាប់គោលបំណងរបស់យើងបានទេ» ។ មិនមែនជាការគួរឲ្យភ្ញាក់ផ្អើលទេ គឺការដេញដោលសួររបៀបនេះប្រៀបបាននឹងល្បែង «ដែលសួរមនុស្សខ្វាក់អំពីពណ៌របស់វត្ថុ» យ៉ាងដូច្នោះដែរ ។

មើលទៅមានអ្នកទោសជាច្រើនត្រូវបានចាប់ខ្លួនជាអាទិ៍ដើម្បីបង្ខំឲ្យក្បត់នឹងអ្នកនៅពីលើខ្លួន ។ អ៊ីចឹងហើយបានជាកម្មាភិបាលជាច្រើននាក់ដែលបានចាប់ខ្លួននៅឆ្នាំ១៩៧៦ ត្រូវបានសួរចម្លើយដើម្បីកសាងសំណុំរឿងចោទប្រកាន់លេខាភូមិភាគបូព៌ាឈ្មោះ សោ ភឹម ហើយនៅឆ្នាំ១៩៧៨ ឈ្មោះ យាង ស៊ុមហាន (ហៅ ប៉ិត) ត្រូវបានអ្នកសួរចម្លើយគាបឲ្យឆ្លើយដាក់សុន សេន ។

អ្នកទោសទាំងអស់នៅមន្ទីរស-២១ លើកលែងតិចណាស់ដែលមិនត្រូវសម្លាប់ មិនមែនត្រឹមតែដោយសារខ្លួនត្រូវបានចោទប្រកាន់ថាមានកំហុសទេ តែដោយសារអត្ថិភាពនៃគុកនេះទីតាំង និងគោលបំណងរបស់គុកស្ថិតក្នុងការរក្សាការសម្ងាត់ ។ ការចាំបាច់ក្នុងការថែរក្សាការសម្ងាត់សំខាន់ណាស់ដូចនេះអ្នកទោសមិនដែលបានរួចខ្លួនឡើយ ។

អ្នកទោសត្រូវបាននាំមកកាន់មន្ទីរស-២១ដោយមូលហេតុច្រើនយ៉ាងដូចជា៖ ពីព្រោះអ្នកទោសទាំងនោះត្រូវបានឆ្លើយដាក់តាមរយៈចម្លើយសារភាពរបស់អ្នកទោសដទៃដោយសារមេបញ្ជាការអង្គភាពខ្លួនត្រូវបានសង្ស័យថាជា «ខ្មាំង» ឬដោយសារតែមានការសង្ស័យពីខាងសន្តិសុខភូមិភាគ ។ ចម្លើយសារភាពរបស់ ហូ នឹម បង្ហាញថា ជួនកាល «ខ្មាំង» ត្រូវបានរកឃើញក្នុងពេលប្រជុំស្វ័យទិតៀនថ្នាក់កម្មាភិបាលដែលធ្វើឡើងដោយទៀងទាត់ ។ «ខ្មាំង» ត្រូវបញ្ជូនចេញមកកាន់មន្ទីរស-២១ ក្រោយពីសួរចម្លើយទាំងបង្ខំឲ្យឆ្លើយសារភាពពីអំពើក្បត់របស់ខ្លួន ។

ក៏ប៉ុន្តែការដែលអ្នកទោសត្រូវជ្រើសរើស គោះប្រជុំប្រមូលផ្តុំ និងបញ្ចេញទៅមន្ទីរស-២១របៀបណានោះ មិនមានលក្ខណៈច្បាស់លាស់ឡើយ ហើយទំនាក់ទំនងរដ្ឋបាលរវាងមន្ទីរស-២១ និង «សាលាអប់រំ» ក៏យ៉ាងដូច្នេះដែរ (ពាក្យថា «គុក» មិនត្រូវបានប្រើនៅគ្រប់ទីកន្លែងក្នុងទូទាំងប្រទេសទេ ប៉ុន្តែយើងដឹងថាគ្រប់តំបន់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ សុទ្ធតែមានការិយាល័យសន្តិបាលរបស់ខ្មែរក្រហមដែលរៀបចំឡើងមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងមន្ទីរស-២១ដែរ) ។ ការិយាល័យទាំងនេះបានរាយការណ៍ទៅលេខាភូមិភាគ តែមិនរាយការណ៍ទៅមន្ទីរស-២១ ឬមជ្ឈិមបក្សនៅភ្នំពេញទេ ។ ក្រៅពីចម្លើយសារភាព យើងនៅដឹងបន្តិចបន្តួចដែរអំពីភស្តុតាងជាសំណេរដែលត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ចាប់មនុស្ស ឬធ្វើឡើងសម្រាប់អ្នកសួរចម្លើយធ្វើការនៅគុក ។ សំណួរតិចណាស់ដែលអ្នកទោសភាគច្រើនបានឆ្លើយបង្ហាញថាមានការចងក្រងឯកសារមួយចំនួនតូចដែលអមជាមួយអ្នកទាំងនោះទៅកាន់មន្ទីរ

ស-២១ ។

ជាទូទៅ អ្នកធ្វើការថ្នាក់ក្រោមត្រូវបានចោទប្រកាន់ដោយសមាជិករបស់ខ្លួននៅក្នុងជួរយោធានិងអន្តភាពបង្កបង្កើនផលដែលបានប្រព្រឹត្តសកម្មភាពមិនល្អ ឬដោយការចាប់ខ្លួនអ្នកនៅពីលើ ។ ប៉ុន្តែអ្នកទោសដែលត្រូវបានសួរចម្លើយយ៉ាងយូរ ត្រូវតែឆ្លើយអំពីទោសកំហុសក្បត់របស់ខ្លួន ក៏ដូចជាការពាក់ព័ន្ធជាមួយអ្នកដទៃ ។ ទោសកំហុសភាគច្រើនមានលក្ខណៈមិនគួរឲ្យជឿទាល់តែសោះ ។

នៅក្នុងចម្លើយសារភាពរបស់ខ្លួន អ្នកទោសតែងតែត្រូវបានឲ្យឆ្លើយដាក់អ្នកធ្វើការជិតដិតជាមួយខ្លួន ។ «ខ្សែក្បត់» ដែលមាននៅស្ទើរគ្រប់ចម្លើយសារភាពមានរហូតដល់រាប់រយ ដោយបង្កើតបានជាចំណាប់អារម្មណ៍មួយពីការសមគំនិតដ៏ធំនិងទូទាំងប្រទេស ។ នេះគឺជាអ្វីដែល ឌុច និងអ្នកនៅថ្នាក់លើតែងតែមាននៅក្នុងគំនិត ។ ស៊ីវ ហេដឌ័រ កត់សម្គាល់ថា «លោកទស្សនៈនៃចម្លើយសារភាពរបស់ (មន្ទីរស-២១) រួមទាំងបុគ្គលដែលកំពុងតែឆ្លើយសារភាព គឺអ្នកនៅពីលើដែលបញ្ចុះបញ្ចូលឲ្យបុគ្គលនោះក្បត់បដិវត្តន៍ និងអ្នកនៅខាងក្រោមដែលបុគ្គលនេះបញ្ចុះបញ្ចូលឲ្យក្បត់នឹងបដិវត្តន៍» ។ អ្វីៗគ្រប់យ៉ាងគឺត្រូវបានមើលឃើញជាខ្សែសង្វាក់និងកម្លាំង ។ មានអ្នកទោសតិចណាស់ដែលសារភាពថាបានធ្វើការសម្រេចចិត្តដោយខ្លួនឯង ។ តែផ្ទុយទៅវិញអ្នកទោសជាទូទៅឆ្លើយថា ត្រូវបានលង់ចូលឬក្បត់បដិវត្តន៍ដោយសារអ្នកមានបុណ្យស័ក្តិខ្ពស់ដែលពូកែខាងវោហារ និងពូកែពាក់ទាក់ ។ ឧទាហរណ៍ជាក់ស្តែងឈ្មោះ អែម ជឿន បានពុតការនិយាយអំពីការខកខានរបស់បដិវត្តន៍ក្នុងការបញ្ចេញសម្ភារប្រើប្រាស់ឲ្យបានសំបូរគ្រប់គ្រាន់ ។ មួយឆ្នាំក្រោយមក ជឿន បានសារភាពថា «ខ្ញុំបានពុតការនិយាយរបៀបនេះច្បាស់ណាស់ ។ ខ្ញុំខឹងនឹងបក្ស ហើយក៏ចាប់ផ្តើមបំផ្លាញបក្ស» ។ ហាក់ គីម ឈាង ដែលធ្លាប់ត្រូវគ្រូបង្រៀនវាយកាលពីក្មេង និយាយថា គាត់ត្រូវបាន «ភ្នាក់ងារស៊ើបការណ៍ចិន» ជ្រើសរើសនៅថ្ងៃត្រង់នៅពេលនោះតែម្តង នៅពេលដែលខ្លួនកំពុងយំ ហើយយុវតី គីម ភួង ក៏ត្រូវបានទាក់ទាញឲ្យចូលធ្វើសកម្មភាពក្បត់ ក្រោយពីមានការរៀបរាប់អំពីកម្មសិទ្ធិដែលខ្លួននឹងទទួលបានពីការគាំទ្រ «សេរីភាព» ។

ជារឿយៗ អ្នកនាំចូលបដិវត្តន៍ក្រោយមកក៏ត្រូវបានចោទប្រកាន់ថា បានជំរុញឲ្យអ្នកដែលខ្លួនបាននាំឲ្យចូលឲ្យក្បត់នឹងបដិវត្តន៍ ។ ប្រហែលជាដោយសារត្រូវបានបំភ័យ និងមានការឈឺចាប់អ្នកទោសជាច្រើនបានក្បត់អ្នកដែលនាំខ្លួនចូលបក្ស ដោយរំពឹងទុកថា ពត៌មាននេះគឺជាអ្វីដែលអ្នកសួរចម្លើយចង់បានបំផុត ។ កង្វះសមត្ថភាពរបស់របបនេះដែលបញ្ចូលសុទ្ធតែ «ខ្មាំង» មកធ្វើការនៅក្នុងជួរបក្សកុម្មុយនិស្តកម្ពុជា មិនដែលត្រូវបានលើកយកមកនិយាយឡើយ ។ ប៉ុន្តែការរៀបរាប់តាមដំណើរដើមទងនូវការក្បត់តាមរយៈចម្លើយសារភាព គឺមានបំណងសង្កត់ធ្ងន់ទៅលើចរិតសមគំនិតនៃសង្គមនៅក្រៅបក្សនិងកាត់បន្ថយព្រមទាំងធ្វើឲ្យគ្រោះថ្នាក់ដល់សកម្មភាពបដិវត្តពិតៗរបស់អ្នកទោស ឬអតីតបក្ខពួករបស់អ្នកទោសទាំងនោះ ។

នៅក្នុងទម្រង់ការនេះ បុរស-ស្ត្រីជាច្រើនដែលបានលះបង់ជីវិតដើម្បីបុព្វហេតុបដិវត្តន៍ ដែលរួមទាំងអ្នកធ្លាប់ធ្វើការជិតដិតជាមួយ ប៉ុល ពត ជាច្រើននាក់ទៀត ត្រូវបានបង្ខំឲ្យឆ្លើយសារភាពអំពីការពាក់ព័ន្ធរបស់ខ្លួនតាំងពីយូរណាស់មកហើយជាមួយ សេ.អ៊ី.អា ។ អ្នកទោសម្នាក់ឈ្មោះ រ៉េ បូ យ៉ាងហោចណាស់បានដឹងអំពីអ្វីដែលខ្លួនត្រូវឆ្លើយៈ «ខ្ញុំជាជនក្បត់តាំងពីថ្ងៃដែលខ្ញុំបានចូលបដិវត្តន៍ដល់ថ្ងៃដែលខ្ញុំត្រូវបានចាប់ខ្លួន» ។ តើវាអាចទៅជារឿងផ្សេងបានដែរឬទេ? នៅក្រោមក្រសែភ្នែករបស់មជ្ឈិមបក្ស អ្នកណាចូលបដិវត្តន៍ដោយស្មោះត្រង់ មិនអាចក្បត់បដិវត្តន៍វិញទេ ។ បញ្ច្រាសមកវិញ អ្នកដែលក្បត់បដិវត្តន៍ មិនអាចស្មោះត្រង់បានទេ ។

«ចំណុចខ្វះខាត» នៅក្នុងចម្លើយសារភាពនៅមន្ទីរស-២១ ត្រូវបាន ឌុច និងអ្នកធ្វើការជាមួយ យល់ថា មិនមែនជាភ័ស្តុតាងបង្ហាញថាអ្នកទោសមិនចាំអ្វីនោះទេ តែយល់ថាជាឱកាសដែលអ្នកទោសប៉ុនប៉ងលាក់បាំងការពិតទៅវិញទេ ។ ភាពរួញរាឬមិនច្បាស់លាស់ ធ្វើឲ្យអ្នកសួរចម្លើយមានការស្មុគស្មាញ ហើយក៏ចាត់ទុកជាភ័ស្តុតាងបញ្ជាក់ពីកំហុសរបស់អ្នកទោសតែម្តង ។ តាមពិតភាគច្រើន ភាពឯកា ការដេកមិនលក់ ទារុណកម្ម និងការភ័យខ្លាច បានធ្វើឲ្យអ្នកទោសប្របូកប្របល់ក្នុងចិត្ត ទទួលឥទ្ធិពល




ឬទទួលរងនូវអំពើទាំងពីររួចទៅហើយ ។

វិធីសាស្ត្រទាំងពីរនេះត្រូវបានអ្នកសួរចម្លើយនៅមន្ទីរ ស-២១ យកមកប្រើប្រាស់ដូចៗគ្នា ដើម្បីជម្រិតយកលទ្ធផលចុងក្រោយត្រូវបានហៅថា “ធ្វើនយោបាយ” និង “ដាក់ទារុណកម្ម” ដែលត្រូវលើកយកមកពិភាក្សានៅក្នុងវគ្គទី៥ ។ “ធ្វើនយោបាយ” មានន័យថាចោទប្រកាន់អ្នកទោសដោយសួរសំណួរនិងបញ្ចុះបញ្ចូលថាបក្សបានដឹងកំហុសរបស់អ្នកទោសរួចហើយ ។ សៀវភៅរៀនសូត្រឆ្នាំ១៩៧៦បានសរសេរដំណើរការសួរចម្លើយដែលមានប្រាំពីរចំណុច÷ ១)ទីមួយស្រង់យកពត៌មានពីវា ២)បន្ទាប់មកប្រមូលចំណុចឲ្យបានច្រើនដើម្បីសង្កត់ឲ្យជាប់និងកុំឲ្យវាចេញរួច ៣)សង្កត់ដោយឃោសនានយោបាយ ៤)គាបសួរបៀបប្រមាថ ឬធ្វើឲ្យខឹង ៥)ធ្វើទារុណកម្ម ៦)ពិនិត្យសាឡើងវិញ និងវិភាគចម្លើយដើម្បីសួរសំណួរបន្ថែម ៧)ពិនិត្យសាឡើងវិញនិងវិភាគចម្លើយដើម្បីរៀបចំជាឯកសារ ។

ចំណុចចាប់ផ្តើមនិងបញ្ចប់រំឭកអំពីដំណើរការរបស់នគរបាលនៅគ្រប់ទីកន្លែងទាំងអស់ ប៉ុន្តែបញ្ហាកើតឡើងនៅត្រង់ចំណុចទី២ដល់ទី៥ ។ ភាពខុសគ្នារវាង “ឃោសនានយោបាយ” និង “សួរបៀបប្រមាថឬធ្វើឲ្យខឹង” ហើយកម្រិតរវាង “ការគាបសង្កត់” និង «ទារុណកម្ម» មិនកំណត់ច្បាស់លាស់ទេ ។ ការធ្វើអំពើអមនុស្សធម៌ទៅលើអ្នកទោស ទំនាក់ទំនងអំណាចមិនស្មើនៅមន្ទីរស-២១ ការសម្របតាមវប្បធម៌របស់អ្នកទោសនិងភាពបន្ទាន់ដែលធ្វើឡើងនៅពេលធ្វើទារុណកម្ម បានធ្វើឲ្យមានអំពើឃោរឃៅក្នុងទ្រង់ទ្រាយធំ ។ អស់រយៈពេលយ៉ាងយូរមុនពេលធ្វើទារុណកម្ម ការសួរចម្លើយត្រូវធ្វើឡើងជាប្រចាំដោយការទាត់ធាក់វាយតប់ ។ អតីតឆ្មាំគុកម្នាក់ឈ្មោះ គក ស្រស់ បានរំឭកថា ជារឿយៗអ្នកទោសមាន “ឈាមជោគខ្លួន” នៅពេលនាំចូលទៅក្នុងបន្ទប់តូចវិញ ហើយរូបថតពាក់កណ្តាលខ្លួនរបស់អ្នកទោសជាច្រើន បង្ហាញឲ្យឃើញអំពីការវាយដំច្រំធាក់ ។ ការសង្កេតឃើញរបស់ គក ស្រស់ ក៏មិនខុសគ្នានឹងសម្តីរបស់អ្នកដែលមានជីវិតរស់ចាកផុតពីសេចក្តីស្លាប់នៅមន្ទីរស-២១ ឈ្មោះ ផា ចាន់ថា ដែរ ។

ទាក់ទងនឹងការ“ធ្វើនយោបាយ” វាមិនខុសគ្នាអ្វីទៅនឹងរបៀបដែលត្រូវបានធ្វើនៅវៀតណាមកាលពីទសវត្សរ៍ឆ្នាំ ១៩៥០ទេ ។ នៅក្នុងយុទ្ធនាការកែទម្រង់ដីធ្លីធ្វើឡើងដោយរដ្ឋាភិបាលកុម្មុយនិស្តដែលទើបលើកបន្តុបថ្មី អ្វីដែលហៅថាក្បួន “ទ្រុយបុក” ត្រូវបានយកមកប្រើក្នុងការស្រង់យកចម្លើយពី “ម្ចាស់ដី” នៅតាមជនបទដែលត្រូវបានចោទប្រកាន់ ។ ពាក្យថា “ទ្រុយបុក” ដែលសម្រាយមកថា “សួរអង្កៀម” ពិពណ៌នាអំពីដំណើរការដែលត្រូវបានយកមកប្រើនៅក្នុងការ “ធ្វើនយោបាយ” នៅមន្ទីរស-២១ និងកន្លែងសួរចម្លើយផ្សេងៗទៀត ។

ទម្រង់នៃគាបសង្កត់តាមរយៈពាក្យសម្តីដែលត្រូវបានប្រើ គឺពិបាកយល់ណាស់ ។ ស្ទើរតែគ្រប់ចម្លើយសារភាពសំណួររបស់អ្នកសួរចម្លើយត្រូវលុបចោល ។ ការសួរចម្លើយប្រភេទនេះដែលត្រូវបានលើកឡើងយ៉ាងច្បាស់ដោយអ្នកនិពន្ធ អារទូឡុនដុន, សូលហេវ្សនីតស៊ីន, ហ្សាកូបូ ទីមឺម៉ាន និងអ្នកនិពន្ធដទៃទៀត មិនបានយកមកសរសេរឡើយ ។

**(នៅមានត)**

# គុកជ្រៃអូរញ្ញៅ

ជ្រៃអូរញ្ញៅ ជាឈ្មោះភ្នំមួយដែលអ្នកស្រុកអ្នកភូមិនៅស្រុកគងពិសី ខេត្តកំពង់ស្ពឺ និយមហៅតាំងពីដើមរៀងមក ។ ក្នុងរយៈពេលជាង៣ឆ្នាំដែលគ្រប់គ្រងដោយរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ភ្នំនេះបានប្រែក្លាយទៅជាទីតាំងធ្វើទារុណកម្មមនុស្សយ៉ាងចំហមួយក្នុងភូមិភាគនិរតី ។ ក្នុងចម្ងាយដីជាង៤០គីឡូម៉ែត្រពីភ្នំពេញ តាមផ្លូវជាតិលេខ៣ និងក្នុងចម្ងាយដីជាងពីរគីឡូម៉ែត្រពីផ្សារដើមរកា (ប៉ែកខាងកើតថ្នល់ជាតិលេខ៣) តាមបណ្តោយផ្លូវក្រួសក្រហមមួយខ្សែ ខ្ញុំបានទៅដល់ភ្នំមួយដែលឈរជង្រ្គឹងប៉ែកខាងត្បូងផ្លូវលំមួយខ្សែនេះ ។ ភ្នំនោះគឺជាភ្នំជ្រៃអូរញ្ញៅ ។ ភ្នំនេះគ្មានបានបន្សល់ទុកនូវអ្វីដែលជាភស្តុតាងធំដុំឡើយ ក្រៅពីស្រះទឹកដែលជីកដោយកម្លាំងអ្នកទោស និងអគារបាក់បែកមួយខ្នងនៅពីមុខសាលាបឋមសិក្សាមួយនៅជាប់ខាងកើតជើងភ្នំ ដែលជាអតីតមន្ទីរពេទ្យប្រចាំសហករណ៍ខ្មែរក្រហម ។

មន្ទីរសន្តិសុខជ្រៃអូរញ្ញៅស្ថិតនៅក្នុងភូមិជើងភ្នំ ឃុំវាល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ តំបន់៣៣ ភូមិភាគនិរតី ។ មន្ទីរសន្តិសុខនេះត្រូវបានបង្កើតឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យនាចុងឆ្នាំ១៩៧៦ ហើយត្រូវបានផ្តល់ឈ្មោះឲ្យថា មន្ទីរសន្តិសុខតំបន់៣៣ ឬមន្ទីរសន្តិសុខជ្រៃអូរញ្ញៅ ។ នៅមន្ទីរសន្តិសុខជ្រៃអូរញ្ញៅមានការសម្លាប់មនុស្ស ដែលខ្មែរក្រហមគិតថាជាមនុស្សជាប់និន្នាការនយោបាយពីសង្គមមុន ដែលត្រូវជាប្តី ជាឪពុក ឬជាមេគ្រួសារ ដោយបន្សល់តែកូនគ្មានឪពុកជាមួយម្តាយដែលជាមេម៉ាយ...គ្មានប្រជាជន ឬអតីតអ្នកទោសណាម្នាក់បានស្គាល់អ្នកធ្វើការនៅក្នុងមន្ទីរសន្តិសុខជ្រៃអូរញ្ញៅច្បាស់ឡើយ ក្រៅពីតាខុន(កំបុតដៃម្ខាង) ដែលជាប្រធានមន្ទីរសន្តិសុខ និងតាបែន ជាអនុប្រធាន ។ លើសពីនេះអ្នកស្រុកភាគច្រើនដែលរស់នៅក្នុងឃុំវាល បានពន្យល់យ៉ាងក្បោះក្បាយថា សុទ្ធតែជាសមាសភាពមកពីតំបន់ផ្សេងទាំងអស់ ។ អ៊ំប្រុស ខៀវ ឡូ បាននិយាយថា "ពួកវា (សន្តិសុខខ្មែរក្រហម) សុទ្ធតែនិយាយរដឺនៗ" ។ គ្មានពួកសន្តិសុខណាម្នាក់មានដើមកំណើតនៅភូមិក្បែរៗមន្ទីរសន្តិសុខនេះឡើយ ។ លោក មាស មាំង ប្រាប់ថា "ពួកអាសន្តិសុខខ្មែរក្រហមនេះភាគច្រើនមកពីខាងជាំសង្កែ (ស្រុកថ្កូង) ឬកាត់ភ្លុក មិនមាននៅស្រុកនេះទេ" ។

ភូមិភាគនិរតីស្ថិតក្រោមការគ្រប់គ្រងរបស់ តាម៉ុក ក្នុងអំឡុងឆ្នាំ១៩៧៥-៧៩ ហើយក៏ជាភូមិភាគឈានមុខនិងគំរូមួយក្នុងវិស័យបោសសម្អាតខ្មាំងគ្រប់ប្រភេទរបស់អង្គការ ។

ពាក្យ "**បដិវត្តន៍កម្មេច ឬ អង្គការកម្មេច**" ជាពាក្យដែលអ្នកជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខជ្រៃអូរញ្ញៅ ធ្លាប់ឮឡើងស៊ាំត្រចៀកទៅហើយនោះ ក៏នៅតែជាពាក្យមួយម៉ាត់ដែលធ្វើឲ្យអតីតអ្នកទោសនៅមន្ទីរសន្តិសុខជ្រៃអូរញ្ញៅមានការឈឺចាប់អស់មួយជីវិត ។ អ៊ំ ណាប់ ត្អូញត្អែរថា "មូលហេតុពួកខ្មែរក្រហមចាប់ខ្លួនខ្ញុំយកទៅដាក់នៅជ្រៃអូរញ្ញៅ ព្រោះគ្រួសាររបស់ខ្ញុំត្រូវបដិវត្តន៍កម្មេច" ។ ប្តីរបស់លោកយាយត្រូវពួកខ្មែរក្រហមបញ្ឆោតដោយសរសេរសំបុត្រមកប្រាប់ថាឲ្យទៅមើលថែរក្សាបងរបស់គាត់ម្នាក់ទៀត ដែលជាគ្រូសង្ឃរាជដែលកាលនោះ




អ៊ឹ ណាប់

ពាក្យសម្តីនៅក្នុងសំបុត្របានបញ្ជាក់ថា «គាត់មានទុក្ខធ្ងន់ណាស់» ។ តាមពិតគ្រួសង្សារជនោះត្រូវពួកខ្មែរក្រហមយកទៅសម្លាប់តាំងពីឆ្នាំ១៩៧០មកម្ល៉េះ ។ លោកយាយបន្តថា «ពេលបាត់គាត់ ខ្ញុំខំដើររកគ្រប់ច្រកល្ហក ។ ទៅសួររហូតដល់ប្រធានភូមិទៀត ទីបំផុតទើបប្រធានភូមិនោះប្រាប់ខ្ញុំថា ប្តីខ្ញុំត្រូវបដិវត្តន៍កម្ទេចបាត់ហើយ» ។ លោកយាយបានត្រឹមបង្ហូរទឹកភ្នែករាល់ថ្ងៃមិនហ៊ានស្តីបន្ទោស ឬទាមទារឲ្យអង្គការសងប្តីសម្លាញ់របស់គាត់វិញឡើយ ព្រោះខ្លាចពួកឈ្លបទាំងនោះយកគាត់ទៅសម្លាប់ទៀត ។ មិនត្រឹមតែគ្រួសារលោកយាយប៉ុណ្ណោះទេដែលទទួលការបែកបាក់គ្រួសារ នៅមានគ្រួសារជាច្រើនទៀតដែលមិនអាចគេចផុតបានដូចគ្នា ។ លោក ប្រាក់ សារិន ជាជិទប់លេខ២ ឃុំវាល ស្រុកគងពិសី បានពន្យល់ ថា «អ្នកទោសដែលមកជាប់នៅគុកជ្រៃអូរញ្ញៀនេះ សុទ្ធសឹងតែជាអ្នកមានគ្រួសារដែលត្រូវបដិវត្តន៍កម្ទេច មានន័យថាឲ្យតែមានកូន ប្តី ឬប្រពន្ធនៅក្នុងបន្ទុក ហើយត្រូវអង្គការយកទៅសម្លាប់នោះ គឺគ្រួសារហ្នឹងត្រូវយកទៅដាក់នៅក្នុងគុកជ្រៃអូរញ្ញៀទាំងអស់» ។ ក្នុងការប្រមូលយកទៅនេះ គឺសូម្បីតែក្មេងតូចៗ ឬចាស់ជរានៅក្នុងបន្ទុកដែលដើរមិនរួច ក៏ពួកខ្មែរក្រហមយកទៅទាំងអស់ដែរ ។ លោក ប្រាក់ សារិន បន្តថា «បានជាយើងថាអ៊ីចឹងគឺប្រហែលមកពីខ្មែរក្រហមគិតថាអាចប្រមូលផ្តុំដើម្បីងាយស្រួលក្នុងការគ្រប់គ្រងនិងរឹតបន្តឹង ។ ព្រោះយើងសុទ្ធតែដឹងថាគ្រួសារនោះសុទ្ធតែគ្រួសារអ្នកដែលមានកំហឹងជាមួយអង្គការ» ។ អ្នកស្រុកម្នាក់រស់នៅភូមិព្រៃខ្ទុង ឃុំវាលបាននិយាយពីការចាប់យកមនុស្សទៅដាក់នៅជ្រៃអូរញ្ញៀថា ចាប់មិនដែលមានខុសមួងណាឡើយ ព្រោះពួកកងឈ្លប ឬប្រធានភូមិឃុំសុទ្ធតែមានបញ្ជីចាប់ខ្លួនត្រឹមត្រូវ ។ អ៊ឹស្រី ប្រាក់ គី ជាប្រជាជនរស់នៅក្នុងភូមិព្រៃខ្ទុង បានរៀបរាប់ថា ពេលដែលមកចាប់ខ្លួននោះគឺមិនមែនមកចាប់យកទៅតែម្តងទេ គឺពួកកងឈ្លបមកនិយាយតាមសម្រួល និងមានភាពគួរសម ព្រមទាំងកាយវិការទន់ភ្លន់ទៀតផង ។ តាមពិតកាយវិការ និងពាក្យសម្តីរបស់ពួកឈ្លបខ្មែរក្រហមសុទ្ធតែផ្ទុយទៅនឹងធាតុពិតដែលមាននៅក្នុងចិត្តអ្នកទាំងនោះ ។ ប្តីរបស់អ៊ឹស្រី ប្រាក់ គី ត្រូវពួកប្រធានសហករណ៍បញ្ឆោតយកទៅសម្លាប់កាលពីខែមករា ឆ្នាំ១៩៧៦ ដោយយកលេសថាឲ្យទៅដឹកជញ្ជូនត្រវ៉ាន់ពីសហករណ៍ ។ ក្រោយពីប្តីត្រូវសម្លាប់ហើយ ក្រុមគ្រួសាររបស់អ៊ឹស្រីក្លាយទៅជាគ្រួសារដែលអង្គការចាត់ទុកជា «គ្រួសារអង្គការកម្ទេច» ហើយត្រូវក្លាយខ្លួនជាអ្នកទោសនៅជ្រៃអូរញ្ញៀជាមួយក្រុមគ្រួសារដទៃជាច្រើនទៀត ។

ប្រជាជនមកពីតំបន់២៥បូករួមទាំងទាហានពីភូមិភាគបូព៌ា ដែលកាលនោះត្រូវបានចោទថាក្បត់ហ្នឹងអង្គការបក្ស ក៏ត្រូវដឹកយកមកដាក់និងសម្លាប់នៅជ្រៃអូរញ្ញៀនេះដែរ ។ លោក


ប្រាក់ សារិន

ប្រាក់ សារិន បានប្រាប់ពីការគាស់រណ្តៅសាកសពជាច្រើនកន្លែងជុំវិញបរិវេណមន្ទីរសន្តិសុខជ្រៃអូរញ្ញៀ កាលពីឆ្នាំ១៩៨២ ថាបានឃើញស្រស់ៗនូវខោអាវទាហានពណ៌ត្រួយចេកដែលស្រោបខ្លួនសាកសពចំនួនរាប់រយនាក់ ។ គាត់ស្គាល់ច្បាស់ថា នេះជាខោអាវរបស់ទាហានភូមិភាគបូព៌ា ។ លោកយាយ ណាប់ បញ្ជាក់បន្ថែមថា លោកយាយបានឃើញពួកខ្មែរក្រហមដឹកមនុស្សមកទាំងឡានៗចូលមកគុកជ្រៃអូរញ្ញៀ ប៉ុន្តែក្រោយមកមិនដែលឃើញមនុស្សទាំងនោះឡើយ ។ ទាហានជាច្រើនត្រូវបានលោកយាយរាយការណ៍ថា ដឹកម្តងពី៥ទៅ៦ឡានចូលមកហើយឃើញតែសំបកឡានទទេចេញទៅវិញ ។

អ្នកទោសម្នាក់ៗនៅគុកជ្រៃអូរញ្ញៀ សុទ្ធតែត្រូវធ្វើការងារយ៉ាងច្រើនក្នុងមួយថ្ងៃៗ ។ មាស លាភ និយាយទាំងហួសចិត្តថា «បន្ទាប់ពីយកខ្ញុំមកភ្នំជ្រៃអូរញ្ញៀ ពួកសន្តិសុខប្រើខ្ញុំខ្វាំងជាងនៅឯក្រៅទៀត ។ ខ្ញុំត្រូវភ្ជួរស្រែពីម៉ោង៣ភ្លឺដល់ម៉ោង១២ថ្ងៃត្រង់ទើបបានឈប់ ។ ភ្ជួររួចហើយអត់បានឈប់សម្រាកទេ ត្រូវទៅឃ្វាលគោម្នាក់៣នឹមទៀត ។ ឃ្វាលគោ៣នឹមហើយ

ម៉ោង៣ចាប់ភ្ជួរទៀត ។ អាសល់ពីនោះ អ្នកអត់ឃ្វាលគោត្រូវទៅភ្ជួរស្រែ ។ ការងារនៅក្នុងមន្ទីរសន្តិសុខជ្រៃអូរញ្ញៅត្រូវបានបែងចែកជាកម្លាំងទី១ ទី២ ទី៣....ទៀត ។ អ្នកទោសណាដែលមានកម្លាំងខ្លាំងត្រូវចូលទៅក្នុងកម្លាំងទី១ អ្នកបន្ទាប់គឺទី២ ហើយអ្នកខ្សោយបំផុតដូចយាយៗត្រូវស្ថិតនៅក្នុងកងមើលចៅឬមើលក្មេងតូចៗដែលម្តាយត្រូវទៅធ្វើការឆ្ងាយៗពីកន្លែង ។ ជួនកាលពួកសន្តិសុខក៏ប្រើយាយៗទាំងនោះឲ្យទៅធ្វើ


ប្រាក់ គី

ស្រែនិងរែកដីដែរ ។ អ៊ំស្រី ប្រាក់ គីស្ថិតក្នុងកងដកស្ទូង រែកដី លើកទំនប់ជីកប្រឡាយឬជីកស្រះ... ។ កូនខ្ចីរបស់គាត់ត្រូវយកទៅឲ្យយាយៗជាអ្នកមើលថែ ។ ពេលល្ងាចឬយប់ម៉ោង៨ ម៉ោង៩ ទើបគាត់ទៅយកកូនពីយាយៗមកឲ្យបៅឲ្យដេក ។ ការងារមិនកំណត់ថាយប់ ឬថ្ងៃឡើយ ។ កាលណាខែភ្លឺ កងនារី-យុវជនត្រូវទៅធ្វើការទាំងយប់តាមផែនការដាក់ចុះពីគណៈកង ។ បងស្រី មាស រុំ អាយុ៣៨ឆ្នាំ រស់នៅភូមិព្រៃខ្នុង ឃុំវាល និយាយទាំងអស់សំណើចថា “ជួនកាលពួកខ្ញុំរែកដីប្រណាំងគ្នាដើម្បីបានហូបឆ្អែត” ។ គ្មានមធ្យោបាយណាមួយអាចឲ្យបងស្រីនិងអ្នកឯទៀតហូបបានឆ្អែតឡើយ លើកលែងតែថ្ងៃទី១០ និងទី២០ ជារៀងរាល់ខែដែលអាចហូបឆ្អែតបាន ។ ជំទប់ទី២ឃុំវាល បានពន្យល់ថា ឲ្យតែដល់ថ្ងៃទី១០និងទី២០គឺពួកខ្មែរក្រហមបន្ធូរបន្ថយច្រើនដល់ការជួបជុំសាច់ញាតិបងប្អូន ប្តី ប្រពន្ធ តែនៅក្នុងបរិវេណគុកប៉ុណ្ណោះ ។ ការហូបចុកគឺបានឆ្អែតល្មមដែរ ។

មានសហករណ៍ចំនួន៦ជាចំណុះរបស់មន្ទីរសន្តិសុខជ្រៃអូរញ្ញៅ ។ សហករណ៍ទាំងនេះសង់ជារោងវែងៗ ដែលផ្ទុកមនុស្សជាច្រើនពាន់នាក់ ។ ប៉ុន្តែសុទ្ធតែមានការបែងចែកតាមប្រភេទកម្លាំង ។ តាមសហករណ៍នីមួយៗគឺមានមន្ទីរពេទ្យមួយសម្រាប់ព្យាបាល ។ លោកយាយ ណាប់ បានប្រាប់ថា ពេទ្យនេះអាចព្យាបាលបានតែប្រភេទជម្ងឺធ្ងន់ៗប៉ុណ្ណោះ ។ ទោះជាយ៉ាងនេះក៏ដោយ មានមនុស្សស្លាប់ជារៀងរាល់ថ្ងៃដោយសារតែឈឺនិង


មាស រុំ

អត់បាយ ។ អ្នកជិតរបស់ខាង យាយ ណាប់ បានស្លាប់ដោយសារជំងឺ ។ អ្នករួមការងារជាមួយបងស្រី មាស រុំ បានស្លាប់ដោយសារឃ្លានខ្លាំងពេក ។ បងស្រី រុំ បាននិយាយថា “ខ្ញុំបានជួបប្រទះមនុស្សស្លាប់ក្បែរខ្លួនពីរ-បីដង ដូចជាឈ្មោះ ថុល ម្នាក់ទៀតឈ្មោះ ម៉ាប់ និងម្នាក់ទៀតភ្លេចឈ្មោះ” ។

ទិដ្ឋភាពសម្លាប់មនុស្សទាំងកណ្តាលថ្ងៃ ខ្មោចស្លាប់ក្បែរខ្លួនទាំងកណ្តាលអធ្រាត្រ មិនត្រឹមតែធ្វើឲ្យមនុស្សមានវ័យ៤០ឆ្នាំដូចមីង គី លែងខ្លាចខ្មោច សូម្បីតែក្មេងស្រីអាយុទើប១៣ឆ្នាំដូច រុំ លាភ និង សារឿន ក៏នឹកមិនឃើញរឿងខ្លាចខ្មោចលងដែរ ។ រុំ រំឭកថា “ដំបូងខ្ញុំភ័យយំរាល់យប់ ដល់យូរៗទៅធម្មតា បើយប់ណាក៏មានងាប់ យូរទៅដូចជារស់នៅជាមួយខ្មោចទៅហើយ ។ ក្នុងក្រុមកុមារី យប់ណាក៏មានងាប់ដែរ ព្រោះពេលយើងវិលត្រឡប់មកពីធ្វើការវិញហេវហត់ ឈឺរងា ខ្លួនទទឹកជោគហើយនាំគ្នាចូលដេកអត់មានមុងភួយអ្វីទាំងអស់ ។ ព្រលឹមឡើងពេលមេកងមកដាស់ឲ្យងើបឡើងទៅធ្វើការ ខ្លះងាប់រឹងស្តូកបាត់ទៅហើយ” ។

បញ្ហានយោបាយមិនត្រូវបានបញ្ចុះបញ្ចូលដល់អ្នកទោសចាស់ៗឡើយ មានតែការប្រជុំការងារម្តងម្កាលប៉ុណ្ណោះ ដែលរៀបចំឡើងដោយប្រធាននិងអនុប្រធានគុក គឺតា ខុន និងតាបែន ។ ប៉ុន្តែមានកើតឡើងខ្លះនូវការបញ្ចុះបញ្ចូលផ្នែកមនោគមវិជ្ជាចំពោះកុមារ ។ ក្នុងអង្គប្រជុំក្រុមកុមារវិញ តាមអតីតអ្នកទោសក្នុងសហករណ៍កុមារឲ្យដឹងថា ការប្រជុំម្តងៗគឺនិយាយតែអំពីការបំពាក់បំប៉នកុមារឲ្យខំធ្វើការងារឲ្យស្រឡាញ់អង្គការបដិវត្តឲ្យមានចិត្តដាច់ខាត ។ សារឿន រំឭកអំពីការបំពាក់បំប៉នមនោគមន៍វិជ្ជារបស់ប្រធានក្រុមកុមារក្នុងអង្គប្រជុំក្រុមកុមារនៅខាងជើងភ្នំជ្រៃអូរញ្ញៅថា “ថ្ងៃមួយ រ៉ា ប្រធានក្រុមខ្ញុំប្រជុំណែនាំកុមារយើងឲ្យខំធ្វើការបម្រើអង្គការ ព្រោះយើងជាកូនរបស់អង្គការ ។ កុមារត្រូវតែដាច់ខាត មិនត្រូវស្តាយស្រណោះអាឡោះអាល័យអ្វីទាំងអស់ ។ ឪពុកម្តាយយើងធ្វើខុសដូច្នេះត្រូវតែស្លាប់ហើយ

យើងក៏ត្រូវតែហ៊ានសម្លាប់ឪពុកម្តាយយើងដែរ ។ ពេលនិយាយចប់ វ៉ា ស្នួរកុមារក្នុងអង្គប្រជុំថា «មើល! មិត្តយើងណាខ្លះហ៊ានសម្លាប់ឪពុកម្តាយ? បើហ៊ានត្រូវលើកដៃ» ។ ពេលនោះទាំងខ្ញុំទាំងគេលើកដៃទាំងអស់គ្នា» ។

ក្រៅពីនេះ មានការប្រជុំជារៀងរាល់ថ្ងៃពីសំណាក់ប្រធានកងហ្វា ប្រធានកងរយ ឬប្រធានក្រុម ជាមួយកូនក្រុមរបស់ខ្លួនដែលជាអ្នកទោសដូចគ្នា ។ ការប្រជុំរបស់ប្រធានក្រុម ប្រធានកងហ្វា កងរយ គឺកើតមានជារៀងរាល់ល្ងាចពេលបាយហើយ ។ មាស លាភ បានឲ្យដឹងថា «ប្រជុំរាល់ថ្ងៃ ។ គេប្រជុំថាឲ្យយើងខំធ្វើការ ។ មេធំៗគឺប្រធានក្រុមហ្នឹង អ្នកបើកអង្គប្រជុំ ។ មុនដំបូង ថ្ងៃហ្នឹងប្រជុំប្រធានក្រុម ស្អែកប្រធានកងហ្វា ប្រធានកងរយ វិលមកក្រុមតូចៗវិញ» ។ ដូចសម្តីតា បែន និយាយកាលបើកអង្គប្រជុំ ហើយត្រូវយាយ ណាប់ ចាប់អារម្មណ៍លើកមកនិយាយថា «បែន និយាយពេលប្រជុំឲ្យប្រយ័ត្នខ្លួនឥឡូវដល់ពេលចម្រាញ់ដូចអង្ករអីចឹង គឺយើងចម្រាញ់យកតែដើម យកតែអាល្អ អាចុងមិនយកទេ គ្រវាត់ចោលហើយ» ។

វិន័យនៅក្នុងមន្ទីរសន្តិសុខជ្រៃអូរញ្ញោ ពិតជាពិបាកគោរពអនុវត្តតាមណាស់ ។ មូលហេតុអត់ឃ្លានធ្វើឲ្យមនុស្សយ៉ាងច្រើនសន្ធឹកសន្ធាប់នៅជ្រៃអូរញ្ញោស្លាប់ជាបន្តបន្ទាប់ ហើយក៏កាន់តែធ្វើឲ្យមនុស្សចេះលួចហ៊ានល្មើសនឹងច្បាប់ដែលបានដាក់ចុះ ។ អ្នកទោសម្នាក់ត្រូវបានស្លាប់ដោយសារតែរើសកូនកង្កែបមួយនៅពេលដែលខ្លួនកំពុងតែភ្ជួររាស់ ។ យាយ ណាប់ រំឭកថា «កាលនោះខ្ញុំអាណិតតានោះណាស់ ខ្ញុំឃើញពួកកងឈ្លបចាប់គាត់វ៉ៃនឹងគល់ឫស្សី ហើយបណ្តើរគាត់យកទៅបាត់ទៅ» ។ លោកតូ សារិន បានអធិប្បាយយ៉ាងក្បោះក្បាយថា «បន្ទុកនៃការទទួលខុសត្រូវក្នុងការសម្លាប់មនុស្សនៅភូមិភាគនិរតីគឺយើងពិបាកនិយាយណាស់ បើយើងនិយាយឲ្យចំទៅថា សម័យនោះបើចង់សម្លាប់ ឬមិនចង់សម្លាប់ មិនចាំបាច់សុំយោបល់ពីថ្នាក់លើទេ ថ្នាក់លើមិនគាបសង្កត់ មិនយកទោសទេ កម្មាភិបាលម្នាក់ៗសម្លាប់មនុស្សដូចសម្លាប់កូនកង្កែប» ។ តាមការរាយការណ៍របស់បងស្រី មាស រុំ ថា ចំនួនអ្នកទោសដែលស្លាប់ដោយជំងឺនិងអត់បាយមានចំនួនស្មើរតែស្មើគ្នានឹងអ្នកដែលត្រូវយកទៅសម្លាប់ ។ សាកសពអ្នកទោសទាំងនោះត្រូវបានអូសយ៉ាងទីណាត់ទីណែងយកទៅកប់ចោលនៅព្រៃស្តេច ព្រៃខ្នុង វត្តចំប៉ា... ។

ក្រោយបែកឆ្នាំ១៩៧៩ មានជនរងគ្រោះតិចណាស់ដែលបានរួចរស់ជីវិតចេញពីគុកជ្រៃអូរញ្ញោ ។ អ្នកដែលនៅរស់ទាំងនោះ ម្នាក់ៗសុទ្ធតែមានបាត់សមាជិកគ្រួសាររបស់ខ្លួនស្ទើរតែទាំងអស់ ។ មាស លាភ និងប្អូនស្រីបង្កើត មាស រុំ បានរ៉ាយរ៉ាប់ទាំងអួលដើមកថា គាត់បានបាត់បង់ម្តាយជាទីស្រលាញ់នៅពេលដែលអង្គការចាប់ម្តាយនិងកូនពីរនាក់ទៅដាក់នៅគុកជ្រៃអូរញ្ញោ បន្ទាប់ពីពីរខែនៃការចាប់ខ្លួនឪពុករបស់គាត់យកទៅកម្ទេច ។ មីង សុន បានឲ្យដឹងថា ជីវិតកូនស្រីពៅអាយុ៥ឆ្នាំរបស់គាត់ម្នាក់បានស្លាប់យ៉ាងវេទនាបំផុតនៅគុកជ្រៃអូរញ្ញោ ។ គួររំឭកដែរថា នៅឆ្នាំ១៩៧៧ មីង សុន រួមនឹងមនុស្ស១៧នាក់ ផ្សេងទៀតក្នុងភូមិភ្នំតូច ឃុំសូភី ស្រុកបាទី ខេត្តតាកែវ ត្រូវបានចាប់ខ្លួន ហើយបញ្ជូនតាមរទេះគោ២ទៅកាន់មន្ទីរសន្តិសុខភ្នំជ្រៃអូរញ្ញោ ។ មីង


លលាដ៍ក្បាលជនរងគ្រោះ

សុន រំឭកអំពីមូលហេតុនៃការចាប់ខ្លួនក្រុមរបស់គាត់ថា "ដោយសារយើងទាំងអស់គ្នាជាប្រពន្ធជាកូនខ្មាំងរបស់អង្គការ" ។ មីង គឺ បានស្លាប់កូនអស់ប្រាំនាក់នៅជ្រៃអូរញ៉ៅតែក្នុងរយៈពេលពីរឆ្នាំប៉ុណ្ណោះ ប្តីរួមទាំងប្តីរបស់មីងដែលត្រូវអង្គការកម្ទេចកាលពីខែមករា ឆ្នាំ១៩៧៦ គឺចំពេលដែលគាត់កំពុងមានផ្ទៃពោះ ៣ ខែ ។

ស្ត្រីនិងកុមាររាប់ម៉ឺននាក់ត្រូវបាត់ស្លាប់បង់ជីវិតនៅមន្ទីរសន្តិសុខភ្នំជ្រៃអូរញ៉ៅ ។ ស្ត្រីនិងកុមារដែលសល់ពីស្លាប់ ក្លាយជាស្ត្រីមេម៉ាយនិងក្មេងកំព្រា ។ សព្វថ្ងៃលោកយាយ ណាប់ រស់នៅតែម្នាក់ឯង គាត់ធ្វើការងារគ្រប់បែបយ៉ាង តាំងពីភ្ជួររាស់ ដកស្ទូងនិងការងារក្នុងផ្ទះ ។ លោកយាយ ណាប់ បានបន្តទាំងសំឡេងអួលដើមកថា "ពេលណាធ្វើដំណើរកាត់ភ្នំជ្រៃអូរញ៉ៅម្តងៗ ខ្ញុំតែងស្រមៃឃើញមនុស្សម្នាក្នុងសម្លៀកបំពាក់ខ្មៅរូបរាងស្គមស្គាំងខំប្រឹងដើរសំដៅទៅធ្វើការងារ ។ អ្នកខ្លះត្រូវចាប់វ៉ៃធ្វើបាបនិងសម្លាប់" ។

ស្តូបដែលសម្លាប់រង្គាលនៅក្នុងភូមិភាគនិរតី តួយ៉ាងដូចនៅភ្នំជ្រៃអូរញ៉ៅ បានរួមចំណែកធ្វើឲ្យថ្នាក់ដឹកនាំភូមិភាគទាំងមូលដូចតាម៉ុក ក្លាយជាជនឈានមុខក្នុងចលនាបុព្វហេតុបម្រើមាគ៌ាបដិវត្តន៍ក្រហមឆ្អិនឆ្អៅរបស់ខ្មែរក្រហមក្នុងអំឡុងឆ្នាំ១៩៧៥-៧៩ ។ ផ្ទុយមកវិញ ស្នាដៃរបស់ជនឈានមុខមហាលោតផ្លោះមហាអស្ចារ្យរូបនេះ បានធ្វើឲ្យកុមារនិងស្ត្រីរាប់ម៉ឺននាក់បាននិងកំពុងទទួលរងនូវការលំបាកវេទនានិងឈឺចាប់គ្មានថ្ងៃបំភ្លេចបានឡើយ ។

**ផេង ពង្សរ៉ាស៊ី**



បូជនីយដ្ឋានតម្កល់អដ្ឋិធាតុនៅវត្តស្អនពេជ្រ

## ពាក្យស្លោកខ្មែរក្រហម

- **ពង្រីកបន្ថែម ស្នេហាជាតិ និយមបដិវត្តន៍ និងមោទនភាពបដិវត្តន៍ ចំពោះជាតិខ្លួន ប្រជាជន កងទ័ពបដិវត្តនិងបក្សខ្លួនឱ្យរឹងដូចដែកជាប់ជានិច្ច។**
- **បង្កើនកម្លាំងចិត្ត កម្លាំងកាយ កម្លាំងប្រាជ្ញាទាំងអស់របស់បុគ្គល របស់អង្គភាព និងរបស់ជាតិទាំងមូល សាមគ្គីជាធ្លុងមួយ គស៊ូកម្ចាត់ខ្មាំងគ្រប់ប្រភេទ ពិសេសខ្មាំងយួនខាតទឹកលេបទឹកដី រក្សាការពារជាតិនិងពូជសាសន៍កម្ពុជាឱ្យគង់វង្សទាំងស្រុង ជារៀងរហូត។**
- **សមរភូមិមុខ ជាគំណាងដ៏ឆ្នើមនៃមោទនភាពបដិវត្តន៍របស់ប្រជាជាតិ និងប្រជាជនទាំងមូល។**

(ដកស្រង់ចេញពីសៀវភៅលេខ១០៧៦ កណាហ)

សូមសរសេរលិខិត
ឬអត្ថបទពិភាក្សាជុំវិញបញ្ហាខ្មែរក្រហម ផ្ញើមក
**ទស្សនាវដ្តី «ស្វែងរកការពិត»**
ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ឬតាមទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
ឬ Email: dccam@bigpond.com.kh

# តម្លៃនៃភស្តុតាង

**(តពីលេខមុន)** ដើម្បីកាត់សេចក្តីទៅលើអតីតមេដឹកនាំខ្មែរក្រហម អំពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការកាត់ក្តីនេះត្រូវបង្ហាញឲ្យឃើញថា ការវាយប្រហាររបស់ខ្មែរក្រហមមកលើខ្មាំងគឺសំដៅលើក្រុមជនស៊ីវិលហើយធ្វើឡើងដោយហេតុផលសង្គមនយោបាយ ជាតិសាសន៍ សាសនាឬវប្បធម៌ ។ ដើម្បីដាក់ពិរុទ្ធភាពបានសម្រេចទៅលើចុងចោទពីបទប្រល័យពូជសាសន៍ ភស្តុតាងដាក់បន្ទុកនឹងត្រូវបានតម្រូវកាន់តែធ្ងន់ឡើងជាងនេះទៅទៀត ពោលគឺតម្រូវថា មេដឹកនាំនៃបក្សកុម្មុយនិស្តកម្ពុជាមានចេតនាបំផ្លិចបំផ្លាញទាំងស្រុងឬដោយផ្នែកណាមួយតាមរយៈអំពើនៃការសម្លាប់ ការបង្ករបួសធ្ងន់ធ្ងរ ឬក៏ចាត់វិធានការណាមួយដែលបង្កភាពហិនហោចដល់ស្ថានភាពរស់នៅរបស់សញ្ជាតិមួយ ជាតិពន្ធុមួយ និងជាតិសាសន៍មួយ ឬក៏ក្រុមសាសនាមួយ ។

ការនាំផ្លូវនិងការយោងយ៉ាងច្បាស់ក្រឡែតនៃឯកសារជាច្រើនចំពោះអ្នកប្រឆាំងនឹងអង្គការ ដែលផ្តល់ជាភស្តុតាងមួយចំនួនថា អ្នកប្រឆាំងផ្នែកនយោបាយត្រូវបានចាត់ទុកជា “ខ្មាំង” ឬ “សមាសភាពមិនល្អ” ។ ឯកសារទាំងនេះនៅមានភស្តុតាងប្រយោលថែមទៀត គឺថាពាក្យទាំងនេះត្រូវបានប្រើសំដៅជនបរទេស (ជាពិសេសវៀតណាម) និងសង្ស័យជាភ្នាក់ងារសេ.អ៊ី.អា ឬមន្ត្រីមួយចំនួនរបស់ “ចក្រពត្តិអាមេរិក” ។ ការដៅកំណត់របៀបនេះបញ្ជាក់ពីមូលហេតុនាំដល់ការប្រព្រឹត្តអំពើឃោរឃៅរបស់ខ្មែរក្រហមដែលនឹងចូលជាលក្ខខណ្ឌចាំបាច់នៃបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។

ការប្រើប្រាស់ឯកសារតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការបង្ហាញឲ្យឃើញថាជាបទប្រល័យពូជសាសន៍អាចនឹងមានការពិបាកបន្តិចហើយ ។ ឯកសាររបស់បក្សកុម្មុយនិស្តកម្ពុជាមិនសូវមានសញ្ញាច្បាស់ៗច្រើនប៉ុន្មានទេ ដែលបង្ហាញថា “ខ្មាំង” ឬ “សមាសភាពមិនល្អ” រួមបញ្ចូលក្នុងក្រុមជាតិពន្ធុ ជនជាតិ ជាតិសាសន៍ ឬក្រុមសាសនា ។ តាមការកត់សម្គាល់ពីខាងលើឃើញថាឯកសារយោងដល់ជនជាតិវៀតណាមនិងកូកាហ្សិនមានកម្រិត ។ ឯកសារក៏មាននិយាយយោងចំៗដែរទៅដល់ជនជាតិថៃ ហើយនិយាយដល់កន្លែងមួយចំនួនដែលបក្សកុម្មុយនិស្តកម្ពុជាមានចេតនាលុបបំបាត់សាសនា ។ មិនតែប៉ុណ្ណោះ នៅមានភស្តុតាងប្រយោលសំខាន់ៗជាច្រើនទៀតដែលមាននៅក្នុងញត្តិធ្វើឡើងដោយអ្នកដែលនៅរស់រាន និងនៅក្នុងកិច្ចសម្ភាសន៍មួយចំនួនធ្វើឡើងដោយប្រវត្តិវិទូល្បីៗមួយចំនួនដែលបង្ហាញថាជនជាតិចាម វៀតណាម កូកាហ្សិន ព្រមទាំងក្រុមជនជាតិភាគតិចផ្សេងៗទៀត ត្រូវបានធ្វើឲ្យរងគ្រោះក្នុងចំនួនវិសមាមាត្រ ។ ក៏ប៉ុន្តែមានភស្តុតាងផ្ទាល់តិចតួចណាស់ក្នុងឯកសាររបស់បក្សកុម្មុយនិស្តកម្ពុជាដែលនិយាយដល់ “ខ្មាំង” និង “សមាសភាពមិនល្អ” រួមបញ្ចូលក្នុងក្រុមសាសនានិងក្រុមជនជាតិភាគតិចដែលត្រូវបានការពារដោយច្បាប់ ។ ការកាត់សេចក្តីប្រហែលជាត្រូវការជាចាំបាច់ក្នុងការធ្វើឲ្យមានសក្ខីកម្មមានទម្ងន់ពីអ្នកជំនាញនិងពីអតីតមន្ត្រីនៃបក្សកុម្មុយនិស្តកម្ពុជា ប្រសិនបើអាចធ្វើបានក្នុងការបង្ហាញឲ្យឃើញថាមានបញ្ជាក់ពាក្យ “ខ្មាំង” និង “សមាសភាពមិនល្អ” រួមបញ្ចូលក្នុងក្រុមដែលចាត់ចូលជាមុខសញ្ញាដោយហេតុផលជាតិសាសន៍ ជនជាតិ ជាតិពន្ធុ និងសាសនា ។

ចំពោះពាក្យសម្គាល់ផ្សេងៗទៀតរបស់បក្សកុម្មុយនិស្តកម្ពុជា បញ្ហានៅក្នុងការកំណត់ពាក្យថា “ខ្មាំង” និង “សមាសភាពមិនល្អ” គឺជាភាពមិនច្បាស់លាស់ដែលផ្តល់ជាផ្លូវដោះទ័លយ៉ាងសំខាន់ដល់ភាគីចុងចោទ ។ ការកាត់សេចក្តីត្រូវតែបង្ហាញថាពាក្យទាំងនេះតែងតែត្រូវបានយកមកប្រើយ៉ាងហោចណាស់ក៏មួយផ្នែកដែរសម្រាប់ដៅក្រុមមនុស្សឲ្យក្លាយជាមុខសញ្ញាដោយសារហេតុផលនយោបាយ សាសនា ជនជាតិ ជាតិសាសន៍ ឬជាតិពន្ធុ ។

ប្រសិនបើភាគីចុងចោទបង្ហាញថា ពាក្យទាំងនេះជួនកាលត្រូវបានប្រើដៅទៅលើខ្មែរក្រហមជន កងប្រដាប់អាវុធបរទេស ឈ្លានពានទឹកដី ឬខ្មាំងផ្ទាល់ខ្លួននៃវីរជនរបស់បក្សកុម្មុយនិស្តកម្ពុជា នោះនឹងអាចរកបានទទ្ទីករណ៍ដែលមានសុពលភាពគ្រប់គ្រាន់បញ្ជាក់ថា រាល់ការប្រើប្រាស់ពាក្យនេះគឺមិនច្បាស់លាស់ទេ ហើយក្នុងករណីណាមួយអាចនិយាយយោងទៅដល់ក្រុមដែលមិនមានការការពារដោយច្បាប់ទៀតផង ។

មិនខុសពីនិយមន័យរបស់ពាក្យ"កម្ទេច" និង "បោសសម្អាត" ឡើយពាក្យថា "ខ្មាំង" និង "សមាសភាពមិនល្អ" ចាំបាច់ត្រូវតែកំណត់ន័យឲ្យបានជាក់លាក់ ។ នៅក្នុងករណីមួយចំនួន ដូចជានៅពេលដែលបទបញ្ជានយោបាយដ៏ទូលាយត្រូវបានចែងឲ្យអនុវត្ត(ឧបមាថា÷ យើងត្រូវបន្តការសម្រិតសម្រាំងខ្មាំងរបស់យើង) ជាការគ្រប់គ្រាន់ក្នុងការបង្ហាញថា និយមន័យនៃពាក្យ "ខ្មាំង" និយាយដល់ក្រុមដែលត្រូវបានការពារដោយច្បាប់ ។ ប្រសិនបើមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជានិយាយក្តែងៗប្រាប់ដល់កូនចៅនៅក្រោមបញ្ជា ឲ្យសម្លាប់ឲ្យអស់នូវជនជាតិចាមនិងកងប្រដាប់អាវុធឈ្លានពានទឹកដីនោះ លក្ខខណ្ឌដើម្បីឲ្យមានបទប្រល័យពូជសាសន៍គ្មានបាត់មួយចម្រៀកណាសោះ ។ ប៉ុន្តែបើគ្រាន់តែយកមកប្រើដើម្បីពណ៌នាអំពីព្រឹត្តិការណ៍ជាលក្ខណៈបុគ្គល(ឧបមាថា÷ យើងបានកម្ទេចខ្មាំងបីក្បាលនៅខេត្តកំពង់ធំ) និយមន័យដ៏ទូលំទូលាយនេះនឹងផ្តល់ជាល្បិចដោះទ័លយ៉ាងពិតប្រាកដ ។ ហេតុដូច្នេះ ការកាត់សេចក្តីគួរតែព្យាយាមធ្វើយ៉ាងណាដើម្បីកំណត់និយមន័យនេះឲ្យបានជាក់ច្បាស់តាមតែអាចធ្វើទៅបាន ។

ការកំណត់ឲ្យបានច្បាស់លាស់នូវពាក្យ "សមាសភាពមិនល្អ" មិនសូវសំខាន់ប៉ុន្មានទេ ពីព្រោះពាក្យនេះជាធម្មតានិយាយយោងដល់នយោបាយឬការអនុវត្តទូទៅ (ឧទាហរណ៍យើងបន្តការបោសសម្អាតសមាសភាពមិនល្អ) ។ ដរាបណាការកាត់សេចក្តីបង្ហាញថាក្រុមដែលត្រូវបានការពារដោយច្បាប់ស្ថិតក្នុងចំណោមមុខសញ្ញាដែលត្រូវមានចេតនាមកលើដូចជានយោបាយនិងការអនុវត្តទូទៅ និយមន័យទូលំទូលាយខាងលើ ក៏ជាការគ្រប់គ្រាន់ដែរ ។ ជាការច្បាស់ណាស់ មិនចាំបាច់និយាយក៏ដឹងដែរថានិយមន័យនោះមានការផ្ចិតផ្ចង់ត្រឹមត្រូវពិតប្រាកដ ។ ប៉ុន្តែឯកសារមិនបានបង្ហាញជាសញ្ញាច្បាស់លាស់ទេថា ខ្មែរក្រហមជនភ្នាក់ងារស៊ើបការណ៍បរទេសនិងក្រុមដែលមិនមានការការពារដោយច្បាប់ អាចមិនត្រូវបានរាប់បញ្ចូលទៅក្នុងនិយមន័យរបស់ពាក្យ "សមាសភាពមិនល្អ" ។

កាន់តែសំខាន់ជាងនេះទៅទៀតក្នុងការកំណត់ការយល់ឃើញរបស់អង្គជំនុំជម្រះក្តីទៅលើពាក្យថា "ខ្មាំង" ពីព្រោះឯកសារជាច្រើនរបស់បក្សកុម្មុយនិស្តកម្ពុជាដែលរាយការណ៍អំពីសកម្មភាពជាក់លាក់នៃការសម្លាប់បាននិយាយយោងទៅដល់ "ខ្មាំង"របស់អង្គការ ។ តាមន័យទូទៅ ពាក្យនេះអាចមានន័យទូលំទូលាយរហូតដល់អាចបញ្ចូលទាំងមនុស្សដែលមិនត្រូវបានការពារដោយច្បាប់ទៀតផង ។ នៅក្នុងករណីមួយចំនួន "ខ្មាំង" គឺជាយុទ្ធជនប្រយុទ្ធរបស់វៀតណាមដែលបំពាក់ទៅដោយអាវុធត្រឹមត្រូវ ។

ដូចនេះ ដើម្បីទទួលបានជោគជ័យ ការកាត់សេចក្តីត្រូវតែធ្វើយ៉ាងណាចែកនិយមន័យនៃពាក្យថា "ខ្មាំង"នេះឲ្យបានដាច់ស្រឡះ ដោយយល់ស្របថា នៅក្នុងករណីមួយចំនួន ពាក្យនេះនិយាយយោងដល់កងកម្លាំងយោធាបរទេស អ្នកស៊ើបការណ៍និងទាហានបះបោរ ។ ក្នុងករណីផ្សេងទៀតពាក្យនេះនិយាយយោងដល់ក្រុមដែលទទួលបានការការពារដោយច្បាប់ ។ កិច្ចការនេះពិតជាពិបាកហើយនឹងត្រូវប្រើប្រាស់សក្ខីកម្មជំនាញនិងមានអាជីពច្បាស់លាស់ ។

## ៤) ឈ្មោះក្លែង

ឈ្មោះហៅកាត់គឺមានសារសំខាន់ដូចគ្នា ។ គ្រប់មន្ត្រីថ្នាក់លើរបស់បក្សកុម្មុយនិស្តកម្ពុជាសុទ្ធតែមានឈ្មោះក្លែងមួយឬច្រើន ហើយការលាតត្រដាងពីឈ្មោះក្លែងនេះគឺមានសារប្រយោជន៍ណាស់សម្រាប់ការកាត់សេចក្តីទៅលើបុគ្គលនីមួយៗ ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាផ្តល់នូវសញ្ញាប្រាប់ផ្លូវយ៉ាងច្រើនទាក់ទងនឹងអត្តសញ្ញាណរបស់មន្ត្រីនៃបក្សកុម្មុយនិស្តកម្ពុជា ហើយសញ្ញាបង្ហាញផ្លូវទាំងនេះអាចផ្គុំគ្នាដើម្បីក្លាយជារូបភាពភ័ស្តុតាងមួយដ៏ពេញលេញបញ្ជាក់អំពីឈ្មោះហៅកាត់របស់ខ្មែរក្រហម ។ សក្ខីកម្មជំនាញនិងមានអាជីពច្បាស់លាស់ក៏អាច

ជាជំនួយបុច្ចាំបាច់សម្រាប់បង្កើតបានជាឈ្មោះក្លែងពិតប្រាកដរបស់បុគ្គលនីមួយៗ ។ ការមូលមតិទាក់ទងនឹងពាក្យក្លែងនេះហាក់ដូចជាមានប្រយោជន៍សម្រាប់សម្រួលដល់បន្ទុកភ័ស្តុតាង ។ ប៉ុន្តែយ៉ាងណាក៏ដោយ នៅតែអាចទៅរួចដែលថា តុលាការឧក្រិដ្ឋកម្មនឹងតម្រូវឲ្យមានភ័ស្តុតាងជាក់ស្តែងជាមិនខាន ។

## ១) ការប្រើប្រាស់ភ័ស្តុតាងជាទូទៅទៅលើឯកសារដែលមានតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា

### ១) ទោសកម្មជាមូលដ្ឋាន

បទឧក្រិដ្ឋភាគច្រើនដែលចោទប្រកាន់ទៅលើអតីតមន្ត្រីបក្សកុម្មុយនិស្តកម្ពុជានឹងត្រូវធ្វើឡើងដោយផ្អែកលើទ្រឹស្តីនៃគោលការណ៍នៃការទទួលខុសត្រូវលើការបញ្ជា ។ យោងតាមមតិទូទៅផ្នែកប្រវត្តិសាស្ត្រឃើញថា ការធ្វើទារុណកម្ម ការកាប់សម្លាប់និងអំពើផ្សេងៗទៀត មានតែមួយភាគតូចប៉ុណ្ណោះដែលត្រូវបានប្រព្រឹត្តដោយផ្ទាល់ដោយមន្ត្រីថ្នាក់លើកំពូលៗ ។ ដូច្នេះច្បាប់តម្រូវឲ្យមានការកាត់សេចក្តីថា មុននឹងបង្ហាញថាមេដឹកនាំនៃបក្សកុម្មុយនិស្តកម្ពុជាបានបំពេញធាតុផ្សំនៃការទទួលខុសត្រូវលើការបញ្ជា ត្រូវបង្ហាញជាមុនសិនថា កូនចៅថ្នាក់ក្រោមរបស់ខ្លួនបានប្រព្រឹត្តបទល្មើសដែលអាចដាក់ទោសព្រហ្មទណ្ឌបាន ។

ការទទួលស្គាល់ទូទាំងពិភពលោកចំពោះអំពើឃោរឃៅរបស់ខ្មែរក្រហម មិនគ្រប់គ្រាន់ទេក្នុងការបង្ហាញតាមផ្លូវច្បាប់ថាកូនចៅក្រោមបញ្ជារបស់មេដឹកនាំនៃបក្សកុម្មុយនិស្តកម្ពុជាបានប្រព្រឹត្តអំពើឧក្រិដ្ឋ ។ ក៏ប៉ុន្តែប្រសិនបើយោងទៅតាមភ័ស្តុតាងប្រវត្តិសាស្ត្រដ៏ច្រើនលើសលប់ដែលបង្ហាញឲ្យឃើញអំពីការកើតមានអំពើឧក្រិដ្ឋនោះ គឺសមតែជាការងាយស្រួលបំផុតសម្រាប់ព្រះរាជអាជ្ញា ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានឯកសារជាច្រើនប្រភេទដើម្បីជួយជ្រោមជ្រែងក្នុងការបង្ហាញថា អំពើឧក្រិដ្ឋដែលមានទ្រង់ទ្រាយធំត្រូវបានប្រព្រឹត្តឡើងដោយសមាជិកនៃបក្សកុម្មុយនិស្តកម្ពុជា ។

ក) របាយការណ៍នៃការចុះធ្វើផែនទីរណ្តៅសាកសព

ប្រភពភ័ស្តុតាងសំខាន់ជាបឋមគឺរបាយការណ៍នៃការចុះធ្វើផែនទីរណ្តៅសាកសពដែលមានរៀបរាប់អំពីទីតាំងលក្ខណៈផ្សេងៗនៃគុក អដ្ឋិធាតុដែលនៅសេសសល់និងរណ្តៅសាកសពនៅទូទាំងប្រទេសកម្ពុជា ។ របាយការណ៍នៃការចុះធ្វើផែនទីរណ្តៅសាកសពអាចមានប្រយោជន៍យ៉ាងសំខាន់ ពីព្រោះរបាយការណ៍ទាំងនេះគឺជាឯកសារដ៏ពេញលេញនិងមានស្រាប់ដែលបង្ហាញពីភ័ស្តុតាងជាក់ស្តែងបន្សល់ទុកដោយរបបកម្ពុជាប្រជាធិបតេយ្យ ។ ដោយផ្គុំគ្នាជាមួយនឹងសក្ខីកម្មកោសល្យវិច័យជំនាញទាក់ទងទៅនឹងអាយុកាលរបស់អដ្ឋិធាតុនិងរបៀបស្លាប់នៃជនរងគ្រោះ របាយការណ៍ផែនទីអាចភ្ជាប់យ៉ាងមានប្រសិទ្ធភាពទៅនឹងអំពើឃោរឃៅដែលកើតឡើងនៅក្នុងអំឡុងនៃការកាន់អំណាចរបស់បក្សកុម្មុយនិស្តកម្ពុជា ។ អ្នកជំនាញខាងកោសល្យវិច័យក៏អាចទាញភ្ជាប់គុកណាមួយនិងវត្ថុសម្រាប់ធ្វើទារុណកម្មផ្សេងៗដែលកត់ត្រានៅក្នុងរបាយការណ៍ផែនទីទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យបានដែរ ។

តុលាការអាចសម្រេចទទួលយករបាយការណ៍ផែនទីថាមានភាពសុក្រឹត ដោយផ្អែកជាមួយសក្ខីកម្មកោសល្យវិច័យដោយអ្នកជំនាញ ។ ម្យ៉ាងវិញទៀត តុលាការអាចយករបាយការណ៍ចុះធ្វើផែនទីជាការបំភ្លឺផ្លូវចំពោះការស៊ើបអង្កេតឯករាជ្យរកអង្គហេតុតាមលក្ខណៈគតិយុត្តិ ។ នៅក្នុងករណីទាំងពីរនេះរបាយការណ៍ចុះធ្វើផែនទីនឹងផ្តល់ភ័ស្តុតាងប្រយោលដ៏មានទម្ងន់អំពីការធ្វើទារុណកម្ម ការសម្លាប់ដែលមានការរៀបចំទុកនិងការកប់សាកសពទាំងហ្វូងៗ ប្រព្រឹត្តឡើងដោយកម្មាភិបាលនៃបក្សកុម្មុយនិស្តកម្ពុជា ។

ជាការប្រសើរណាស់ចំពោះការកាត់សេចក្តីដោយយករបាយការណ៍នៃការចុះធ្វើផែនទីមកប្រើប្រាស់ឲ្យបានច្រើនតាមតែអាចធ្វើទៅបាន ។ ទោះបីជាមានទម្រង់ជាច្រើននៃភ័ស្តុតាងផ្ទាល់បង្ហាញពីអំពើឃោរឃៅដាច់ៗពីគ្នាយ៉ាងណាក៏ដោយ របាយការណ៍នៃការចុះធ្វើផែនទីគឺជាភ័ស្តុតាងមួយចំណែកដ៏សំខាន់ក្នុងចំណោមភ័ស្តុតាងនានាដែលបង្ហាញពីវិសាលភាពផ្នែកភូមិសាស្ត្រដ៏ធំទូលាយ ការប្រព្រឹត្តបទឧក្រិដ្ឋកម្មនិងការធ្វើទារុណកម្ម និងការកាប់សម្លាប់ជាលក្ខណៈប្រព័ន្ធ ។ ដូចដែលបានលើកមកពិភាក្សាខាងលើប្រភេទនៃបទល្មើសឧក្រិដ្ឋកម្មដែលមានទ្រង់ទ្រាយធំ និងមានការរៀបចំទុកផ្តល់នូវភ័ស្តុតាងប្រយោលដែល

បង្ហាញថា មេដឹកនាំបានដឹងពីការប្រព្រឹត្តទាំងនោះហើយបំពេញបានទៅនឹងលក្ខខណ្ឌតម្រូវ "ទេតនាខក្រិដ្ឋ" នៃការទទួលខុសត្រូវលើការបញ្ជា ។

ខ) ញត្តិរបស់អ្នកនៅរស់

ប្រភពសំខាន់ទីពីរនៃភ័ស្តុតាងឯកសារដែលបង្ហាញថា កម្មាភិបាលរបស់បក្សកុម្មុយនិស្តកម្ពុជាបានប្រព្រឹត្តអំពើឃោរឃៅជាទ្រង់ទ្រាយធំ គឺញត្តិដ៏ច្រើនសន្ធឹកសន្ធាប់ដែលធ្វើឡើងដោយបុគ្គលដែលបានរួចផុតពីសេចក្តីស្លាប់នៃរបបកម្ពុជាប្រជាធិបតេយ្យ ។ មជ្ឈមណ្ឌលឯកសារកម្ពុជា មានញត្តិពាក្យបណ្តឹងជាច្រើនច្បាប់ដែលបញ្ជាក់និងចុះហត្ថលេខាដោយប្រជាជនកម្ពុជាជាងមួយលានប្រាំសែននាក់នៅទូទាំងប្រទេស ។ ពត៌មានភាគច្រើននៅក្នុងញត្តិទាំងនេះក្នុងន័យបច្ចេកទេស គឺជាពាក្យចចាមអារ៉ាម ហើយប្រហែលជាអាចមានទម្ងន់ស្រាលជាងដោយផ្អែកលើវិធាននៃច្បាប់ស៊ីវិល ។ ទោះជាយ៉ាងណាក៏ដោយ គ្រាន់តែគិតពីចំនួនញត្តិដ៏ច្រើនលើសលប់ក៏អាចធ្វើឲ្យភ័ស្តុតាងកាន់តែមានទម្ងន់ឡើង ។ លើសពីនេះទៀត ការកាត់សេចក្តីអាចធ្វើឲ្យឯកសារមានកម្លាំងកាន់តែខ្លាំងបើមានការទាក់ទងជាមួយនឹងអ្នកសរសេរញត្តិទាំងនេះ ។ ចំពោះករណីនេះ ញត្តិដើរតួជាសាក្សីយ៉ាងសំខាន់សម្រាប់ការកាត់សេចក្តី ឬសម្រាប់តុលាការ ប្រសិនបើតុលាការនេះខិតខំធ្វើការស៊ើបអង្កេតរកតម្រូវការអង្គហេតុឯករាជ្យ ។

គ) ឯកសារឆ្លើយឆ្លង

សំបុត្រទាក់ទងជាច្រើនច្បាប់របស់បក្សកុម្មុយនិស្តកម្ពុជា បង្កើតបានជាទោសកម្មយ៉ាងច្បាស់ក្រឡែតដែលបានប្រព្រឹត្តឡើងដោយអ្នកសរសេរសំបុត្រទាំងនេះ ឬដោយសមាជិកក្នុងជួរបក្សកុម្មុយនិស្តកម្ពុជា ។ ឯកសាររបៀបនេះគឺជាភ័ស្តុតាងផ្ទាល់បញ្ជាក់ពីអំពើឧក្រិដ្ឋកម្ម ។ ប្រសិនបើឯកសារមានសញ្ញាបញ្ជាក់ថាពិតដែលអាចយកជាការបាននោះ ជាការពិបាកនឹងបដិសេធណាស់ ។ កម្រិតជាក់ស្តែងរបស់សំបុត្រទាំងនេះគឺថា វាបានផ្តល់នូវភ័ស្តុតាងចំពោះតែបទឧក្រិដ្ឋជាច់ដោយឡែកឬក្នុងកម្រិតណាមួយតែប៉ុណ្ណោះ ។ ក្នុងករណីនេះ ឯកសារឆ្លងឆ្លើយទាំងនេះបំពេញគ្នាទៅវិញទៅមកជាមួយនឹងរបាយការណ៍ផ្ទៃទីនិងញត្តិបានយ៉ាងល្អ ។

ការបកស្រាយពាក្យឬឃ្លាដែលខ្មែរក្រហមប្រើ គឺជាវនាំងយ៉ាងមាំដែលត្រូវឆ្លងកាត់ក្នុងការប្រើប្រាស់ឯកសារឆ្លងឆ្លើយទាំងអស់នេះ ។ ជាទូទៅ អំពើឧក្រិដ្ឋត្រូវបានរាយការណ៍ដោយប្រើពាក្យបំព្រួញពិសេសដូចជា "កម្ទេចវាចោល" ឬ "បន្តសម្រិតសម្រាំងសមាសភាពមិនល្អ" ។ ដូចនេះដើម្បីពង្រីកតម្លៃនៃភ័ស្តុតាងចេញពីឯកសាររបៀបនេះ ន័យរបស់ពាក្យបំព្រួញសម្ងាត់ត្រូវតែបានសម្រួលឲ្យបានច្បាស់លាស់ជាក់លាក់ ទើបអាចដំណើរការទៅបាន ។

## ២) ទំនាក់ទំនងនៃការបញ្ជា

មជ្ឈមណ្ឌលឯកសារកម្ពុជាមានឯកសារជាច្រើនដែលអាចយកមកប្រើប្រាស់ជាភ័ស្តុតាងក្នុងការបង្កើតឲ្យបានជាទំនាក់ទំនងនៃការបញ្ជាតាមវិធីពីរយ៉ាង÷ ទីមួយឯកសារទាំងនេះអាចបង្ហាញពីទំនាក់ទំនងនៃការបញ្ជាដោយផ្ទាល់រវាងបុគ្គលពីរនាក់ឬច្រើននាក់ ។ ទីពីរទៀត ឯកសារអាចត្រូវបានយកមកភ្ជាប់បញ្ចូលគ្នាដើម្បីបង្ហាញពីឋានានុក្រមទូទៅនិងខ្សែសង្វាក់នៃការបញ្ជានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ការបង្ហាញឲ្យឃើញពីខ្សែសង្វាក់នៃការបញ្ជាផ្តល់នូវភ័ស្តុតាងប្រយោលថា ទំនាក់ទំនងនៃការបញ្ជាពិតជាមានរវាងក្រុមបុគ្គលមួយជាក់លាក់ ។

នៅក្នុងចំណោមឯកសារដែលមានប្រយោជន៍បំផុតតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជាសម្រាប់បង្កើតបានជាទំនាក់ទំនងនៃការបញ្ជា គឺសំបុត្រឆ្លងឆ្លើយមកពីកូនចៅនៅថ្នាក់ក្រោមផ្ញើជូនថ្នាក់លើរបស់ខ្លួន ។ ឯកសារជំពូកនេះជាច្រើនច្បាប់ មានសញ្ញាបង្ហាញពីការទំនាក់ទំនងគ្នារវាងថ្នាក់លើនិងថ្នាក់ក្រោម ពោលគឺអ្នកសរសេរនិងអ្នកទទួល ។ ឯកសារទាំងនេះត្រូវបានផ្ញើជារបាយការណ៍ និងស្វែងរកតម្រុយយ៉ាងច្បាស់ឆ្ពោះទៅរកអ្នកទទួល ។ កម្រិតដើមនៃឯកសារទាំងនេះគឺថា វាអាចបង្ហាញពីទំនាក់ទំនងនៃការបញ្ជាតែមួយគត់ ។ វាបានផ្តល់នូវភ័ស្តុតាងដ៏មានទម្ងន់ថា អ្នកដែលបានទទួលសំបុត្របានបញ្ជាទៅលើកងយោធាឬមន្ត្រីបក្សដ៏ច្រើន ។

**(នៅមានត)**

**ចន ឆរតីអារី**

# សេចក្តីថ្លែងការណ៍របស់សហគមន៍អឺរ៉ុបនៅឯកិច្ចប្រជុំក្រុមប្រឹក្សាយោបល់ស្តីអំពីជំនួយសម្រាប់កម្ពុជា ទីក្រុងតូក្យូថ្ងៃទី១១-១៣ខែមិថុនាឆ្នាំ២០០១

## សេចក្តីប្រកាសពត៌មាន ប្រូសសែល ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០១

សហគមន៍អឺរ៉ុបស្វាគមន៍ចំពោះឱកាសពិនិត្យមើលទូទៅលើការរីកចម្រើនរបស់ព្រះរាជាណាចក្រកម្ពុជាដើម្បីឈានដល់គោលដៅដែលសម្រេចដោយកិច្ចប្រជុំប្រឹក្សាយោបល់កាលពីមុនដែលរៀបចំឡើងនៅទីក្រុងប៉ារីស ។

សហគមន៍អឺរ៉ុបសូមស្វាគមន៍ចំពោះជំហានជាវិជ្ជមានរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាកាលពីឆ្នាំទៅមុន ។ យើងសូមអបអរចំពោះការរីកចម្រើនផ្នែកម៉ាក្រូសេដ្ឋកិច្ច ស្ថិរភាពនយោបាយទូទៅ កំណែទម្រង់សារពើពន្ធ និងប្រព័ន្ធធនាគារនៅកម្ពុជា ។ យើងក៏នៅតែបន្តជំរុញរាជរដ្ឋាភិបាលជម្នះឧបសគ្គនានាដែលរារាំងដល់ការអភិវឌ្ឍដូចជាធ្វើឲ្យមានការរីកចម្រើន និងការរៀបចំបែងចែកប្រាក់ចំណូលឲ្យមានសមធម៌ថែមទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។



អ្វីដែលសំខាន់ ហើយដែលត្រូវមានជាមុនសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនិងកម្មវិធីកែទម្រង់ជាទូទៅ គឺការពង្រឹងសង្គមស៊ីវិលមួយនៅក្នុងទម្រង់សង្គមប្រកបដោយស្ថិរភាពដែលយកវិធាននៃច្បាប់មកធ្វើជាមូលដ្ឋាននិងការអភិវឌ្ឍប្រព័ន្ធរដ្ឋបាលប្រកបដោយតម្លាភាព ។ សហគមន៍អឺរ៉ុបសូមសង្កត់ធ្ងន់ទៅលើការចាំបាច់ជាបន្ទាន់ក្នុងការពង្រីកនិងពង្រឹងវិធាននៃច្បាប់ ហើយរៀបចំខ្លួនបន្តជួយកម្ពុជាក្នុងវិស័យនានាដូចដែលបានលើកឡើងនេះ ។ ការអនុវត្តច្បាប់គួរតែត្រូវពង្រឹងឲ្យបាន ពោលគឺជម្នះឲ្យបាននូវភាពរួចទោស ការពារសិទ្ធិមនុស្ស និងបង្កើតជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ។

ចំពោះបញ្ហាពុករលួយ សហគមន៍អឺរ៉ុបកត់សម្គាល់ឃើញថា រាជរដ្ឋាភិបាលកម្ពុជាមានការសោកស្តាយចំពោះការរាលដាលនៃអំពើពុករលួយនៅក្នុងផ្នែកគ្រប់គ្រងសាធារណៈ ។ ប៉ុន្តែត្រូវមានវិធានការដាច់ណាត់ថែមទៀតក្នុងផ្នែកនេះ ។ យើងសូមជំរុញឲ្យរដ្ឋាភិបាលអនុវត្តពេញទំហឹងនូវផែនការប្រឆាំងនឹងអំពើពុករលួយ ។ ប្រព័ន្ធតុលាការដែលរួមទាំងធនធានមនុស្សក៏ចាំបាច់ត្រូវពង្រឹងដែរ ទន្ទឹមនឹងនេះគួរធ្វើកំណែទម្រង់បន្តបន្ទាប់ឆ្ពោះទៅរកវិមជ្ឈការ ។

យើងសូមអបអរចំពោះការរីកចម្រើនក្នុងការរៀបចំបោះឆ្នោតឃុំសង្កាត់នៅឆ្នាំ ២០០២ ។ ប្រសិនបើមានការរៀបចំឲ្យបានត្រឹមត្រូវ ការបោះឆ្នោតនេះនឹងក្លាយជាជំហានយ៉ាងសំខាន់សម្រាប់ជំរុញឲ្យមានអភិបាលកិច្ចបែបប្រជាធិបតេយ្យ ។ យើងសូមជំរុញឲ្យរាជរដ្ឋាភិបាលចាត់វិធានការនានាតាមតែអាចធ្វើទៅបានដើម្បីធានាឲ្យប្រាកដថា ការបោះឆ្នោតនេះនឹងមានលក្ខណៈសេរីនិងយុត្តិធម៌ និងប្រព្រឹត្តទៅក្នុងបរិយាកាសប្រកបដោយសន្តិសុខនិងសន្តិភាព ។

ដូចគ្នានេះដែរ ការកែទម្រង់ផ្នែករដ្ឋបាលក៏គួរតែជំរុញទៅមុខដែរ ។ សហគមន៍អឺរ៉ុបសូមស្វាគមន៍ចំពោះផែនការរបស់រាជរដ្ឋាភិបាលក្នុងការបង្កើនប្រាក់បៀវត្សរ៍សម្រាប់បុគ្គលិករដ្ឋ ។

សហគមន៍អឺរ៉ុបសូមជំរុញយ៉ាងទទូចដល់រាជរដ្ឋាភិបាលកម្ពុជានិងរដ្ឋសភាជាតិ ឲ្យឈានដល់ការព្រមព្រៀងបង្កើត

តុលាការកាត់ទោសខ្មែរក្រហម ។ សហគមន៍អឺរ៉ុបជំរុញឲ្យរាជរដ្ឋាភិបាលនិងរដ្ឋសភាជាតិកម្ពុជាបញ្ចប់ និងអនុម័តច្បាប់កាត់ទោសខ្មែរក្រហមឲ្យបានឆាប់ ដើម្បីកាត់សេចក្ដីមេដឹកនាំខ្មែរក្រហមដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ តាមបទដ្ឋានអន្តរជាតិប្រកបដោយយុត្តិធម៌មិនលម្អៀង និងត្រឹមត្រូវតាមនីតិវិធី ។ ***សហគមន៍អឺរ៉ុបជំរុញឲ្យរាជរដ្ឋាភិបាលព្រមទាំងសភាជាតិកម្ពុជាបង្កើតតុលាការដោយគ្មានពន្យារពេលទៅមុខទៀតឡើយ ។***

សហគមន៍អឺរ៉ុបសូមអបអរចំពោះរដ្ឋាភិបាលកម្ពុជាដែលកំពុងតែបង្កើនការយកចិត្តទុកដាក់លើការលុបបំបាត់ភាពក្រីក្រដូចដែលបាននិយាយច្បាស់នៅក្នុងផែនការសេដ្ឋកិច្ចសង្គមនិងដំណើរការសិក្សាផែនការយុទ្ធសាស្ត្រក្នុងការកាត់បន្ថយភាពក្រីក្រ ។ ត្រូវបង្កើនការផ្ដល់ថវិកាលើផ្នែកសង្គមថែមទៀត ។ សកម្មភាពនេះអាចធ្វើទៅបានតាមរយៈការអនុវត្តកម្មវិធីរំសាយកងទ័ព ។ សហគមន៍អឺរ៉ុបរៀបចំខ្លួនជាស្រេចក្នុងការចូលរួមវិភាគទានដល់កម្មវិធីនេះ ។

តម្លាភាពនិងការដាក់ឲ្យទទួលខុសត្រូវគឺជាមានសារសំខាន់ណាស់ចំពោះកិច្ចសហប្រតិបត្តិការរបស់យើងជាមួយកម្ពុជា ។ វិធានការអនុវត្តដ៏សំខាន់គឺត្រូវរៀបចំ «អាជ្ញាធរអធិការកិច្ចជាតិ» ឲ្យមានសមាជិកដែលមានសមត្ថភាព និងត្រូវធ្វើឲ្យអង្គការនេះដំណើរការទៅមុខបានយ៉ាងលឿន ។

សេចក្ដីព្រាងច្បាប់ស្ដីអំពីការកែទម្រង់ដីធ្លីនិងច្បាប់ព្រៃឈើគឺជាឧបករណ៍យ៉ាងសំខាន់ក្នុងការប្រឆាំងនឹងអំពើពុករលួយនិងកាត់បន្ថយអំពើពុករលួយ ។ សហគមន៍អឺរ៉ុបជំរុញយ៉ាងខ្លាំងឲ្យរាជរដ្ឋាភិបាលនិងសភាជាតិកម្ពុជាបន្តដំណើរទៅមុខដើម្បីអនុម័តនិងការអនុវត្តច្បាប់នោះ ។ យើងក៏សូមបញ្ជាក់អំពីសារសំខាន់នៃការសង្កត់ធ្ងន់លើការការពារសិទ្ធិកាន់កាប់ដីធ្លីនិងព្រៃឈើដែលជាតម្រូវការចាំបាច់សម្រាប់អាជ្ញាធរកម្ពុជាក្នុងការបន្តដោះស្រាយបញ្ហាអាជីវកម្មព្រៃឈើខុសច្បាប់ ។

សហគមន៍អឺរ៉ុបបន្តផ្ដោតយ៉ាងសំខាន់មកលើកម្ពុជានិងរៀបចំខ្លួនរួចជាស្រេចក្នុងការគាំទ្រដល់កិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍប្រទេសជាតិរបស់ខ្លួន ។

## កម្ពុជាៈ ដៃគូរអភិវឌ្ឍន៍អន្តរជាតិផ្ដល់ការគាំទ្រចំពោះជំនួយសំរាប់កម្មវិធីអភិវឌ្ឍកម្ពុជា

ទីក្រុងតូក្យូ, ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០១ៈ ប្រទេសអ្នកផ្ដល់ជំនួយអន្តរជាតិបានជួបប្រជុំជាមួយតំណាងរាជរដ្ឋាភិបាលកម្ពុជានៅថ្ងៃទី១២-១៣ ខែមិថុនា ឆ្នាំ២០០១ ដើម្បីពិនិត្យជាទូទៅលើកិច្ចខំប្រឹងប្រែងរបស់កម្ពុជាឆ្ពោះទៅរកការរីកចម្រើន ការកាត់បន្ថយភាពក្រីក្រ និងអភិបាលកិច្ចល្អ ។ ប្រទេសអ្នកផ្ដល់ជំនួយមានការស្ងើចសរសើរចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលបានបន្តខិតខំឲ្យមានការកើនឡើងជាបន្តបន្ទាប់ក្នុងការអនុវត្តកម្មវិធីកំណែទម្រង់និងចំពោះកំណើនផលិតផលក្នុងស្រុកសរុបខ្ពស់គួរសមក្នុងឆ្នាំកន្លងទៅទោះជាកម្ពុជាបានទទួលរងការខូចខាតពីគ្រោះទឹកជំនន់ធ្ងន់ធ្ងរបំផុតក្នុងប្រវត្តិសាស្ត្ររបស់ខ្លួនក៏ដោយ ។

ក្នុងពេលជាមួយគ្នានេះដែរ អង្គប្រជុំក៏បានកត់សម្គាល់ថា ការអនុវត្តកំណែទម្រង់នយោបាយមួយចំនួនត្រូវបានពន្យារពេល ហើយនៅមានចំណុចជាច្រើនទៀតដែលត្រូវអនុវត្តដើម្បីសម្រេចឲ្យបាននូវការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពនិងការកាត់បន្ថយភាពក្រីក្រ ។ ដូច្នេះក្រុមអ្នកផ្ដល់ជំនួយបានផ្ដល់នូវការស្វាគមន៍យ៉ាងកក់ក្ដៅចំពោះការប្ដូរផ្ដាច់របស់សម្ដេច ហ៊ុន សែន ក្នុងការរក្សានិងបង្កើនជំហាននៃកម្មវិធីកំណែទម្រង់នេះ ។

កំណែទម្រង់តុលាការនិងច្បាប់ត្រូវធ្វើជាបន្ទាន់ ហើយការកែប្រែបន្ថែមទៀតលើផ្នែកប្រឆាំងអំពើពុករលួយ រួមបញ្ចូលទាំងការបង្កើតឡើងនូវការិយាល័យត្រួតពិនិត្យជាតិនិងកំណែទម្រង់រដ្ឋបាលសាធារណៈផង ដូចជាវិមជ្ឈការជាដើម ។ **មធ្យោបាយផ្សេងក៏ត្រូវបានចាត់ចែងដែរដើម្បីធានាឲ្យបាននូវការបោះឆ្នោតក្នុងស្រុកដោយសេរី និងយុត្តិធម៌ និងអនុម័តច្បាប់តុលាការកាត់ទោសខ្មែរក្រហម និងបង្កើតសាលាជម្រះក្ដីនេះឲ្យបានឆាប់ដោយគ្មានពន្យារពេលទៅមុខទៀតឡើយ ។** ចំណាត់វិធានការបន្ថែមទៀតក្នុងការបំបាត់ចោលនូវវប្បធម៌នៃភាពរួចទោសនិងដើម្បីបង្កើនការគោរពសិទ្ធមនុស្ស គឺមានសារសំខាន់ណាស់ ។ ដើម្បីជាការលើកទឹកចិត្តដល់រាជរដ្ឋាភិបាលកម្ពុជាប្រទេសអ្នកផ្ដល់ជំនួយបានសន្យាផ្ដល់ជំនួយគិតជាទឹកប្រាក់ចំនួន៥៦០លានដុល្លារសហរដ្ឋអាមេរិកសម្រាប់ជួយទ្រទ្រង់ដល់ការបោះឆ្នោតក្រុមប្រឹក្សាសង្កាត់នៅព្រះរាជាណាចក្រកម្ពុជាដែលនឹងប្រព្រឹត្តទៅនៅពេលខាងមុខនេះ ។

# តុលាការខ្មែរក្រហមនឹងផ្សះរបួសសង្គមកម្ពុជា

សប្តាហ៍នេះ នៅឯអគ្គប្រជុំក្រុមពិភាក្សានៅទីក្រុងតូក្យូ **សហគមន៍អឺរ៉ុបបានអំពាវនាវយ៉ាងទទូចដល់រាជរដ្ឋាភិបាលនិងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាឲ្យបង្កើតតុលាការខ្មែរក្រហមមួយ "ដោយគ្មានពន្យារពេលទៅមុខទៀតឡើយ"** តាមសេចក្តីប្រកាសព័ត៌មានពីទីក្រុងប្រ៊ុចសែលថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០១។ កាលពីខែមិថុនាកន្លងមកនេះដែរ មានអតីតខ្មែរក្រហមជាឈ្លបឃុំម្នាក់ត្រូវបានតុលាការខេត្តកំពង់ធំកាត់ទោសឲ្យជាប់គុក១៨ឆ្នាំ និងពិន័យជាប្រាក់សងជំងឺចិត្តចំនួន២លានរៀល។ ការសម្រេចសាលក្រមកាត់ទោសនេះមិនមែនដោយសារទណ្ឌិតនេះជាអតីតខ្មែរក្រហមទេ ប៉ុន្តែគឺដោយសារតែកាលពីឆ្នាំកន្លងទៅនេះ គាត់បានបាញ់សម្លាប់មិត្តភក្តិរួចពុះទ្រូងរួងយកថ្លើមមកក្លែមស្រា។ ឃាតករមានឈ្មោះ ហ៊ាង ហុន អាយុ៣៦ឆ្នាំបានរស់នៅជាប្រជាជនសាមញ្ញចាប់តាំងពីទាហានខ្មែរក្រហមធ្វើសមាហរណកម្មចូលក្នុងរាជរដ្ឋាភិបាលកម្ពុជាមកម្ល៉េះ។ តាមរយៈការចុះសិក្សាស្រាវជ្រាវរបស់ខ្ញុំនៅខេត្តមណ្ឌលគិរី បានដឹងអំពីឈ្មោះអតីតកម្មាភិបាលខ្មែរក្រហមដែលបានធ្វើសមាហរណកម្មរួចហើយ។ ចំណែកនៅស្រុកមួយផ្សេងទៀត ខ្ញុំមិនបានដឹងអំពីឈ្មោះអ្នកដែលតាមសម្លាប់ជនរងគ្រោះកាលពីជំនាន់ខ្មែរក្រហមកាន់អំណាចនោះទេ។ នៅខេត្តពោធិសាត់ អ្នកស្រុកអ្នកភូមិបានប្រាប់ខ្ញុំថាអតីតគណៈសហករណ៍ខ្មែរក្រហមម្នាក់នឹងក្លាយជាបេក្ខជនឈរឈ្មោះបោះឆ្នោតឃុំនៅឆ្នាំ២០០២ខាងមុខនេះ។ នៅខេត្តព្រៃវែង មានអតីតឈ្លបឃុំម្នាក់ធ្វើជាប្រធានភូមិ។ នៅខេត្តកំពង់ឆ្នាំង អតីតឆ្មាំនៅគុកទួលស្លែងមកប្រកបមុខរបរចិញ្ចឹមជីវិតជាកសិករ។ ចំណែកឯនៅខេត្តតាកែវវិញ អតីតកម្មាភិបាលគុកទួលស្លែងពីរនាក់ប្រកបរបរជាអ្នករកស៊ីជួញដូរ និងធ្វើស្រែចិញ្ចឹមជីវិត។ នៅខេត្តតាកែវនេះដែរមានអតីតខ្មែរក្រហមមួយចំនួនដែលបានធ្វើសមាហរណកម្មចូលក្នុងរាជរដ្ឋាភិបាលរួចហើយ ឥឡូវនេះរស់នៅអន្លង់វែងឬ ប៉ៃលិន ហើយខ្លាចមិនហ៊ានចូលមករស់នៅតាមភូមិស្រុកកំណើតទេ គ្រាន់តែមកលេងម្តងម្កាលនៅពេលមានបុណ្យទានតែប៉ុណ្ណោះ។ អ្នកស្រុកអ្នកភូមិខ្លះទៀតមិនហ៊ាននិយាយអំពីរឿងខ្មែរក្រហម ព្រោះចេះតែខ្លាចរអារឿងសន្តិសុខដោយមានអតីតខ្មែរក្រហមរស់នៅក្នុងភូមិជាមួយគ្នានោះ។ នៅមានករណីជាច្រើនផ្សេងៗទៀត។

តើមានអ្នកណាខ្លះនឹងស៊ីថ្លើមមនុស្សទៀតទេ? ក្នុងសភាពបច្ចុប្បន្ន ខ្ញុំមិនសង្ឃឹមថាមានធនធាននីតិវិធីគ្រប់គ្រាន់ដើម្បីយកមកកាត់ទោសអតីតជនដៃដល់ខ្មែរក្រហមបានទាំងអស់ឡើយ។ ប៉ុន្តែ ខ្ញុំជឿជាក់យ៉ាងមុតមាំថា ប្រសិនបើតុលាការដែលបាននិងកំពុងពិភាក្សាមកដល់សព្វថ្ងៃនេះចាប់ផ្តើមដំណើរការនោះ នឹងអាចបញ្ឈប់មិនឲ្យមានអ្នកស៊ីថ្លើមមនុស្សមិនឲ្យអតីតកម្មាភិបាលធ្វើជាប្រធានឃុំ ហើយឲ្យអ្នកស្រុកអ្នកភូមិមានសិទ្ធិនិយាយអំពីទុក្ខសោករបស់ខ្លួនដោយពុំមានការព្រួយបារម្ភ។ មានលក្ខខណ្ឌនេះទើបអាចសម្រេចបាននូវការផ្សះផ្សាជាតិពិតប្រាកដ ហើយទើបមានន័យថា រាជរដ្ឋាភិបាលការពារប្រជាជន និងបានធ្វើឲ្យប្រជាជនទុកចិត្តលើរាជរដ្ឋាភិបាលខ្លួនឯង។ មានតែយ៉ាងដូច្នេះទេ ទើបយើងអាចអភិវឌ្ឍប្រទេសជាតិឲ្យចម្រើនរុងរឿងទៅបាន។

**ស៊ឹម សុរិយ៉ា**



# ជនកុម្មុយនិស្តខ្មែរក្រហម និង វៀតណាមៈ ប្រវត្តិទំនាក់ទំនងរវាងខ្មែរក្រហម និង វៀតណាម

**(តពីលេខមុន)**

ការសម្របសម្រួលជាមួយទីក្រុងហាណូយ បានធ្វើឲ្យ ប៉ុល ពត រក្សាអំណាចរបស់ខ្លួននៅក្នុងជួរដឹកនាំបក្ស ផ្តល់សម្ភារសឹកនិងជំនួយយោធាដល់ក្រុមដែលកំពុងតែប្រយុទ្ធគ្នា ដែល ប៉ុល ពត ហៅថាកងទ័ពបដិវត្តន៍ ។ នៅក្នុងអំឡុងឆ្នាំ១៩៦៨-១៩៧០ កងទ័ពនេះបានបើយុទ្ធនាការសឹកទៅលើកម្លាំងដឹកនាំប្រទេស ដោយទទួលបរាជ័យយ៉ាងដំណំ ហើយគ្មានសេចក្តីសង្ឃឹមបន្តិចណាសោះឡើយក្នុងការឡើងកាន់អំណាច ។

ឱកាសដ៏ល្អសម្រាប់ ប៉ុល ពត និងខ្មែរកុម្មុយនិស្ត មាននៅក្នុងខែមីនា ឆ្នាំ១៩៧០ ។ សត្រូវដ៏យូរអង្វែងរបស់ ប៉ុល ពត ពោលគឺសម្តេច សីហនុ ត្រូវបានផ្តួលរំលំពីអំណាចដោយរដ្ឋប្រហារយោធាមួយនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ។ សម្តេច សីហនុ ត្រូវចូលរួមផ្នែកយោធានិងនយោបាយជាមួយនឹងជនកុម្មុយនិស្ត ដើម្បីមកកាន់អំណាចសាជាថ្មី ។

វាបានក្លាយជាចំណុចរបត់មួយសម្រាប់ជនកុម្មុយនិស្តៈ នៅក្នុងក្រសែភ្នែករបស់ប្រជាកសិកររាប់ពាន់នាក់ អ្នកទាំងនេះបានប្រែក្លាយពីសត្រូវរបស់សម្តេច សីហនុ មកជាអ្នកការពារសម្តេច សីហនុ ទៅវិញ ។ កងទ័ពបដិវត្តន៍បានចាប់ផ្តើមរីកលូតលាស់យ៉ាងឆាប់រហ័ស ហើយមូលដ្ឋានមហាជនកុម្មុយនិស្តកើនឡើងយ៉ាងសន្ធឹកសន្ធាប់ ។ នៅពេលនេះ អង្គការកុម្មុយនិស្តបរិសុទ្ធជាក់ស្តែងត្រូវបានទុកមួយឡែកសិន ហើយពាក្យស្លោកការពារប្រធានរដ្ឋស្របច្បាប់និងឯករាជ្យជាតិបានលេចធ្លោយ៉ាងខ្លាំង ។

នៅខែមេសា-ឧសភា ឆ្នាំ១៩៧០ កម្លាំងសំខាន់របស់វៀតណាមខាងជើងបានចូលមកកម្ពុជាតាមការរំពឹងសុំជំនួយពីសំណាក់វៀតណាម មិនមែនដោយ ប៉ុល ពត ទេ ប៉ុន្តែដោយអនុរបស់ ប៉ុល ពត គឺ នួន ជា ។ ង្វៀន កូ ថាច់ រំឭកថា «នួន ជា បានសុំជំនួយ ហើយយើងបានរំដោះខេត្តបានចំនួនប្រាំក្នុងរយៈពេល១០ថ្ងៃ» ។ ព័ត៌មានមកពីកិច្ចសន្ទនារវាងមិត្តអាល្លឺម៉ង់ជាមួយនឹងអនុរដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ង្វៀន កូថាច់ ដែលស្នាក់នៅលម្ហែកាយនៅសាធារណរដ្ឋអាល្លឺម៉ង់ ចាប់ពីថ្ងៃទី១ដល់ថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៧៨ ។ តាមពិតនៅឆ្នាំ១៩៧០ កងទ័ពវៀតណាមបានកាន់កាប់ទឹកដីកម្ពុជាស្ទើរតែមួយភាគបួនទៅហើយ ហើយតំបន់គ្រប់គ្រងតាមបែបកុម្មុយនិស្តបានរីកលូតលាស់ជាច្រើនដង ពីព្រោះអំណាចនៅក្នុងតំបន់រំដោះត្រូវបានប្រគល់ទៅឲ្យបក្សកុម្មុយនិស្តកម្ពុជា ។ នៅពេលនោះ ទំនាក់ទំនងរវាង ប៉ុល ពតនិងមេដឹកនាំវៀតណាមខាងជើង មានលក្ខណៈកក់ក្តៅជាទីបំផុត ទោះជាយើងអាចនិយាយថាវៀតណាមបានបង្កភាពប្រទូសរ៉ាយជាក់ស្តែងក្នុងចំណោមថ្នាក់ដឹកនាំកម្ពុជាតាមរយៈនយោបាយ «បង១» ស្មោះស្ម័គ្រចំពោះជនជាតិខ្មែរក៏ដោយ ។

ថ្នាក់ដឹកនាំវៀតណាមថែមទាំងមិនលាក់ការពិតដែលថា ដោយសហការជាមួយបក្សពលករវៀតណាម បក្សកុម្មុយនិស្តកម្ពុជាត្រូវបានប្រគល់តួនាទីជា «ប្អូន» មានភារកិច្ចដើរតាមទិសដៅរបស់ «បង១» ។ ឧទាហរណ៍លេខាគណៈកម្មាធិការមជ្ឈិមនៃបក្សពលករវៀតណាមឈ្មោះ ហ៊ីង អាញ់ បានប្រកាសនៅក្នុងកិច្ចប្រជុំពេញអង្គនៃគណៈកម្មាធិការមជ្ឈិមបក្សពលករវៀតណាមនៅក្នុងខែមករា ឆ្នាំ១៩៧១ ថា «យើងគួរតែពង្រីងមូលដ្ឋានបដិវត្តន៍នៅក្នុងប្រទេសកម្ពុជា ហើយដឹកនាំប្រទេសនេះតាមមាគ៌ាសង្គមនិយម ។ នេះគឺជានយោបាយរបស់បក្សយើង» ។ មិនតែប៉ុណ្ណោះ អង្គទូតសូវៀតដែលធ្វើការនៅទីក្រុងហាណូយបានកត់សម្គាល់ថា «កាលពីឆ្នាំទៅមិត្តវៀតណាមបានលើកឡើងនូវ «១» មួយចេញពីកម្មវិធីរបស់អតីតបក្សកុម្មុយនិស្តឥណ្ឌូចិនទាក់ទងនឹងការបង្កើតសហព័ន្ធឥណ្ឌូចិន» ។

គំនិតនៃការបង្កើតសហព័ន្ធនេះគឺស្ថិតនៅក្នុងការបង្រួបបង្រួមវៀតណាម ឡាវ និងកម្ពុជា ជារដ្ឋតែមួយក្រោយពីជ័យជម្នះបដិវត្តន៍ឥណ្ឌូចិន ក្រោមការដឹកនាំដាក់ទិសរបស់កុម្មុយនិស្តវៀតណាមក្នុងនាមជា«បង» ។ ជាធម្មតា ផែនការរបស់មេដឹកនាំក្រុងហាណូយត្រូវបានដឹងឮសុះសាយនៅក្នុងប្រទេសកម្ពុជា ហើយមិនអាចមិនបង្កឲ្យមានគំនុំនិងការមិនទុកចិត្តគ្នារវាងខ្មែរកុម្មុយនិស្តដែលមិនយកគំនិតរបស់ខ្លួនទៅគិតគូរអំពីអនាគតរបស់កម្ពុជាឡើយ ។ តំណាងសូវៀតនៅក្នុងប្រទេសវៀតណាមបានជ្រាបច្បាស់ណាស់អំពីឥរិយាបថប្រុងប្រយ័ត្ននិងប្រទូសរ៉ាយរបស់ខ្មែរកុម្មុយនិស្តនិងឡាវកុម្មុយនិស្ត ចំពោះផែនការរបស់ទីក្រុងហាណូយទៅលើការដាក់លក្ខខណ្ឌចំពោះឯករាជ្យភាពរបស់ឡាវនិងកម្ពុជា ព្រមទាំងអង្គការថ្មីនៃអតីតទឹកដីឥណ្ឌូចិនក្រោមអាណានិគមបារាំង ។ នៅក្នុងសំបុត្រនយោបាយមួយច្បាប់ក្នុងឆ្នាំ១៩៧១ តំណាងសូវៀតបានកត់សម្គាល់ថា « ដំណោះស្រាយជាតិចង្អៀតចង្អល់របស់មិត្តវៀតណាមចំពោះដំណោះស្រាយបញ្ហាឥណ្ឌូចិន និងការប៉ុនប៉ងដែលគួរកត់សម្គាល់ក្នុងការដាក់បញ្ហាឡាវនិងកម្ពុជានៅក្នុងផលប្រយោជន៍វៀតណាម បានបណ្តាលឲ្យមានការមិនពេញចិត្ត តែមិនទាន់ស្តែងចេញឲ្យឃើញពីសំណាក់មិត្តឡាវនិងកម្ពុជានៅឡើយទេ ។

ការមិនពេញចិត្ត«មិនទាន់ស្តែងចេញឲ្យឃើញ»នេះត្រូវបានមើលឃើញតាមរយៈការទាក់ទងរបស់ ប៉ុល ពត និង ឡេ យន់ ។ នៅក្នុងសំបុត្រឆ្នាំ១៩៧៤ ប៉ុល ពត និយាយថា «ជ័យជម្នះទាំងអស់មិនអាចកាត់ផ្តាច់ចេញពីជំនួយរបស់បងប្អូននិងមិត្តរួមអាវុធយើងទេ ពោលគឺប្រជាជនវៀតណាមនិងបក្សពលករវៀតណាម» ហើយប្រកាសដាច់ខាតថា «ទំនាក់ទំនងរវាងបក្សរបស់យើងគឺផ្អែកលើការគោរពគ្នាទៅវិញទៅមក និងមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងគ្នា» ។

ជាការច្បាស់ណាស់ថា បក្សនិងអង្គការចាត់តាំងយោធារបស់ខ្មែរក្រហម«កាន់តែមានកម្លាំងខ្លាំងឡើង ។ បំណងរបស់មេដឹកនាំខ្មែរក្រហម អរិភាព និងភាពមិនទុកចិត្តសួពូជចំពោះវៀតណាម» តាមប្រវត្តិសាស្ត្រ ខ្មែរតែងតែមិនចូលចិត្តវៀតណាម ដោយចាត់ទុកវៀតណាមថាជា(អ្នកឈ្លានពានទឹកដី) បានចេញរូបរាងកាន់តែច្បាស់ឡើងៗៈ «ខ្មែរក្រហមឲ្យតែមានឱកាសន្ទាលនឹងកំណត់ជំហររបស់ខ្លួន គឺឯករាជ្យពីវៀតណាម ។ នៅក្នុងតំបន់រំដោះ ខ្មែរក្រហមបានហាមប្រាមប្រជាជនមូលដ្ឋានមិនឲ្យទៅទាក់ទងជាមួយវៀតណាម វាយប្រហារក្រុមវៀតណាមដែលបែកពីហ្វូង ចាប់រទេះដែលដឹកស្បៀងអាហារ គ្រាប់រំសេវនិងសម្ភារសឹក» ។


យោធាខ្មែរក្រហម១៩៧៥-១៩៧៩

ចុងក្រោយ លទ្ធភាពធ្វើឲ្យ «អាម៉ាស់មុខ» និង «ផ្តាច់ខ្លួន» ពីទីក្រុងហាណូយត្រូវបានផ្តល់ដល់ខ្មែរក្រហមនៅឆ្នាំ១៩៧៣ ក្រោយពីបញ្ចប់កិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីស ប៉ុល ពត បានប្រែក្លាយពីមេដឹកនាំផ្លូវការមកជាមេដឹកនាំដាក់ស្តែងគ្រប់គ្រងទឹកដីរំដោះរបស់ប្រទេសខ្លួន ។ មូលហេតុនៃការផ្លាស់ប្តូរនេះ មកពីវៀតណាម

បានយល់ព្រមដកកងទ័ពរបស់ខ្លួនទាំងអស់ចេញពីកម្ពុជាតាមកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវកាលពីឆ្នាំ១៩៥៤ ។ ការដកកងទ័ពរបស់វៀតណាម បានបន្ធូរការពឹងពាក់របស់ថ្នាក់ដឹកនាំខ្មែរក្រហមចំពោះសេចក្តីណែនាំរបស់ទីក្រុងហាណូយ មិនឲ្យរចនាសម្ព័ន្ធរបស់បក្សរួបរឹតទៅដោយនយោបាយនិងមនោគមវិជ្ជារបស់ទីប្រឹក្សាវៀតណាមដ៏ច្រើនសន្ធឹកសន្ធាប់ និងជាពិសេសបង្អាក់ជីហររបស់សមាសភាពគាំទ្រវៀតណាមដោយស្មោះត្រង់នៅក្នុងបក្សកុម្មុយនិស្តកម្ពុជា ។ ហែម សាមិន ដែលជិតដិតជាមួយនឹងវៀតណាម និងជាសមាជិកមុនដំបូងបង្អស់របស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានរំឭកឡើងវិញថា ចាប់តាំងពីឆ្នាំ១៩៧៣ មកអ្នកដែលត្រឹមតែបានចូលរួមជាមួយបក្សនៅក្នុងកិច្ចប្រជុំយោធាបក្ស «បានចូលមកកាន់មុខតំណែងដោយសេរីបញ្ចេញភាពគ្រោតគ្រាត និងរិះគន់ដោយគ្មានមូលដ្ឋានច្បាស់លាស់ចំពោះទាហានជើងចាស់ដែលគាំទ្រវៀតណាម ។ ឆ្នាំ១៩៧៣ មានការរត់ភៀសខ្លួនលើកដំបូងរបស់កម្មាភិបាលនៅក្នុងខណៈដែលអនាគតឥស្សរជនល្បីៗក្រោយពីសម័យ ប៉ុល ពត ដូចជា មាច សំណាង និង កែវ ចិន្តា ជាមួយនឹងកងទ័ពវៀតណាម រត់ចាកចេញពីប្រទេស ។ ប៉ែន សុវណ្ណ ដែលក្លាយជាប្រធានគណបក្សប្រជាជនបដិវត្តន៍កម្ពុជាបង្កើតឡើងសាជាថ្មីដោយវៀតណាមនៅក្រោយឆ្នាំ១៩៧៩ បានចាកចេញពីគណៈកម្មាធិការនាយកនៃវិទ្យុខ្មែរក្រហមនៅក្នុងឆ្នាំ១៩៧៣ ហើយបានរត់ភៀសខ្លួនទៅប្រទេសវៀតណាម ។ ការដកកងទ័ពវៀតណាមចេញពីប្រទេសកម្ពុជា និងការបន្ថយទម្ងន់នៃការគ្រប់គ្រងរបស់វៀតណាម បានធ្វើឲ្យថ្នាក់ដឹកនាំសំខាន់ៗរបស់ខ្មែរចាប់ផ្តើមភ្ញាក់រឭករៀបចំផែនការរបស់ខ្លួនដើម្បីរឹតបន្តឹងនយោបាយក្នុងស្រុក ក្នុងស្មារតី «មហាលោតផ្លោះ មហាអស្ចារ្យ» និង «បដិវត្តន៍វប្បធម៌» ។ ការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនិងខ្លាំងក្លាផាកមករកការធ្វើឲ្យជីវភាពភូមិខ្មែរទៅរបបជាសង្គមនិយមនិងអង្គការចាត់តាំងថ្មីតាមរបៀបឃុំនានារបស់ចិន បានចាប់ផ្តើមឡើងក្រោយពេលដែលវៀតណាមដកចេញពីប្រទេសតែម្តង ។ វាគឺជាការផាររប្រថុយគ្រោះថ្នាក់ ដោយសារថាវានឹងអាចបង្កការសង្ស័យថា មេដឹកនាំកុម្មុយនិស្តកម្ពុជានឹងមិនដើរតាមគន្លងផ្លូវរបស់សូវៀតឬវៀតណាម តែបែរជាពេញចិត្តបទពិសោធន៍របស់ចិនទៅវិញ ។

ជីហររបស់ខ្មែរក្រហមពង្រឹងខ្លួនសាជាថ្មីក្រោយពីមានជោគជ័យនៅគ្រប់សមរភូមិមុខ នៅក្នុងការវាយប្រហារទ្រង់ទ្រាយធំនៅចុងខែមករានិងដើមខែកុម្ភៈ ឆ្នាំ១៩៧៣ ។ ហេតុដូចនេះ ប៉ុល ពត ស្ទើរតែបង្ហាញឲ្យអ្នកទាំងអស់ឃើញថា «ការក្បត់» របស់វៀតណាម«ហាណូយបានចាកចេញពីយើង(នៅក្នុងកិច្ចសន្ទនាជាមួយនឹងសម្តេច សីហនុ ខៀវសំផន បានវាយតម្លៃទៅលើកិច្ចព្រមព្រៀងទីក្រុងបារីស)» ហើយការធ្វើឲ្យធ្លាក់ដុនដាបនូវទំនាក់ទំនងជាមួយបក្សពលករវៀតណាមដោយសារតែការបដិសេធពីសំណាក់ខ្មែរក្រហមមិនចូលរួមក្នុងកិច្ចចរចាជាមួយនឹងរដ្ឋាភិបាល លន់ ណុល ទោះបីជាមាន «អនុសាសន៍» ដ៏ទទូចរបស់វៀតណាមយ៉ាងណាក៏ដោយ ក៏មិនមានផលប៉ះពាល់ដល់ប្រតិបត្តិការរបស់ខ្មែរកុម្មុយនិស្តឡើយ ។ នៅក្រោមការដឹកនាំរបស់ ប៉ុល ពត បក្សកុម្មុយនិស្តកម្ពុជាមិនដូចនៅឆ្នាំ១៩៥៤ ទេគឺបានរៀបចំខ្លួនជាស្រេចសម្រាប់ការផ្លាស់ប្តូរព្រឹត្តិការណ៍ហើយមានលទ្ធភាពយកជ័យជម្នះផ្នែកយោធាដោយឯករាជ្យនៅក្នុងប្រទេសកម្ពុជា ។

នៅក្នុងនិទាឃរដូវឆ្នាំ១៩៧៣ នៅក្នុងកិច្ចសន្ទនាជាមួយនឹងឯកអគ្គរដ្ឋទូតសហភាពសូវៀត ឡេ យន់ និយាយថា «ការផ្តួចផ្តើមគំនិតនៅក្នុងកិច្ចការកម្ពុជានេះមិនស្ថិតនៅក្នុងដៃរបស់យើងទេ» ។ នេះជាការត្រឹមត្រូវ ប៉ុន្តែការទទួលស្គាល់របស់មេដឹកនាំវៀតណាមរូបនេះវាយឺតពេលទៅហើយ ។ ផាម ហុង សមាជិកគណៈកម្មាធិការប្រធានផ្នែកនយោបាយនិងប្រតិបត្តិទទួលបន្ទុកកម្ពុជានៃបក្សពលករវៀតណាម បានធ្វើការប៉ុនប៉ងបានសម្រេចក្នុងការប្រតិបត្តិទៅតាមការរៀបចំទុកជាមុនរបស់វៀតណាម ។ មនុស្សទាំងអស់យល់ច្បាស់ណាស់ថា ប៉ុល ពត កំពុងតែធ្វើសង្គ្រាមខ្លួនឯងដោយមិនពឹងពាក់ទីក្រុងហាណូយ ផាម ហុង បានរៀបចំកិច្ចប្រជុំមួយចំនួនជាមួយ ប៉ុល ពត នៅថ្ងៃទី២៤-២៦ ខែមករា ឆ្នាំ១៩៧៣ (ណាយ៉ាន់ ចាន់ដា: បងប្អូនដែលជាសត្រូវ) ។

នៅក្នុងខែមេសា ឆ្នាំ១៩៧៣ ទីក្រុងហាណូយបានផ្តល់

យោបល់ជាចំហដល់សម្ព័ន្ធមិត្តសូវៀតរបស់ខ្លួនថា វៀតណាម មិនបានគ្រប់គ្រងច្បាស់លាស់ទៅលើសភាពការណ៍នៅក្នុងបក្សកុម្មុយនិស្តកម្ពុជាទេ ។ នៅក្នុងកិច្ចសន្ទនាដដែលនេះដែរជាមួយនឹងឯកអគ្គរដ្ឋទូតសហភាពសូវៀត ឡេ យន់ ប្រកាសថា «បក្សប្រជាជនបដិវត្តន៍កម្ពុជាមិនមានការស្រុះស្រួលគ្នាដាច់ស្រេចទាំងជាមួយនឹងសម្ដេច សីហនុ និងសមាជិករបស់ខ្លួន ។ អង្គការរបស់បក្សនេះគឺមានមូលដ្ឋាននៅទីក្រុងប៉េកាំង ។ សូម្បីតែស្ថានទូតចិនប្រចាំនៅទីក្រុងហាណូយក៏មានការទាក់ទងជាច្រើនជាមួយនឹងអង្គការនេះជាងយើងទៀតផង ។ ប៉ុន្តែទោះបីជាយ៉ាងនេះក្ដី សមមិត្តខ្មែរមានការប្រុងប្រយ័ត្នខ្លាំងណាស់ ។ ជំនួយរបស់យើងចំពោះអង្គការនេះមានច្រើនគួរសម ដែលអាចឲ្យយើងមានលទ្ធភាពក្នុងការខិតចូលកាន់ជិតជាបណ្ដើរៗ» ។

ផាម វ៉ាន់ដុង បានប្រាប់ឯកអគ្គរដ្ឋទូតសហភាពសូវៀតអំពីភាពលែងជិតស្និទ្ធនៃទំនាក់ទំនងដ៏ជូរចត់រវាងជនកុម្មុយនិស្តខ្មែរនិងជនកុម្មុយនិស្តវៀតណាម ។ នៅក្នុងកិច្ចសន្ទនាថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៣ នាយករដ្ឋមន្ត្រីវៀតណាមបានកត់សម្គាល់ថា «កិច្ចគាំទ្រនិងជំនួយការរបស់យើងចំពោះមិត្តកម្ពុជាកំពុងតែថយចុះ ហើយឥឡូវនេះ ទម្ងន់នៃកិច្ចគាំទ្រនិងជំនួយការនេះមិនសំខាន់ទៀតទេ» ។ ផាម វ៉ាន់ដុង បានប្រកាន់ជំហរសុទិដ្ឋិនិយមបើប្រៀបធៀបជាមួយនឹងជំហររបស់ ឡេ យន់ នៅក្នុងខណៈដែលគាត់ត្រូវបានសួរដោយតំណាងសូវៀតស្ដីអំពី «វត្តមាននៃការរួមគំនិតនៅក្នុងបញ្ហាកម្ពុជានៅក្រោយខ្នងវៀតណាម» ផាម វ៉ាន់ដុង និយាយថា «យើងដឹងថាមានផែនការសំដៅបង្កើតការលំបាក រកាំរកូសនៅក្នុងទំនាក់ទំនងរវាងប្រជាជននៅជ្រោយឥណ្ឌូចិន ។ តែទោះជាយ៉ាងណា យើងមានកម្លាំងគ្រប់គ្រាន់ក្នុងការប្រឆាំងទប់ទល់នឹងផែនការនេះ ។ ថ្នាក់ដឹកនាំសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមកំពុងតែធ្វើការឥតឈប់ឈរលើបញ្ហាកម្ពុជា» ។

តាមទិដ្ឋភាពទូទៅឃើញថា ដោយស្ថិតនៅក្រោមឥទ្ធិពលនៃពត៌មានរបស់មេដឹកនាំវៀតណាមស្ដីអំពីឯករាជ្យភាពដែលមានសារសំខាន់របស់ថ្នាក់ដឹកនាំខ្មែរ មន្ត្រីទីក្រុងម៉ូស្គូបានទាញសន្និដ្ឋានអំពីភាពចាំបាច់ក្នុងការធ្វើការទាក់ទងដោយខ្លួនឯងជាមួយនឹងខ្មែរក្រហម ។ នៅក្នុងកិច្ចសន្ទនាជាមួយនឹង ផាម វ៉ាន់ដុង ឯកអគ្គរដ្ឋទូតសហភាពសូវៀតនិយាយថា «សមមិត្តបក្សប្រជាជនបដិវត្តន៍កម្ពុជាវាយតម្លៃមិនត្រឹមត្រូវទៅលើការទាក់ទងរបស់ខ្លួនជាមួយនឹងបក្សកុម្មុយនិស្តសហភាពសូវៀត ដោយពឹងផ្អែកតែទៅលើបញ្ហាទទួលស្គាល់សម្ដេច សីហនុ របស់សហភាពសាធារណរដ្ឋសង្គមនិយមសូវៀត ។ យើងចាំបាច់ត្រូវការកម្ពុជាជួយ ដើម្បីឲ្យយើងដឹងអំពីសភាពការណ៍នៅកម្ពុជាកាន់តែច្បាស់ថែមទៀត» ។

បន្តិចក្រោយមក នៅខែមិថុនា ឆ្នាំ១៩៧៣ ទីប្រឹក្សារបស់ស្ថានទូតសហភាពសាធារណរដ្ឋសង្គមនិយមសូវៀតប្រចាំនៅសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម បានជម្រាបទីក្រុងម៉ូស្គូថា «តាមការចាត់តាំងពីមជ្ឈិម ខ្ញុំបានប្រគល់សំបុត្ររបស់គណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនិស្តសហភាពសូវៀតទៅឲ្យគណៈកម្មាធិការមជ្ឈិមនៃបក្សប្រជាជនបដិវត្តន៍កម្ពុជា ។ នៅក្នុងកិច្ចសន្ទនាជាមួយនឹងអនុប្រធានមន្ទីរនៃគណៈកម្មាធិការមជ្ឈិមនៃបក្សពលករវៀតណាមឈ្មោះ ជិន ជី កៀន ទីប្រឹក្សារូបនេះបាននិយាយថា ជាការពិបាកក្នុងការទាយទុកមុនអំពីការឆ្លើយតបរបស់មិត្តកម្ពុជាទាក់ទងនឹងបញ្ហាថាតើកម្ពុជានឹងពិចារណាគំនិតផ្តួចផ្តើមរបស់គណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនិស្តសហភាពសូវៀតតាមរបៀបណា» ។

តាមការវិភាគឯកសារនេះបានបណ្ដាលឲ្យមានការភ្ញាក់ផ្អើលថា ការប៉ុនប៉ងរបស់ទីក្រុងម៉ូស្គូក្នុងការបង្កើតការទាក់ទងជាមួយនឹងខ្មែរក្រហមត្រូវបានធ្វើឡើងដោយប្រយោលតាមរយៈសម្ព័ន្ធមិត្តវៀតណាមដែលថ្នាក់ដឹកនាំខ្មែរជឿទុកចិត្តតិចតួចបំផុត ។ ការប្រគល់បន្ទូវការស្នើជាផ្លូវការសុំកិច្ចសហប្រតិបត្តិការជាមួយខ្មែរតាមរយៈបក្សពលករវៀតណាម ធ្វើឲ្យគម្រោងការទាំងមូលត្រូវជួលរលំបះដើង ។ តាមទិដ្ឋភាពសព្វថ្ងៃនេះ ទីក្រុងម៉ូស្គូមានបំណងចង់បង្កើតទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងថ្នាក់ដឹកនាំខ្មែរក្រហម ក្នុងពេលដែលខ្លួនមិនចង់ធ្វើឲ្យមានភាពស្មុគស្មាញនៅក្នុងទំនាក់ទំនងជាមួយនឹងទីក្រុងហាណូយ ដោយព្យាយាមចូលកៀកថ្នាក់ដឹកនាំកម្ពុជាពីលើក្បាលហាណូយ ។ ***(នៅមានត)***

**មិទ្រី មូសយ៉ាកូវ**

# រឿងរ៉ាវនៃការនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោស

**(តពីលេខមុន)** រីក យ៉័ររី ដែលចាត់ទុកខ្មែរក្រហមថាមានកំហុសប្រព្រឹត្ត «អំពើឃោរឃៅគ្មានត្រាប្រណី» និង «ឃាតកម្ម» ទាញហេតុផលថា នៅក្នុងប្រទេសកម្ពុជាមិនដូចនៅក្នុងប្រទេសចិននិងវៀតណាមទេ «ជាតិនិយម មហាជននិយម និងប្រជាកសិករនិយម បានសម្រេចនូវកុម្មុយនិស្តនិយម» ។ អំពើឃោរឃៅរបស់កម្ពុជាប្រជាធិបតេយ្យមុនដំបូងគឺដោយសារវាជាការសម្រេចបដិវត្តន៍ដោយមានជនបដិវត្តន៍ដែលជាកសិករធ្វើនូវអ្វីដែលអ្នកបះបោរកសិករតែងតែបានធ្វើឡើងចំពោះខ្មាំងនៅទីក្រុងរបស់ខ្លួន។ រីក យ៉័ររី ជឿជាក់ថា របបកាន់លទ្ធិម៉ាក្សអាចត្រូវបានទទួលយក ។ ប៉ុន្តែ ឆេនដល័រ ទាញហេតុផលបញ្ច្រាសវិញថា លទ្ធិម៉ាក្សជាអ្នកទទួលខុសត្រូវចំពោះអំពើឃោរឃៅ ការបំប្លែងកត្តាដទៃ ទៀតមានដូចជានយោបាយរើសអើងនិងនយោបាយប្រល័យពូជសាសន៍។ ឆេនដល័រ ទាញហេតុផលថា «ក្រោមរបបកម្ពុជាប្រជាធិបតេយ្យមានប្រជាជនមួយលាននាក់ ឬមួយនាក់ក្នុងចំណោមប្រជាជន៨នាក់ ស្លាប់ដោយបញ្ហាសុខភាព ការអត់អាហារ ធ្វើការបាក់កម្លាំង ជំងឺតម្កាត់ដែលត្រូវបានធ្វើរោគវិនិច្ឆ័យខុស និងដោយការសម្លាប់ ។ ប៉ុន្តែភាគច្រើននៃការស្លាប់ទាំងនេះមិនមែនជាចេតនារបស់កម្ពុជាប្រជាធិបតេយ្យឡើយ ។ ផ្ទុយទៅវិញ ប្រជាជនកម្ពុជាមួយនាក់ក្នុងចំណោម៨នាក់ក្លាយជាជនរងគ្រោះដោយសារកម្មវិធីស្អាតស្អំឥតខ្ចោះរបស់រដ្ឋាភិបាលដែលជាការផ្លាស់ប្តូរផ្នែកសង្គមយ៉ាងឆាប់រហ័ស ដែលមេដឹកនាំរបបនេះបានសង្ឃឹមទុកថានឹងចំណាយជាងនេះឆ្ងាយណាស់ ។

ការបដិសេធថាមិនមានអំពើប្រល័យពូជសាសន៍នេះទោះបីជាខ្ញុំយល់ថាមិនពិតក៏ដោយ គឺមានលក្ខណៈស្របច្បាប់គួរសមដែរ ។ រីក យ៉័ររី និង ឆេនដល័រ មិនស្ថិតក្នុងជំហរសើរើអំពីហាយនភាពដូចជាលោក ស៊ឺរ ធីយ៉ុង ឡើយ ដោយបដិសេធកម្រិតនិងលទ្ធភាពនៃអំពើប្រល័យពូជសាសន៍។ ធីយ៉ុង ប្រើពាក្យ «ការនិរទេស» សម្រាប់វាសនារបស់ជនជាតិជ្វីហ្វ នៅក្នុងទឹកដីអឺរ៉ុបដែលកាន់កាប់ដោយពួកណាហ្ស៊ី ហើយមានចម្ងល់ទៅលើភ័ស្តុតាងនៃកន្លែងឧស្ម័នពុល ។ (នៅក្នុងករណីដូចជា ធីយ៉ុង អះអាងថា ឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមអាចត្រូវបានវិនិច្ឆ័យក្តីនៅក្នុងតុលាការប្រទេសកម្ពុជាប្រសើរជាងតុលាការអន្តរជាតិ) ។ ប៉ុន្តែផ្ទុយមកវិញ ការទាញហេតុផលនានាដែលថា ប្រជាជនកម្ពុជាមិនទទួលរងអំពើប្រល័យពូជសាសន៍ ប៉ុន្តែរងនូវ «បដិវត្តប្រជាកសិករបរិសុទ្ធ» (រីក យ៉័ររី) ឬ «បដិវត្តបរិសុទ្ធឥតខ្ចោះនិងហួតចត់ដើរតាមលទ្ធិម៉ាក្ស-លេនីន» (ឆេនដល័រ) មានមូលដ្ឋានអាចការពារខ្លួនបាន ។

ការវិភាគផ្សេងៗរបស់ រីក យ៉័ររី និង ឆេនដល័រ មានលក្ខណៈពិតជាងជំហរទី៣ ដែលថាពុំមានអំពើប្រល័យពូជសាសន៍កើតឡើងដូចអ្វីដែលទិនានុប្បវត្តិទំព័រពិសេសបានពិពណ៌នាទេក្នុងគោលបំណងបន្លំការស៊ើបអង្កេតអំពើនេះ ។ ឥឡូវខ្ញុំសូមធ្វើការពិនិត្យទៅលើការប៉ុនប៉ងមួយចំនួនក្នុងការគាបសង្កត់ការកត់ត្រាជាប្រវត្តិសាស្ត្ររបស់ស៊ី.ដី.ភី ទៅលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក្នុងក្តីសង្ឃឹម ដើម្បីធ្វើជាមេរៀនបង្ហាញផ្លូវសម្រាប់អ្នកសរសេរកាលប្បវត្តិស្តីអំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ និយាយឲ្យខ្លី ខ្ញុំនឹងសង្កត់ធ្ងន់ទៅលើការទាញហេតុផលរបស់អ្នកដែលបដិសេធមិនព្រមប្រើពាក្យ «ប្រល័យពូជសាសន៍» ក្នុងករណីប្រទេសកម្ពុជា ប្រឆាំងនឹងការចាត់វិធានការនៃអ្នកដែលព្យាយាមបង្វែងជានការស៊ើបអង្កេតឲ្យទៅផ្តោតលើបញ្ហាផ្សេងៗវិញ ឬនិយាយឲ្យស្រួលស្តាប់ ការព្យាយាមក្នុងការគាបសង្កត់អង្គហេតុពិតនៃករណីទាំងនេះ ។

ការប៉ុនប៉ងទីមួយក្នុងការធ្វើឲ្យស៊ី.ដី.ភីដួលច្រងាប់ច្រងិលគឺចេញមកពីប្រភពបុរសម្នាក់ដែលហៅខ្លួនឯងថា «ជនជាតិឈីលីដ៏កម្សត់ម្នាក់ដែលជាប្រជាជាតិតតិយលោក» ។ ដូលីយ៉ូ អេ.ដីលជ្រេស បានចេញពីប្រទេសឈីលីមុនរដ្ឋប្រហារឆ្នាំ១៩៧៣ ហើយបន្ទាប់មកបានធ្វើដំណើរទៅកាន់ប្រទេសអូស្ត្រាលីនិងប្រទេសកម្ពុជា ។ នៅទសវត្សរ៍ឆ្នាំ១៩៧០ ដីលជ្រេស មិនត្រឹមតែជាអ្នកគាំទ្រអំណាចយោធាផ្តាច់ការរបស់ពីណូដេនៅប្រទេស

ឈីលីប៉ុណ្ណោះទេ តែថែមទាំងជាសមាជិកនៃអង្គការរណសិរ្សអន្តរជាតិរបស់ខ្មែរក្រហមទៀតផង ។ ក្នុងអំឡុងពេលប៉ុន្មានសប្តាហ៍នៃដំណើរការកម្មវិធីសិក្សាអំពីប្រល័យពូជសាសន៍នៅប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩៥ ជីលជ្រេស បានចេញផ្សាយអត្ថបទមួយមានចំណងជើងថា "ការស៊ើបអង្កេតពីអំពើប្រល័យពូជសាសន៍ជាការគួរឲ្យភ្ញាក់ផ្អើលមិនអាចទទួលយកបាន" ។

ក្នុងការឆ្លើយតបវិញ ខ្ញុំសង្កេតឃើញថា ជីលជ្រេស គាំទ្ររបបដឹកនាំរបស់លោក ពីណូជេ ។ ជីលជ្រេស បានបដិសេធយ៉ាងរហ័សថា មិនបានធ្វើការឲ្យរបបបក្សដែលដឹកនាំដោយឧត្តមសេនីយ៍ ពីណូជេឡើយ ដោយប្រកាសថាខ្លួនជា "សមាជិកម្នាក់នៃក្រុមរបាំប្រជាប្រិយឈីលី ដែលមិនមែនជាក្រុមនយោបាយជាសមាគមវប្បធម៌ដែលគ្មានពាក់ព័ន្ធផ្នែកនយោបាយ" ។ ក៏ប៉ុន្តែសេចក្តីប្រកាសរបស់ ជីលជ្រេស បោះផ្សាយនៅឆ្នាំ១៩៧៥ ដែលមានហត្ថលេខារបស់លោកផ្ទាល់ក្នុងនាមជា "ប្រធានក្លិបឈីលីនេះ" មិនមាននិយាយអំពីរបាំប្រពៃណីនេះឡើយ ។ នៅក្នុងសេចក្តីប្រកាសនោះ ជីលជ្រេស បានសម្តែងការអាណិតចំពោះលោក ពីណូជេ របស់ប្រទេសឈីលី ដែលលោកឆ្លើយថា"ជាជនរងគ្រោះនៃឥរិយាបថរបស់រដ្ឋាភិបាលប្រទេសអូស្ត្រាលីចំពោះប្រទេសខ្ញុំ" ។ ជីលជ្រេស បានសរសើររដ្ឋប្រហាររបស់ ពីណូជេ ធ្វើឡើងនៅឆ្នាំ១៩៧៣ ដើម្បីធានាសើៗថា "លទ្ធិម៉ាក្សត្រូវបានបណ្តេញចេញហើយ" ។ ជីលជ្រេស មិនការពារចំពោះវិនាសកម្មនៃលទ្ធិប្រជាធិបតេយ្យរបស់ប្រទេសឈីលីឡើយ តែបែរជាប្រកាសបដិសេធការគាំទ្រពីអន្តរជាតិទៅលើលទ្ធិប្រជាធិបតេយ្យទៅវិញ ។ មិនខុសពី ពីណូជេ ទេ ជីលជ្រេស បានឲ្យតម្លៃប្រជាធិបតេយ្យស្មើនឹងលទ្ធិកុម្មុយនិស្ត ហើយត្អូញត្អែរថា អំណាចផ្តាច់ការរបស់ប្រទេសឈីលីគឺជា "គោលដៅនៃយុទ្ធនាការអន្តរជាតិប្រឆាំងនឹងយើង" ។

ដូច្នេះមិនមែនជាការភ្ញាក់ផ្អើលឡើយ ដែលក្រោយមកឃើញលោក ជីលជ្រេស ប៉ុនប៉ងទប់ស្កាត់ការចាត់វិធានការប្រឆាំងនឹងរបបពោរពេញដោយឃាតកម្មដទៃទៀត ហើយពិសេសនៅប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះតែម្តង ។ ជីលជ្រេស បានធ្វើជា "សមាជិកកិត្តិយស" នៃអង្គការរណសិរ្សខ្មែរក្រហមអស់រយៈពេលយ៉ាងហោចណាស់ក៏៥ឆ្នាំដែរ ។ នៅក្នុងឆ្នាំ១៩៧៦ ជីលជ្រេស បានលើកដើងខ្លួនឯងដែលស្ថិតនៅក្នុងឋានៈ "កិត្តិយស" បន្តទៅទៀត ។ ក្នុងឆ្នាំ១៩៧៨ នៅពេលមានអំពើប្រល័យពូជសាសន៍ពេញទំហឹង ជីលជ្រេស បានចូលខាងខ្មែរក្រហមប្រឆាំងនឹងវៀតណាម ហើយថែមទាំងអះអាងថារបប ប៉ុល ពត បានប្រាប់គាត់អំពីរឿងរ៉ាវទាំងអស់ដែលគាត់ចង់ដឹង ។ ពេលនោះ ជីលជ្រេស បាននិយាយថា "ស្ថានទូតកម្ពុជាប្រចាំនៅប្រទេសចិន បានជម្រាបខ្ញុំដោយឥតលាក់លៀមអ្វីទាំងអស់" ។ មកដល់ឆ្នាំ១៩៩៥ ដែលជាឆ្នាំនៃយុទ្ធនាការប្រឆាំងនឹងការស៊ើបអង្កេតរបស់ ស៊ី.ជី.ភី ទៅលើសម័យខ្មែរក្រហម ជីលជ្រេស បានបន្តអះអាងថារបបកម្ពុជាប្រជាធិបតេយ្យ "គឺជាប្រភពតែមួយគត់ដែលផ្តល់ព័ត៌មានអំពីអ្វីដែលកំពុងកើតឡើងនៅប្រទេសកម្ពុជា" ។ ជីលជ្រេស ជាមនុស្សតែម្នាក់គត់ដែលមិនបានពិចារណាពត៌មានមកពីជនភៀសសឹកនិងជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ ។

នៅទសវត្សរ៍ឆ្នាំ១៩៨០ ជីលជ្រេស បានសហការជាមួយរណសិរ្សមួយទៀតរបស់ខ្មែរក្រហម ដែលជារដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យនិរទេស ។ នៅដើមទសវត្សរ៍ឆ្នាំ១៩៩០ ជីលជ្រេស បានធ្វើការនៅទស្សនាវដ្តីមនសិការខ្មែរ ដែលបោះផ្សាយសំណេររបស់ ថាច់ ប៊ុនរឿន ។ នៅក្នុងសារព័ត៌មានជាភាសាអង់គ្លេស-ខ្មែរ ឆ្នាំ១៩៩៥ និងឆ្នាំ១៩៩៦ ជីលជ្រេស បានបន្តនិយាយប្រឆាំងការស៊ើបអង្កេតរបស់ស៊ី.ជី.ភីដដែល ។

ការប៉ុនប៉ងរបស់បុគ្គលទាំងនេះ ក្នុងការគាបសង្កត់កម្មវិធីសិក្សាស្រាវជ្រាវដើម្បីចងក្រងជាឯកសារទាក់ទងនឹងឧក្រិដ្ឋកម្មមានភាពផ្សេងៗគ្នាទាក់ទងនឹងនយោបាយនៃ "ការបដិសេធ" ថាមានអំពើប្រល័យពូជសាសន៍ ។ សម្ព័ន្ធមិត្តយូរអង្វែង និងសូម្បីតែសមាជិកនៃអង្គការខ្មែរក្រហម ក៏បានចាត់ទុកខ្លួនឯងថាជាអ្នកប្រឆាំងនឹងអំពើប្រល័យពូជសាសន៍ដែរ ដោយទាមទារឲ្យធ្វើការស៊ើបអង្កេតកាត់ៗទៅបានហើយ ។ ក៏ប៉ុន្តែល្បិចនយោបាយនេះមិនអាចច្រឡំគ្នាជាមួយនឹងនិយមន័យផ្សេងៗគ្នានៃពាក្យថា អំពើប្រល័យពូជសាសន៍ ឬក៏ជាមួយនឹងការពិភាក្សាក្នុងមជ្ឈដ្ឋានអ្នកសិក្សាជាន់ខ្ពស់ស្តីពីសារជាតិនៃសោកនាដកម្មនេះឡើយ ។

ការវាយប្រហារ ទិនានុប្បវត្តិ វ៉ុលស្ទ្រីត មកលើស៊ី.ដី.ភី ត្រូវបានចាប់ផ្តើមឡើងដោយ ស៊ីវហ៊ិន ម៉ូរី ដែលបានជួប ដូលីយ៉ូ ជីលជ្រេស នៅក្នុងទីក្រុងបាងកកនៅទសវត្សរ៍កន្លងទៅនេះ ។ នៅពេញទសវត្សរ៍ឆ្នាំ១៩៨០ ម៉ូរី ក៏ដូចជា ជីលជ្រេស និង ថាច់ ប៊ុនរឿន ដែរ បានលះបង់ការតាំងចិត្តចូលរួមក្នុងសកម្មភាពនយោបាយគាំទ្រខាងក្រុមផ្សេងៗដែលចងសម្ព័ន្ធភាពជាមួយនឹងខ្មែរក្រហមកុម្មុយនិស្ត ។ ប៉ុន្តែ ម៉ូរី បានសរសើរក្រុមនេះទៅវិញថា "ជាអ្នកប្រឆាំងនឹងកុម្មុយនិស្ត" ។ នៅឆ្នាំ១៩៨៩ ម៉ូរី រអ៊ូថា រដ្ឋាភិបាលប្រជាធិបតេយ្យនៃប្រទេសថៃកំពុងតែលក់ខ្មែរក្រហមចេញ ។ "ឥឡូវនេះដល់ថ្នាក់មេបញ្ជាការថៃបានផ្តល់ការណ៍សម្ងាត់ បង្ហាញពីទីតាំងអង្គភាពច្បាស់ៗចំៗរបស់ខ្មែរក្រហមដល់មេបញ្ជាការកាំភ្លើងធំនៃក្រុងភ្នំពេញ ។ នៅរដូវរំហើយឆ្នាំ១៩៩០ ម៉ូរី បានចូលរួមប្រជុំជាមួយជនជាតិខ្មែរមួយក្រុមនៅក្នុងទីក្រុងប្រែតុន នៃរដ្ឋម៉ាសាឈូសេត ។ យោងតាមសម្តីរបស់សាក្សីបានឲ្យដឹងថា ម៉ូរី បានឡើងមកលើវេទិកា ហើយបានព្រមានប្រជាជនខ្មែរនៅក្នុងបន្ទប់នោះថា កុំធ្វើអ្វីដែលជាការគាំទ្រដល់រដ្ឋាភិបាលកម្ពុជាដែលគាំទ្រដោយវៀតណាម ហើយកុំស្ងួវជាយកចិត្តទុកដាក់ចំពោះអំពើឃោរឃៅរបស់ខ្មែរក្រហមពេក" ។ ម៉ូរី មិនបានគាំទ្រឲ្យមានតុលាការសម្រាប់ជម្រះក្តីខ្មែរក្រហមឡើយ ហើយសន្មតថា ការបានពត៌មានផ្ទៃក្នុងស្តីពីសភាពការណ៍កម្ពុជាជាលទ្ធផលនៃការចូលរួមភោជនាហារជាមួយមេដឹកនាំខ្មែរក្រហម ។ ម៉ូរី បានសរសេរថា "បំណងយោធារបស់ខ្មែរក្រហមគឺ...បង្ខំឲ្យទីក្រុងភ្នំពេញទទួលយកនូវដំណោះស្រាយនយោបាយទូលំទូលាយមួយដូចជាផែនការសន្តិភាពរបស់អង្គការសហប្រជាជាតិជាដើម" ។ ការវាយប្រហាររបស់ ម៉ូរី ចំពោះដំណើរការស៊ើបអង្កេតរបស់ ស៊ី.ដី.ភី ទៅលើរឿងរ៉ាវខ្មែរក្រហមគឺអាចទាយទុកមុនបាន ។ ម៉ូរី ក៏ធ្លាប់សរសើរ ស៊ីវ ហេង៉រ ជាអ្នកដែលខ្លួនបានកត់សម្គាល់ថា ជាអ្នកគាំទ្រគំនិតរបស់ខ្មែរក្រហមម្នាក់ដែរ ។

អ្វីជាការគួរឲ្យភ្ញាក់ផ្អើលជាងនេះ គឺភាពរៀបចំខ្លួនជាស្រេចរបស់ទិនានុប្បវត្តិ វ៉ុលស្ទ្រីត ក្នុងការទុកកន្លែងឲ្យអ្នកនិពន្ធដែលបានធ្វើឲ្យទិនានុប្បវត្តិខ្លួនឯងអាម៉ាស់មុខម្តងរួចមកហើយ ។ នៅក្នុងឆ្នាំ១៩៩០ ម៉ូរី បានវាយប្រហារលើ ឡេសលី ខក់ប៊ិន ដែលជាអ្នកផលិតពត៌មាននៅក្នុងក្រុមហ៊ុនផ្សាយសម្លេងសហរដ្ឋអាមេរិកចំពោះការផ្សាយសាច់រឿងរបស់នាងចំពោះបញ្ហាកម្ពុជា ។ ជាការជំទាស់ទៅនឹងការពិពណ៌នាដ៏សុក្រិត ចំពោះការគាំទ្រផ្នែកការទូតរបស់សហរដ្ឋអាមេរិកក្នុងទសវត្សរ៍ឆ្នាំ១៩៨០ ម៉ូរី ថែមទាំងបានវាយប្រហារអ្វីដែលគាត់ហៅថា "ឯកសារ ភីប៊ីអេស ឆ្នាំ១៩៨៧ របស់ ខក់ប៊ិន ដែលមានចំណងជើងថា ឃាតកម្មលើរូប រីយ៉ូ សាន ជាន" ។ ខក់ប៊ិន គ្មានការពាក់ព័ន្ធនឹងកម្មវិធីនេះឡើយ ហើយនាយកនិពន្ធយល់ព្រមថា ម៉ូរី ជាអ្នកធ្វើឲ្យមានកំហុស" ។

ការបរិហាររបស់ទិនានុប្បវត្តិទៅលើស៊ី.ដី.ភី បានទាក់ទាញឲ្យមានការចាប់អារម្មណ៍ពីសំណាក់ "រីដជ័រ ដាយបេស" ដែលស៊ើបអង្កេតដល់ការបោះពុម្ពសាជាថ្មី ។ នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៩៥ និពន្ធនាយកផ្នែកស្រាវជ្រាវរបស់ "រីដឌ័រ ដាយបេស" បានទូរស័ព្ទហៅខ្ញុំអំពីរឿងផ្សេងៗ ក្នុងនោះមានសំណួរមួយសួរថា តើខ្ញុំមានដែលមានប្រើពាក្យថា ម៉ាក្សស៊ីស ដែរឬទេ ។ ហើយបន្ទាប់មកគាត់ក៏ទូរស័ព្ទសួរប្រធានផ្នែករបស់ខ្ញុំនៅសកលវិទ្យាល័យយែល សួរថាតើខ្ញុំជាជនកុម្មុយនិស្តមែនឬ មិនមែន ។ ជារឿងសម្ងាត់ជាងនេះទៀត គាត់បានសាកសួរសមាជិកជាន់ខ្ពស់ដទៃទៀតធ្វើការនៅកន្លែងដដែលនេះ "តើអស់លោកដឹងទេថា ឃៀរនិន ជាជនកុម្មុយនិស្ត?" ។ ប៉ុន្តែពេលដែលខ្ញុំឆ្លើយតបទៅនឹងការវាយប្រហារទីពីររបស់ ម៉ូរី ដែលលេចឡើងនៅលើទំព័រទិនានុប្បវត្តិ វ៉ុលស្ទ្រីត នៅថ្ងៃទី៣០ ខែឧសភា សារពត៌មាន "រីដឌ័រ ដាយបេស" ក៏សម្រេចមិនចុះផ្សាយនូវអត្ថបទរបស់ ម៉ូរី ។

ទិនានុប្បវត្តិ បានផ្តល់ឱកាសជាលើកទី៣ ដល់ ម៉ូរី ក្នុងការនិយាយឡើងវិញនូវការចោទប្រកាន់របស់គាត់ ។ ពាក្យចុងក្រោយបានចេញមកពេលដែលអ្នកសិក្សាជាន់ខ្ពស់ស្តីពីបញ្ហាកម្ពុជាថ្នាក់អន្តរជាតិ២៩រូបសរសេរថា "ឃៀរនិន កន្លងមក គឺជាអ្នកហ៊ាននិយាយចេញមុខនឹងគួបដិបក្ខមិនចេះនឿយហត់ប្រឆាំងនឹងខ្មែរក្រហមអស់រយៈពេល១៧ឆ្នាំហើយ" ក្នុងខណៈដែល "ម៉ូរី កំពុងតែគាំទ្រដល់រដ្ឋាភិបាលចម្រុះនិរទេសដែលគ្របដណ្តប់អំណាច

ដោយពួកខ្មែរក្រហម» ។ អ្នកសិក្សាទាំងនេះដែលរួមទាំង វីកយ័រី និង ឆេនដល័រ ទោះជាមានគំនិតផ្សេងៗអំពី ស៊ី.ជី.ភី យ៉ាងណាក្តី ទៅលើបញ្ហាប្រល័យពូជសាសន៍បានបន្ថែមថា «យើងមានការជឿជាក់យ៉ាងមាំចំពោះសមត្ថភាពពេញលេញរបស់សាស្ត្រាចារ្យ យៀរនិន ដែលមានការចេះដឹងជ្រៅជ្រះនិងសមត្ថភាពអនុវត្តកិច្ចការសំខាន់ៗ លើកម្មវិធីសិក្សាអំពីប្រល័យពូជសាសន៍នៅកម្ពុជា» ។

យុទ្ធនាការនេះក៏បានចប់សព្វគ្រប់ទៅ ។ ដោយសារការបរាជ័យក្នុងការដេញដោលគ្នាក្នុងពិភពអ្នកសិក្សាជាន់ខ្ពស់ និងប្រព័ន្ធឃោសនា ម៉ូរី បានងាកទៅរកអ្នកមានអំណាចវិញ ។ រ៉ូប ម៉ាក ជាមន្ត្រីសេ.អ៊ី.អា ដែលត្រូវបានតែងតាំងជាជំនួយការពិសេសបណ្តោះអាសន្នរបស់សមាជិកព្រឹទ្ធសភា លោក បប ដូល បានព្រាងសំបុត្រមួយច្បាប់សរសេរសាឡើងវិញអំពីការចោទប្រកាន់របស់ ម៉ូរី ប្រឆាំងនឹងខ្ញុំ ។ សមាជិកព្រឹទ្ធសភានៃគណបក្សសាធារណរដ្ឋ មានលោក ដូល លោកមេដឹកនាំភាគច្រើនព្រឹទ្ធសភា ត្រិនឡូត់ ប្រធានគណៈកម្មាធិការទំនាក់ទំនងបរទេសព្រឹទ្ធសភា ជេស៊ីហែម និងបីនាក់ទៀត បានផ្ញើសំបុត្រទៅរដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិកនៅថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៩៥ ។ មានហត្ថលេខាពីរនាក់ គឺ ត្រិនឡូត់ និង ជេស៊ីហែម ត្រូវគ្នាជាមួយនឹងក្រុមប្រឹក្សាពលរដ្ឋអភិរក្សនិយម ដែលបានអះអាងក្នុងចំណោមបញ្ហាដទៃផ្សេងៗទៀតថា អាពាហ៍ពិពាហ៍រវាងជាតិផ្សេងៗគ្នា «នាំឲ្យមានអំពើប្រល័យពូជសាសន៍» ដែលជនជាតិជ្វីហ្វ បានប្រែក្លាយគំនុំទៅជាសុខមាលភាព ហើយថា ជនជាតិអាមេរិកដើមកំណើតអាហ្វ្រិក និងឡាទីនទទួលរងនូវ «ករណីឧក្រិដ្ឋកម្មកម្រិតខ្ពស់ និងមានបញ្ញាទាប» ។ នៅឆ្នាំ១៩៩២ សមាជិក ព្រឹទ្ធសភា ត្រិនឡូត់ បានថ្លែងសុន្ទរកថាដ៏មានន័យនេះទៅកាន់អង្គប្រជុំគណៈកម្មាធិការជាតិនៃក្រុមប្រឹក្សា ។ «មនុស្សម្នាទាំងអស់នៅក្នុងបន្ទប់នេះ ចូរក្រោកឈរឡើងដើម្បីទទួលនូវគោលការណ៍និងទស្សនវិជ្ជាដ៏ត្រឹមត្រូវនេះ» ។ ៦ឆ្នាំក្រោយមក ឡូត់ ប្រកាសថា ខ្លួនគាត់ «មិនបានដឹង» ចំពោះគំនិតក្រុមប្រឹក្សានេះឡើយ ។ នៅពេលសំបុត្រទៅដល់ អលប្រាយ អ្នកនៅពីក្រោយ ម៉ូរី មកពី «មូលនិធិមរតក» បានទាក់ទង អាលហ្វូន ឡាប៉ីតា ដែលជាប្រធានការិយាល័យក្រសួងការបរទេសនៃការស៊ើបអង្កេតទៅលើអំពើប្រល័យពូជសាសន៍នៅកម្ពុជា ហើយនិយាយថា «ប្រសិនបើលោកមិនបានកម្ចាត់ យៀរនិន យើងនឹងព្យាយាមដើរតាមរករឿងលោកទាល់តែបាន» ។ ឡាប៉ីតា ទាញសេចក្តីសន្និដ្ឋានថា ប្រសិនបើខ្ញុំមិនចុះចេញពីតំណែងទេ ព្រឹទ្ធសភានឹងដកហូតវិញនូវជំនួយឧបត្ថម្ភចំពោះស៊ី.ជី.ភី ដោយបញ្ចប់នូវការស៊ើបអង្កេតរបស់យើងទៅលើរបបខ្មែរក្រហម ។ ខ្ញុំបានឈរលើមូលដ្ឋានរបស់ខ្ញុំដោយមានការគាំទ្រពីសកលវិទ្យាល័យយែល ។ នៅថ្ងៃទី២ ខែតុលា កិច្ចឧបត្ថម្ភគាំទ្រថ្មីទៀតបានមកដល់ ។ បទវិចារណកថា មួយនៅក្នុងកាសែតអភិរក្ស «វ៉ាស៊ីនតោនថែម៍» បានសរសើរសមិទ្ធិផលរបស់ស៊ី.ជី.ភី ហើយបានហៅយុទ្ធនាការរបស់ ម៉ូរី និង ដូល ដែលប្រឆាំងនឹងខ្ញុំថា «ជាអំពើឆ្កួតៗ» ។ បញ្ហានេះបានស្ងប់ស្ងាត់ទៅវិញដោយមានការគាំទ្រពីសំណាក់សភាអាមេរិកចំពោះ ស៊ី.ជី.ភី ត្រូវបានលើកកម្ពស់មួយកម្រិតទៀត ។ នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៩៦ ណាន់ស៊ី ដឺវ៉ុលស្មិត មកពីទិនានុប្បវត្តិ វិលស្រ្ទីត បានទូរស័ព្ទពីហុងកុងមកខ្ញុំ ។ ណាន់ស៊ីបាននិយាយថាមានរឿងមួយ «កំពុងតែក្លាយជាបញ្ហា» ។ បញ្ហានោះគឺកាលពីខែមុន ក្រសួងការពារជាតិសហរដ្ឋអាមេរិកមិនអាចមានសិទ្ធិប្រើប្រាស់បណ្ណសារនគរបាលសម្ងាត់របស់ខ្មែរក្រហមដែលបុគ្គលិកស៊ី.ជី.ភីនៅភ្នំពេញ គឺមជ្ឈមណ្ឌលឯកសារកម្ពុជា បានរកឃើញកាលពីខែមីនា ឆ្នាំ១៩៩៦ ។ ស្មិត បានចាប់អារម្មណ៍ដែលយើងមិនអាចបញ្ជាក់បានថាឯកសារក្នុងចន្លោះឆ្នាំ១៩៧៥-៧៩ មានពត៌មានទាក់ទងនឹងវាសនានៃជនជាតិអាមេរិកាំងដែលបាត់ខ្លួននៅក្នុងប្រទេសកម្ពុជានៅក្នុងសម័យកលយុគចាប់តាំងពីឆ្នាំ១៩៧០-៧៥ទេ ។ ខ្ញុំបានពន្យល់ថាក្រសួងការពារជាតិសហរដ្ឋអាមេរិកមិនបានពិភាក្សាជាមួយខ្ញុំទេ មុនពេលបញ្ជូនអ្នកសិក្សាស្រាវជ្រាវដែលបានចុះកិច្ចសន្យាដោយផ្ទាល់មកប្រទេសកម្ពុជាកាលពីខែមុន ។ អ្នកសិក្សាស្រាវជ្រាវទាំងអស់បានមកដល់មជ្ឈមណ្ឌលឯកសារកម្ពុជាដោយនិយាយថា «អ្វីៗគ្រប់យ៉ាងត្រូវបានដោះស្រាយរួចហើយ» ។ អ្នកទាំងនោះចង់ចាប់ផ្តើមការងាររបស់ខ្លួនពេលនោះភ្លាម មុនពេលឯកសារត្រូវបានរៀបចំចុះបញ្ជីត្រឹមត្រូវ ។ **(នៅមានត)**

**បែន យៀរនិន**



ថូម៉ាស់ ហាម៉ាប៊ឺក

# ◆ ការពិភាក្សារវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិៈ តើកិច្ចព្រមព្រៀងទៅលើការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមកើតឡើងដោយរបៀបណា?





**(តពីលេខមុន)** ប៉ុន្តែគួរឲ្យសោកស្តាយ របាយការណ៍នេះបានលេចឮដល់ប្រព័ន្ធផ្សព្វផ្សាយមុននេះទៅទៀត ។ ទន្ទឹមគ្នានេះដែរ ក៏មានបញ្ហាមួយចំនួនទាក់ទងនឹងការបញ្ជូនរបាយការណ៍ពីក្រុមបេសកកម្មកម្ពុជានៅទីក្រុងញូវយ៉កមកភ្នំពេញ និងការបកប្រែជាភាសាខ្មែរ ដែលបញ្ហាទាំងអស់នេះនឹងពន្យល់អំពីការមិនពេញចិត្តដែលឥឡូវនេះហាក់លេចឡើងនៅការិយាល័យនាយករដ្ឋមន្ត្រី និងការិយាល័យក្រសួងការបរទេស ។

នៅថ្ងៃទី៣ ខែមីនា មានការឆ្លើយតបមួយត្រូវបានផ្ញើទៅលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ការឆ្លើយតបនេះក៏ត្រូវបានចេញផ្សាយភ្លាម ទោះជារបាយការណ៍របស់ក្រុមអ្នកជំនាញមិនទាន់ត្រូវបានប្រកាសជាសាធារណៈនៅក្នុងដំណាក់កាលនេះក៏ដោយ ។ ការឆ្លើយតបមួយផ្នែកមានសេចក្តីដូចតទៅ÷

«យើងមិនដែលប្រានចោលនូវការដាក់ឲ្យទទួលខុសត្រូវជាបុគ្គលរបស់មេដឹកនាំខ្មែរក្រហមចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជាម្តងណាឡើយ ។ ប៉ុន្តែយើងគ្រាន់តែចង់ណែនាំថា រាល់ការសម្រេចចិត្តក្នុងការនាំយកមេដឹកនាំខ្មែរក្រហមមកកាន់តុលាការដើម្បីជម្រះទោស ត្រូវតែគិតបញ្ចូលអំពីសេចក្តីត្រូវការរបស់កម្ពុជាចង់បានសន្តិភាព ការបង្រួបបង្រួមជាតិ ការស្តារនីតិសម្បទា និងការអភិវឌ្ឍសេដ្ឋកិច្ចដើម្បីការកាត់បន្ថយភាពក្រីក្រ ។ ហេតុដូចបានជម្រាបមកនេះ ប្រសិនបើធ្វើទៅមានការខុសឆ្គង និងគ្មានការប្រុងប្រយ័ត្ន ការកាត់សេចក្តីមេដឹកនាំខ្មែរក្រហមអាចធ្វើឲ្យអតីតមន្ត្រីខ្មែរក្រហមផ្សេងទៀត និងកូនទាហានតូចតាចដែលបានលើកដៃចុះចូលហើយនោះ រត់ចូលព្រៃបន្តសង្គ្រាមឈ្លបនៅក្នុងប្រទេសកម្ពុជាតទៅទៀត» ។

សំបុត្រនេះក៏និយាយដែរថា រដ្ឋាភិបាលកម្ពុជាបច្ចុប្បន្នកំពុងតែសិក្សាអំពីបេសកកម្មស្វែងរកការពិតនិងការបង្រួបបង្រួមជាតិនៅប្រទេសអាហ្វ្រិកខាងត្បូង ដើម្បីយកមកធ្វើគំរូសម្រាប់ប្រទេសកម្ពុជាបើអាចទៅរួច ។

ចំណុចទាំងអស់នេះត្រូវបានលើកឡើងជាថ្មីម្តងទៀតនៅក្នុងកិច្ចជំនួបរវាងរដ្ឋមន្ត្រីការបរទេសនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ ហោ ណាំហុង ជាមួយនឹងខ្ញុំនៅទីក្រុងភ្នំពេញនៅថ្ងៃទី៤ ខែមីនា ។

នៅថ្ងៃទី៦ ខែមីនា មានការវិវត្តធំមួយទៀត ។ មេដឹកនាំម្នាក់ក្នុងចំណោមមេដឹកនាំខ្មែរក្រហមដែលនៅសេសសល់ឈ្មោះ តាម៉ុក (ឬ ឈិត ជឿន) ដែលជាអតីតលេខាភូមិភាគនិរតី និងជាអនុលេខានៃបក្សកុម្មុយនិស្តកម្ពុជា ត្រូវបានចាប់ខ្លួននៅព្រំដែនថៃនៅភាគខាងជើងនៃប្រទេសកម្ពុជា និងនាំមកឃុំខ្លួននៅទីក្រុងភ្នំពេញ ។ តាមរយៈព្រឹត្តការណ៍នេះ ការប្រែប្រួលអំពីលទ្ធភាពនៃការជំនុំជម្រះមានសភាពកាន់តែច្បាស់ឡើងៗ ។ ការចាប់ខ្លួន តាម៉ុក បានកម្រិតលើពេលវេលានៃការពិភាក្សា ព្រោះថា យោងតាមច្បាប់កម្ពុជា គ្មានជនណាអាចត្រូវបានឃុំខ្លួនមុនពេលជម្រះក្តីលើសពី៦ខែឡើយ ។

មួយសប្តាហ៍ក្រោយមកទៀត លោករដ្ឋមន្ត្រីការបរទេស ហោ ណាំហុង ត្រូវបានបញ្ជូនទៅទីក្រុងញូវយ៉កដើម្បីជួបប្រជុំ និងជូនកំណត់ប្រវត្តិជំនួយស្មារតីចំពោះលោកអគ្គលេខាអង្គការសហប្រជាជាតិ ។ ឯកសារនេះដែលចុះថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៩៩ ចាប់ផ្តើមដោយនិយាយថា កម្ពុជាប្រជាធិបតេយ្យត្រូវបានអនុញ្ញាតឲ្យកាន់កាប់អាសនៈរបស់កម្ពុជានៅក្នុងអង្គការ

សហប្រជាជាតិ រហូតដល់មានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសនៅឆ្នាំ១៩៩១ ។ ឯកសារនេះនិយាយថា ខ្មែរក្រហមត្រូវបានធ្វើឲ្យមានលក្ខណៈស្របច្បាប់តាមរយៈកិច្ចព្រមព្រៀង ហើយក៏បានចូលមកអង្គុយនៅក្នុងក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជានៅអំឡុងសម័យអន្តរកាល ។ ជាការច្បាស់ណាស់ថា សារនេះគឺនិយាយអំពីការលាក់ពុតរបស់អង្គការសហប្រជាជាតិ ។

អនុស្សារណៈជំនួយស្មារតីនេះ និយាយយោងថែមទៀតទៅដល់សំបុត្រចុះខែមិថុនា ឆ្នាំ១៩៩៧ របស់សហនាយករដ្ឋមន្ត្រី ហើយនិយាយថា អង្គការសហប្រជាជាតិមិនមានការឆ្លើយតបឲ្យបានច្បាស់ទេរហូតមកដល់ពាក់កណ្តាលឆមាសទីពីរនៃខែវិច្ឆិកា ឆ្នាំ១៩៩៨ ។ “ដល់ពេលមានដំណើរការផ្តាច់ខ្លួននិងការចុះចូលជាបន្តបន្ទាប់នៃមេដឹកនាំនិងកូនទាហានតូចតាចខ្មែរក្រហមបានមកដល់ទីបញ្ចប់ហើយ ទើបមានក្រុមអ្នកជំនាញការបីរូបបានមកធ្វើបេសកកម្មនៅកម្ពុជា” ។

ការចុះចូលរបស់ ខៀវ សំផន និង នួន ជា ត្រូវបានពិពណ៌នាថាជាទីបញ្ចប់នៃ“ការរលំរលាយផ្នែកអង្គការចាត់តាំងយោធានិងនយោបាយរបស់ចលនាខ្មែរក្រហម” ។ រដ្ឋាភិបាលនឹងផ្តោតសំខាន់ទៅលើអាទិភាពផ្សេងៗទៀត ជាពិសេសលើការអភិវឌ្ឍសេដ្ឋកិច្ចនិងការកាត់បន្ថយភាពក្រីក្រ ។

“...តាម៉ុក ដែលជាមេដឹកនាំក្បាលរឹងរបស់ខ្មែរក្រហម នៅតែជាឃាតករដ៏សាហាវបំផុត ហើយបានប្រព្រឹត្តអំពើឃោរឃៅធ្ងន់ធ្ងរបំផុតរាប់មិនអស់ រហូតមកដល់ថ្ងៃចាប់ខ្លួនដោយកងកម្លាំងប្រដាប់អាវុធនៃកងយោធពលពលខេមរភូមិន្ទ...។ ដំណើរការជម្រះក្តី [ប្រឆាំងនឹងតាម៉ុក] នឹងធានាឲ្យមានគំរូតុលាការយុត្តិធម៌និងប្រសិទ្ធភាពពិតប្រាកដ” ។

ហាក់ដូចជាថា តុលាការត្រូវបានយកជាមធ្យោបាយក្នុងការយកឈ្នះលើខ្មែរក្រហមយ៉ាងដូច្នេះដែរ ។ នៅពេលដែលគោលដៅនេះត្រូវបានសម្រេចតាមរយៈមធ្យោបាយផ្សេងហើយនោះ មិនចាំបាច់មានការកាត់ទោសអ្នកណាក្រៅពីជនដែលមិនបានចុះចូលឡើយ ពោលគឺ តាម៉ុក ។ នៅពេលនិយាយដល់ដំណើរការកាត់ក្តី តាម៉ុក គ្មានការលើកមកនិយាយអំពីគំរូបទដ្ឋានអន្តរជាតិឡើយ ។

មានទស្សនីករណ៍ចំនួនពីរដែលត្រូវបានលើកមកពិភាក្សា ។ ទីមួយគឺថា អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍មិនតម្រូវថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ចាំបាច់ត្រូវតែកាត់ក្តីនៅក្នុងតុលាការអន្តរជាតិទេ ។ មាត្រាទី៦នៃអនុសញ្ញានេះនិយាយអំពីលទ្ធភាពនៃដំណើរការកាត់ក្តីនៅក្នុងស្រុក ។ ចំណុចមួយទៀតហាក់ដូចជាមានភាពជាក់លាក់ថា មាត្រាទី៣៣នៃរដ្ឋធម្មនុញ្ញបានហាមប្រាមមិនឲ្យមានការចាប់បញ្ជូនខ្លួនប្រជាពលរដ្ឋខ្មែរទៅឲ្យប្រទេសក្រៅណាមួយឡើយ ។ ក៏ប៉ុន្តែបើពិនិត្យពិច័យទៅ គ្មានទស្សនីករណ៍ណាមួយនិយាយចំសាច់រឿងឬគួរឲ្យជឿបានសោះ ។

លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ បានទទួលយោបល់ពីសំណាក់ក្រុមអ្នកជំនាញការ និងយោបល់អវិជ្ជមានរបស់រដ្ឋាភិបាលកម្ពុជា ។ នៅថ្ងៃទី១៥ ខែមីនា លោកអគ្គលេខាធិការបានដាក់ជូននូវរបាយការណ៍របស់ក្រុមអ្នកជំនាញការនេះជូនមហាសន្និបាតអង្គការសហប្រជាជាតិនិងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ។ ក្នុងការដាក់ជូននេះ លោកអគ្គលេខាបានសម្តែងគំនិតផ្ទាល់ខ្លួនថា មេដឹកនាំខ្មែរក្រហមដែលមានការទទួលខុសត្រូវចំពោះអំពើឃោរឃៅបំផុត គួរតែត្រូវនាំមកវិនិច្ឆ័យទោសនៅមុខតុលាការដែលមានគំរូបទដ្ឋានអន្តរជាតិ ដែលមានយុត្តិធម៌ ភាពគ្មានលម្អៀង និងនីតិវិធីត្រឹមត្រូវតាមច្បាប់ ។ លោកអគ្គលេខាបញ្ជាក់ថា ការរួចទោសមិនអាចទទួលយកបានទេចំពោះអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មផ្សេងៗទៀតដែលប្រឆាំងនឹងមនុស្សជាតិ ។

លោកអគ្គលេខាធិការសង្កត់ធ្ងន់ថា ប្រសិនបើគំរូបទដ្ឋានរបៀបនេះត្រូវនឹងអនុវត្តតាមនោះ តុលាការនេះនឹងមានលក្ខណៈអន្តរជាតិដូចដែលបានរំពឹងទុកជាមិនខាន ។ នេះមិនមានន័យជាចាំបាច់ថា តុលានេះនឹងត្រូវយកគំរូតាមឬភ្ជាប់ទៅនឹងតុលាការពិសេសនានាដែលមានស្រាប់នោះឡើយ ។ មានជម្រើសផ្សេងៗទៀតដែលត្រូវរិះរកដោយគិតរួមបញ្ចូលការវិភាគនិងសេចក្តីសន្និដ្ឋានផ្សេងៗរបស់ក្រុមអ្នកជំនាញការផង ។ លោកអគ្គលេខាក៏បានគូសបញ្ជាក់ទៀតថា ដោតជ័យចេញពីតុលាការណាមួយក៏ដោយ ត្រូវ

មានកិច្ចសហការយ៉ាងពេញលេញពីសំណាក់រដ្ឋាភិបាលកម្ពុជា ។

**ជំនួបជាមួយសម្តេច ហ៊ុន សែន និងមន្ត្រីផ្សេងៗទៀត នៅក្នុងខែមីនា ឆ្នាំ១៩៩៩**

ខ្ញុំបានជួបសម្តេច ហ៊ុន សែន ម្តងទៀតនៅថ្ងៃទី២៥ ខែមីនា ។ មន្ត្រីដែលមានវត្តមាននៅក្នុងឱកាសនោះដែរ រួមមាន រដ្ឋមន្ត្រីការបរទេស ហោ ណាំហុង រដ្ឋមន្ត្រីយុត្តិធម៌ អ៊ុក វិធន់ ទេសរដ្ឋមន្ត្រី សុខ អាន និងប្រធានតុលាការកំពូល ឌិត មន្ទីរ ។ ជាទូទៅខ្ញុំជួបសម្តេច ហ៊ុន សែន ដោយគ្មានវត្តមានរបស់រដ្ឋមន្ត្រីផ្សេងៗទៀតឡើយ ។ ការចូលរួមរបស់រដ្ឋមន្ត្រីទាំងនេះហាក់ដូចជាសង្កត់ធ្ងន់ទៅលើសារសំខាន់និងទឹកចុងក្រោយនៃការពិភាក្សាអំពីបញ្ហាតុលាការ ។ នៅមុនពេលមានកិច្ចប្រជុំ មានសំបុត្រមួយច្បាប់ផ្ញើជូនលោកអគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវបានចេញផ្សាយ ដែលជាថ្មីម្តងទៀតនិយាយយោងដល់មាត្រាទី៣៣នៃរដ្ឋធម្មនុញ្ញ និងមាត្រាទី៦ ស្តីអំពីអនុសញ្ញាអំពើប្រល័យពូជសាសន៍ ។

សំបុត្រនិយាយថា ការជំនុំជម្រះក្តី តាម៉ុក អាចនឹងត្រូវបានរៀបចំឡើងនៅក្នុងតុលាការជាតិ និងស្វាគមន៍ចំពោះអ្នកជំនាញការច្បាប់មកពីបរទេស ប្រសិនបើមានការអញ្ជើញពីសំណាក់តុលាការក្នុងស្រុក ។ អំពីបញ្ហាថាតើមនុស្សផ្សេងទៀតនឹងត្រូវយកមកកាត់ទោសដែរឬយ៉ាងណា គឺស្ថិតនៅលើតុលាការខ្លួនឯងផ្ទាល់ ។ (សម្តេច ហ៊ុន សែន មានប្រសាសន៍ប្រាប់ខ្ញុំតែពីរនាក់ក្រោយកិច្ចប្រជុំថា នួន ជា និង ខៀវ សំផន នឹងត្រូវ "ហៅមក" កាន់តុលាការនេះ ។ ប៉ុន្តែនៅតែមិនច្បាស់ថាតើអ្នកទាំងពីរមកក្នុងនាមជាសាក្សីឬក៏ចុងចោទ) ។

នៅពេលចាប់ផ្តើមដំបូង សម្តេច ហ៊ុន សែន មានប្រសាសន៍ថានឹងមិនមានតុលាការអន្តរជាតិទេ ទោះជាស្ថិតនៅក្រៅឬក្នុងប្រទេសកម្ពុជាក៏ដោយ ហើយថាច្បាប់កម្ពុជាមិនអនុញ្ញាតឲ្យមានការចូលរួមពីសំណាក់ចៅក្រមឬព្រះរាជអាជ្ញាបរទេសឡើយ ។ ទីប្រឹក្សាបរទេសមួយចំនួនអាចត្រូវបានទទួលយក តែរឿងនេះវាអាស្រ័យទៅលើព្រះរាជអាជ្ញាជាអ្នកសម្រេច ។ រដ្ឋាភិបាលនានាដែលមានចំណាប់អារម្មណ៍ក្នុងការគាំទ្រតុលាការនេះ អាចទាក់ទងជាមួយនឹងក្រសួងការបរទេសឬក្រសួងយុត្តិធម៌ ។

ជំហរនេះជាការផ្ទុយទៅនឹងសំណើសុំជំនួយអន្តរជាតិចុះថ្ងៃខែមិថុនា ឆ្នាំ១៩៩៧ ។ សំបុត្រផ្ញើមកពីសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ និងសម្តេច ហ៊ុន សែន បានសង្កត់ធ្ងន់ថា កម្ពុជាមិនមានធនធាន ឬជំនាញក្នុងការអនុវត្តដំណើរការជំនុំជម្រះក្តីដ៏សំខាន់នេះទេ ។ បញ្ហាសំខាន់នេះ ក្រោយមកត្រូវបានវិភាគដោយក្រុមអ្នកជំនាញការដែលបានទាញសេចក្តីសន្និដ្ឋានថា តុលាការកម្ពុជាមិនបានបំពេញលក្ខខណ្ឌសំខាន់ៗបី ÷ ទីមួយ អង្គចៅក្រម មេធាវី និងអ្នកស៊ើបអង្កេត ដែលមានការហ្វឹកហាត់ត្រឹមត្រូវ ។ ទីពីរ រចនាសម្ព័ន្ធគ្រប់គ្រាន់តាមបទដ្ឋានទូទៅ ។ ទីបី វប្បធម៌គោរពនីតិវិធីត្រឹមត្រូវតាមច្បាប់ ។ (ភាពទន់ខ្សោយទាំងនេះ មួយផ្នែកបណ្តាលមកពីការកាប់សម្លាប់នៅក្នុងរបបខ្មែរក្រហម ដែលធ្វើឲ្យប្រព័ន្ធតុលាការកម្ពុជាមានភាពទ្រុឌទ្រោមយ៉ាងខ្លាំង) ។

តាមគំនិតខ្ញុំគឺថា បញ្ហាដែលទាក់ទងទៅនឹងប្រព័ន្ធតុលាការគឺមានភាពជាក់ស្តែងពិតប្រាកដពេក ដែលមិនអាចកែតម្រូវបានភ្លាមៗសម្រាប់ការកាត់សេចក្តីក្នុងទំហំទ្រង់ទ្រាយបែបនេះតាមរយៈការឲ្យយោបល់តែមួយមុខ ។ ថ្វីដ្បិតតែភាពចាំបាច់ឲ្យមានការកែទម្រង់យ៉ាងធំទៅលើប្រព័ន្ធតុលាការជាផ្នែករឿងដ៏សំខាន់នៅក្នុងរបាយការណ៍ស្តីអំពីសិទ្ធិមនុស្សយ៉ាងណាក៏ដោយ ក៏ត្រូវតែជ្រាបថាដំណើរការផ្លាស់ប្តូរនេះនឹងស៊ីពេលវេលាមិនតិចឡើយ ។ កម្មវិធីរបស់រដ្ឋាភិបាលសម្រាប់ឆ្នាំ១៩៩៨-២០០៣ បានផ្តោតសំខាន់ទៅលើតម្រូវការកែទម្រង់ប្រព័ន្ធតុលាការដោយលើកឡើងថា "ប្រព័ន្ធយុត្តាធិការនិងតុលាការគឺមានលក្ខណៈចាំបាច់ត្រូវរុះរើឡើងវិញទាំងអស់ ។ តាមបរិបទច្បាប់ ប្រពន្ធ័យុត្តាធិការនិងតុលាការគួរតែមានឯករាជ្យ ភាពស្មោះត្រង់ និងមានភាពគួរឲ្យទុកចិត្ត" ។

ជាការច្បាស់ណាស់ថា មានតែតុលាការដែលមានចរិតអន្តរជាតិទេដែលអាចធានាឲ្យមានគំរូបទដ្ឋានអន្តរជាតិលើបញ្ហាយុត្តិធម៌ ភាពគ្មានលម្អៀង និងនីតិវិធីត្រឹមត្រូវតាមច្បាប់ ។ ក៏ប៉ុន្តែជាការសំខាន់ណាស់ថា លោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានស្រាយបំភ្លឺថា តុលាការបែបនេះមិនចាំបាច់ត្រូវយកគំរូតាម ឬភ្ជាប់ទៅនឹងតុលាការពិសេសដែលមានស្រាប់សម្រាប់អតីតប្រទេស

យូហ្គោស្លាវីនិងរ៉្វាន់ដា លើផ្នែកស្ថាប័ន ផ្នែករដ្ឋបាល ឬផ្នែកហិរញ្ញវត្ថុឡើយ ។ មានការបើកចំហឲ្យមានជម្រើសផ្សេងៗទៀត ។

ទោះជាយ៉ាងនេះក៏ដោយ នៅឯកិច្ចប្រជុំធ្វើឡើងនៅថ្ងៃទី២៥ ខែមីនា មិនមានការចាប់អារម្មណ៍មកលើបញ្ហានេះឡើយ ។ របៀបនិយាយមានលក្ខណៈអវិជ្ជមាន ហើយមានចរិតជាសង្គ្រាមស្នាបប៉ាក្កាទៀតផង ដូចដែលលោករដ្ឋមន្ត្រីការបរទេស ហោ ណាំហុង បានមានប្រសាសន៍៖ «សហគមន៍អន្តរជាតិនិយាយអំពីការស្វែងរកយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជា ។ កម្ពុជាយល់ព្រមស្វែងរកយុត្តិធម៌សម្រាប់ជនជាតិកម្ពុជា និងសម្រាប់មនុស្សជាតិទាំងមូល ។ ប៉ុន្តែតើអ្វីដែលសហគមន៍អន្តរជាតិបាននិងកំពុងតែធ្វើទាក់ទងនឹងរឿងខ្មែរក្រហមចុងក្រោយនេះ? នៅពេលដែលរបបប្រល័យពូជសាសន៍ខ្មែរក្រហមត្រូវបានផ្តួលរំលំ សហគមន៍ស្ទើរតែនោះនៅតែបន្តខបត្ថម្ភគាំទ្រដល់ខ្មែរក្រហមតទៅទៀត ។ សហគមន៍អន្តរជាតិបានបង្ខំឲ្យកម្ពុជាទទួលយកខ្មែរក្រហមជាដៃគូនៅក្នុងកិច្ចចរចាស្វែងរកសន្តិភាពទីក្រុងប៉ារីសនិងក្រុមប្រឹក្សាជាន់ខ្ពស់កម្ពុជា ។ សហគមន៍អន្តរជាតិមិនបាននិយាយអំពីការទទួលខុសត្រូវរបស់ខ្មែរក្រហមឡើយ កុំថាឡើយការកាត់ទោសនោះ ។ ប៉ុន្តែដល់ឥឡូវ នៅពេលដែលកម្ពុជាសម្រេចបានសន្តិភាពនិងការបង្រួបបង្រួមជាតិ គេបែរជាអំពាវនាវឲ្យមានតុលាការអន្តរជាតិទៅវិញ ។ តើយើងអាចទុកចិត្តទៅលើសហគមន៍អន្តរជាតិឬទេ? នេះជារឿងផ្នែកសីលធម៌ ។ ឥឡូវចូលមករឿងច្បាប់វិញម្តង ។ យើងជាជនជាតិកម្ពុជាបានទទួលរងនូវការឈឺចាប់ជាទីបំផុត និងចង់បានយុត្តិធម៌ជាទីបំផុត ។ មាត្រីទី៦ស្តីអំពីអនុសញ្ញាអំពើប្រល័យពូជសាសន៍ មិនហាមប្រាមការកាត់សេចក្តីដោយតុលាការជាតិឡើយ ។ មាត្រាទី៣៣នៃរដ្ឋធម្មនុញ្ញកម្ពុជាមិនអនុញ្ញាតឲ្យមានការចាប់បញ្ជូនខ្លួនប្រជាពលរដ្ឋខ្មែរទៅឲ្យប្រទេសក្រៅណាមួយឡើយ ។ ការកាត់សេចក្តីក្នុងស្រុកដែលត្រូវបានស្នើឡើងគឺស្របតាមច្បាប់ ។ គំរូបទដ្ឋានអន្តរជាតិមិនមានលក្ខណៈច្បាស់លាស់ឡើយ ។ យើងបានរៀបចំខ្លួនជាស្រេចហើយក្នុងការទទួលយកនូវជំនួយពីអន្តរជាតិដើម្បីឆ្លើយតបទៅនឹងផ្នែកផ្លូវសីលធម៌ និងផ្នែកច្បាប់និងបំណងចង់បានសន្តិភាព ។ នៅពីក្រោយសហគមន៍អន្តរជាតិ មានប្រទេសមួយឬពីរដែលជំរុញឲ្យមានតុលាការអន្តរជាតិ ។ មានប្រទេសខ្លះបានគាំទ្រដល់ខ្មែរក្រហមរហូតដល់ឆ្នាំ១៩៩១ ។ តើគេស្រឡាញ់ប្រជាជនកម្ពុជាជាងប្រជាជនកម្ពុជាស្រលាញ់ខ្លួនឯងផ្ទាល់ទៅទៀតឬ?» ។

ខ្ញុំមានអារម្មណ៍ថា ការពិតដែលថាទឡ្ហីករណ៍ទាំងនេះត្រូវបានយល់ថាសំខាន់នោះ គឺអាចបង្ហាញពីការលំបាកផ្ទៃក្នុងជាមួយនឹងរដ្ឋាភិបាលក្នុងការថែរក្សាគំរូបទដ្ឋានឲ្យបានខ្ពស់ ។ គ្មានតំណាងអន្តរជាតិណាម្នាក់បាននិយាយថា អនុសញ្ញាស្តីអំពីអំពើប្រល័យពូជសាសន៍មិនបញ្ចូលលទ្ធភាពក្នុងការជំនុំជម្រះក្តីជាលក្ខណៈជាតិឡើយ ។ នេះមិនមែនជាបញ្ហាទេ ។ មាត្រាទី៣៣ នៃរដ្ឋធម្មនុញ្ញកម្ពុជាមិនបានគាំទ្រដល់ការបកស្រាយរបស់រដ្ឋមន្ត្រី ហោ ណាំហុង ទេ ។ មាត្រានេះគ្រាន់តែលើកឡើងថាចាំបាច់ត្រូវមានការយល់ព្រមទៅវិញទៅមករវាងរដ្ឋាភិបាលដែលពាក់ព័ន្ធ មុនពេលពលរដ្ឋម្នាក់ត្រូវបានបញ្ជូនទៅប្រទេសក្រៅណាមួយ ។ កិច្ចព្រមព្រៀងគ្នានេះប្រហែលជាមិនអាចជាបញ្ហាឡើយ ប្រសិនបើតុលាការអន្តរជាតិត្រូវបានរៀបចំ ហើយអាជ្ញាធរមានសមត្ថកិច្ចកម្ពុជាមានការចូលរួមជាវិជ្ជមាននោះ ។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មិនបានត្រឡប់មកចំណុចទាំងនេះវិញទេ នៅពេលដែលខ្ញុំធ្វើការស្រាយបញ្ជាក់ដូចដែលបានជម្រាបនេះ ។

សម្តេច បានលើកយកមកបង្ហាញនូវទឡ្ហីករណ៍ពីរដើម្បីពន្យល់ជំហរផ្លាស់ប្តូរផ្សេងពីសំបុត្រចុះថ្ងៃទី២១ ខែមិថុនាកន្លងទៅ ។ ទី១គឺថា មេដឹកនាំខ្មែរក្រហមនៅតែមានសកម្មភាពនៅឡើយ នៅក្នុងខែមិថុនា ឆ្នាំ១៩៩៧ ហើយគំរាមកំហែងដល់សន្តិភាពនិងស្ថិរភាព ។ នៅពេលខ្មែរក្រហមលើកដៃចុះចូល ឬត្រូវបានចាប់ខ្លួនដូចក្នុងករណី តាម៉ុក សភាពការណ៍បានផ្លាស់ប្តូរ ។ នៅពេលនេះមិនចាំបាច់ជំនួយពីខាងក្រៅទៀតឡើយ ។ ទី២គឺថា រដ្ឋាភិបាលចិនបានដាក់ការគាបសង្កត់មិនឲ្យមានតុលាការអន្តរជាតិ ហើយពេលដែលរដ្ឋាភិបាលថៃបានបដិសេធមិនចាប់ខ្លួន តាម៉ុក នៅក្នុងទឹកដីថៃ សម្តេច ហ៊ុន សែន លែងអាចអះអាងទៀតហើយថានេះជាបញ្ហាអន្តរជាតិ ។ **(នៅមានត)**

# យុត្តិធម៌គឺពុំមែនជាការសងសឹកទេ

នៅពេលដែលសង្គ្រាមស៊ីវិលកម្ពុជាមានសន្ទុះខ្លាំងបំផុតនៅដើមទសវត្សរ៍ឆ្នាំ១៩៧០ ខ្ញុំមិនដឹងទាល់តែសោះថាតើហេតុអ្វីបានជាប្រជាជនកម្ពុជាវាយប្រយុទ្ធគ្នាឯងយ៉ាងដូច្នេះ ។ កាលនោះខ្ញុំទើបមានអាយុ៦ឆ្នាំតែប៉ុណ្ណោះ ។ នៅពេលសង្គ្រាមស៊ីវិលបានផុតរលត់នៅឆ្នាំ១៩៧៥ ខ្ញុំអាចយល់រឿងរ៉ាវបានខ្លះៗ ។ ខ្ញុំបានឃើញទាហានខ្មែរក្រហមឈរនៅមុខផ្ទះខ្ញុំ ហើយស្រែកប្រកាសតាមមីក្រូឲ្យគ្រួសារខ្ញុំចាកចេញពីផ្ទះ បើមិនអ៊ីចឹងទេអាមេរិកាំងនឹងទម្លាក់គ្រាប់បែកលើឥឡូវហើយ ។ ខ្ញុំក៏នៅចាំបានទៀតថាឪពុកខ្ញុំពេលនោះត្រូវអំបែងគ្រាប់នៅត្រង់កែងដៃ ។ ដោយគ្មានមន្ទីរពេទ្យនៅក្បែរផ្ទះ បងប្អូននៅក្នុងគ្រួសារខ្ញុំក៏ជួយសង្គ្រោះឪពុកខ្ញុំទៅតាមលទ្ធភាពដើម្បីឲ្យគាត់បានធូរស្រាលមួយគ្រាសិន ។

ដូចជាប្រជាជនទីក្រុងភ្នំពេញជាច្រើនទៀតដែរ គ្រួសារខ្ញុំក៏ត្រូវបានបង្ខំឲ្យរៀបចំសម្ភារចាកចេញពីទីក្រុង ។ នៅតាមដងផ្លូវចេញពីទីក្រុង ខ្ញុំបានឃើញសាកសពរាប់រយអណ្តែតតាមខ្សែទឹកទន្លេ ហើយដែលភាគច្រើនជាសាកសពទាហានស្ថិតក្នុងសម្លៀកបំពាក់ឯកសណ្ឋាន ។ ឪពុករបស់ខ្ញុំនៅពេលកំពុងតែមានរបួសនោះ បានប្រាប់ឲ្យគ្រួសារខ្ញុំដោយនាំគ្នាទៅកាន់ស្រុកកំណើតរបស់គាត់នៅខេត្តតាកែវ ។

ដោយសារតែពួកកុម្មុយនិស្តឈ្នះសង្គ្រាម អ្នកខ្លះដឹងក្នុងចិត្តថាខ្មែរក្រហមនឹងមិនអត់ឱនឲ្យអ្នកណាដែលវាយប្រយុទ្ធជាមួយខ្លួនឡើយ ។ ការលាក់កំបាំងអត្តសញ្ញាណរបស់ខ្លួនគឺជាមធ្យោបាយដ៏ល្អបំផុតសម្រាប់រួចពីសេចក្តីស្លាប់ ។ នៅពេលក្រុមគ្រួសារខ្ញុំបានមកដល់ស្រុកកំណើតរបស់ឪពុកខ្ញុំ យើងក៏គិតថាយើងកំពុងតែស្ថិតក្នុងមុខសញ្ញារបស់ខ្មែរក្រហមហើយ ព្រោះឪពុកខ្ញុំគាត់ធ្លាប់ធ្វើជាប៉ូលិសឲ្យរបបសាធារណរដ្ឋខ្មែរ ។ ទោះបីជាឪពុកខ្ញុំគ្រាន់តែជាប៉ូលិសតូចតាច ហើយក្រីក្រយ៉ាងណាក៏ដោយក៏គាត់ត្រូវស្ថិតនៅក្នុងបញ្ជីខ្មែរក្រហមដែរ ។ ពេលនោះឪពុកខ្ញុំខំលាក់អត្តសញ្ញាណរបស់គាត់មិនឲ្យអ្នកណាម្នាក់ដឹងទេ ។

នៅពេលប្រជាជនហូរចូលមកភូមិកាន់តែច្រើនឡើងៗ អង្គការថ្នាក់លើក៏សួរថាមានអ្នកណាស្ម័គ្រចិត្តប្តូរទីលំនៅ ។ ក្រោយពីសេចក្តីប្រកាសនេះភ្លាម ឪពុកខ្ញុំក៏លើកដៃចុះឈ្មោះ ។ គាត់សង្ឃឹមក្នុងចិត្តថា ការចាកចេញឲ្យឆ្ងាយពីស្រុកភូមិដែលធ្លាប់រស់នៅបែបនេះគ្មានអ្នកណាដឹងថាគាត់ធ្លាប់ធ្វើអ្វីពីមុនទេ ។ ដូច្នេះមានន័យថា គាត់អាចរួចពីសេចក្តីស្លាប់ ។ ចំពោះខ្ញុំយល់ថានេះជាជំហានមួយដ៏ប្រពៃណាស់ ។

ខ្ញុំនៅចាំបានច្បាស់ណាស់នៅពេលដែលជិះរថភ្លើងទៅកាន់ខេត្តបាត់ដំបង ខ្ញុំឃ្លានបាយស្ទើរដាច់ពោះវៀន ហើយម្តាយខ្ញុំខំរកនេះរកនោះឲ្យខ្ញុំហូប ។ គ្រួសារខ្ញុំក៏បានដល់ទិសដៅគឺស្រុកមោង ខេត្តបាត់ដំបង ។ នៅទីនោះខ្វះអាហារហូបចុកណាស់ ។ ឪពុកម្តាយខ្ញុំត្រូវយករបស់របរផ្សេងៗទៅដូរយកអង្ករពីអ្នកស្រុកអ្នកភូមិនៅទីនោះ ។

ជីវិតនៅក្នុងស្រុកនេះពិបាកវេទនាណាស់ រកពាក្យអ្វីមករៀបរាប់ជូនសមិនបាន ។ ខ្មែរក្រហមបានបង្ខំឲ្យយុវជននិងក្មេងជំទង់ៗឲ្យធ្វើការនៅវាលស្រែរាល់ថ្ងៃ ទោះជាមានភ្លៀងផ្គររឬថ្ងៃក្តៅយ៉ាងណាក៏ដោយ ។ ប្រជាជនអត់អ៊ីហូបដាច់ពោះស្លាប់រាល់ថ្ងៃ ។ ខ្លះទៀតក៏ត្រូវខ្មែរក្រហមសម្លាប់ចោល ។ សំណាងល្អខ្ញុំមិនត្រូវបានដាក់បញ្ចូលក្នុងកងពលកម្មទេ ដោយសារខ្ញុំនៅក្មេងពេក (ប្រហែលជាអាយុ៨ឆ្នាំ) ហើយមានជំងឺទៀតផង ។ ឪពុកខ្ញុំធ្វើការជាទម្ងន់ ហើយមិនសូវមានបាយហូបគ្រប់គ្រាន់ទៀតផង ។ ពេលគាត់បានហូបម្តងៗ គាត់ខំក្បិតក្បៀតលួចលាក់ចំណីទុកឲ្យកូនៗ ។ តាមខ្ញុំដឹងឪពុកខ្ញុំជាមនុស្សត្រឹមត្រូវណាស់ ។ ប៉ុន្តែនៅពេលដែលជួបប្រទះភាពអត់ឃ្លាន ភាពត្រឹមត្រូវនេះមិនអាចនៅជាមួយគាត់រហូតបានទេ ។ ភាពអត់ឃ្លានគឺចាំបាច់ណាស់សម្រាប់មនុស្សគ្រប់ៗរូប ។ បើគ្មានអ៊ីហូបទេនោះពិតជាត្រូវដាច់ពោះស្លាប់មិនខាន ។

មានព្រឹកមួយ ឪពុកខ្ញុំបានដាច់ចិត្តចាកចេញពីផ្ទះទៅដើរ

រកត្រីនៅតាមអូរ ។ យោធាខ្មែរក្រហមពីរនាក់ឃើញគាត់ហើយ ក៏ហៅឲ្យគាត់ឡើងគោក ។ យោធាខ្មែរក្រហមបានសួរចម្លើយគាត់ ហើយយកខ្សែចងគាត់ជាប់ ។ ឪពុកខ្ញុំត្រូវយោធាខ្មែរក្រហមចងទុកចោលនៅកណ្តាលវាលស្រែអស់រយៈពេលជាច្រើនម៉ោង ។ នៅពេលអ្នកស្រុកអ្នកភូមិដឹងរឿងដូច្នេះ ក៏ស្ទុះស្ទាមកប្រាប់ម្តាយខ្ញុំនៅឯផ្ទះ ។ ពេលនោះម្តាយខ្ញុំក៏សុំឲ្យអ្នកភូមិអ្នកស្រុកជួយយកឪពុកខ្ញុំមកផ្ទះវិញ ។ ហេតុការណ៍នេះនៅដក់ជាប់ក្នុងអារម្មណ៍ពុកខ្ញុំជារៀងរហូត ។ គាត់មានការឈឺចាប់និងប៉ះទង្គិចផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ ។ ចាប់ពីពេលនោះមកឪពុកខ្ញុំចាប់ផ្តើមយល់សប្តិអាក្រក់ ហើយឃើញសេចក្តីស្លាប់នៅនឹងមុខរបស់គាត់ ។ គាត់ធ្លាក់ខ្លួនឈឺកាន់តែធ្ងន់ទៅៗ ។ ដោយសារតែជីវភាពគ្រួសារមិនអំណោយផល ម្តាយខ្ញុំលះបង់ទ្រព្យសម្បត្តិផ្សេងៗដែលគាត់មានមកដោះដូរជាមួយអង្ករនិងថ្នាំសង្កូវ ជួយធ្វើយ៉ាងម៉េចឲ្យឪពុកខ្ញុំបានរស់រានមានជីវិត ។

មនុស្សប្រុសនៅក្នុងភូមិនេះភាគច្រើនត្រូវបានសម្លាប់ចោលទាំងអស់ ។ ឪពុកខ្ញុំដឹងខ្លួនថា ការស្លាប់គង់តែធ្លាក់មកលើរូបគាត់មិនខានគ្រាន់តែយូរនិងឆាប់តែប៉ុណ្ណោះ ។ មានយប់មួយនោះ នៅពេលម្តាយនិងបងប្អូនខ្ញុំដេកលក់អស់ ឪពុកខ្ញុំក៏ដាច់ខ្យល់ស្លាប់ទៅយ៉ាងស្ងប់ស្ងាត់ជាទីបំផុតដោយគ្មានអ្នកណាម្នាក់ដឹងឡើយ ។ ខ្ញុំនៅចាំបានច្បាស់ណាស់ថា សមាជិកក្នុងគ្រួសារខ្ញុំទាំងអស់ត្រូវកោរសក់ដើម្បីគោរពវិញ្ញាណក្ខន្ធឪពុកខ្ញុំ ។ សាកសពរបស់គាត់ត្រូវដាក់នៅផ្ទាល់ដីអស់រយៈពេលបីថ្ងៃទម្រាំតែម្តាយខ្ញុំរកអ្នកភូមិមកជួយលើកសពគាត់យកទៅកប់ ។ ម្នាក់ៗមានកម្លាំងទ្រុឌទ្រោមណាស់ ហើយខ្លាចមិនចង់មកជួយក្រុមគ្រួសារខ្ញុំទេ ។

ឪពុកខ្ញុំអាចចៀសផុតពីការកាប់សម្លាប់របស់ខ្មែរក្រហម ប៉ុន្តែមិនអាចគេចផុតពីការពិសោធន៍ដ៏អាក្រក់របស់ខ្មែរក្រហមបានទេ ។ មរណភាពរបស់ឪពុកខ្ញុំបានផ្លាស់ប្តូរជីវិតរបស់គ្រួសារខ្ញុំទាំងមូល ។ ម្តាយខ្ញុំមិនអាចធ្វើការអ្វីកើតអស់រយៈពេលពីរបីឆ្នាំ ហើយបងប្រុសបងស្រីនិងខ្ញុំត្រូវធ្វើអ្វីគ្រប់យ៉ាងដែលអាចធ្វើទៅបានដើម្បីរស់ ។ សព្វថ្ងៃនេះខ្ញុំរស់នៅសហរដ្ឋអាមេរិក ។ ទោះបីជាខ្ញុំរស់នៅបានសុខស្រួលក៏ពិតមែន ខ្ញុំនៅតែនឹកដល់ឪពុកខ្ញុំជានិច្ច ហើយប្រាថ្នាចង់រកផ្លូវឲ្យគាត់បានស្លាប់ប្រសើរជាងនេះ ។ មកដល់ឥឡូវនេះ ក្នុងចំណោមបងប្អូនខ្ញុំគ្មានអ្នកណាម្នាក់ដឹងពីកន្លែងកប់សាកសពឪពុកខ្ញុំទេ ។ ខ្ញុំដឹងក្នុងចិត្តថា ឪពុកខ្ញុំមិនមែនស្លាប់ដោយឥតន័យនោះឡើយ ។ មិនខុសពីប្រជាជនកម្ពុជាទេខ្ញុំចង់ឲ្យមានការនាំយកខ្មែរក្រហមមកកាន់តុលាការដើម្បីវិនិច្ឆ័យទោសតាមច្បាប់ ។ ខ្ញុំចង់បានយុត្តិធម៌ ហើយយុត្តិធម៌នេះពុំមែនជាការសងសឹកនោះទេ ។ម្យ៉ាងវិញទៀត ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជាសព្វថ្ងៃមានការតាំងចិត្តច្បាស់លាស់ក្នុងការនាំយកដំណើរការប្រជាធិបតេយ្យមកក្នុងប្រទេសមែននោះ ការបម្រើយុត្តិធម៌ពិតជាមានសារសំខាន់ណាស់សម្រាប់ប្រជាជនក្នុងការយល់ដឹងថា ការប្រព្រឹត្តអំពើឧក្រិដ្ឋពិតជាត្រូវទទួលរងទោសជាមិនខាន ។ នៅពេលមានយុត្តិធម៌ហើយ ទើបឪពុកខ្ញុំនិងប្រជាជនកម្ពុជារាប់លាននាក់ដែលបានបាត់បង់ជីវិតក្រោមរបបកម្ពុជាប្រជាធិបតេយ្យបានទៅកាន់សុគតិភពជារៀងរហូត ។




**កែវ សំអាន**

*កំណាព្យខ្មែរក្រហមៈ*

# ភោគផលសម្បត្តិធម្មជាតិខ្មែរ

ប្រទេសខ្មែរអើយចំដាល្អ
មានហ្វូងបក្សាហ្វូងបក្សី
មានសព្វមានគ្រប់វត្ថុធាតុ
ដែលជាតម្លៃដ៏ពិសេស
មានទាំងទន្លេបឹងសមុទ្រ
មច្ឆាច្រើនណាស់ពេញទីឋាន
ឯស្រូវសន្ទូងដុះលូតលាស់
មានទាំងភោគផលព្រៃព្រឹក្សា
បក្សាបក្សីក្នុងព្រៃព្រឹក្ស
ស្រែកញ្ចកញ្ជ្រៀវរំពងព្រៃ
មានស្រែចម្ការសុទ្ធដីជាតិ
ដាំដុះគ្រប់មុខទុកហូបចាយ
សំបូរសម្បត្តិសម្បើមណាស់
ស្លៀកពាក់ស៊ីចុកមិនថ្លូវ
ចេះរួមសាមគ្គីជាកម្លាំង
តែបើពិនិត្យមិនប្រាកដ
អ្នកមានភាគខ្វះហួសទៅហើយ
៩០ភាគរយអ្នកក្រពិត
ខ្វះខោខ្វះអាវអង្ករបាយ
នេះព្វពុំមែនព្រោះបាប

រុក្ខជាតិដុះគ្រប់ពណ៌ខៀវខ្ចី
ក្នុងទឹកក្នុងព្រៃមិនចេះខ្វះ ។
មាសពេជ្រនិងជាតិស្រូវក្រៃក្រាស់
ហូរហៃពេញពាសពីបុរាណ ។
សំបូរបំផុតហួសប្រមាណ
ច្រើនរាប់ពុំបានពេញគគ្គា ។
ស្លឹកខៀវខ្ចីស្រស់ល្អអស្ចារ្យ
មានផ្លែមានផ្កាគ្រប់រដូវ ។
ព្វស្រែកសន្ធឹកច្រើនក្រាស់ក្រៃ
ទាំងតូចទាំងធំសែនសប្បាយ ។
កសិករសង្ហាតខំគាស់កាយ
ស្លៀកពាក់គ្រប់កាយដោយសំបូរ ។
ចាយវាយប្រើប្រាស់យ៉ាងហៀរហូរ
ប្រទេសសំបូរមិនក្រខ្សត់ ។
មិនចេះអួតអាងហើយអត់ធ្មត់
កសិករក្រខ្សត់ខ្វះល្វាចព្រឹក ។
រីអ្នកសល់នៅច្រើនសន្ធឹក
ព្រោះកៀបគៀតឲ្យថោកទាប ។
ខ្វះលុយកាក់ចាយជាដរាប
មកពីសភាពការជិះជាន់ ។

**កត់ត្រាចងក្រងជាឯកសារ**
**កញ្ញា សើ សាយ្យាណា**

# ដំណឹងរកបងប្អូន


ថៃ ហាន

នាងខ្ញុំឈ្មោះ ថៃ សុខុម ជាកូនរបស់លោកតា ថៃ ចូ (បច្ចុប្បន្នស្លាប់) និងលោកយាយ យុត ហាក់ (បច្ចុប្បន្ននៅរស់អាយុ៧៦ឆ្នាំ) រស់នៅភូមិស្នាពីមុខ ឃុំព្រែកខ្ពប ស្រុកឯកភ្នំ (ពីមុនស្រុកសង្កែ) ខេត្តបាត់ដំបង ។

សូមសួររកឈ្មោះ ថៃ ហាន (បច្ចុប្បន្នអាយុ៥០ឆ្នាំ) ដោយឈ្មោះ ថៃ ហាន នេះបានចេញទៅរៀននៅភ្នំពេញជានិស្សិតថ្នាក់ត្រៀមនៃមហាវិទ្យាល័យនីតិសាស្ត្រ ហើយស្នាក់នៅផ្ទះបងស្រីជីដូនមួយឈ្មោះ ជុំ ជួប និងប្តីឈ្មោះ វ៉ែន វុន ជាកម្មកររោងចក្រតម្បាញ សេង ថៃ នៅគីឡូម៉ែត្រលេខ៦ ក្រុងភ្នំពេញ ។

លុះដល់ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ នាងខ្ញុំបានឮដំណឹងថាឈ្មោះ ថៃ ហាន បានធ្វើដំណើរមកផ្ទះដោយជិះកង់កាត់តាមខេត្តកំពង់ធំ ហើយមកដល់ស្រុកកំពង់ក្តីក្នុងខេត្តសៀមរាបក៏បាត់ដំណឹងទៅ ។

អាស្រ័យដូចបានជម្រាបខាងលើនេះ បើបងប្រុសបានឮហើយ សូមបងវិលត្រឡប់មកផ្ទះ ព្រោះម៉ែគាត់ចាស់ហើយចាំមើលតែផ្លូវបងទេ ។

ម្យ៉ាងទៀត បើបងប្អូនណាបានស្គាល់ឈ្មោះ ថៃ ហាន នេះ សូមប្រាប់ជាដំណឹងឲ្យនាងខ្ញុំតាមអាសយដ្ឋានផ្ទះលេខ១៣៥ ក្រុមទី៩ ភូមិស្នាពីមុខ ស្រុកឯកភ្នំ ខេត្តបាត់ដំបងដោយអនុគ្រោះ ។

សូមអរគុណ ។

ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុក និងឃុំ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងនាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@bigpond.com.kh. Thank you.

A magazine of the Documentation Center of Cambodia: Searching for the Truth! Number 19 July 2001.
Funded by the Royal Ministry of Foreign Affairs, Oslo, Norway, Section for the Human Rights and Humanitarian Assistance;
Canadian International Development Agency (CIDA) through the Civil Society Fund, the Swedish International Development Cooperation Agency(Sida);
the Royal Danish Government and the Royal Netherlands Government, *The Hague*.